# Khmer: Unlocked Literal Bible for Genesis

Formatted for Translators



generated on Wed Mar 12 15:32:40 2025

©2022 Wycliffe Associates
Released under a Creative Commons Attribution-ShareAlike 4.0 International License.

Bible Text: The English Unlocked Literal Bible (ULB)
©2017 Wycliffe Associates
Available at https://bibleineverylanguage.org/translations
The English Unlocked Literal Bible is based on the unfoldingWord® Literal Text, CC BY-SA 4.0. The original work of the unfoldingWord® Literal Text is available at https://unfoldingword.bible/ult/.
The ULB is licensed under the Creative Commons Attribution-ShareAlike 4.0 International License.

Notes: English ULB Translation Notes
©2017 Wycliffe Associates
Available at https://bibleineverylanguage.org/translations
The English ULB Translation Notes is based on the unfoldingWord translationNotes, under CC BY-SA 4.0. The original unfoldingWord work is available at https://unfoldingword.bible/utn.
The ULB Notes is licensed under the Creative Commons Attribution-ShareAlike 4.0 International License.

To view a copy of the CC BY-SA 4.0 license visit http://creativecommons.org/licenses/by-sa/4.0/

Below is a human-readable summary of (and not a substitute for) the license.
You are free to:

Share — copy and redistribute the material in any medium or format. Adapt — remix, transform, and build upon the material for any purpose, even commercially.

The licensor cannot revoke these freedoms as long as you follow the license terms.
Under the following conditions:

Attribution — You must attribute the work as follows: "Original work available at https://BibleInEveryLanguage.org." Attribution statements in derivative works should not in any way suggest that we endorse you or your use of this work. ShareAlike — If you remix, transform, or build upon the material, you must distribute your contributions under the same license as the original. No additional restrictions — You may not apply legal terms or technological measures that legally restrict others from doing anything the license permits.

Notices:
You do not have to comply with the license for elements of the material in the public domain or where your use is permitted by an applicable exception or limitation.
No warranties are given. The license may not give you all of the permissions necessary for your intended use. For example, other rights such as publicity, privacy, or moral rights may limit how you use the material.

# លោកុប្បត្តិ

ជំពូក ១

1កាលដំបូងឡើយ ព្រះជាម្ចាស់បានបង្កើតស្ថានសួគ៌ និងផែនដី។2ផែនដីគ្មានទម្រង់ និងទទេ។ សេចក្ដីងងឹតគ្របនៅលើផ្ទៃនៃជម្រៅទឹក។
ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់រេរានៅលើផ្ទៃនៃទឹកនោះ។
3ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរមានពន្លឺ» ហើយពន្លឺក៏មានឡើង។4ព្រះជាម្ចាស់ទតឃើញពន្លឺនោះថាល្អ។ ព្រះអង្គបានញែកពន្លឺចេញពីភាពងងឹត។
5ព្រះជាម្ចាស់បានហៅពន្លឺថាជា «ថ្ងៃ» ហើយព្រះអង្គហៅងងឹតថាជា «យប់»។ ក៏មានល្ងាច និងព្រឹក ជាថ្ងៃទីមួយ។
6ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរមានលំហមួយនៅចន្លោះទឹក ហើយឲ្យលំហនោះបានញែកទឹកចេញពីគ្នា»។7ព្រះជាម្ចាស់ធ្វើលំហ
ហើយបានញែកទឹកដែលនៅក្រោមលំហនោះពីគ្នា។ វាក៏កើតមានដូច្នោះ។8ព្រះជាម្ចាស់ហៅលំហនោះថាជា «មេឃ»។ ក៏មានល្ងាច និងព្រឹក ជាថ្ងៃទីពីរ។
9ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរឲ្យទឹកដែលនៅក្រោមមេឃបានប្រមូលគ្នាមកនៅតែមួយកន្លែង ហើយចូរឲ្យមានដីស្ងួតលេចឡើង»។ វាក៏កើតមានដូច្នោះ។
10ព្រះជាម្ចាស់ហៅដីស្ងួតថាជា «ផែនដី» ហើយហៅទឹកដែលប្រមូលជុំគ្នាថាជា «សមុទ្រ»។ ព្រះអង្គទតឃើញថាល្អ។
11ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរឲ្យផែនដីមានរុក្ខជាតិដុះដូចជា៖ រុក្ខជាតិដែលមានគ្រាប់ ហើយដើមឈើដែលមានផ្លែតាមពូជរបស់វា»។ វាក៏កើតមានដូច្នោះ។
12ផែនដីបានបង្កើតឲ្យមានរុក្ខជាតិ គឺរុក្ខជាតិដែលមានគ្រាប់តាមពូជរបស់វា ហើយដើមឈើបានបង្កើតផលដែលមានគ្រាប់ពូជនៅក្នុងវា តាមប្រភេទរបស់វា។
ព្រះជាម្ចាស់ទតឃើញថាល្អ។13ក៏មានល្ងាច និងមានព្រឹក ជាថ្ងៃទីបី។
14ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរឲ្យមានពន្លឺនៅលើមេឃ ដើម្បីញែកថ្ងៃចេញពីយប់ និងដើម្បីឲ្យវាធ្វើជាសញ្ញាសម្គាល់ សម្រាប់រដូវ សម្រាប់ថ្ងៃ និងឆ្នាំ។
15ចូរឲ្យមានពន្លឺនៅលើមេឃ ដើម្បីបំភ្លឺមកលើផែនដី»។ ក៏មានដូច្នោះ។
16ព្រះជាម្ចាស់បានបង្កើតពន្លឺដ៏ធំពីរ ពន្លឺដែលភ្លឺជាង ដើម្បីបំភ្លឺនៅពេលថ្ងៃ ហើយពន្លឺដែលមិនសូវភ្លឺ ដើម្បីបំភ្លឺនៅពេលយប់។17ព្រះអង្គក៏បង្កើតពួកផ្កាយផងដែរ។
ព្រះជាម្ចាស់បានដាក់ពួកគេនៅលើមេឃដើម្បីផ្ដល់ពន្លឺមកលើផែនដី18ដើម្បីបំភ្លឺនៅពេលថ្ងៃ និងបំភ្លឺនៅពេលយប់ ហើយដើម្បីញែកពន្លឺចេញពីងងឹត។
ព្រះជាម្ចាស់ទតឃើញថាល្អ។19ក៏មានល្ងាច និងព្រឹក ជាថ្ងៃទីបួន។
20ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរឲ្យទឹកបានពេញទៅដោយសត្វដែលមានជីវិតជាច្រើន ហើយចូរមានសត្វស្លាបហើរនៅលើផែនដីនៅក្នុងចន្លោះអាកាស»។
21ព្រះជាម្ចាស់បានបង្កើតសត្តនិករយ៉ាងសម្បើមនៅក្នុងសមុទ្រ និងសត្តនិករដែលមានជីវិតទាំងឡាយតាមប្រភេទរបស់វា ដែលមានជីវិតនៅក្នុងទឹកគ្រប់ទីកន្លែង
និងសត្វស្លាបហើរតាមប្រភេទរបស់វា។ ព្រះជាម្ចាស់ទតឃើញថាល្អ។
22ព្រះជាម្ចាស់បានឲ្យពរដល់ពួកវា ដោយមានបន្ទូលថា៖ «ចូរបង្កើតផល និងបានចម្រើនឡើង ហើយបានពេញទឹកនៅក្នុងសមុទ្រ។
ចូរឲ្យសត្វស្លាបបានចម្រើនឡើងពេញផែនដីផងដែរ»។23ក៏មានល្ងាច និងព្រឹកជាថ្ងៃទីប្រាំ។
24ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរឲ្យផែនដីបង្កើតឲ្យមានសត្តនិករនីមួយៗទៅតាមប្រភេទរបស់វា សត្វជើងបួន សត្វលូនវា និងសត្វព្រៃនៅផែនដី
ទៅតាមប្រភេទនីមួយៗរបស់វា»។ ក៏កើតមានដូច្នោះ។25ព្រះជាម្ចាស់បានបង្កើតសត្វព្រៃនៅផែនដី ទៅតាមប្រភេទរបស់វា សត្វជើងបួនទៅតាមប្រភេទរបស់វា
និងសត្វលូនវានៅលើដីគ្រប់យ៉ាងទៅតាមប្រភេទរបស់វា។ ព្រះអង្គទតឃើញថាល្អ។
26ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរយើងបង្កើតមនុស្សនៅក្នុងរូបភាពរបស់យើង មានលក្ខណដូចជាយើង។ ឲ្យពួកគេមានអំណាចនៅលើត្រីនៅក្នុងសមុទ្រ
នៅលើសត្វនៅលើអាកាស នៅលើសត្វជើងបួន និងមានអំណាចនៅលើផែនដីទាំងមូល ព្រមទាំងនៅលើសត្វលូនវាដែលលូនវានៅលើផែនដី»។
27ព្រះជាម្ចាស់បានបង្កើតមនុស្សនៅក្នុងរូបភាពរបស់ព្រះអង្គផ្ទាល់។ គឺព្រះអង្គបានបង្កើតគេនៅក្នុងរូបភាពរបស់ព្រះអង្គផ្ទាល់។ ព្រះអង្គបង្កើតពួកគេជាបុរស និងស្ត្រី។
28ព្រះជាម្ចាស់បានឲ្យពរដល់ពួកគេ ហើយមានបន្ទូលទៅពួកគេថា៖ «ចូរបង្កើតផលឲ្យបានច្រើន ហើយចម្រើនឡើង។ បំពេញផែនដី ហើយបង្ក្រាបវាផង។
ចូរមានអំណាចនៅលើត្រីនៅក្នុងសមុទ្រ នៅលើសត្វស្លាបនៅលើមេឃ ហើយនិងអ្វីៗដែលមានជីវិតនៅលើផែនដីផង»។29ព្រះជាម្ចាស់មានបន្ទូលថា៖ «មើល៍!
យើងបានប្រគល់រុក្ខជាតិដែលមានគ្រាប់ ដែលមាននៅលើផែនដីទាំងមូល និងគ្រប់ទាំងដើមឈើដែលមានគ្រាប់តាមពូជផង។ វានឹងបានជាអាហារដល់អ្នក។
30ចំពោះសត្វព្រៃនៅលើផែនដី គ្រប់ទាំងសត្វស្លាបនៅលើមេឃ និងអ្វីៗដែលលូនវានៅលើផែនដី ព្រមទាំងសត្តនិករទាំងអស់ដែលមានខ្យល់ដង្ហើមនៃជីវិត
យើងប្រគល់ស្មៅខៀវខ្ចីជាអាហារ»។31ព្រះជាម្ចាស់បានទតឃើញអ្វីៗដែលព្រះអង្គបានបង្កើត។ មើលចុះ វាល្អប្រពៃណាស់។ ក៏មានល្ងាច និងព្រឹក ជាថ្ងៃទីប្រាំមួយ។

ជំពូក ២

1បន្ទាប់ពីបង្កើតស្ថានសួគ៌ និងផែនដី និងអ្វីៗដែលមានជីវិតទាំងអស់រួចហើយ។2នៅថ្ងៃទីប្រាំពីរ ព្រះជាម្ចាស់បានសម្រាកពីព្រះរាជកិច្ចដែលព្រះអង្គបានធ្វើ
ដូច្នេះហើយបានជាព្រះអង្គសម្រាកនៅថ្ងៃទីប្រាំពីរពីព្រះរាជកិច្ចគ្រប់យ៉ាងរបស់ព្រះអង្គ។3ព្រះជាម្ចាស់បានឲ្យពរដល់ថ្ងៃទីប្រាំពីរ ហើយរាប់ជាវិសុទ្ធ
ព្រោះព្រះអង្គសម្រាកនៅថ្ងៃនោះពីព្រះរាជកិច្ចគ្រប់យ៉ាងរបស់ព្រះអង្គដែលព្រះអង្គបានធ្វើគឺនៅក្នុងការបង្កបង្កើតរបស់ព្រះអង្គ។
4ព្រឹត្តិការណ៍ទាំងនេះទាក់ទងនឹងស្ថានសួគ៌ និងផែនដី នៅពេលដែលបានបង្កើតឡើង នៅថ្ងៃនោះព្រះអម្ចាស់ដ៏ជាព្រះបានបង្កើតផែនដី និងស្ថានសួគ៌។
5គ្មានកំពូតព្រៃនៅតាមវាលនៅលើផែនដីនៅឡើយ ហើយក៏គ្មានរុក្ខជាតិដុះនៅតាមទីវាលនៅឡើយដែរ ដ្បិត
ព្រះអម្ចាស់ដ៏ជាព្រះមិនបានធ្វើឲ្យមានភ្លៀងកើតឡើងនៅលើផែនដីនៅឡើយ ហើយក៏គ្មានមនុស្សភ្ជួរស្រែចម្ការដែរ។6ប៉ុន្តែ មានអ័ព្ទចេញពីផែនដីមក
ហើយបានស្រោចស្រពផ្ទៃដីទាំងមូលផង។
7ព្រះអម្ចាស់ដ៏ជាព្រះបានបង្កើតមនុស្សពីធូលីដីពីដីមក ហើយបានផ្លុំខ្យល់នៃជីវិតចូលទៅក្នុងច្រមុះរបស់គាត់ ហើយបុរសនោះក៏មានជីវិតរបស់ឡើង។
8ព្រះអម្ចាស់ដ៏ជាព្រះបានធ្វើសួនមួយនៅភាគខាងកើត នៅក្នុងស្រុកអេដែន ហើយព្រះអង្គបានដាក់មនុស្សដែលព្រះអង្គបានបង្កើតនៅទីនោះ។
9ព្រះអម្ចាស់ដ៏ជាព្រះបានបង្កើតដើមឈើគ្រប់យ៉ាងដុះចេញពីដីមក ដែលគួរជាទីពេញចិត្ត ហើយល្អសម្រាប់ជាអាហារផង។
បូករួមទាំងដើមឈើនៃជីវិតដែលនៅចំកណ្ដាលនៃសួនច្បារ និងដើមដឹងល្អ និងដឹងអាក្រក់។10មានទន្លេមួយហូរចេញពីអេដែនមកស្រោចស្រពសួនច្បារនោះ។ នៅទីនោះ
មានទន្លេបួនបែកចេញពីគ្នា។
11ទន្លេទីមួយឈ្មោះពីសុន។ ជាទន្លេដែលហូរកាត់ស្រុកហាវីឡាទាំងមូល ជាស្រុកដែលមានមាស។12មាសនៅក្នុងស្រុកនោះគឺជាមាសល្អ។ ក៏មានជ័រប្ដេលាម
និងត្បូងអូនីក្សដែរ។
13ទន្លេទីពីរមានឈ្មោះថា គីហូន ជាទន្លេដែលកាត់ស្រុកគូសទាំងមូល។14ហើយទន្លេទីបីឈ្មោះថា ហ៊ីដេកែល ដែលហូរកាត់ភាគខាងកើតនៃស្រុកអាស៊ើរ។
ទន្លេទីបួនឈ្មោះថាអឺប្រាត។
15ព្រះអម្ចាស់ដ៏ជាព្រះបានយកមនុស្ស ហើយដាក់គាត់នៅក្នុងសួនរបស់អេដែន ដើម្បីធ្វើការ និងរក្សាការពារនៅទីនោះ។16ព្រះអម្ចាស់ដ៏ជាព្រះបានបង្គាប់ដល់មនុស្ស
ដោយមានបន្ទូលថា៖ «អ្នកអាចហូបពីផ្លែឈើនៅក្នុងសួននេះបានដោយសេរី។17ប៉ុន្តែ អ្នកមិនត្រូវហូបផ្លែឈើដឹងល្អ ដឹងអាក្រក់ឡើយ ដ្បិត
នៅថ្ងៃណាដែលអ្នកហូបពីផ្លែរបស់វា អ្នកប្រាកដជាស្លាប់មិនខាន»។


generated on Wed Mar 12 15:32:40 2025

18បន្ទាប់មក ព្រះអម្ចាស់ដ៏ជាព្រះមានបន្ទូលថា៖ «បុរសនៅម្នាក់ឯងមិនល្អទេ។ យើងនឹងបង្កើតអ្នកជំនួយម្នាក់ ដើម្បីជួយគាត់»។
19ព្រះអម្ចាស់ដ៏ជាព្រះបានបង្កើតសត្វពាហនៈនៅតាមវាលគ្រប់ប្រភេទ និងសត្វស្លាបហើរនៅលើអាកាសគ្រប់ប្រភេទដែរ។ បន្ទាប់មក
ព្រះអង្គបាននាំពួកគេចូលមកឯមនុស្ស ដើម្បីឲ្យពួកគេបានដាក់ឈ្មោះឲ្យ។ នៅពេលមនុស្សហៅសត្តនិករណាមួយថាជាអ្វី នោះគឺជាឈ្មោះរបស់សត្វនោះហើយ។
20បុរសបានដាក់ឈ្មោះសត្វស្រុកទាំងអស់ ហើយបានដាក់ឈ្មោះសត្វស្លាបដែលហើយលើមេឃ ព្រមទាំងសត្វព្រៃដែលនៅតាមវាលដែរ។ ប៉ុន្តែ
បុរសមិនទាន់មាននរណាអាចធ្វើជាជំនួយជួយដល់គាត់នៅឡើយទេ។
21ព្រះអម្ចាស់ដ៏ជាព្រះធ្វើឲ្យបុរសដេកលង់លក់ បុរសក៏ដេកលក់។ ព្រះអម្ចាស់ដ៏ជាព្រះបានយកឆ្អឹកជំនីរបស់គាត់
ហើយភ្ជិតសាច់គាត់ដែលព្រះអង្គបានយកឆ្អឹងជំនីចេញមកនោះវិញ។22ព្រះអម្ចាស់ដ៏ជាព្រះបានយកឆ្អឹងជំនីដែលបានយកពីបុរសមក ព្រះអង្គបានបង្កើតស្ត្រីម្នាក់
ហើយបាននាំនាងទៅឯបុរសនោះ។23បុរសនោះនិយាយថា៖ «នេះគឺជាឆ្អឹងដែលចេញពីឆ្អឹងរបស់ខ្ញុំ ហើយជាសាច់ដែលចេញពីសាច់របស់ខ្ញុំដែរ។ នាងនឹងត្រូវបានហៅថា
«ស្ត្រី» ដោយសារនាងបានយកចេញពីបុរសមក»។
24ហេតុដូច្នេះហើយ បានជាបុរសនឹងត្រូវចេញពីឪពុក និងម្ដាយរបស់គាត់ គាត់នឹងបានរួមមកតែមួយជាមួយភរិយារបស់គាត់
ហើយពួកគេនឹងបានត្រឡប់ទៅជាសាច់តែមួយ។25ពួកគេទាំងពីរនាក់អាក្រាត ទាំងបុរស និងភរិយារបស់គាត់ ប៉ុន្តែ មិនមានការអៀនខ្មាសទេ។

## ជំពូក ៣

1ពស់ជាសត្វដែលឆ្លាតជាងសត្វព្រៃនៅតាមវាល ដែលព្រះជាអម្ចាស់ដ៏ជាព្រះបានបង្កើត។ វាបាននិយាយទៅកាន់ស្ត្រីថា៖ «តើព្រះជាម្ចាស់ពិតជាបានមានបន្ទូលថា៖
«អ្នកមិនត្រូវហូបពីផ្លែណាមួយពីដើមឈើដែលនៅក្នុងសួននេះមែនទេ?»2ស្ត្រីនិយាយទៅកាន់សត្វពស់ថា៖ «យើងអាចហូបផ្លែឈើពីដើមឈើនៅក្នុងសួនបាន3ប៉ុន្តែ
ចំពោះផ្លែឈើដែលនៅចំកណ្ដាលសួន ព្រះជាម្ចាស់មានបន្ទូលថា៖ «អ្នកមិនត្រូវហូបវា ឬប៉ះវាឡើយ បើមិនដូច្នោះទេ អ្នកនឹងស្លាប់»។
4សត្វពស់បាននិយាយទៅកាន់ស្ត្រីថា៖ «អ្នកប្រាកដជាមិនស្លាប់ទេ។5ដ្បិត ព្រះជាម្ចាស់ជ្រាបថា នៅថ្ងៃដែលអ្នកហូបវា ភ្នែករបស់អ្នកនឹងភ្លឺឡើង
ហើយអ្នកនឹងបានដូចជាព្រះជាម្ចាស់ ដឹងល្អ និងដឹងអាក្រក់»។6នៅពេលស្ត្រីឃើញផ្លែឈើ ល្អសម្រាប់ជាអាហារ ហើយជាទីគាប់ចិត្តដល់ភ្នែក
ហើយដើមឈើនោះជាទីប្រាថ្នា ដើម្បីឲ្យបានប្រាជ្ញាផង នាងក៏បេះផ្លែឈើនោះខ្លះ ហើយក៏ហូបវា។ បន្ទាប់មក នាងបានប្រគល់ខ្លះឲ្យទៅស្វាមីដែលនៅជាមួយនាង
ហើយគាត់ក៏ហូបដែរ។
7ភ្នែករបស់ពួកគេទាំងពីរក៏ភ្លឺឡើង ហើយពួកគេបានដឹងថា ពួកគេនៅខ្លួនទទេ។ ពួកគេបានដេរស្លឹកឧទុម្ពរជាមួយគ្នា
ហើយធ្វើជាសម្លៀកបំពាក់សម្រាប់បាំងខ្លួនរបស់ពួកគេ។8ពួកគេបានឮសម្លេងព្រះអម្ចាស់ដ៏ជាព្រះយាងនៅក្នុងសួនដែលមានខ្យល់បក់រំភើយ ពេលនោះ បុរស
និងភរិយារបស់គាត់បានលាក់ខ្លួនពីព្រះវត្តមានរបស់ព្រះអម្ចាស់ដ៏ជាព្រះនៅក្រោមដើមឈើនៅក្នុងសួន។
9ព្រះអម្ចាស់ដ៏ជាព្រះបានហៅបុរសហើយមានបន្ទូលទៅគាត់ថា៖ «តើអ្នកនៅឯណា?»10បុរសបានទូលឆ្លើយថា៖ «ទូលបង្គំបានឮព្រះអង្គនៅក្នុងសួន ហើយទូលបង្គំក៏ខ្លាច
ដោយសារទូលបង្គំនៅខ្លួនទទេ។ ដូច្នេះ ទូលបង្គំក៏លាក់ខ្លួនទូលបង្គំទៅ»។11ព្រះជាម្ចាស់មានបន្ទូលថា៖ «តើអ្នកណាប្រាប់អ្នកថា អ្នកនៅខ្លួនទទេ?
តើអ្នកបានហូបផ្លែឈើដែលយើងបានបង្គាប់អ្នកមិនឲ្យហូបមែនទេ?»
12បុរសទូលថា៖ «ស្ត្រីដែលព្រះអង្គប្រទានឲ្យនៅជាមួយទូលបង្គំ នាងបានឲ្យផ្លែពីដើមឈើមកទូលបង្គំ ហើយទូលបង្គំក៏ហូបទៅ»។
13ព្រះអម្ចាស់ដ៏ជាព្រះមានបន្ទូលទៅស្ត្រីថា៖ «ហេតុអ្វីបានជានាងធ្វើបែបនេះ?» ស្ត្រីទូលថា៖ «សត្វពស់កុហកខ្ញុំម្ចាស់ ហើយខ្ញុំម្ចាស់ក៏ហូបទៅ»។
14ព្រះអម្ចាស់ដ៏ជាព្រះមានបន្ទូលទៅសត្វពស់ថា៖ «ដោយសារឯងបានធ្វើបែបនេះ បណ្ដាសានឹងធ្លាក់មកលើឯង នៅក្នុងចំណោមសត្វស្រុក
និងសត្វព្រៃដែលនៅតាមវាលទាំងអស់។ ឯងនឹងវាដោយពោះ ហើយឯងនឹងស៊ីដីអស់មួយជីវិតរបស់ឯង។15យើងនឹងធ្វើឲ្យឯងក្លាយជាសត្រូវនឹងស្ត្រី
និងពូជឯងជាមួយនឹងពូជនាងក៏ជាសត្រូវនឹងគ្នាដែរ។ គាត់នឹងជាន់ក្បាលឯង ហើយឯងនឹងខាំកែងជើងរបស់គាត់»។
16ព្រះអង្គមានបន្ទូលទៅស្ត្រីថា៖ «យើងនឹងធ្វើឲ្យនាងមានការឈឺចាប់យ៉ាងខ្លាំងនៅពេលមានកូន។ នាងនឹងប្រាថ្នាចង់បានស្វាមី ប៉ុន្តែ ស្វាមីនឹងគ្រប់គ្រងលើនាង»។
17ព្រះអង្គមានបន្ទូលទៅលោកអដាំថា៖ «ដោយសារអ្នកស្ដាប់តាមសម្លេងភរិយារបស់អ្នក ហើយបានហូបផ្លែឈើពីដើមឈើ ដែលយើងបានបង្គាប់ដល់អ្នកថា៖
«អ្នកមិនត្រូវហូបពីវាឡើយ»។ ដីត្រូវបណ្ដាសាដោយសារអ្នក អ្នកនឹងត្រូវធ្វើការដោយនឿយហត់ អ្នកនឹងហូបពីវាអស់មួយជីវិតរបស់អ្នក។18ដីនឹងដុះបន្លា
ហើយនិងអញ្ចាញឲ្យអ្នក ហើយអ្នកនឹងហូបពីតិណជាតិដែលដុះនៅតាមវាល។19អ្នកនឹងត្រូវធ្វើការដោយបែកញើស ដើម្បីឲ្យបានហូប
រហូតទាល់តែអ្នកបានត្រឡប់ទៅជាដីវិញ ដ្បិត អ្នកបានកើតពីដីមក។ ដ្បិត អ្នកកើតពីដី ហើយអ្នកនឹងត្រឡប់ទៅជាដីវិញ»។
20បុរសបានហៅភរិយារបស់គាត់ថា៖ «អេវ៉ា» ព្រោះនាងជាមាតានៃអ្វីៗដែលមានជីវិតទាំងអស់។21ព្រះអម្ចាស់ដ៏ជាព្រះបានធ្វើសម្លៀកបំពាក់ឲ្យលោកអាដាំ
និងភរិយារបស់គាត់ពីស្បែកសត្វ ហើយពាក់ដល់ពួកគេ។
22ព្រះអម្ចាស់ដ៏ជាព្រះមានបន្ទូលថា៖ «មើល មនុស្សមានលក្ខណដូចជាម្នាក់នៅក្នុងចំណោមយើង ស្គាល់ល្អ និងអាក្រក់។ ដូច្នេះ
នៅពេលនេះមនុស្សមិនត្រូវបានអនុញ្ញាតឲ្យប៉ះដោយដៃ បេះផ្លែពីដើមឈើនៃជីវិត មកហូប ហើយនឹងរស់នៅអស់កល្បនោះឡើយ»។23ដូច្នេះ
ព្រះអម្ចាស់ដ៏ជាព្រះបានបណ្ដេញមនុស្សចេញពីសួនអេដែន ឲ្យកាប់គាស់ដី ដើម្បីឲ្យបានផលពីវា។24ដូច្នេះ ព្រះជាម្ចាស់បានបណ្ដេញមនុស្សចេញពីសួន
ហើយព្រះអង្គបានដាក់ចេរូប៊ីមនៅភាគខាងកើតនៃសួនអេដែន ហើយកាន់ដាវជាអណ្ដាតភ្លើងដែលបែរទៅរកគ្រប់ទិស ដើម្បីការពារដើមឈើនៃជីវិត។

## ជំពូក ៤

1បុរសបានគេងជាមួយនាងអេវ៉ាភរិយារបស់គាត់។ នាងមានផ្ទៃពោះ ហើយបង្កើតបានកាអ៊ីន។ នាងនិយាយថា៖ «ខ្ញុំបានបង្កើតបុរសម្នាក់ដោយសារព្រះអម្ចាស់ជួយ។
2បន្ទាប់មក នាងបង្កើតបានប្អូនប្រុសរបស់គាត់ម្នាក់ទៀតឈ្មោះ អេបិល។ អេបិលបានត្រឡប់ជាអ្នកគង្វាលម្នាក់ ប៉ុន្តែ កាអ៊ីនជាអ្នកធ្វើស្រែចម្ការ។
3នៅពេលរដូវប្រមូលផលមកដល់ កាអ៊ីនបាននាំផលផ្លែខ្លះពីដីមកធ្វើជាតង្វាយដល់ព្រះអម្ចាស់។4ចំណែកអេបិលវិញ បាននាំកូនដំបូងពីហ្វូងសត្វ
ហើយជាសត្វដែលធាត់ៗ។ ព្រះអម្ចាស់ទទួលអេបិល និងតង្វាយរបស់គាត់5ប៉ុន្តែ កាអ៊ីន និងតង្វាយរបស់គាត់ ព្រះអង្គមិនទទួលទេ។ ដូច្នេះ កាអ៊ីនបានខឹងជាខ្លាំង
ហើយមុខឡើងក្រញ៉ូវ។
6ព្រះអម្ចាស់មានបន្ទូលទៅកាអ៊ីនថា៖ «ហេតុអ្វីបានជាអ្នកខឹង ហើយហេតុអ្វីបានជាអ្នកមុខក្រញ៉ូវដូច្នេះ?7ប៉ុន្តែ ប្រសិនបើ អ្នកមិនបានធ្វើអ្វីដែលត្រឹមត្រូវទេ
បានដេកនៅមាត់ទ្វារ ហើយវាប្រាថ្នាចង់គ្រប់គ្រងអ្នក ប៉ុន្តែ អ្នកត្រូវគ្រប់គ្រងវា»។
8កាអ៊ីនបាននិយាយទៅកាន់អេបិលជាប្អូនប្រុសរបស់គាត់។ នៅពេលពួកគេនៅឯវាល កាអ៊ីនបានក្រោកឡើងទាស់នឹងអេបិលប្អូនប្រុសរបស់គាត់ ហើយបានសម្លាប់គាត់។
9បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលទៅកាអ៊ីនថា៖ «តើអេបិលប្អូនប្រុសរបស់ឯងនៅឯណា?» គាត់ទូលឆ្លើយថា៖ «ទូលបង្គំមិនដឹងទេ។
តើទូលបង្គំជាអ្នកមើលថែប្អូនប្រុសរបស់ទូលបង្គំមែនទេ?»


generated on Wed Mar 12 15:32:40 2025

[10]ព្រះអម្ចាស់មានបន្ទូលថា៖ «តើអ្នកបានធ្វើអ្វីដូច្នេះ? ឈាមរបស់ប្អូនប្រុសរបស់អ្នកកំពុងតែស្រែករកយើងពីដីមក។[11]ឥឡូវនេះ បណ្ដាសានឹងធ្លាក់ទៅលើដី
ដែលនឹងបើកមាត់ក្នុងការទទួលឈាមរបស់ប្អូនរបស់អ្នកចេញពីដៃរបស់អ្នក។[12]ចាប់ពីពេលនេះតទៅ នៅពេលអ្នកភ្ជួររាស់ដី វាលែងបង្កើតផលច្រើនដូចមុនទៀតហើយ។
អ្នកនឹងត្រូវសាត់ព្រាត់ និងអណ្ដែតត្រសែតនៅក្នុងលោកនេះ»។
[13]កាអ៊ីនទូលទៅព្រះអម្ចាស់ថា៖ «ទោសរបស់ទូលបង្គំធ្ងន់ណាស់ ទូលបង្គំមិនអាចទ្រាំទ្របានទេ។[14]ពិតណាស់ ព្រះអង្គបានបណ្ដេញទូលបង្គំចេញពីទឹកដីនេះ
ហើយទូលបង្គំនឹងលាក់ខ្លួននៅចំពោះព្រះភក្ត្ររបស់ព្រះអង្គ។ ទូលបង្គំនឹងសាត់ព្រាត់ ហើយអណ្ដែតត្រសែតនៅក្នុងលោកនេះ
ហើយអស់អ្នកណាដែលបានរកទូលបង្គំឃើញ នឹងសម្លាប់ទូលបង្គំ»។[15]ព្រះអម្ចាស់មានបន្ទូលទៅគាត់ថា៖ «ប្រសិនបើ អ្នកណាសម្លាប់កាអ៊ីន
នឹងត្រូវសងសឹកមួយជាប្រាំពីរ»។ បន្ទាប់មក ព្រះអម្ចាស់បានដាក់សញ្ញានៅលើកាអ៊ីន ដើម្បីកុំឲ្យអ្នកណាម្នាក់អាចរកកាអ៊ីនឃើញ
ហើយអ្នកនឹងមិនអាចប្រហារគាត់បានឡើយ។
[16]ដូច្នេះ កាអ៊ីនបានចេញពីព្រះវត្តមានរបស់ព្រះអម្ចាស់ ហើយបានរស់នៅក្នុងទឹកដីណូឌ នៅខាងកើតស្រុកអេដែន។[17]កាអ៊ីនបានគេងជាមួយភរិយារបស់គាត់
ហើយនាងមានផ្ទៃពោះ។ នាងបង្កើតបានអេណុក។ គាត់បានសង់ទីក្រុង ហើយបានដាក់ឈ្មោះតាមឈ្មោះអេណុកកូនប្រុសរបស់គាត់។
[18]លោកអេណុកបង្កើតអ៊ីរ៉ាដ។ លោកអ៊ីរ៉ាដជាឪពុករបស់មហូយ៉ែល។ លោកមហូយ៉ែលជាឪពុករបស់មទូសែល។ លោកមទូសែលជាឪពុកឡាម៉េក។
[19]លោកឡាម៉េកមានភរិយាពីរនាក់ ម្នាក់ឈ្មោះ នាងអដា ហើយម្នាក់ទៀតឈ្មោះនាងស៊ីឡា។
[20]នាងអដាបង្កើតបានយ៉ាបាល។ គាត់ជាឪពុករបស់អស់អ្នកដែលរស់នៅក្នុងជំរំនៃអ្នកដែលមានហ្វូងសត្វ។[21]ប្អូនប្រុសរបស់គាត់ឈ្មោះលោកយូបាល។
គាត់ជាឪពុកនៃអស់អ្នកលេងពិណ និងចាប៉ី។[22]ចំណែកនាងស៊ីឡាបានបង្កើតទូបាកាអ៊ីន ជាឪពុកនៃពួកជាងលង្ហិន និងដែក។ ប្អូនស្រីរបស់លោកទូបាលកាអ៊ីនឈ្មោះនាង
ណាអាម៉ា។
[23]លោកឡាម៉េកនិយាយទៅកាន់ភរិយារបស់គាត់ថា៖ «អដា និងស៊ីឡាអើយ ចូរស្ដាប់សម្លេងរបស់ខ្ញុំ អ្នកគឺជាភរិយារបស់ឡាម៉េក ចូរស្ដាប់អ្វីដែលខ្ញុំនិយាយ។ ដ្បិត
ខ្ញុំបានសម្លាប់បុរសម្នាក់ ដោយសារធ្វើឲ្យខ្ញុំរងរបួស យុវជនម្នាក់បានវាយដំខ្ញុំ។[24]ប្រសិនបើ គេសងសឹងចំពោះលោកកាអ៊ីនមួយជាប្រាំពីរ ដូច្នេះ
ត្រូវសងសឹកដល់ឡាម៉េកមួយជាចិតសិបដងវិញ»។
[25]លោកអដាំបានគេងជាមួយភរិយារបស់គាត់ម្ដងទៀត ហើយនាងបង្កើតបានកូនប្រុសមួយទៀត។ នាងបានដាក់ឈ្មោះថា សេថ ហើយនាងនិយាយថា៖
«ព្រះជាម្ចាស់បានប្រទានកូនប្រុសមួយទៀតដល់ខ្ញុំ ជំនួសឲ្យអេបិល ដ្បិត កាអ៊ីនបានសម្លាប់គាត់។[26]លោកសេថមានកូនប្រុសម្នាក់ គាត់បានដាក់ឈ្មោះកូនប្រុសនោះថា
អេណុស។ នៅពេលនោះ មនុស្សបានចាប់ផ្ដើមអំពាវនាវរកព្រះនាមរបស់ព្រះអម្ចាស់។

## ជំពូក ៥

[1]នេះគឺជាបញ្ជីពូជពង្សរបស់លោកអដាំ។ នៅថ្ងៃដែលព្រះជាម្ចាស់បានបង្កើតមនុស្សលោក ព្រះអង្គបានបង្កើតពួកគេឲ្យដូចជារូបភាពរបស់ព្រះអង្គ។
[2]ព្រះអង្គបង្កើតពួកគេជាប្រុស ជាស្រី។ នៅពេលព្រះអង្គបង្កើតពួកគេ ព្រះអង្គបានប្រទានពរដល់ពួកគេ ហើយដាក់ឈ្មោះឲ្យពួកគេថាជាមនុស្សលោក។
[3]នៅពេលលោកអដាំរស់បាន ១៣០ឆ្នាំ គាត់មានកូនប្រុសមួយដែលមានលក្ខណដូចជាគាត់ ដូចជារូបរបស់គាត់ ហើយគាត់បានដាក់ឈ្មោះកូនប្រុសនោះថា សេថ។
[4]បន្ទាប់ពីមានសេថជាកូនប្រុសហើយ គាត់រស់បានប្រាំបីរយឆ្នាំទៀត។ គាត់មានកូនប្រុស និងកូនស្រីជាច្រើនទៀត។[5]លោកអដាំរបស់បាន៩៣០ឆ្នាំ
បន្ទាប់គាត់ក៏ស្លាប់ទៅ។
[6]នៅពេលលោកសេថរស់បាន១៥០ឆ្នាំ គាត់បង្កើតបានកូនមួយឈ្មោះ អេណុស។[7]បន្ទាប់ពីគាត់បង្កើតលោកអេណុស គាត់រស់បាន៨០៧ឆ្នាំ ហើយគាត់មានកូនប្រុស
និងស្រីជាច្រើនទៀត។[8]លោកសេថរស់បាន៩១២ឆ្នាំ ហើយបន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[9]នៅពេលលោក អេណុសរស់បានកៅសិបឆ្នាំ គាត់បង្កើតបានកូនប្រុសមួយឈ្មោះកៃណាន។[10]បន្ទាប់ពីគាត់បង្កើតបានកៃណាន លោកអេណុសរបស់បាន ៨១៥។
[11]គាត់មានកូនប្រុស និងកូនស្រីជាច្រើនទៀត។ លោកអេណុសរបស់បាន ៩០៥ឆ្នាំ ហើយបន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[12]នៅពេលលោកកៃណានរស់បានចិតសិបឆ្នាំ គាត់បង្កើតបានម៉ាលេលាល់។[13]បន្ទាប់ពីបង្កើតលោកម៉ាលេលាល់ លោកកៃណានរស់បាន ៨៤០ឆ្នាំទៀត។
គាត់បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀត។[14]លោកកៃណានរស់បាន៩១០ឆ្នាំ ហើយបន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[15]នៅពេលលោកម៉ាលេលាល់រស់បានហុកសិបប្រាំឆ្នាំ គាត់បង្កើតបានយ៉ារ៉េឌ។[16]បន្ទាប់មក គាត់បានបង្កើតលោកយ៉ារ៉េឌហើយ លោកម៉ាលេលាស់រស់បាន ៨៣០ទៀត។
គាត់បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀត។[17]លោកម៉ាលេលាល់រស់បាន៨៩៥ឆ្នាំ ហើយបន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[18]នៅពេលលោកយ៉ារ៉េឌរស់បាន១៦១ឆ្នាំ គាត់បង្កើតបានហេណុក។[19]បន្ទាប់ពីលោកយ៉ារ៉េឌបង្កើតលោកហេណុកមក លោកយ៉ារ៉េឌរស់បានប្រាំបីរយឆ្នាំទៀត។
គាត់បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀត។[20]លោកយ៉ារ៉េឌរស់បាន ៩៦២ឆ្នាំ ហើយបន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[21]នៅពេលលោកហេណុករស់បានហុកសិបប្រាំឆ្នាំ គាត់បង្កើតបានមធូសាឡា។[22]បន្ទាប់មកគាត់បង្កើតបានមធូសាឡា លោកអេណុកដើរនៅចំពោះព្រះជាម្ចាស់បីរយឆ្នាំ។
គាត់បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀត។[23]លោកហេណុករស់នៅបាន៣៦៥ឆ្នាំ។[24]លោកហេណុកដើរនៅចំពោះព្រះជាម្ចាស់ ហើយបន្ទាប់មក
គេលែងឃើញគាត់ទៀត ដ្បិត ព្រះជាម្ចាស់បានយកគាត់ទៅ។
[25]នៅពេលលោកមធូសាឡារស់បាន ១៨៧ឆ្នាំ គាត់បង្កើតបានឡាម៉េក។[26]បន្ទាប់ពីគាត់បង្កើតលោកឡាម៉េកមក លោកមធូសាឡារស់បាន ៧៨២ឆ្នាំទៀត។
គាត់បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀត។[27]លោកមធូសាឡារបស់បាន ៩៦៩ឆ្នាំ។ បន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[28]នៅពេលលោកឡាម៉េករស់បាន ១៨២ឆ្នាំ គាត់បង្កើតបានកូនប្រុសមួយ។[29]គាត់ដាក់ឈ្មោះកូនរបស់គាត់ថា ណូអេ ដោយនិយាយថា៖
«ម្នាក់នេះនឹងជួយឲ្យយើងបានសម្រាកពីកិច្ចការរបស់យើង ហើយពីការធ្វើការដ៏ឈឺចាប់ដែលចេញពីដៃរបស់យើង ដែលយើងត្រូវធ្វើ
ដោយសារតែព្រះអម្ចាស់បានដាក់បណ្ដាសាដល់ដី»។
[30]បន្ទាប់ពីគាត់បង្កើតបានលោកណូអេមក លោកឡាម៉េករស់បាន ៥៩៥ឆ្នាំទៀត។ គាត់បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀត។[31]លោកឡាម៉េករស់បាន ៧៧៧ឆ្នាំ។
បន្ទាប់មកគាត់ក៏ស្លាប់ទៅ។
[32]បន្ទាប់ពីលោកណូអេរស់បានប្រាំរយឆ្នាំ គាត់បង្កើតបាន សិម ហាំ និងយ៉ាផេត។

## ជំពូក ៦

[1]នៅពេលមនុស្សកើនជាច្រើនឡើងនៅលើផែនដី
ហើយពួកគេបង្កើតបានកូនស្រីៗជាច្រើន[2]កូនប្រុសៗរបស់ព្រះជាម្ចាស់ឃើញថាពួកកូនស្រីៗរបស់មនុស្សមានការទាក់ទាញ។
ពួកគេបានយកកូនស្រីៗទាំងនោះមកធ្វើជាភរិយារបស់ពួកគេ ពួកគេបានជ្រើសរើសក្នុងចំណោមពួកស្រីៗទាំងនោះ។[3]ព្រះអម្ចាស់មានបន្ទូលថា៖
«វិញ្ញាណរបស់យើងនឹងមិននៅជាមួយមនុស្សលោករហូតទេ ដ្បិត ពួកគេជាសាច់ឈាម។ ពួកគេនឹងរស់នៅបាន១២០ឆ្នាំប៉ុណ្ណោះ»។


generated on Wed Mar 12 15:32:40 2025

4នៅសម័យនោះ មនុស្សមានមាឌធំៗនៅលើផែនដី ហើយក្រោយមកក៏មានដែរ។ ការនេះកើតឡើងនៅពេលបុត្ររបស់ព្រះជាម្ចាស់រៀបការជាមួយកូនស្រីរបស់មនុស្ស
ហើយពួកគេមានកូនជាមួយគ្នា។ អ្នកទាំងនេះហើយគឺជាមនុស្សដ៏ខ្លាំងពូកែ និងមានឈ្មោះល្បីនៅសម័យបូរាណ។
5ព្រះជាម្ចាស់ឃើញថាអំពើអាក្រក់របស់មនុស្សកាន់តែច្រើនឡើងនៅលើផែនដី ហើយនៅក្នុងគំនិតនៃដួងចិត្តរបស់ពួកគេរវើរវាយតែការអាក្រក់ជាបន្តបន្ទាប់។
6ព្រះអម្ចាស់សោកស្តាយដែលព្រះអង្គបានបង្កើតមនុស្សនៅលើផែនដី ហើយវាបានធ្វើឲ្យទ្រង់ព្រួយនៅក្នុងព្រះទ័យរបស់ព្រះអង្គ។
7ដូច្នេះ ព្រះអម្ចាស់មានបន្ទូលថា៖ «យើងនឹងលុបបំបាត់មនុស្សលោកដែលយើងបានបង្កើតចេញពីផ្ទៃនៃផែនដី ទាំងមនុស្ស និងសត្វស្រុក សត្វលូនវា
ព្រមទាំងសត្វស្លាបដែលហើរនៅលើអាកាស ដើម្បីយើងសោកស្តាយដែលយើងបានបង្កើតពួកគេមក»។8ប៉ុន្តែ ព្រះអម្ចាស់គាប់ព្រះហឫទ័យនឹងលោកណូអេ។
9នេះគឺជាព្រឹត្តិការណ៍ទាក់ទងជាមួយលោកណូអេ។ លោកណូអេជាមនុស្សសុចរិត ហើយគ្មានកន្លែងបន្ទោសបាននៅក្នុងចំណោមមនុស្សនៅសម័យនោះ។
10លោកណូអេបានដើរជាមួយព្រះជាម្ចាស់។ លោកណូអេមានកូនប្រុសបីនាក់គឺឈ្មោះសិម ហាំ និងយ៉ាផេត។
11ផែនដីបានខូចអាក្រក់នៅចំពោះព្រះជាម្ចាស់ និងពេញដោយអំពើឃោរឃៅ។12ព្រះជាម្ចាស់បានឃើញផែនដី មើល៍ ផែនដីបានខូច ដ្បិត
គ្រប់ទាំងមនុស្សបានប្រព្រឹត្តអាក្រក់នៅគ្រប់ទាំងផ្លូវរបស់ពួកគេនៅលើផែនដី។
13ព្រះជាម្ចាស់មានបន្ទូលទៅលោកណូអេថា៖ «យើងឃើញថា ដល់ពេលដែលត្រូវបញ្ចប់ដល់មនុស្សលោកទាំងអស់ហើយ ដ្បិត
ផែនដីបានពេញទៅដោយអំពើឃោរឃៅដោយសារពួកគេ។ ពិតណាស់ យើងនឹងបំផ្លាញពួកគេជាមួយនិងផែនដីដែរ។14ចូរធ្វើទូកពីដើមស្រល់សម្រាប់អ្នក។
ចូរធ្វើបន្ទប់នៅក្នុងទូកនោះ ហើយបិទជ័រនៅខាងក្នុង និងខាងក្រៅផង។15នេះជារបៀបដែលអ្នកត្រូវធ្វើវា៖ ទូកនោះត្រូវមានប្រវែងបីរយហត្ថ ទទឹងហាសិបហត្ថ
និងកំពស់សាមសិបហត្ថ។
16ចូរធ្វើដំបូលគ្របពីលើទូកមានកំពស់មួយហត្ថ។ ចូរដាក់ទ្វារនៅចំហៀងទូក ហើយដាក់នៅជាន់ក្រោម ជាន់ទីពីរ និងជាន់ទីបី។17ចូរស្តាប់
យើងនឹងនាំឲ្យមានទឹកជំនន់នៅលើផែនដី ដើម្បីបំផ្លាញមនុស្សលោកទាំងអស់ដែលមានជីវិតរស់នៅក្រោមស្ថានសួគ៌។ អ្វីៗទាំងអស់ដែលនៅលើផែនដីនឹងស្លាប់។
18ប៉ុន្តែ យើងនឹងបង្កើតសម្ពន្ធមេត្រីរបស់យើងជាមួយអ្នក។ អ្នកត្រូវចូលទៅក្នុងទូក គឺអ្នក និងកូនប្រុសៗ ព្រមទាំងភរិយា ហើយនិងកូនប្រសារស្រីៗរបស់អ្នក។
19អ្នកក៏ត្រូវនាំសត្វលោកទាំងអស់ មួយគូពីចំណោមសត្វទាំងអស់ចូលទៅក្នុងទូក ឲ្យពួកវារស់នៅជាមួយអ្នក ទាំងញីទាំងឈ្មោល។
20អ្នកត្រូវនាំសត្វស្លាបគ្រប់ប្រភេទ ហើយសត្វធំៗតាមពូជរបស់វា ពីសត្វលូនវាតាមពូជរបស់វា ចូរយកមួយគូៗទៅជាមួយអ្នក ឲ្យពួកវារស់នៅជាមួយអ្នក។
21ចូរប្រមូលអាហារសម្រាប់អ្នក និងពួកវាដែរ»។22ដូច្នេះ លោកណូអេក៏ធ្វើការនេះ។ ទៅតាមអ្វីៗដែលព្រះជាម្ចាស់បានបង្គាប់ដល់គាត់ ដូច្នេះ គាត់ក៏ធ្វើតាម។

ជំពូក ៧

1ព្រះអម្ចាស់មានបន្ទូលទៅលោកណូអេថា៖ «ចូរចូលទៅក្នុងទូក អ្នក និងគ្រួសាររបស់អ្នក ដ្បិត យើងបានឃើញថា អ្នកជាមនុស្សសុចរិត
នៅចំពោះយើងនៅក្នុងជំនាន់នេះ។2ចូរនាំសត្វដែលស្អាតៗទៅជាមួយអ្នក ញីប្រាំពីរ និងឈ្មោលប្រាំពីរផង។3ចំណែកសត្វដែលមិនស្អាត ចូរនាំតែមួយគូបានហើយ ឈ្មោល
និងមេញីរបស់វា។ ព្រមទាំងសត្វស្លាបនៅលើមេឃ ចូរនាំឈ្មោលប្រាំពីរ និងញីប្រាំពីរ ដើម្បីបន្តពូជនៅលើផ្ទៃនៃផែនដីទាំងមូលផង។
4ដ្បិត នៅថ្ងៃទីប្រាំពីរ យើងនឹងធ្វើឲ្យមានភ្លៀងធ្លាក់មកលើផែនដីក្នុងរយៈពេលសែសិបថ្ងៃសែសិបយប់។
យើងនឹងបំផ្លាញអ្វីៗដែលមានជីវិតនៅលើផ្ទៃផែនដីដែលយើងបានបង្កើតទាំងអស់»។5លោកណូអេបានធ្វើតាមព្រះអម្ចាស់បានបង្គាប់ដល់គាត់ទាំងអស់។
6ពេលទឹកជំនន់នៅលើផែនដី លោកណូអេមានអាយុប្រាំមួយរយឆ្នាំ។7លោកណូអេ កូនប្រុសៗ និងភរិយា ព្រមទាំងកូនប្រសាស្រីរបស់គាត់បានចូលទៅក្នុងទូកជាមួយគ្នា
ដោយសារទឹកជំនន់។
8សត្វស្អាត និងសត្វដែលមិនស្អាត សត្វស្លាប និងសត្វលូនវានៅលើផែនដីទាំងអស់9មួយគូៗ ទាំងឈ្មោល ទាំងញី បានមករកលោកណូអេ ហើយបានចូលទៅក្នុងទូក
ដូចដែលព្រះជាម្ចាស់បានបង្គាប់ដល់លោកណូអេ។10នៅពេលភ្លៀងបានប្រាំពីរថ្ងៃ ទឹកបានជន់លិចផែនដី។
11នៅពេលលោកណូអេមានអាយុប្រាំមួយរយឆ្នាំ នៅខែទីពីរ គឺនៅថ្ងៃទីដប់ប្រាំ ខែនោះ ថ្ងៃដដែលនោះ ប្រភពទឹកនៅក្នុងទីជម្រៅទាំងអស់បានបើកឡើង
ហើយបង្អួចស្ថានសួគ៌បានបើកដែរ។12ភ្លៀងបានចាប់ផ្តើម ហើយធ្លាក់ចុះមកផែនដីសែសិបថ្ងៃសែសិបយប់។
13នៅថ្ងៃដដែលនោះឯង លោកណូអេ និងកូនប្រុសៗរបស់លោក គឺសិម ហាំ និងយ៉ាផេត ព្រមទាំងភរិយារបស់លោកណូអេ និងភរិយាទាំងបីរបស់កូនប្រុសៗរបស់លោក
បានចូលទៅក្នុងទូកជាមួយពួកគេដែរ។14ពួកគេបានចូលទៅជាមួយសត្វ តាមពូជរបស់វា ហើយសត្វស្រុកក៏តាមពូជរបស់វារៀងៗខ្លួនដែរ
ព្រមទាំងសត្វលូនវានៅលើផែនដីតាមពូជរបស់វា និងសត្វបក្សាបក្សីតាមពូជរបស់វា ព្រមទាំងសត្វស្លាបតាមពូជរបស់វាដែរ។
15សត្វដែលមានជីវិតមួយគូៗបានចូលមកឯលោកណូអេ ហើយបានចូលទៅក្នុងទូក។16សត្វទាំងអស់ដែលចូលទៅក្នុងទូកនោះមានឈ្មោល មានញី
ពួកគេបានចូលទៅក្នុងទូកដូចដែលព្រះជាម្ចាស់បានបង្គាប់ដល់លោក។ បន្ទាប់ពីពួកគេចូលអស់ហើយ ព្រះអម្ចាស់បានបិទទ្វារ។
17បន្ទាប់ពីទឹកជំនន់មកនៅលើផែនដីសែសិបថ្ងៃរួចហើយ ទឹកក៏កាន់តែចម្រើនឡើង ហើយបានលើកទូក ហើយបានអណ្តែតផុតពីដី។18ទឹកមានពេញពាសផែនដីទាំងមូល
ហើយទូកបានអណ្តែតនៅលើផ្ទៃនៃទឹកនោះ។
19ទឹកកាន់ខ្ពស់ឡើងកាន់តែខ្លាំងនៅលើផែនដី ដូច្នេះ សូម្បីតែនៅលើភ្នំខ្ពស់ៗទាំងឡាយដែលនៅក្រោមមេឃក៏លិចអស់ដែរ។
20ទឹកបានឡើងខ្ពស់ផុតពីកំពូលភ្នំដប់ប្រាំហត្ថថែមទៀត។
21គ្រប់ទាំងសត្វមានជីវិតទាំងឡាយដែលរស់នៅលើផែនដីបានស្លាប់ ទាំងសត្វបក្សាបក្សី សត្វស្រុក សត្វព្រៃ
និងសត្តនិករដែលរស់នៅលើផែនដីយ៉ាងសន្ធឹកសន្ធាប់ទាំងអស់បានស្លាប់ និងមនុស្សលោកទាំងអស់ផងដែរ។22គ្រប់ទាំងសត្វដែលមានជីវិតទាំងអស់នៅលើដី
ដែលមានជីវិតរបស់នៅ ហើយដកដង្ហើមតាមច្រមុះរបស់ពួកគេបានស្លាប់ទាំងអស់។
23ដូច្នេះ អ្វីៗដែលមានជីវិតទាំងអស់ ដែលរស់នៅលើផ្ទៃនៃផែនដីត្រូវបានលុបបំបាត់ចោលទាំងអស់ តាំងពីតូចរហូតដល់ធំ ចាប់តាំងពីសត្វលូនវា
និងសត្វដែលហើរលើអាកាស។24ពួកគេត្រូវបានបំផ្លាញទាំងអស់ពីផែនដី។ មានតែលោកណូអេ និងអស់អ្នកដែលនៅក្នុងទូកជាមួយគាត់ទេ។
ទឹកមិនបានជ្រាបចូលទៅក្នុងផែនដីវិញ អស់រយៈពេលមួយរយហាសិបថ្ងៃ។

ជំពូក ៨

1ព្រះជាម្ចាស់បាននឹកចាំពីលោកណូអេ និងសត្វព្រៃទាំងអស់ ព្រមទាំងសត្វស្រុកដែលនៅក្នុងទូកជាមួយគាត់។ ព្រះជាម្ចាស់បានធ្វើឲ្យមានខ្យល់បក់នៅលើផែនដី
ហើយឲ្យទឹកចាប់ផ្តើមស្រក់ចុះ។2ប្រភពទឹកដែលផុតចេញពីជម្រៅ ហើយទ្វារនៃស្ថានសួគ៌បានបិទ ហើយភ្លៀងក៏រាំង។3ទឹកជំនន់បានស្រក់ចុះពីផែនដីយ៉ាងយឺតៗ
ហើយបន្ទាប់ពីផុតមួយរយហាសិបថ្ងៃមកទឹកបានស្រក់ចុះអស់។
4ទូកបានជាប់កឿងនៅក្នុងខែទីប្រាំពីរ នៅថ្ងៃទីដប់ប្រាំពីរនៃខែនោះ នៅលើភ្នំអារ៉ារ៉ាត។5ទឹកបានបន្តស្រក់ចុះរហូតដល់ខែទីដប់។ នៅថ្ងៃទីមួយនៃខែនោះ
កំពូលភ្នំផ្សេងៗបានលេចឡើង។
6សែសិបថ្ងៃក្រោយមក លោកណូអេបានបើកបង្អួចទូកដែលលោកបានធ្វើនោះ។7លោកបានប្រលែងសត្វក្អែកមួយ វាក៏ហើរទៅហើយមក រហូតទាល់តែទឹកស្ងួតពីផែនដី។


generated on Wed Mar 12 15:32:40 2025

[8]បន្ទាប់មក លោកបានប្រលែងសត្វព្រាបមួយទៀត ដើម្បីឲ្យដឹងថា តើទឹកបានស្ងួតពីផ្ទៃនៃផែនដីហើយឬនៅ[9]ប៉ុន្តែ សត្វព្រាបរកកន្លែងទំមិនបាន
វាបានត្រឡប់មករកលោកដែលនៅក្នុងទូកវិញ ដ្បិត ទឹកនៅគ្របដណ្តប់ផែនដីទាំងមូលនៅឡើយ។ គាត់បានឈោងដៃចាប់វា
ហើយយកវាត្រឡប់ចូលមកនៅក្នុងទូកជាមួយគាត់វិញ។
[10]គាត់បានរង់ចាំប្រាំពីរថ្ងៃក្រោយទៀត ហើយគាត់បានប្រលែងព្រាបនោះពីទូកម្តងទៀត។[11]សត្វព្រាបបានត្រឡប់មកឯគាត់វិញនៅពេលល្ងាច។ មើល៍!
នៅមាត់របស់វាមានត្រួយអូលីវមកជាមួយផង។ ដូច្នេះ លោកណូអេបានដឹងថា ទឹកបានស្ងួតពីផែនដីអស់ហើយ។[12]គាត់បានរង់ចាំប្រាំពីរថ្ងៃទៀត
ហើយគាត់បានប្រលែងសត្វព្រាបម្តងទៀត។ វាមិនបានត្រឡប់មករកគាត់វិញទេ។
[13]នៅថ្ងៃទីមួយ ខែទីមួយ និងឆ្នាំទីមួយ នៅពេលលោកណូអេមានអាយុប្រាំមួយរយមួយឆ្នាំ ទឹកបានរីងស្ងួតពីផែនដីទាំងអស់។ លោកណូអេបានរើដំបូលទូកចេញ
សម្លឹងមើលទៅក្រៅ ហើយលោកបានឃើញថា ផ្ទៃនៃផែនដីបានស្ងួត។[14]នៅខែទីពីរ ថ្ងៃទីម្ភៃប្រាំពីរនៃខែនោះ ផែនដីបានស្ងួតអស់។
[15]ព្រះជាម្ចាស់មានបន្ទូលទៅលោកណូអេថា៖[16]«ចូរចេញពីទូក អ្នក ភរិយារបស់អ្នក និងកូនប្រុសៗរបស់អ្នក ព្រមទាំងភរិយារបស់កូនប្រុសៗអ្នកផង។
[17]ចូរយកសត្វមានជីវិតទាំងអស់ដែលនៅជាមួយអ្នកចេញពីទូក គឺសត្វបក្សាបក្សី ហ្វូងសត្វ ហើយសត្វលូនវាទាំងអស់ដែលលូនវានៅលើផែនដី
ដើម្បីឲ្យពួកគេបានបង្កើតពូជនៅពាសពេញផែនដីវិញ ចូរបង្កើតផល និងបានចម្រើនឡើងនៅពេញផែនដីចុះ»។
[18]ដូច្នេះ លោកណូអេ កូនប្រុសៗ និងភរិយារបស់គាត់ ព្រមទាំងភរិយាកូនប្រុសរបស់គាត់បានចេញពីទូកជាមួយគាត់។[19]សត្វដែលមានជីវិត សត្វលូនវា
និងសត្វបក្សាបក្សីទាំងអស់ ដែលមានចលនានៅលើផែនដី តាមពូជ តាមគ្រួសាររៀងៗខ្លួន បានចាកចេញពីទូក។
[20]លោកណូអេបានសង់អាសនៈថ្វាយព្រះអម្ចាស់។ គាត់បានយកសត្វខ្លះពីសត្វស្អាត និងសត្វបក្សាបក្សីខ្លះពីសត្វបក្សាបក្សីដែលស្អាត
ហើយបានថ្វាយជាតង្វាយដុតនៅលើអាសនៈ។[21]ព្រះអម្ចាស់បានធំក្លិនឆ្ងុយគាប់ព្រះទ័យដល់ព្រះអង្គ ហើយព្រះអង្គមានបន្ទូលក្នុងព្រះទ័យរបស់ព្រះអង្គថា
ទោះបីជានៅក្នុងដួងចិត្តរបស់ពួកគេអាក្រក់តាំងពីតូចមកក្តី។ យើងនឹងមិនបំផ្លាញអ្វីៗដែលមានជីវិតទៀត ដូចយើងបានធ្វើនេះទេ។[22]ដរាបណាផែនដីនៅមាន
នឹងមានពេលសាបព្រោះ និងច្រូតកាត់ នឹងមានក្តៅ និងត្រជាក់ នឹងមានរដូវក្តៅ និងរដូវរងា និងមានថ្ងៃ មានយប់ មិនអាក់ខានឡើយ។

ជំពូក ៩

[1]បន្ទាប់មក ព្រះជាម្ចាស់បានប្រទានពរដល់លោកណូអេ និងកូនប្រុសៗរបស់គាត់ ដោយមានបន្ទូលទៅពួកគេថា៖ «ចូរបង្កើតផល ឲ្យបានចម្រើនឡើងបានពេញផែនដី។
[2]សត្វដែលរស់នៅលើផែនដី ទាំងសត្វបក្សាបក្សីនៅលើមេឃ និងអ្វីៗដែលនៅក្រោមដី ហើយនិងត្រីសមុទ្រទាំងអស់នឹងភ័យខ្លាចអ្នករាល់គ្នា។
យើងនឹងប្រគល់ពួកគេនៅក្នុងកណ្តាប់ដៃអ្នករាល់គ្នា។
[3]អ្វីៗទាំងអស់ដែលធ្វើចលនា ដែលមានជីវិតនឹងត្រូវធ្វើជាអាហារដល់អ្នករាល់គ្នា។ យើងឲ្យអ្វីៗទាំងអស់នេះដល់អ្នករាល់គ្នា
ដូចយើងបានឲ្យតិណជាតិទាំងឡាយដល់អ្នករាល់គ្នាដែរ។[4]ប៉ុន្តែ អ្នកមិនត្រូវហូបសាច់ដែលមានជីវិតនៅក្នុងវាទេ នោះឈាមដែលនៅក្នុងវានោះឯង។
[5]ដោយព្រោះឈាមរបស់អ្នក មានជីវិតនៅក្នុងឈាមរបស់អ្នកនោះ យើងនឹងទាមទារឲ្យបង់ថ្លៃវិញ។ ពីគ្រប់ទាំងសត្វណាដែលបង្ហូរឈាមអ្នក យើងនឹងទាមទារមកវិញ។
ហើយបើដៃរបស់មនុស្សណាម្នាក់ គឺដៃដែលរបស់អ្នកដែលបានសម្លាប់បងប្អូនរបស់គេ យើងនឹងទាមទារស្របទៅតាមជីវិតរបស់អ្នកនោះវិញ។
[6]អស់អ្នកដែលណាដែលបង្ហូរឈាមមនុស្ស អ្នកនោះនឹងត្រូវស្លាប់ដែរ ដ្បិត គេគឺជារូបភាពរបស់ព្រះជាម្ចាស់ គឺព្រះអង្គបានបង្កើតគេមក។[7]អ្នករាល់គ្នាក៏ដូចគ្នាដែរ
ចូរបង្កើតផល ហើយបានចម្រើនឡើង នៅពាសពេញផែនដី និងបានចម្រុងចម្រើនឡើង។
[8]បន្ទាប់មក ព្រះជាម្ចាស់មានបន្ទូលទៅកាន់លោកណូអេ និងកូនប្រុសៗដែលនៅជាមួយគាត់ថា ដោយបន្ទូលថា៖[9]«រីឯយើងវិញ ចូរស្តាប់!
យើងនឹងតាំងសម្ពន្ធមេត្រីរបស់យើងជាមួយអ្នករាល់គ្នា
និងពូជពង្សរបស់អ្នកដែលនៅបន្ទាប់ពីអ្នករាល់គ្នា[10]ព្រមទាំងតាំងជាមួយនឹងសត្តនិករមានជីវិតទាំងឡាយដែលនៅជាមួយអ្នក ពីអ្វីៗទាំងអស់ដែលចេញពីទូកមក
និងជាមួយនឹងសត្តនិករទាំងអស់ដែលនៅផែនដី។
[11]យើងតាំងសម្ពន្ធមេត្រីជាមួយនឹងអ្នករាល់គ្នាថា យើងនឹងមិនបំផ្លាញជីវិតទាំងអស់ដោយសារទឹកជំនន់ទៀតទេ។ នឹងមិនមានទឹកជំនន់បំផ្លាញផែនដីទៀតទេ»។
[12]ព្រះជាម្ចាស់មានបន្ទូលថា៖ «នេះគឺជាសញ្ញាសម្គាល់នៃសម្ពន្ធមេត្រីដែលយើងបានតាំងរវាងយើង និងអ្នករាល់គ្នា
ព្រមទាំងសត្តនិករដែលមានជីវិតទាំងឡាយដែលនៅជាមួយអ្នករាល់គ្នា នៅគ្រប់ជំនាន់តរៀងទៅ។[13]យើងបានដាក់ឥន្ទធនូនៅលើពពក
ហើយវាជាទីសម្គាល់នៃសម្ពន្ធមេត្រីរវាងយើង និងផែនដី។
[14]វានឹងកើតឡើងនៅពេលយើងដាក់ពពកនៅលើផែនដី ហើយនឹងឃើញឥន្ទធនូនៅលើពពកនោះ[15]ពេលនោះ យើងនឹងរំលឹកខ្លួនយើងពីសម្ពន្ធមេត្រីរបស់យើង
ដែលបានតាំងរវាងយើង និងអ្នករាល់គ្នា ហើយនិងសត្តនិករដែលមានជីវិតទាំងឡាយ។ ទឹកនឹងមិនត្រឡប់ទៅជាទឹកជំនន់បំផ្លាញជីវិតរបស់មនុស្សទៀតទេ។
[16]ឥន្ទធនូនឹងនៅលើពពក ហើយយើងនឹងឃើញវា ដើម្បីរំលឹកពីសម្ពន្ធមេត្រីដ៏នូវអស់កល្ប រវាងព្រះជាម្ចាស់ និងសត្តនិករដែលមានជីវិតទាំងឡាយ ដែលនៅលើផែនដី។
[17]នៅពេលព្រះជាម្ចាស់មានបន្ទូលទៅកាន់លោកណូអេថា៖ «នេះគឺជាទីសម្គាល់នៃសម្ពន្ធមេត្រីដែលយើងបានតាំងរវាងយើង
និងគ្រប់ទាំងជីវិតដែលនៅរស់នៅលើផែនដីទាំងមូល»។
[18]កូនប្រុសៗរបស់លោកណូអេដែលបានចេញពីទូកមកមានឈ្មោះដូចជា សិម ហាំ និងយ៉ាផេត។ លោកហាំជាឪពុករបស់កាណាន។
[19]នេះគឺជាកូនប្រុសៗទាំងបីរបស់លោកណូអេ ហើយកូនចៅទាំងនេះហើយ បានបានចេញទៅពាសពេញពិភពលោកទាំងមូល។
[20]លោកណូអេបានចាប់ផ្តើមធ្វើស្រែចម្ការ ហើយគាត់បានដាំដើមទំពាំងបាយជូរ។[21]គាត់បានផឹកស្រាខ្លះ ហើយបានស្រវឹង។ គាត់ដេកអាក្រាតនៅក្នុងរោងរបស់គាត់។
[22]លោកហាំជាឪពុករបស់លោកកាណាន បានឃើញភាពអាក្រាតរបស់ឪពុកគាត់ ហើយបានប្រាប់ដល់បងទាំងពីរនាក់ដែលនៅខាងក្រៅ។[23]ដូច្នេះ លោកសិម និង
លោកយ៉ាផេតបានយកសំពត់មួយ ហើយដាក់វាគ្របនៅលើស្មារបស់ពួកគេ ហើយដើរថយក្រោយ ហើយបានគ្របបាំងភាពអាម៉ាសឪពុករបស់ពួកគេ។
ពួកគេបានបានបែរភ្នែកទៅកន្លែងផ្សេង ដើម្បីកុំឲ្យពួកគេបានឃើញភាពអាក្រាតរបស់ឪពុកពួកគេឡើយ។
[24]នៅពេលលោកណូអេភ្ញាក់ឡើងពីភាពស្រវឹងរបស់គាត់ គាត់បានដឹងពីអ្វីដែលកូនប្រុសពៅរបស់គាត់បានធ្វើចំពោះគាត់។ ដូច្នេះ[25]គាត់បាននិយាយថា៖
«កាណានត្រូវបណ្តាសាហើយ។ សូមឲ្យវាបានក្លាយជាអ្នកបម្រើ អ្នកបម្រើរបស់បងៗរបស់វា»។
[26]គាត់និយាយថា៖ «ព្រះអម្ចាស់អើយ និងជាព្រះជាម្ចាស់របស់លោកសិមអើយ សូមឲ្យព្រះអង្គបានប្រកបដោយព្រះពរ
ហើយសូមឲ្យកាណានបានក្លាយជាអ្នកបម្រើរបស់គាត់។[27]សូមព្រះជាម្ចាស់ពង្រីកទឹកដីរបស់លោកយ៉ាផេត ហើយឲ្យគាត់បានធ្វើផ្ទះនៅក្នុងរោងរបស់លោកសិម។
សូមឲ្យកាណានបានក្លាយជាអ្នកបម្រើវិញ»។
[28]បន្ទាប់ពីទឹកជំនន់រួចហើយ លោកណូអេរស់បានមួយរយហាសិបឆ្នាំទៀត។[29]លោកណូអេរស់បានទាំងអស់ប្រាំបួនរយហាសិបឆ្នាំ ហើយបន្ទាប់មក គាត់ក៏ស្លាប់ទៅ។

ជំពូក ១០

[1]នេះគឺជាពូជពង្សកូនៗរបស់លោកណូអេ មានសិម ហាំ និងយ៉ាផេត។ ក្រោយពីទឹកជំនន់ ពួកគេបានបង្កើតកូនទាំងនេះ។


generated on Wed Mar 12 15:32:40 2025

2កូនប្រុសៗរបស់លោកយ៉ាផេត គឺកូមើរ ម៉ាកុក ម៉ាដាយ យ៉ាវ៉ាន ទូបាល ម៉េសេក និងទីរ៉ាស។3កូនប្រុសៗរបស់លោកកូមើរគឺអ័សក្នាស រីផាត និងតូការម៉ា។
4កូនប្រុសៗរបស់លោកយ៉ាវ៉ានគឺអេលីសា តើស៊ីស គីទីម និងដូដានីម។5ពីមនុស្សដែលរស់នៅតាមមាត់សមុទ្រនេះហើយដែលបានបែកខ្ញែក
ហើយចេញទៅក្នុងទឹកដីរបស់ពួកគេ ពួកគេមានភាសារៀងៗខ្លួន ទៅតាមអំបូរ និងប្រជាជាតិរៀងខ្លួន។
6កូនប្រុសៗរបស់លោកហាំគឺគូស មីសរ៉ែម ពូថ និងកាណាន។7កូនប្រុសៗរបស់គូសគឺសេបា ហាវីឡា សាបតា រ៉ាម៉ា និងសាបតិកា។ កូនប្រុសៗរបស់លោករ៉ាម៉ាគឺសេបា
និងដេដាន់។
8លោកគូសជាឪពុករបស់លោកនីមរ៉ូដ លោកនីមរ៉ូដនេះហើយជាវីរបុរសទីមួយនៅលើផែនដី។9លោកគឺជាអ្នកប្រម៉ាញ់ដ៏ខ្លាំងពូកែនៅចំពោះព្រះអម្ចាស់។
ហេតុនេះហើយបានជាមានពាក្យថា «លោកនីមរ៉ូដ គឺជាអ្នកប្រម៉ាញ់ដ៏ខ្លាំងពូកែនៅចំពោះព្រះអម្ចាស់»។10អាណាចក្រទីមួយរបស់លោកគឺបាបិល អេរេក អាកាឌ និង
កាលនេ ជាទីក្រុងដែលនៅទឹកដីស៊ីណើរ។
11ក្រៅពីទឹកដីទាំងនោះ លោកបានទៅទឹកដីអាសស៊ើរ ហើយបានសង់ក្រុងនីនីវេ ក្រុងរេហូបុត ក្រុងកាឡាស12និងក្រុងរេសែនដែលជាក្រុងមួយនៅចន្លោះក្រុងនីនីវេ និង
ក្រុងកាឡាស។ វាជាទីក្រុងដ៏ធំមួយ។13លោកមីសរ៉ែមបង្កើតជនជាតិលូឌ ជនជាតិអណាមីម ជនជាតិលេហាប៊ីម ជនជាតិណាប់ធូហ៊ីម។14ជនជាតិប៉ាទ្រូស៊ីម ជនជាតិ
កាសលូហ៊ីម (ដែលជាដូនតារបស់ជនជាតិភីលីស្ទីន) និងជនជាតិកាប់ថោរីម។
15លោកកាណានបង្កើតបានស៊ីដូន ជាកូនច្បងរបស់គាត់ និងហេត16ព្រមទាំងជនជាតិយេប៊ូស ជនជាតិអាម៉ូរី ជនជាតិគើកាស៊ី17ជនជាតិហេវី ជនជាតិអើគី ជនជាតិ
ស៊ីនី18ជនជាតិអើវ៉ាឌីតសេម៉ារីត ជនជាតិសេម៉ារី ជនជាតិហាម៉ាធីតផងដែរ។ ហើយក្រោយមកអំបូរកាណានបានបែកខ្ញែកគ្នា។
19ព្រំប្រទល់ទឹកដីជនជាតិកាណានចាប់ពីក្រុងស៊ីដូន ឆ្ពោះទៅក្រុងកេរ៉ា រហូតដល់ក្រុងកាសា និងរហូតដល់ក្រុងសូដុម ក្រុងកូម៉ូរ៉ា ក្រុងអាដម៉ា និងក្រុងសេបោម និងរហូត
ទៅដល់ក្រុងឡាសាថែមទៀតផង។20អ្នកទាំងនេះគឺជាពូជពង្សរបស់លោកហាំ និងអំបូររបស់ពួកគេ តាមភាសារបស់ពួកគេ នៅក្នុងទឹកដីរបស់ពួកគេ
និងនៅក្នុងប្រទេសរបស់ពួកគេដែរ។
21លោកសិមជាបងប្រុសច្បងរបស់លោកយ៉ាផេតក៏មានកូនប្រុសៗផងដែរ។ លោកសិមជាបុព្វបុរសរបស់មនុស្សទាំងអស់របស់ជនជាតិហេប៊ើរ។22កូនប្រុសៗរបស់លោក
សិមគឺអេឡាំ អាសស៊ើរ អើប៉ាក សាឌលូឌ និងអើរ៉ាម។23កូនប្រុសៗរបស់លោកអើរ៉ាមគឺ អ៊ូស ហ៊ូល កេធើរ និងម៉ាស។
24លោកអើប៉ាកសាឌជាឪពុករបស់សេឡា ហើយសេឡាជាឪពុករបស់ហេប៊ើរ។25លោកហេប៊ើរមានកូនប្រុសពីរនាក់។ កូនប្រុសមួយឈ្មោះផាឡេក ដ្បិត នៅជំនាន់នោះ
មនុស្សនៅលើផែនដីបានបែកខ្ញែកគ្នា។ ប្អូនរបស់គាត់ឈ្មោះ យ៉ុកថាន។
26លោកយ៉ុកថានជាឪពុករបស់អាល់ម៉ូដាដ សេឡេប ហាសារម៉ាវ៉េត យេរ៉ា27ហាដូរ៉ាម អ៊ូសាល ឌីកឡា28អូបាល អប៊ីម៉ែល សេបា29អូភារ ហាវីឡា និងយ៉ូបាប។ អ្នកទាំង
នេះគឺជាកូនប្រុសៗរបស់លោកយ៉ុកថានទាំងអស់។
30ទឹកដីរបស់ពួកគេចាប់តាំងពីក្រុងមេសា រហូតទៅដល់ក្រុងសេផារ នៅតំបន់ភ្នំខាងកើត។31ពួកគេគឺជាពូជពង្សរបស់លោកសិម តាមពូជអំបូរ តាមភាសា តាមទឹកដី និង
តាមជនជាតិរបស់គេ។
32អ្នកទាំងនេះគឺជាអំបូរកូនប្រុសៗរបស់លោកណូអេ តាមពង្សាវតាររបស់ពួកគេ តាមប្រជាជាតិរបស់ពួកគេ។ ពីប្រជាជាតិទាំងនេះហើយដែលបែកខ្ញែកទៅពាសពេញផែនដី
បន្ទាប់ពីទឹកជំនន់។

## ជំពូក ១១

1ឥឡូវនេះ ផែនដីទាំងមូលបានប្រើភាសាតែមួយ ហើយមានសំដីតែមួយ។2ក្នុងការដែលពួកគេធ្វើដំណើរឆ្ពោះទៅប៉ែកខាងកើតនោះ
ពួកគេបានជួបទីវាលរាបមួយនៅក្នុងទឹកដីស៊ីណើរ ហើយពួកគេក៏តាំងលំនៅនៅទីនោះ។
3ពួកគេបាននិយាយទៅកាន់គ្នាទៅវិញទៅមកថា៖ «មក ចូរយើងធ្វើឥដ្ឋ ហើយដុតវា»។ ពួកគេមានដីឥដ្ឋជំនួសឲ្យថ្ម និងប្រើជ័រខ្មៅជាបាយអ។4ពួកគេនិយាយថា៖ «ចូរមក
តោះយើងសង់ទីក្រុងមួយ និងប៉មមួយសម្រាប់ខ្លួនយើង ដែលមានកំពូលរហូតដល់មេឃ ហើយយើងធ្វើវាដើម្បីកេរ្តិ៍ឈ្មោះពួកយើង។ ប្រសិនបើ យើងមិនធ្វើទេ
យើងនឹងបែកខ្ញែកគ្នាទៅពេញផ្ទៃនៃផែនដីទាំងមូលហើយ»។
5ដូច្នេះ ព្រះអម្ចាស់បានយាងចុះមក ដើម្បីទតមើលទីក្រុង ហើយនិងប៉មដែលកូនចៅរបស់លោកអាដាំបានសង់។6ព្រះអម្ចាស់មានបន្ទូលថា៖ «មើល៍
ពួកគេជាមនុស្សតែមួយ ជាមួយនឹងភាសាតែមួយ ហើយពួកគេចាប់ផ្ដើមធ្វើការនេះ គ្មានអ្វីអាចហាមពីបំណងចិត្តដែលពួកគេចង់ធ្វើបានឡើយ។7មក ចូរយើងចុះទៅ
ហើយបំភាន់ភាសារបស់ពួកគេ ដើម្បីកុំឲ្យពួកគេយល់គ្នាទៅវិញទៅមកបានឡើយ»។
8ដូច្នេះ ព្រះអម្ចាស់បានបំបែកពួកគេចេញពីផ្ទៃនៃផែនដីទាំងមូល ហើយពួកគេបានឈប់សង់ទីក្រុងនោះទៀយ។9ហេតុដូច្នេះហើយ គេបានហៅទីក្រុងនោះថា បាបិល ព្រោះ
ព្រះអម្ចាស់បានបំភាន់ភាសានៅលើផែនដីទាំងមូល ហើយព្រះអម្ចាស់បានបំបែកពួកគេពីទីនោះឲ្យបែកខ្ញែកទៅពេញផ្ទៃនៃផែនដីទាំងមូល។
10អ្នកទាំងនេះគឺជាពូជពង្សរបស់លោកសិម។ លោកសិមមានអាយុមួយរយឆ្នាំ ហើយក្រោយទឹកជំនន់ពីរឆ្នាំ គាត់មានកូនប្រុសមួយឈ្មោះអើប៉ាក់សាឌ ។
11លោកសិមរស់បានប្រាំរយឆ្នាំ បន្ទាប់មកគាត់បង្កើតបានលោកអើប៉ាក់សាឌ។ គាត់ក៏មានកូនប្រុស និងកូនស្រីជាច្រើនទៀតដែរ។
12ពេលលោកអើប៉ាក់សាឌរស់បានសាមសិបឆ្នាំ គាត់បង្កើតបានសេឡា។13លោកអើប៉ាក់សាឌរស់បាន៤០៣ឆ្នាំ បន្ទាប់ពីគាត់បង្កើតបានលោកសេឡារួចហើយ។
គាត់ក៏បង្កើតបានកូនប្រុស និងកូនស្រីជាច្រើនទៀតដែរ។
14លោកសេឡារស់បានសាមសិបឆ្នាំ គាត់បង្កើតបានហេប៊ើរ។15លោកសេឡារបស់បាន៤០៣ឆ្នាំ បន្ទាប់ពីគាត់បង្កើតបានលោកហេប៊ើរ។ គាត់ក៏បង្កើតបានកូនប្រុស
និងកូនស្រីជាច្រើនទៀតផងដែរ។
16លោកហេប៊ើរស់បានសាមសិបបួនឆ្នាំ គាត់បង្កើតបានផាលេក។17បន្ទាប់ពីលោកហេប៊ើររស់បាន៤៣០ឆ្នាំ គាត់បង្កើតបានផាលេក។ គាត់បង្កើតបានកូនប្រុស
និងកូនស្រីជាច្រើនទៀតផងដែរ។
18លោកផាលេករស់បានសាមសិបឆ្នាំ គាត់បង្កើតបានរេហ៊ូវ។19លោកផាលេករស់បាន២០៩ឆ្នាំទៀត បន្ទាប់ពីគាត់បង្កើតលោករេហ៊ូវ។ គាត់បានបង្កើតកូនប្រុស
និងកូនស្រីជាច្រើនទៀត។
20លោករេហ៊ូវរស់បានសាមសិបពីរឆ្នាំ គាត់បង្កើតបានសេរូក។21លោករេហ៊ូវរស់បាន២០៧ឆ្នាំទៀត បន្ទាប់ពីគាត់បង្កើតបានលោកសេរូក។ គាត់ក៏បង្កើតបានកូនប្រុស
និងកូនស្រីជាច្រើនទៀតផងដែរ។
22លោករេហ៊ូវរស់បានសាមសិបឆ្នាំ គាត់បង្កើតបានណាឃរ។23លោករេហ៊ូវរស់បានពីររយឆ្នាំទៀត បន្ទាប់ពីគាត់បង្កើតបានលោកណាឃរ។ គាត់ក៏បង្កើតបានកូនប្រុស
និងកូនស្រីជាច្រើនទៀតផងដែរ។
24លោកណាឃររស់បានម្ភៃប្រាំបួនឆ្នាំ គាត់បង្កើតបានថេរ៉ា។25លោកណាឃររស់បាន១១៩ឆ្នាំទៀត បន្ទាប់ពីគាត់បង្កើតលោកថេរ៉ា។ គាត់ក៏បង្កើតបានកូនប្រុស
និងកូនស្រីជាច្រើនទៀតផងដែរ។26បន្ទាប់មក លោកថេរ៉ារបស់បានចិតសិបឆ្នាំទៀត គាត់បង្កើតបានអាប់រ៉ាម ណាឃរ និងហារ៉ាន។
27ហើយនេះគឺជាពូជពង្សរបស់លោកថេរ៉ា។ លោកថេរ៉ាបង្កើតបានលោកអាប់រ៉ាម លោកណាឃរ និងលោកហារ៉ាន ហើយលោកហារ៉ានបង្កើតបានឡុត។
28លោកហារ៉ានបានស្លាប់នៅចំពោះមុខថេរ៉ាជាឪពុករបស់គាត់ នៅក្នុងទឹកដីកំណើតរបស់គាត់ នៅក្នុងក្រុងអ៊ើរនៃទឹកដីខាល់ដេ។


generated on Wed Mar 12 15:32:40 2025

[29]លោកអាប់រ៉ាម និងលោកណាឃរបានរៀបការ។ ភរិយារបស់លោកអាប់រ៉ាមឈ្មោះនាងសារ៉ាយ ហើយភរិយារបស់លោកណាឃរឈ្មោះនាងមីលកា
ត្រូវជាកូនស្រីរបស់លោកហារ៉ាន ដែលជាឪពុករបស់មីលកា និងយីសកា។[30]នាងសារ៉ាយជាស្ត្រីអារ នាងគ្មានកូនទេ។
[31]លោកថេរ៉ាបាននាំលោកអាប់រ៉ាមកូនប្រុសរបស់គាត់ លោកឡុតត្រូវជាកូនប្រុសរបស់កូនប្រុសគាត់គឺលោកហារ៉ាន ហើយពួកគេបានចេញទៅពីក្រុងអ៊ើនៃទឹកដីខាល់ដេ
ទៅក្នុងទឹកដីកាណាន។ ប៉ុន្តែ ពួកគេបានទៅហារ៉ាន ហើយស្នាក់នៅទីនោះ។[32]លោកថេរ៉ារស់នៅបាន២០៥ឆ្នាំ ហើយបន្ទាប់គាត់ក៏បានស្លាប់នៅក្នុងក្រុងហារ៉ាន។

ជំពូក ១២

[1]ព្រះអម្ចាស់មានបន្ទូលទៅលោកអាប់រ៉ាមថា៖ «ចូរចេញពីប្រទេស ពីសាច់ញាតិ និងពីគ្រួសាររបស់អ្នក ទៅកាន់ទឹកដីដែលយើងបានបង្ហាញដល់អ្នក។
[2]យើងនឹងធ្វើឲ្យអ្នកត្រឡប់ទៅជាប្រទេសមួយដ៏ធំ ហើយយើងនឹងប្រទានពរដល់អ្នក ហើយធ្វើឲ្យអ្នកមានឈ្មោះល្បី ព្រមទាំងឲ្យអ្នកបានត្រឡប់ទៅជាពរដល់អ្នកដទៃ។
[3]យើងនឹងឲ្យពរដល់អស់អ្នកដែលឲ្យពរដល់អ្នក ប៉ុន្តែ អស់អ្នកណាដែលមើលងាយដល់អ្នក យើងនឹងដាក់បណ្តាសាដល់អ្នកនោះវិញ។
គ្រួសារទាំងអស់ដែលនៅផែនដីនឹងបានពរតាមរយៈអ្នក»។
[4]ដូច្នេះ លោកអាប់រ៉ាមបានចេញទៅ តាមដែលព្រះអម្ចាស់បង្គាប់ដល់គាត់ឲ្យធ្វើ ហើយលោកឡុតបានទៅជាមួយគាត់ដែរ។ លោកអាប់រ៉ាមមានអាយុចិតសិបប្រាំ
ពេលគាត់ចេញពីហារ៉ាន។[5]លោកអាប់រ៉ាមបានយកនាងសារ៉ាយជាភរិយាររបស់គាត់ និងលោកឡុត ក្មួយប្រុសរបស់គាត់ និងទ្រព្យសម្បត្តិទាំងអស់ដែលពួកគេមាន
ហើយនិងទាសករដែលពួកគេបានទិញនៅក្នុងទឹកដីហារ៉ាន។ ពួកគេបានចាកចេញ ដើម្បីធ្វើដំណើរទៅទឹកដីកាណាន ហើយបានមកដល់ទឹកដីរបស់កាណាន។
[6]លោកអាប់រ៉ាមបានឆ្លងកាត់ទឹកដីកាណានមកដល់ ស៊ីគែម នៅត្រង់ដើមដើមជ្រៃរបស់លោកម៉ូរេ។ នៅសម័យនោះ ជនជាតិកាណានជាម្ចាស់ទឹកដីដែលគេរស់នៅ។
[7]ព្រះអម្ចាស់បានយាងមកឲ្យលោកអាប់រា៉ាមឃើញ ហើយមានបន្ទូលថា៖ «យើងនឹងប្រគល់ទឹកដីនេះ ដល់ពូជពង្សរបស់អ្នក»។ នៅទីនោះ
លោកអាប់រ៉ាមបានសង់អាសនៈមួយថ្វាយព្រះអម្ចាស់ ដែលបានយាងមកឲ្យគាត់ឃើញ។
[8]គាត់បានចាកចេញពីទីនោះទៅប្រទេសដែលមានភ្នំគឺភាគខាងកើតនៃបេតអែល គាត់បានសង់ត្រសាលរបស់គាត់នៅទីនោះ បេតអែលនៅខាងលិចគឺនៅចន្លោះ នឹងក្រុង
អៃ ដែលនៅខាងកើត។ គាត់បានសង់អាសនៈថ្វាយព្រះអម្ចាស់ ហើយអំពាវនាវរកព្រះនាមព្រះរបស់ព្រះអម្ចាស់នៅទីនោះ។[9]បន្ទាប់មក លោកអាប់រ៉ាមបានបន្តដំណើរ
ឆ្ពោះទៅក្នុងក្រុងណេកិប។
[10]នៅពេលនោះ មានគ្រោះទុរភិក្សកើតឡើងនៅក្នុងទឹកដីរបស់គាត់ ដូច្នេះ លោកអាប់រ៉ាមបានចុះទៅរស់នៅអេស៊ីប ដ្បិត
មានគ្រោះទុរភិក្សយ៉ាងខ្លាំងកើតឡើងនៅក្នុងទឹកដីរបស់គាត់។[11]នៅពេលគាត់ជិតចូលទៅក្នុងទឹកដីរបស់អេស៊ីបហើយ
គាត់បាននិយាយទៅកាន់សារ៉ាយភរិយារបស់គាត់ថា៖ «មើល៍ បងដឹងថា អូនជាស្រីម្នាក់ដែលស្អាត។[12]នៅពេលជនជាតិអេស៊ីបឃើញអូន ពួកគេនឹងនិយាយថា
នេះជាភរិយារបស់គាត់ ហើយគេនឹងសម្លាប់បងហើយ តែគេនឹងទុកឲ្យអូនរស់វិញ។[13]ចូរនិយាយថា អូនជាប្អូនស្រីរបស់បង
ដើម្បីឲ្យពួកគេបានធ្វើល្អជាមួយបងដោយសារអូន ហើយអូនបានការពារជីវិតបងផងដែរ»។
[14]នៅពេលលោកអាប់រ៉ាមបានចូលទៅក្នុងទឹកដីអេស៊ីប ជនជាតិអេស៊ីបបានឃើញថា នាងសារ៉ាយស្អាតខ្លាំងណាស់។[15]ពួកមន្ត្រីរបស់ស្តេចផារោនបានឃើញនាង
ហើយបានសរសើរនាងចំពោះស្តេចផារោន ហើយគេបាននាំនាងទៅក្នុងដំណាក់របស់ស្តេចផារោន។
[16]ស្តេចផារោនបានប្រព្រឹត្តជាមួយលោកអាប់រ៉ាមយ៉ាងល្អដោយព្រោះនាង ហើយបានប្រទានចៀម គោ និងសត្វលាឈ្មោលៗ អ្នកបម្រើទាំងប្រុស និងអ្នកបម្រើស្រី
សត្វលាញីៗ និងសត្វអូដ្ឋជាច្រើនផង។
[17]បន្ទាប់មក ព្រះអម្ចាស់បានធ្វើឲ្យស្តេចផារោន និងញាត្តិវង្សរបស់ស្តេចជួបគ្រោះកាចយ៉ាងខ្លាំង ដោយសារនាងសារ៉ាយ ភរិយារបស់អាប់រ៉ាម។
[18]ស្តេចផារោនបានកោះហៅលោកអាប់រ៉ាម ហើយមានបន្ទូលថា៖ «ហេតុអ្វីបានជាអ្នកធ្វើចំពោះយើងយ៉ាងដូច្នេះ?
ហេតុអ្វីបានជាអ្នកមិនប្រាប់យើងថានាងជាភរិយារបស់អ្នក?[19]ហេតុអ្វីបានជាអ្នកនិយាយថានាងជាប្អូនស្រីរបស់អ្នកទៅវិញ
ធ្វើឲ្យយើងយកនាងទៅជាមហេសីរបស់យើងដូច្នេះ? ឥឡូវនេះ មើល៍ នេះ ភរិយារបស់អ្នក។ ចូរយកនាង ហើយចេញទៅ?»។[20]បន្ទាប់មក
ស្តេចផារោនបានបង្គាប់ដល់ពួកប្រុសៗរបស់ព្រះអង្គទាំងអស់ទាក់ទងនឹងលោក ហើយពួកគេបានចាត់លោកឲ្យទៅ ជាមួយភរិយារបស់លោក
និងជាមួយអ្វីៗទាំងអស់ដែលគាត់មាន។

ជំពូក ១៣

[1]ដូច្នេះ លោកអាប់រ៉ាមបានចេញពីអេស៊ីប ហើយធ្វើដំណើរទៅណេកិប ជាមួយភរិយា និងអ្វីៗទាំងអស់ដែលគាត់មាន។ លោកឡុតក៏ទៅជាមួយពួកគេដែរ។
[2]លោកអាប់រ៉ាមមានហ្វូងសត្វ ប្រាក់ និងមាសជាច្រើន។
[3]គាត់បានបន្តធ្វើដំណើរពីណេកិតទៅបេតអែល ទៅកន្លែងដែលគាត់បានសង់ត្រសាលកាលពីមុន នៅចន្លោះបេតអែល និងក្រុងអៃ។
[4]គាត់បានទៅដល់កន្លែងដែលមានអាសនៈ ដែលគាត់បានសង់ពីមុន។ នៅទីនេះ គាត់អំពាវនាវព្រះនាមព្រះជាម្ចាស់។
[5]លោកឡុតបានធ្វើដំណើរជាមួយលោកអាប់រ៉ាម គាត់មានហ្វូងសត្វ ហ្វូងចៀម ហ្វូងគោ និងមានត្រសាលជាច្រើនដែរ។
[6]ទឹកដីនោះមិនអាចផ្គត់ផ្គង់ពួកគេទាំងពីរនាក់ឲ្យរស់នៅជាមួយគ្នាបានទេ ដោយសារពួកគេមានទ្រព្យសម្បត្តិយ៉ាងច្រើន ដូច្នេះ ពួកគេមិនអាចនៅជាមួយគ្នាបានទេ។
[7]ក៏មានជម្លោះរវាងអ្នកគង្វាលសត្វរបស់លោកអាប់រ៉ាម និងអ្នកគង្វាលសត្វរបស់លោកឡុត។ ជនជាតិកាណាន និងជនជាតិពេរិស៊ីត ក៏រស់នៅក្នុងស្រុកនោះដែរ។
[8]ដូច្នេះ លោកអាប់រ៉ាមនិយាយទៅកាន់លោកឡុតថា៖ «កុំឲ្យមានជម្លោះរវាងឯងនិងអ៊ំ និងអ្នកគង្វាលសត្វរបស់ឯង និងអ្នកគង្វាលសត្វរបស់អ៊ំដែរ
ព្រោះយើងជាគ្រួសារតែមួយទេ។[9]តើទឹកដីនៅខាងមុខឯងទាំងអស់នេះ មិនមែនជារបស់ឯងទេឬអី? ចូរទៅចុះ ហើយយើងបែកផ្លូវគ្នាចុះ។ ប្រសិនបើ ឯងទៅខាងឆ្វេង
អ៊ំនឹងទៅខាងស្តាំ។ ឬ ប្រសិនបើ ឯងទៅខាងស្តាំ អ៊ំនឹងទៅខាងឆ្វេង»។
[10]ដូច្នេះ លោកឡុតក៏សម្លឹងមើលជុំវិញ ហើយគាត់បានឃើញទឹកដីទាំងអស់នៅវាលទន្លេយ័រដាន់មានទឹកច្រើនល្អ រហូតដល់ក្រុងសូអារ ស្អាតដូចជាសួនរបស់ព្រះអម្ចាស់
ដូចជាទឹកដីរបស់អេស៊ីប។ ការនេះ នៅមុនព្រះអម្ចាស់បំផ្លាញក្រុងសូដុម និងក្រុងកូម៉ូរ៉ា។[11]ដូច្នេះ លោកឡុតក៏ជ្រើសរើសវាលរបស់ទន្លេយ័រដាន់
ហើយបានធ្វើដំណើរទៅភាគខាងកើត ហើយពួកគេបានបែកខ្ញែកពីសាច់ញាតិរបស់ពួកគេ។
[12]លោកអាប់រ៉ាមបានរស់នៅក្នុងទឹកដីកាណាន ហើយលោកឡុតរស់នៅក្នុងចំណោមទីក្រុងដែលមានវាលទំនាប។
គាត់បានសង់ត្រសាលនៅពេលដែលគាត់មកដល់ក្រុងសូដុម។[13]មនុស្សនៅក្នុងក្រុងសូដុមជាមនុស្សបាប អាក្រក់ជាខ្លាំងទាស់នឹងព្រះអម្ចាស់។
[14]ព្រះអម្ចាស់មានបន្ទូលទៅកាន់លោកអាប់រ៉ាម បន្ទាប់ពីលោកឡុតចេញពីគាត់ «ចូរមើលពីកន្លែងដែលអ្នកឈរនេះ ទៅជើង ទៅត្បូង ទៅកើត និងទៅលិច។
[15]ទឹកដីទាំងអស់ដែលអ្នកឃើញ យើងនឹងប្រគល់ឲ្យអ្នក និងពូជពង្សរបស់អ្នករហូតតទៅ។
[16]យើងនឹងធ្វើឲ្យពូជពង្សរបស់អ្នកបានចម្រើនឡើងដូចជាធូលីនៅលើផែនដី ប្រសិនបើ មនុស្សអាចរាប់ធូលីដីបាន នោះគេក៏អាចរាប់ពូជពង្សរបស់អ្នកបានដែរ។
[17]ចូរក្រោកឡើង ចូរដើរឲ្យពេញទឹកដីនេះ ដ្បិត យើងបានប្រគល់ឲ្យអ្នកហើយ»។[18]ដូច្នេះ លោកអាប់រ៉ាមបានដំឡើងត្រសាលរបស់គាត់
ហើយមករស់នៅជិតដើមជ្រៃរបស់លោកម៉ាមរ៉េ ដែលនៅក្រុងហេប្រុន ហើយបានសង់កន្លែងថ្វាយតង្វាយថ្វាយដល់ព្រះអម្ចាស់នៅទីនោះ។


generated on Wed Mar 12 15:32:40 2025

## ជំពូក ១៤

1កាលនោះ ព្រះបាទអាំរ៉ាផែលជាស្ដេចរបស់ប្រទេសស៊ីណើរ ព្រះបាទអើយ៉ុកជាស្ដេចរបស់ប្រទេសអេឡាសារ ព្រះបាទកេដូឡោមើរជាស្ដេចប្រទេសអេឡាំ និងព្រះបាទ
ធីដាលជាស្ដេចរបស់ប្រទេសកូយីម2ពួកគេបានធ្វើសង្គ្រាមទាស់នឹងព្រះបាទបេរ៉ាជាស្ដេចក្រុងសូដុម ព្រះបាទប៊ីសារជាស្ដេចក្រុងកូម៉ូរ៉ា ព្រះបាទស៊ីណាបជាស្ដេចក្រុង
អាដម៉ា ព្រះបាទសេមេប៊ើរជាស្ដេចក្រុងសេបោម និងស្ដេចក្រុងបេឡា (ដែលហៅថាក្រុងសូអារផងដែរ)។
3ក្រោយមក ស្ដេចទាំងប្រាំបានរួមគ្នានៅជ្រលងភ្នំស៊ីឌីម (ដែលហៅថាសមុទ្រប្រៃ)។4ស្ដេចទាំងនេះបានបម្រើព្រះបាទកេដូឡោមើរ អស់រយៈពេលដប់ពីរឆ្នាំ ប៉ុន្តែ នៅឆ្នាំទីដប់
បីពួកគេបាននាំគ្នាបះបោរ។5បន្ទាប់មក នៅឆ្នាំទីដប់បួន ព្រះបាទកេដូឡោមើរ និងស្ដេចផ្សេងៗ ដែលនៅជាមួយព្រះអង្គ បាននាំគ្នាមកវាយលុកជនជាតិរេផែម នៅក្រុង
អាសថារ៉ូតកើណែម ជនជាតិស៊ូស៊ីម នៅក្រុងហាំ ជនជាតិអេមីម នៅក្រុងគារយ៉ាថែម6និងជនជាតិហូរី នៅតំបន់ភ្នំសៀរ រហូតដល់តំបន់អែលបារ៉ាន ដែលនៅជិតទី
រហោស្ថាន។
7បន្ទាប់មក ពួកគេបានត្រឡប់ ហើយមកឯក្រុងអេនមីសផាត (ដែលហៅថាក្រុងកាដេស) វិញ ហើយបានវាយយករបស់ជនជាតិអាម៉ាឡេក ព្រមទាំងជនជាតិអាម៉ូរី ដែល
រស់នៅទឹកដីហាសាសូនតាម៉ារផង។8បន្ទាប់មក ស្ដេចក្រុងសូដុម ស្ដេចក្រុងកូម៉ូរ៉ា និងស្ដេចបេឡា (ដែលហៅថាក្រុងសូអារ)9បានចេញទៅធ្វើសង្គ្រាមតទល់នឹងព្រះបាទ
កេដូឡោមើរជាស្ដេចរបស់ទឹកដីអេឡាំ ព្រះបាទធីដាលជាស្ដេចទឹកដីកូយីម ព្រះបាទអាំរ៉ាផែលជាស្ដេចរបស់ទឹកដីស៊ីណើរ និងព្រះបាទអើរយ៉ុកជាស្ដេច
របស់ទឹកដីអេឡាសារ គឺស្ដេចបួនអង្គតទល់នឹងស្ដេចប្រាំអង្គ។
10ឥឡូវនេះ នៅជ្រលងភ្នំស៊ីឌីមពេញទៅដោយអណ្ដូងប្រេងជាច្រើន ហើយស្ដេចក្រុងសូដុម និងក្រុងកូម៉ូរ៉ា បានរត់ ហើយពួកគេបានធ្លាក់ទៅក្នុងអណ្ដូងនោះ។
ហើយពួកអ្នកដែលនៅសល់បានរត់ទៅតាមភ្នំផ្សេងៗ។11ដូច្នេះ ពួកសត្រូវបានយករបស់របរនៅក្រុងសូដុម និងក្រុងកូម៉ូរ៉ាទាំងអស់
ព្រមទាំងទ្រព្យសម្បត្តិរបស់ពួកគេទៅជាមួយដែរ។12នៅពេលពួកគេនាំចេញទៅ ពួកគេបាននាំលោកឡុត
ក្មួយរបស់លោកអាប់រ៉ាមដែលរស់នៅក្នុងក្រុងសូដុមទៅជាមួយដែរ រួមទាំងទ្រព្យសម្បត្តិរបស់គាត់ទាំងអស់ផងដែរ។
13មានម្នាក់ដែលបានគេចរួចបានមកប្រាប់លោកអាប់រ៉ាមជាជនជាតិហេព្រើរ។ លោករស់នៅក្បែរដើមជ្រៃដែលជាកម្មសិទ្ធិរបស់លោកម៉ាមរ៉េជាជនជាតិអាម៉ូរី ដែលត្រូវជា
បងប្អូនរបស់លោកអែសកុល និងលោកអាន់នើរ ដែលជាសម្ពន្ធមិត្តរបស់លោកអាប់រ៉ាម។14នៅពេលនេះ លោកអាប់រ៉ាមបានឮថា
ពួកសត្រូវបានចាប់យកសាច់ញាតិរបស់គាត់ លោកបាននាំអ្នកបម្រើដែលកើតនៅក្នុងផ្ទះរបស់គាត់ ដែលគាត់បានបង្វឹកចំនួន៣១៨នាក់
ហើយគាត់បានដេញតាមពួកគេរហូតដល់ក្រុងដាន់។
15គាត់បានបែងចែកគ្នារបស់គាត់ដើម្បីប្រយុទ្ធជាមួយពួកគេនៅពេលយប់ ហើយបានវាយលុកពួកគេ និងដេញតាមពួកគេរហូតដល់ក្រុងហូបា ដែលនៅខាងជើងក្រុង
ដាម៉ាស។16បន្ទាប់មក គាត់បាននាំទ្រព្យសម្បត្តិទាំងអស់ ហើយបាននាំលោកឡុតដែលជាសាច់ញាតិរបស់គាត់ ព្រមទាំងរបស់របរ រួមទាំងភរិយា
និងអ្នកផ្សេងទៀតផងដែរ។
17បន្ទាប់ពីលោកអាប់រ៉ាមបានត្រឡប់ពីវាយលុកព្រះបាទកេដូឡោមើរ និងស្ដេចទាំងឡាយដែលនៅជាមួយរួចមក ស្ដេចក្រុងសូដុមក៏ចេញមកទទួលគាត់នៅជ្រលងភ្នំសាវេ
(ដែលហៅថាជ្រលងភ្នំហ្លួងផងដែរ)។18ព្រះបាទម៉ិលគីស្សាដែកជាស្ដេចនៅក្រុងសាឡិម បានឲ្យគេយកនំប៉័ង និងស្រាទំពាំងបាយជូរមកជូនលោកអាប់រ៉ាម។
គាត់គឺជាមហាបូជាចារ្យរបស់ព្រះជាម្ចាស់ដ៏ខ្ពស់បំផុត។
19គាត់បានឲ្យពរដល់លោកដោយថ្លែងថា៖ «សូមព្រះជាម្ចាស់ដ៏ខ្ពស់បំផុត ជាព្រះដែលបានបង្កើតស្ថានសួគ៌ និងផែនដី បានប្រទានពរដល់លោកអាប់រ៉ាម។
20សូមព្រះជាម្ចាស់ដ៏ខ្ពស់បំផុត ជាព្រះដែលបានប្រគល់ខ្មាំងសត្រូវមកក្នុងកណ្ដាប់ដៃរបស់លោក ប្រទានពរដល់លោក»។ បន្ទាប់មក
លោកអាប់រ៉ាមបានថ្វាយមួយភាគដប់ដល់ស្ដេចពីអ្វីៗទាំងអស់។
21ស្ដេចក្រុងសូដុមមានបន្ទូលទៅលោកអាប់រ៉ាមថា៖ «ចូរប្រគល់មនុស្សមកឲ្យយើងវិញ ហើយយកទ្រព្យសម្បត្តិសម្រាប់លោកទៅចុះ»។
22លោកអាប់រ៉ាមទូលទៅស្ដេចក្រុងសូដុមថា៖ «ទូលបង្គំសូមលើកដៃរបស់ទូលបង្គំនៅចំពោះព្រះអម្ចាស់ជាព្រះដ៏ខ្ពង់ខ្ពស់បំផុត ជាព្រះដែលបានបង្កើតស្ថានសួគ៌ និង
ផែនដីថា23ទូលបង្គំនឹងមិនយកអំបោះមួយសរសៃ ឬខ្សែស្បែកជើងមួយ ឬអ្វីៗដែលជាសម្បត្តិរបស់ព្រះករុណាសោះឡើយ ដើម្បីកុំឲ្យព្រះករុណាមានបន្ទូលថា៖ «យើង
បានធ្វើឲ្យអាប់រ៉ាមទៅជាអ្នកមាន»។24ទូលបង្គំនឹងមិនយកអ្វីឡើយ លើកលែងតែអ្វីៗដែលសម្រាប់យុវជនហូប ហើយចែករំលែកជាមួយអ្នកដែលទៅជាមួយទូលបង្គំ
ប៉ុណ្ណោះបានហើយ សូមឲ្យលោកអាន់នើរ លោកអេសកុល និងលោកម៉ាមរ៉េបានយកចំណែករបស់ពួកគេផង»។

## ជំពូក ១៥

1បន្ទាប់ការទាំងនេះកើតឡើង ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់លោកអាប់រ៉ាមនៅក្នុងនិមិត្តថា៖ «អាប់រ៉ាមអើយ! កុំខ្លាចអី យើងជាខែល និងជារង្វាន់ដ៏ធំរបស់អ្នក»។
2លោកអាប់រ៉ាមទូលថា៖ «ព្រះអម្ចាស់អើយ តើព្រះអង្គនឹងប្រទានអ្វីដល់ទូលបង្គំ? បើទូលបង្គំគ្មានកូនដូច្នេះ ហើយអ្នកដែលនឹងទទួលកេរមត៌កនៅក្នុងផ្ទះរបស់ទូលបង្គំ គឺ
អេលាស៊ើរជាអ្នកក្រុងដាម៉ាសឯណោះវិញទេ»។3លោកអាប់រ៉ាមបន្តទៀតថា៖ «ព្រះអង្គមិនបានប្រទានឲ្យទូលបង្គំមានកូន មើល
មានតែអ្នកបម្រើនៅក្នុងផ្ទះរបស់ទូលបង្គំទេ នឹងទទួលកេរមត៌ករបស់ទូលបង្គំ»។
4មើល៍ ព្រះបន្ទូលរបស់ព្រះអម្ចាស់បានមកដល់គាត់ ថា៖ «បុរសនេះនឹងមិនទទួលកេរមត៌ករបស់អ្នកឡើយ ប៉ុន្តែ ម្នាក់ដែលកើតចេញពីរូបកាយរបស់អ្នកទេ
ដែលនឹងទទួលកេរមត៌ករបស់អ្នក»។5បន្ទាប់មក ព្រះអង្គបាននាំគាត់ចេញមកក្រៅ ហើយមានបន្ទូលថា៖ «ចូរមើលទៅស្ថានសួគ៌ ហើយរាប់ចំនួនផ្កាយ ប្រសិនបើ
អ្នកអាចរាប់ចំនួនវាបាន»។ បន្ទាប់មកព្រះអង្គមានបន្ទូលទៅគាត់ថា៖ «ដូច្នេះ អ្នកនឹងរាប់ពូជពង្សរបស់អ្នកបានហើយ»។
6គាត់បានជឿលើព្រះអម្ចាស់ ហើយគាត់ត្រូវបានរាប់ជាសុចរិត។7ព្រះអង្គមានបន្ទូលទៅគាត់ថា៖ «យើងគឺព្រះអម្ចាស់ ដែលបាននាំអ្នកចេញពីក្រុងអ៊ើរ ទឹកដីខាល់ដេ
យើងនឹងប្រគល់ទឹកដីនេះជាកេរមត៌កដល់អ្នក»។8គាត់ទូលថា៖ «ព្រះអម្ចាស់ដ៏ជាព្រះអើយ តើទូលបង្គំដឹងបានយ៉ាងដូចម្ដេចថា ទូលបង្គំនឹងបានទទួលវានោះ?»
9បន្ទាប់មក ព្រះអង្គមានបន្ទូលទៅគាត់ថា៖ «មើល៍ ចូរយកគោញីមួយអាយុបីឆ្នាំ ពពែញីមួយអាយុបីឆ្នាំ និងកូនចៀមឈ្មោលមួយអាយុបីឆ្នាំ ព្រាបមួយ
និងលលកជំទើរមួយមក»។10គាត់បានយកសត្វទាំងអស់នោះមកថ្វាយព្រះអង្គ ហើយកាត់ពួកវាជាពីរ និងយកមកពាក់កណ្ដាលមកដាក់ផ្ទុយគ្នា ប៉ុន្តែ
គាត់មិនបានពុះសត្វស្លាបទេ។11ពេលនោះ មានត្មាតមកឆាបសាច់សត្វ លោកអាប់រ៉ាមបានដេញវា។
12បន្ទាប់មក នៅពេលថ្ងៃជិតលិច លោកអាប់រ៉ាមងងុយគេងជាខ្លាំង ហើយមើល មានភាពងងឹត និងគួរឲ្យភ័យខ្លាចជាខ្លាំងចំពោះគាត់។13បន្ទាប់ពី
ព្រះអម្ចាស់មានបន្ទូលមកលោកអាប់រ៉ាមថា៖ «ចូរដឹងជាប្រាកដថា ពូជពង្សរបស់អ្នកនឹងក្លាយជាជនបរទេសនៅក្នុងទឹកដីសាសន៍ដទៃដែលមិនមែនជាទឹកដីរបស់ខ្លួន
ហើយនឹងក្លាយជាទាសករ ហើយត្រូវគេជិះជាន់អស់រយៈពេលបួនរយឆ្នាំ។
14យើងនឹងជំនុំជម្រះប្រជាជាតិដែលពួកគេនឹងបម្រើនោះ ហើយបន្ទាប់មកពួកគេនឹងចេញពីប្រទេសនោះជាមួយនឹងទ្រព្យសម្បត្តិយ៉ាងច្រើនសន្ធឹក។15ប៉ុន្តែ
អ្នកនឹងត្រឡប់ទៅឯឪពុករបស់ដោយសេចក្ដីសុខសាន្ត ហើយអ្នកនឹងត្រូវបញ្ចុះក្នុងផ្នូរក្នុងអាយុវែងល្អហើយ។16នៅក្នុងជំនាន់ទីបួន ពួកគេនឹងមកទីនេះម្ដងទៀត
ដើម្បីអំពើរំលងរបស់អាម៉ូរីមិនទាក់កម្រិតរបស់វានៅឡើយ»។


generated on Wed Mar 12 15:32:40 2025

17នៅពេលថ្ងៃជិតលិច ហើយសេចក្ដីងងឹតក៏មកដល់ មើល៍ មានឆ្នាំងភ្លើងហុយផ្សែង ហើយនិងអណ្ដាតភ្លើងឆេះនៅចន្លោះដុំសាច់ទាំងនោះ។18នៅថ្ងៃនោះ
ព្រះអម្ចាស់បានធ្វើសម្ពន្ធមេត្រីជាមួយលោកអាប់រ៉ាម ដោយមានបន្ទូលថា៖ «យើងនឹងប្រគល់ទឹកដីនេះ ដល់ពូជពង្សរបស់អ្នក ពីទន្លេអេស៊ីប
រហូតដល់ទន្លេធំអឺប្រាត19ជនជាតិកែន ទឹកដីកេនិស៊ីត ទឹកដីកាត់ម៉ូនី20ទឹកដីហេត ទឹកដីពេរិស៊ីត ទឹកដីរេផែម21ទឹកដីអាម៉ូរី ទឹកដីកាណាន ទឹកដីគើកាស៊ី និងទឹកដី
យេប៊ូស»។

## ជំពូក ១៦

1ឥឡូវនេះ នាងសារ៉ាយ ភរិយារបស់លោកអាប់រ៉ាម មិនបានបង្កើតកូនណាមួយឲ្យលោកអាប់រ៉ាមទេ ប៉ុន្តែ នាងមានអ្នកបម្រើស្រីម្នាក់ ជាជនជាតិអេស៊ីប នាងឈ្មោះហាកា។
2ដូច្នេះ នាងសារ៉ាយបានប្រាប់លោកអាប់រ៉ាមថា៖ «មើល៍ ព្រះអម្ចាស់បានបង្ខាំងខ្ញុំមិនឲ្យមានកូន។ ចូរទៅគេងជាមួយអ្នកបម្រើស្រីរបស់ខ្ញុំចុះ។
ខ្ញុំប្រហែលជាមានកូនដោយសារនាង»។ លោកអាប់រ៉ាមបានស្ដាប់តាមសំដីរបស់នាងសារ៉ាយ។3ការនេះកើតឡើងបន្ទាប់ពីលោកអាប់រ៉ាមករស់នៅទឹកដីកាណានដប់ឆ្នាំ
ដែលនាងសារ៉ាយភរិយារបស់លោកអាប់រ៉ាមប្រគល់នាងហាកា ជាអ្នកបម្រើស្រីរបស់នាង ទៅឲ្យស្វាមីរបស់នាងធ្វើជាភរិយា។4ដូច្នេះ លោកក៏បានរួមរស់ជាមួយនាងហាកា
ហើយនាងក៏មានផ្ទៃពោះ។ នៅពេលនាងឃើញថា នាងមានកូនដូច្នេះ នាងចាប់ផ្ដើមមើលងាយម្ចាស់ស្រីរបស់នាង។
5បន្ទាប់មក នាងសារ៉ាយប្រាប់លោកអាប់រ៉ាមថា៖ «នេះជាកំហុសរបស់អូនគឺដោយសារតែបង។ អូនបានប្រគល់អ្នកបម្រើស្រីរបស់អូនទៅឲ្យបងឱប
ហើយនៅពេលនាងដឹងថា នាងមានផ្ទៃពោះ នាងបែរជាមើលងាយអូនទៅវិញ។ សូមឲ្យព្រះអម្ចាស់វិនិច្ឆ័យ រវាងអូននិងបងចុះ»។6ប៉ុន្តែ
លោកអាប់រ៉ាមនិយាយទៅនាងសារ៉ាយថា៖ «មើល៍ អ្នកបម្រើស្រីរបស់អូននៅក្នុងអំណាចរបស់អូនហើយ ចូរធ្វើតាមតែចិត្តអូនចុះ»។ ដូច្នេះ
នាងសារ៉ាយបានប្រព្រឹត្តនឹងនាងយ៉ាងគ្រោតគ្រាត ហើយនាងហាកាក៏រត់ចេញពីនាង។
7ទេវតារបស់ព្រះអម្ចាស់បានមកជួបនាងនៅក្បែរប្រភពទឹកមួយនៅទីរហោស្ថាន ប្រភពទឹកនោះនៅតាមផ្លូវទៅទឹកដីស៊ើរ។8លោកនិយាយនឹងនាងថា៖ «ហាកា
អ្នកបម្រើរបស់នាងសារ៉ាយអើយ តើអ្នកមកពីណា ហើយទៅណា?» បន្ទាប់មក នាងក៏តបថា៖ «នាងខ្ញុំរត់ចេញពីលោកស្រីសារ៉ាយម្ចាស់ស្រីរបស់ខ្ញុំ»។
9ទេវតារបស់ព្រះអម្ចាស់ប្រាប់ទៅនាងថា៖ «ចូរត្រឡប់ទៅម្ចាស់ស្រីរបស់អ្នកវិញចុះ ហើយចុះចូលនឹងសិទ្ធិអំណាចរបស់នាង»។10បន្ទាប់មក
ទេវតារបស់ព្រះអម្ចាស់និយាយទៅនាងថា៖ «យើងនឹងធ្វើឲ្យពូជពង្សរបស់នាងបានចម្រើនច្រើនឡើង គ្មាននរណាអាចរាប់បានឡើយ»។
11ទេវតារបស់ព្រះអម្ចាស់ក៏ប្រាប់ទៅនាងផងដែរថា៖ «មើល អ្នកមានផ្ទៃពោះ ហើយនាងនឹងបង្កើតបានកូនប្រុសមួយ ហើយអ្នកត្រូវដាក់ឈ្មោះថា អ៊ីស្មាអែល
ដោយសារព្រះអម្ចាស់បានឮទុក្ខលំបាករបស់នាង។12គាត់នឹងបានដូចជាសត្វលាព្រៃ។ គាត់នឹងវាយមនុស្សទាំងអស់ ហើយមនុស្សទាំងអស់នឹងវាយវាវិញ
ហើយវានឹងរស់នៅដោយឡែកពីបងប្អូនទាំងអស់របស់វា»។
13បន្ទាប់មក នាងបានថ្វាយព្រះនាមដល់ព្រះអម្ចាស់ដែលមានបន្ទូលជាមួយនាងថា៖ «ព្រះអង្គជាព្រះជាម្ចាស់ដែលទតឃើញខ្ញុំម្ចាស់» ដ្បិតនាងនិយាយថា៖
«តើខ្ញុំពិតជាមើលឃើញ សូម្បីតែព្រះអង្គបានទតឃើញខ្ញុំ?»14ដូច្នេះ អណ្ដូងនោះត្រូវបានហៅថា អណ្ដូងឡាហាយរយ មើល វាស្ថិតនៅចន្លោះភូមិកាដេស និងភូមិបារ៉េដ។
15នាងហាកាបង្កើតបានកូនប្រុសមួយឲ្យលោកអាប់រ៉ាម ហើយលោកអាប់រ៉ាមបានដាក់ឈ្មោះកូនប្រុសរបស់គាត់ ដែលនាងហាកាបង្កើតនោះថា អ៊ីស្មាអែល។
16លោកអាប់រ៉ាមមានអាយុប៉ែតសិបប្រាំមួយឆ្នាំ ពេលនាងហាកាបង្កើតអ៊ីស្មាអែលដល់លោកអាប់រ៉ាម។

## ជំពូក ១៧

1ពេលលោកអាប់រ៉ាមមានអាយុកៅសិបប្រាំបួនឆ្នាំ ព្រះអម្ចាស់បានយាងមកជួបលោក ហើយមានបន្ទូលទៅគាត់ថា៖ «យើងគឺជាព្រះអម្ចាស់ដ៏មានព្រះចេស្ដា។
2ចូរដើរនៅចំពោះយើង ហើយឲ្យបានគ្រប់លក្ខណ៍ចុះ។ បន្ទាប់មក យើងនឹងចងសម្ពន្ធមេត្រីរវាងយើងនិងអ្នក
ហើយយើងនឹងធ្វើឲ្យពូជពង្សរបស់អ្នកបានកើតចំនួនច្រើនឡើង»។
3លោកអាប់រ៉ាមបានក្រាបមុខដល់ដី ហើយព្រះជាម្ចាស់មានបន្ទូលជាមួយគាត់ថា៖4«ចំណែកយើង មើល យើងនឹងចងសម្ពន្ធមេត្រីជាមួយអ្នក។
អ្នកនឹងក្លាយជាឪពុកនៃប្រជាជាតិជាច្រើន។5ឈ្មោះរបស់អ្នកលែងជាអាប់រ៉ាមទៀតហើយ ប៉ុន្តែ ឈ្មោះរបស់អ្នកនឹងទៅជាអប្រាហាំវិញ ដ្បិត យើងបានរើសតាំងអ្នក
ដើម្បីឲ្យធ្វើជាឪពុកនៃប្រជាជាតិជាច្រើន។6យើងនឹងធ្វើឲ្យអ្នកបានចម្រុងចម្រើនឡើង ហើយយើងនឹងធ្វើឲ្យអ្នកក្លាយជាប្រជាជាតិជាច្រើន ហើយស្ដេចនឹងកើតចេញពីអ្នក។
7យើងនឹងចងសម្ពន្ធមេត្រីរបស់យើង រវាងយើងនិងអ្នក ព្រមទាំងជាមួយពូជពង្សរបស់អ្នកដែលមកតាមក្រោយអ្នក គ្រប់ទាំងតំណរតទៅ ដ្បិត សម្ពន្ធមេត្រីនេះស្ថិតស្ថេរ
នៅអស់កល្បជានិច្ច ឲ្យយើងបានធ្វើជាព្រះជាម្ចាស់របស់អ្នក និងពូជពង្សដែលនៅក្រោយអ្នក។8យើងនឹងប្រគល់ទឹកដីដែលអ្នកកំពុងរស់នៅនេះ ដល់អ្នក
និងដល់កូនចៅបន្ទាប់ពីអ្នក គឺទឹកដីកាណានទាំងអស់ សម្រាប់ជាសម្បត្តិដ៏នៅអស់កល្បជានិច្ច ហើយយើងនឹងធ្វើជាព្រះជាម្ចាស់របស់ពួកគេ»។
9បន្ទាប់មក ព្រះជាម្ចាស់មានបន្ទូលមកលោកអ័ប្រាហាំថា៖ «ចំណែកអ្នកវិញ អ្នកត្រូវកាន់តាមសម្ពន្ធមេត្រីរបស់យើង អ្នកនិងកូនចៅនៅបន្ទាប់ពីអ្នក
និងគ្រប់ទាំងតំណរបស់ពួកគេតទៅ។10នេះគឺជាសម្ពន្ធមេត្រីរបស់យើង ដែលអ្នកត្រូវកាន់តាម រវាងយើង និងអ្នក ព្រមទាំងពូជពង្សនៅបន្ទាប់ពីអ្នក
អ្នកត្រូវកាត់ស្បែកភេទប្រុសដែលនៅក្នុងចំណោមអ្នកទាំងអស់។11អ្នកត្រូវកាត់ស្បែកចុងលិង្គរបស់មនុស្សទាំងអស់ ហើយនេះគឺជាសញ្ញាសម្គាល់នៃសម្ពន្ធមេត្រីរវាងយើង
និងអ្នក។
12គ្រប់ទាំងភេទប្រុសទាំងអស់នៅក្នុងចំណោមអ្នកដែលមានអាយុប្រាំបីថ្ងៃ គឺមនុស្សគ្រប់ទាំងតំណរបស់អ្នក។ ការនេះ បូករួមទាំងអស់អ្នកដែលបានកើតនៅក្នុងគ្រួសារ
និងអស់អ្នកដែលបានទិញពីសាសន៍ដទៃដែលមិនមែនជាពូជពង្សរបស់អ្នក។13អស់អ្នកដែលកើតមកនៅក្នុងគ្រួសាររបស់អ្នក
និងអស់អ្នកដែលអ្នកបានទិញត្រូវតែកាត់ស្បែក។ ដូច្នេះ សម្ពន្ធមេត្រីរបស់យើងនឹងចងជាមួយអ្នក ដ្បិត សម្ពន្ធមេត្រីនេះ ស្ថិតស្ថេរនៅអស់កល្បជានិច្ច។14ប្រសិនបើ
បុរសមិនកាត់ស្បែកណាដែលមិនបានកាត់ស្បែកខាងសាច់ឈាម ចុងលិង្គរបស់គាត់ទេ ចូរកាត់កាល់គាត់ចេញពីមនុស្សរបស់គាត់ទៅ។
គាត់បានបំបែកសម្ពន្ធមេត្រីរបស់យើង»។
15ព្រះជាម្ចាស់មានបន្ទូលមកលោកអ័ប្រាហាំថា៖ «ចំណែក នាងសារ៉ាយ ភរិយារបស់អ្នក កុំហៅនាងថាសារ៉ាយទៀត។ ផ្ទុយទៅវិញ ត្រូវហៅនាងថាសារ៉ាវិញ។
16យើងនឹងឲ្យពរដល់នាង ហើយយើងនឹងឲ្យកូនប្រុសមួយដល់នាង។ យើងនឹងឲ្យពរដល់នាង ហើយនាងនឹងក្លាយជាម្ដាយនៃប្រជាជាតិជាច្រើន ស្ដេចរបស់ប្រជារាស្ត្រ
នឹងកើតចេញមកពីនាង»។
17ពេលនោះ លោកអប្រាហាំបានក្រាបចុះ ឱនមុខទៅដី ហើយបានសើច ហើយគាត់និយាយនៅក្នុងចិត្តរបស់គាត់ថា៖ «តើមនុស្សមានអាយុមួយរយឆ្នាំហើយ
អាចមានកូនបានដែរឬ? តើនាងសារ៉ា ដែលមានអាយុកៅសិបឆ្នាំហើយ អាចមានកូនបានដែរឬ?»18លោកអប្រាហាំទូលទៅព្រះជាម្ចាស់ថា៖ «ព្រះអង្គអើយ
សូមឲ្យអ៊ីស្មាអែលបានរស់នៅចំពោះព្រះអង្គទៅបានហើយ!»។
19ព្រះជាម្ចាស់មានបន្ទូលថា៖ «អត់ទេ គឺសារ៉ា ភរិយារបស់អ្នកទេ ដែលបង្កើតកូនប្រុសនោះ ហើយអ្នកត្រូវដាក់ឈ្មោះថា អ៊ីសាក។ យើងនឹងចងសម្ពន្ធមេត្រីជាមួយកូននោះ
ជាសម្ពន្ធមេត្រីដ៏នូវអស់កល្បជានិច្ចជាមួយនឹងពូជពង្សបន្ទាប់ពីគាត់ដែរ។20ចំណែកអ៊ីស្មាអែលវិញ យើងបានឮអ្នក។ មើល៍ យើងនឹងឲ្យពរដល់គាត់
ហើយនឹងធ្វើឲ្យគាត់បង្កើតផល ហើយបានចម្រើនច្រើនឡើងជាបរិបូរ។ គាត់នឹងធ្វើជាឪពុកនៃអ្នកដឹកនាំកុលសម្ព័ន្ធទាំងដប់ពីរ
ហើយយើងនឹងធ្វើឲ្យគាត់ក្លាយជាប្រជាជាតិមួយដ៏ធំ។21ប៉ុន្តែ សម្ពន្ធមេត្រីដែលយើងនឹងចងជាមួយអ៊ីសាក ជាកូនដែលសារ៉ាបានបង្កើតដល់អ្នកនៅឆ្នាំក្រោយនេះ»។


generated on Wed Mar 12 15:32:40 2025

22នៅពេលព្រះអង្គមានបន្ទូលជាមួយលោកចប់ ព្រះជាម្ចាស់យាងចេញពីលោកអប្រាហាំ។23បន្ទាប់មក លោកអប្រាហាំបានយកអ៊ីស្មាអែលកូនប្រុសរបស់គាត់
និងអស់អ្នកដែលបានកើតនៅក្នុងគ្រួសាររបស់គាត់ទាំងអស់ ព្រមទាំងអស់ដែលបានទិញដោយលុយ និងគ្រប់ទាំងប្រុសៗនៅក្នុងគ្រួសាររបស់លោកអប្រាហាំទាំងអស់
មកកាត់ស្បែកចុងលិង្គនៅថ្ងៃតែមួយនោះឯង ដូចព្រះជាម្ចាស់បានមានបន្ទូលទៅគាត់។
24លោកអប្រាហាំមានអាយុកៅសិបប្រាំបួនឆ្នាំ នៅពេលលោកកាត់ស្បែកចុងលិង្គរបស់គាត់។25អ៊ីស្មាអែលកូនប្រុសរបស់គាត់មានអាយុដប់បីឆ្នាំ
ពេលគាត់កាត់ស្បែកចុងលិង្គរបស់គាត់។26នៅថ្ងៃដដែលនោះ លោកអប្រាហាំ និងអ៊ីស្មាអែលកូនប្រុសរបស់គាត់កាត់ស្បែកទាំងពីរនាក់។
27ប្រុសៗទាំងអស់នៅក្នុងគ្រួសាររបស់គាត់ត្រូវបានកាត់ស្បែកជាមួយគាត់ រួមទាំងអស់អ្នកដែលកើតនៅក្នុងគ្រួសាររបស់គាត់
និងអស់អ្នកដែលបានទិញដោយលុយពីជនបរទេស។

ជំពូក ១៨

1ព្រះអម្ចាស់បានយាងមកឲ្យលោកអប្រាហាំឃើញនៅក្បែរនៅដើមជ្រៃលោកម៉ាមរ៉េ។
គឺក្នុងកាលដែលគាត់អង្គុយនៅច្រកទ្វារត្រសាលរបស់គាត់នៅក្នុងពេលថ្ងៃកំពុងពេញកម្ដៅ។2គាត់បានសម្លឹងមើល ហើយមើល៍
គាត់បានឃើញបុរសម្នាក់កំពុងឈរនៅទល់មុខគាត់។ ពេលគាត់បានឃើញពួកគេ គាត់បានរស់ទៅជួបពួកគេពីច្រកទ្វារត្រសាល ហើយក្រាបផ្ដាប់មុខទៅនឹងដី។
3គាត់ទូលថា៖ «ព្រះអម្ចាស់អើយ ប្រសិនបើ ទូលបង្គំគាប់ព្រះហឫទ័យដល់ព្រះអង្គ សូមមេត្តាកុំយាងហួស ដោយទុកចោលអ្នកបម្រើព្រះអង្គឡើយ។
4សូមឲ្យគេបានយកទឹកមកលាងព្រះបាទរបស់ព្រះអង្គ ហើយសម្រាកនៅក្រោមដើមឈើនេះសិនហើយ។5សូមឲ្យទូលបង្គំនាំអាហារបន្តិចបន្តួចមកថ្វាយ
ដើម្បីឲ្យព្រះអង្គបានសោយ។ បន្ទាប់មក ព្រះអាចយាងចេញពីទូលបង្គំបានហើយ ព្រោះព្រះអង្គបានយាងមកជួបអ្នកបម្រើព្រះអង្គរួចហើយ»។ ពួកគេឆ្លើយថា៖
«ចូរតាមសម្ដីរបស់អ្នកចុះ»។
6បន្ទាប់មក លោកអប្រាហាំទៅរកនាងសារ៉ាយ៉ាងលឿននៅក្នុងត្រសាល ហើយនិយាយថា៖ «ចូរប្រញាប់ឡើង យកម្សៅយ៉ាងម៉ដ្ឋបីរង្វាល់មក ច្របាច់វា
ហើយធ្វើជានំប៉័ង»។7បន្ទាប់មក លោកអប្រាហាំរត់ទៅឯអ្នកឃ្វាលសត្វ ហើយបានយកកូនគោ ដែលស្ទាវ ហើយល្អមួយ ហើយប្រគល់វាទៅឲ្យអ្នកបម្រើ
ហើយគាត់ក៏ប្រញាប់ទៅចម្អិនវា។8គាត់បានយកខ្លាញ់ និងទឹកដោះគោ ព្រមទាំងសាច់កូនគោដែលគេបានចម្អិននោះ មកដាក់នៅមុខរបស់ពួកគេ
ហើយគាត់ឈរនៅក្បែរពួកគេនៅក្នុងដើមឈើ នៅពេលពួកគេកំពុងហូប។
9ពួកគេនិយាយទៅកាន់គាត់ថា៖ «តើសារ៉ាភរិយារបស់លោកនៅឯណា?» គាត់ឆ្លើយថា៖ «នៅក្នុងត្រសាលឯណោះ»។10ព្រះអង្គមានបន្ទូលថា៖
«យើងនឹងត្រឡប់មកវិញជាប្រាកដនៅក្នុងរដូវលំហើយ ហើយមើល៍ សារ៉ាយភរិយារបស់លោកនឹងមានកូនប្រុសមួយ»។ នាងសារ៉ាយក៏កំពុងស្ដាប់នៅមាត់ទ្វារក្នុងត្រសាល
ដែលនៅពីក្រោយគាត់។
11ឥឡូវ លោកអប្រាហាំ និងនាងសារ៉ាមានវ័យចាស់ណាស់ហើយ នាងសារ៉ាមានអាយុហួសក្នុងការមានកូនហើយ។12នាងសារ៉ាសើចនឹងខ្លួនឯង
ហើយនិយាយមកកាន់ខ្លួននាងថា៖ «ខ្ញុំចាស់ចំណាស់នេះហើយ ស្វាមីខ្ញុំក៏ចាស់ណាស់ដែរ យើងខ្ញុំនៅមានតម្រេកអ្វីទៀត?»
13ព្រះអម្ចាស់មានបន្ទូលទៅលោកអប្រាហាំថា៖ «ហេតុអ្វីបានជានាងសារ៉ាសើច ហើយនិយាយថា តើខ្ញុំអាចមានកូនបាន ក្នុងការដែលខ្ញុំចាស់ហើយនោះ?
14តើមានអ្វីដែលពិបាកពេកសម្រាប់ព្រះអម្ចាស់ទេ? នៅពេលកំណត់ យើងនឹងត្រឡប់មកឯអ្នកវិញ គឺនៅក្នុងរដូវលំហើយ។ នៅឆ្នាំក្រោយ នៅក្នុងរដូវនេះ
នាងសារ៉ានឹងមានកូនប្រុសមួយ»។15បន្ទាប់មក នាងសារ៉ាបដិសេធវា ហើយនិយាយថា៖ «ខ្ញុំម្ចាស់មិនបានសើចទេ» ដ្បិត នាងខ្លាច។ គាត់ឆ្លើយថា៖ «អត់ទេ
នាងបានសើចមែន»។
16បន្ទាប់មក ពួកគេបានក្រោកឡើងដើម្បីចាកចេញហើយសម្លឹងមើលទៅក្រុងសូដុម។ លោកអប្រាហាំបានចេញទៅជាមួយពួកគេ ដើម្បីជូនដំណើរពួកគេ។17ប៉ុន្តែ
ព្រះអម្ចាស់មានបន្ទូលថា៖ «តើគួរឲ្យយើងលាក់ជាមួយលោកពីអ្វីដែលខ្ញុំនឹងធ្វើដែរឬទេ?18លោកអប្រាហាំនឹងក្លាយជាប្រជាជាតិមួយដ៏ធំ ហើយខ្លាំងពូកែ
ហើយប្រជាជាតិទាំងអស់នៅលើផែនដីនឹងបានពរដោយសារគាត់។19ដ្បិត យើងបានជ្រើសរើសគាត់ ដើម្បីឲ្យគាត់បានបង្រៀនដល់កូន
និងគ្រួសាររបស់គាត់ដែលមកតាមក្រោយឲ្យកាន់តាមផ្លូវរបស់ព្រះអម្ចាស់ ឲ្យប្រព្រឹត្តសេចក្ដីសុចរិត និងយុត្តធម៌ ដើម្បីឲ្យព្រះអម្ចាស់បានសម្រេចដល់លោកអប្រាហាំ តាម
សេចក្ដីដែលព្រះអង្គបានមានបន្ទូលនឹងគាត់»។
20បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលថា៖ «ដោយព្រោះមានសម្រែកយំទាស់នឹងក្រុងសូដុម និងក្រុងកូម៉ូរ៉ាខ្លាំងពេក
ហើយបាបរបស់ពួកគេក៏ខ្លាំងណាស់ដែរ21យើងនឹងចុះទៅទីនោះ ហើយមើលពីសម្រែកទាស់នឹងក្រុងនោះបានមកដល់យើង
ថាតើពួកគេពិតជាបានធ្វើការនោះមែនឬយ៉ាងណា។ ប្រសិនបើ មិនបានធ្វើទេ យើងនឹងបានដឹង»។
22ដូច្នេះ បុរសទាំងនោះបានចេញពីទីនោះ ហើយធ្វើដំណើរឆ្ពោះទៅក្រុងសូដុម ប៉ុន្តែ លោកអប្រាហាំឈរនៅចំពោះព្រះអម្ចាស់។23បន្ទាប់មក
លោកអប្រាហាំបានចូលទៅជិត ហើយទូលថា៖ «តើព្រះអង្គបំផ្លាញមនុស្សសុចរិត ជាមួយនឹងមនុស្សទុច្ចរិតមែនឬ?
24ប្រហែលជាមានមនុស្សសុចរិតហាសិបនាក់នៅក្នុងទីក្រុង។ តើព្រះអង្គនឹងបំផ្លាញទីក្រុងនោះចោល
ហើយមិនទុកកន្លែងសម្រាប់មនុស្សដែលសុចរិតហាសិបអ្នកដែលនៅទីនោះដែរទេឬ?25ព្រះអង្គមិនធ្វើដូច្នោះទេ
ព្រះអង្គមិនសម្លាប់មនុស្សសុចរិតជាមួយមនុស្សទុច្ចរិតឡើយ ដូច្នេះមនុស្សសុចរិតនឹងទទួលរងដូចមនុស្សទុច្ចរិតដែរ។ ព្រះអង្គមិនធ្វើដូច្នោះទេ!
តើចៅក្រមរបស់ផែនដីទាំងមូលមិនធ្វើអ្វីដែលយុត្តិធម៌ទេឬ?»26ព្រះអម្ចាស់មានបន្ទូលថា៖ «ប្រសិនបើ យើងរកឃើញមនុស្សសុចរិតហាសិបនាក់នៅក្នុងក្រុងសូដុម
យើងនឹងមិនបំផ្លាញទីនោះទេ ដោយយល់ដល់ពួកគេ»។
27លោកអប្រាហាំឆ្លើយ ហើយទូលថា៖«មើល៍ សូមអត់ទោសដល់ទូលបង្គំផង ដែលទូលបង្គំគ្រាន់តែជាធូលីដី និងជាផេះ ហ៊ាននិយាយតវ៉ាជាមួយព្រះអម្ចាស់!
28ចុះបើមានមនុស្សសុចរិតតែសែសិបប្រាំនាក់? តើព្រះអង្គនឹងបំផ្លាញទីក្រុងទាំងមូលដោយខ្វះតែប្រាំនាក់មែនទេ?» នោះព្រះអង្គមានបន្ទូលថា៖ «យើងមិនបំផ្លាញទេ
ប្រសិនបើមានសែសិបប្រាំនាក់»។
29គាត់ទូលព្រះអង្គសារជាថ្មីទៀតថា៖ «ចុះបើមានតែសែសិបនាក់នៅទីនោះ?» ព្រះអង្គតបថា៖ «យើងនឹងមិនបំផ្លាញទេ ដោយព្រោះអ្នកសែសិបនាក់នោះ»។
30គាត់ទូលទៀតថា៖ «សូមកុំព្រះពិរោធនឹងទូលបង្គំធ្វើអ្វី ព្រះអម្ចាស់អើយ ដែលទូលបង្គំនិយាយដូច្នេះ។ ប្រហែលជាមានមនុស្សសុចរិតតែសាមសិបនាក់នៅទីនោះ»។
ព្រះអង្គតបថា៖ «មើល៍ យើងមិនបំផ្លាញក្រុងនោះទេ ប្រសិនបើ យើងរកឃើញមនុស្សសុចរិតសាមសិបនាក់នៅទីនោះ»។31គាត់ទូលទៀតថា៖ «មើល៍
សូមអត់ទោសដល់ទូលបង្គំផងដែលហ៊ានទូលទៅព្រះអម្ចាស់បែបនេះ! ប្រហែលជាមានមនុស្សសុចរិតតែម្ភៃនាក់នៅទីនោះ»។ ព្រះអង្គតបថា៖
«យើងមិនបំផ្លាញទីក្រុងនោះទេ ដោយយល់ដល់អ្នកម្ភៃនាក់នោះ»។
32គាត់ទូលថា៖ «សូមព្រះអង្គកុំព្រះពិរោធនឹងទូលបង្គំធ្វើអ្វី ព្រះអម្ចាស់អើយ ទូលបង្គំសូមនិយាយបែបនេះជាលើកចុងក្រោយ។
ប្រហែលជារកឃើញមនុស្សសុចរិតតែដប់នាក់ទេ នៅទីនោះ»។ បន្ទាប់មក ព្រះអង្គមានបន្ទូលថា៖ «យើងមិនបំផ្លាញវាទេ ដោយយល់ដល់អ្នកទាំងដប់នាក់នោះ»។
33ព្រះអម្ចាស់បានយាងចេញភ្លាម បន្ទាប់ពីព្រះអង្គបានបញ្ចប់ការសន្ទនាជាមួយលោកអប្រាហាំ ហើយលោកអប្រាហាំក៏ត្រឡប់ទៅផ្ទះរបស់គាត់វិញ។

ជំពូក ១៩


generated on Wed Mar 12 15:32:40 2025

## ជំពូក ២០

1ទេវតាទាំងពីរបានមកដល់ក្រុងសូដុមនៅពេលល្ងាច លោកឡុតកំពុងអង្គុយនៅទ្វារក្រុងសូដុម។ លោកឡុតបានឃើញទេវតាទាំងពីរ ក៏ក្រោកឡើងទៅជួបពួកគេ
ហើយក្រាបចុះមុខទល់ដី។2គាត់និយាយថា៖ «សូមលោកម្ចាស់ សូមមេត្តាចូរទៅផ្ទះខ្ញុំ ជាអ្នកបម្រើរបស់លោក ហើយស្នាក់នៅទីមួយយប់សិន
ព្រមតាំងបានលាងជើងជូនដល់លោកផង។ បន្ទាប់មក លោកអាចក្រោកឡើងពីព្រលឹម ហើយបន្តដំណើរទៅមុខទៀតចុះ»។ ពួកគេឆ្លើយថា៖ «អត់ទេ
យើងនឹងគេងនៅតាមទីធ្លាក្រុងយប់នេះ»។3ប៉ុន្តែ លោកឡុតអង្វរពួកគេជាខ្លាំង ពួកគេក៏ទៅជាមួយគាត់ ហើយចូលទៅក្នុងផ្ទះរបស់គាត់។ គាត់បានចម្អិនអាហារ
ហើយដុតនំបុ័ងឥតមេ ហើយពួកគេក៏ហូប។
4ប៉ុន្តែ មុនពេលពួកគេគេង ពួកប្រុសៗនៅក្នុងទីក្រុង គឺពួកប្រុសៗនៅក្នុងទីក្រុងសូដុម បានព័ទ្ធជុំវិញផ្ទះ ទាំងក្មេងទាំងចាស់ ប្រុសៗទាំងនោះមកពីគ្រប់ទិសទីនៃទីក្រុង។
5ពួកគេបានហៅលោកឡុត ហើយនិយាយទៅគាត់ថា៖ «តើបុរសដែលមកឯលោកនៅឯណា? ចូរនាំពួកគេចេញមកឲ្យពួកយើង ដើម្បីឲ្យយើងបានគេងជាមួយពួកគេ»។
6ដូច្នេះ លោកឡុតបានចេញពីទ្វារទៅរកពួកគេ ហើយបិទទ្វារនៅក្រោយខ្នងគាត់។7គាត់និយាយថា៖ «ខ្ញុំសូមអង្វរ បងប្អូនខ្ញុំអើយ សូមកុំប្រព្រឹត្តអាក្រក់អី។8មើល៍
ខ្ញុំមានកូនស្រីពីរនាក់ មិនទាន់គេងជាមួយបុរសណាឡើយ។ ខ្ញុំសូមអង្វរអ្នកទាំងអស់គ្នា ចូរនាំពួកគេទៅជាមួយអ្នករាល់គ្នាទៅ
ហើយអ្នករាល់គ្នាអាចធ្វើអ្វីដល់ពួកគេតាមតែអ្វីដែលអ្នករាល់គ្នាគិតថាល្អនៅចំពោះភ្នែករបស់អ្នករាល់គ្នាចុះ។ តែសូមកុំធ្វើអ្វីជាមួយបុរសពីរនាក់នេះឡើយ
ព្រោះពួកគេបានមកជ្រកនៅក្រោមដំបូលផ្ទះរបស់ខ្ញុំ»។
9ពួកគេនិយាយថា៖ «ថយចេញទៅ!» ហើយពួកគេក៏បន្តទៀតថា៖ «ម្នាក់នេះជាជនបរទេសមករស់នៅទីនោះសោះ ហើយឥឡូវ វាបានក្លាយជាចៅក្រមរបស់យើងហើយ!
ឥឡូវនេះ យើងនឹងប្រព្រឹត្តអាក្រក់ជាមួយអ្នកខ្លាំងជាងពួកគេទេ»។ ពួកគេបានរុញយ៉ាងខ្លាំងទាស់នឹងលោកឡុត ហើយចូលមកជិតដើម្បីទម្លោះទ្វារ។
10ប៉ុន្តែ បុរសពីនាក់នោះបានលូកដៃរបស់ពួកគេ ហើយបាននាំលោកឡុតចូលមកក្នុងផ្ទះជាមួយពួកគេ ហើយបិទទ្វារវិញ។11បន្ទាប់មក
ទេវតាបានពួកប្រុសៗដែលនៅមាត់ទ្វារផ្ទះឲ្យខ្វាក់ភ្នែក ទាំងក្មេងទាំងចាស់ ដើម្បីឲ្យពួកគេអស់កម្លាំង នៅពេលពួកគេព្យាយាមរកទ្វារ។
12បន្ទាប់មកបុរសទាំងពីរនាក់បាននិយាយទៅកាន់លោកឡុតថា៖ «តើលោកមានអ្នកផ្សេងទៀតនៅទីនេះទេ? កូនប្រសារប្រុសៗ កូនៗ និងកូនស្រីៗរបស់លោក
និងអ្នកផ្សេងៗដែលអ្នកមាននៅក្នុងទីក្រុងនេះ ចូរយកពួកគេចេញពីទីនេះ។13ដ្បិត យើងនឹងបំផ្លាញទីនេះហើយ ដោយសារការចោទប្រកាន់ទាស់នឹងទីក្រុងនេះ
នៅចំពោះព្រះអម្ចាស់បានឮយ៉ាងខ្លាំងបានជាព្រះជាម្ចាស់ចាត់យើងមកឲ្យបំផ្លាញទីក្រុងនេះ»។
14លោកឡុតបានចេញទៅ ហើយបានហៅកូនប្រសារប្រុសៗរបស់គាត់ គឺពួកប្រុសៗដែលបានរៀបការជាមួយកូនស្រីៗរបស់លោក ហើយប្រាប់ថា៖ «ចូរចេញពីទីនេះ
ជាប្រញាប់ ដ្បិត ព្រះអម្ចាស់នឹងបំផ្លាញទីក្រុងនេះហើយ»។ ប៉ុន្តែ កូនប្រសារប្រុសៗរបស់លោក គិតថាគាត់និយាយលេង។15នៅពេលព្រឹកព្រលឹម
ទេវតាទាំងពីរបានបង្ខំលោកឡុត ដោយនិយាយថា៖ «ចូរចេញទៅ យកភរិយា និងកូនស្រីទាំងពីររបស់លោកដែលនៅទីនេះចេញទៅ
ដើម្បីកុំឲ្យលោកត្រូវបំផ្លាញជាមួយទីក្រុងដោយដោយសារការជំនុំជម្រះឡើយ»។
16ប៉ុន្តែ គាត់នៅបង្អែបង្អង់។ ដូច្នេះ ទេវតាទាំងពីរបានចាប់ដៃលោក ហើយដៃភរិយារបស់លោក ព្រមទាំងដៃកូនស្រីទាំងពីររបស់លោក
ដោយសារព្រះអម្ចាស់ផ្តល់មេត្តាដល់ពួកគេ។ ទេវតាទាំងពីរបាននាំពួកគេចេញ ហើយនាំចេញទៅទុកនៅខាងក្រៅក្រុង។17បន្ទាប់មក ទេវតាទាំងពីរបាននាំពួកគេចេញ
ហើយមានម្នាក់និយាយថា៖ «ចូររត់ដើម្បីឲ្យអ្នកបានរស់! កុំមើលក្រោយឡើយ ឬ ស្នាក់នៅទីវាលណាមួយឡើយ។ ចូររត់គេចទៅឯភ្នំ ដើម្បីកុំឲ្យអ្នកត្រូវបំផ្លាញឡើយ»។
18លោកឡុតនិយាយទៅទេវតាទាំងពីរថា៖ «អត់ទេ លោកម្ចាស់អើយ!19ខ្ញុំជាអ្នកបម្រើរបស់លោកម្ចាស់បានទទួលព្រះគុណនៅចំពោះលោកម្ចាស់ ហើយ
លោកម្ចាស់បានផ្តល់ក្តីមេត្តាយ៉ាងធំក្នុងការសង្គ្រោះជីវិតរបស់យើងខ្ញុំ ប៉ុន្តែ ខ្ញុំមិនអាចរត់គេចទៅឯភ្នំបានទេ ព្រោះគ្រោះមហន្តរាយនឹងបំផ្លាញខ្ញុំ និងខ្ញុំនឹងស្លាប់ហើយ។
20មើល៍ ទីក្រុងនៅទីនោះ វាជិតល្មមដែលអាចរត់ទៅដល់ ហើយវាក៏តូចដែរ។ សូមឲ្យខ្ញុំរត់គេចទៅទីនោះចុះ (តើវាមិនតូចទេឬអី?) ហើយខ្ញុំនឹងមានជីវិតរស់នៅទីនោះ»។
21ទេវតាទាំងពីរនិយាយទៅគាត់ថា៖ «មិនអីទេ ខ្ញុំយល់ព្រមតាមសំណើនេះ ថាយើងនឹងមិនបំផ្លាញក្រុងដែលលោកបាននិយាយទេ។22ប្រញាប់ឡើង!
ចូររត់គេចចេញពីទីនេះទៅ ព្រោះយើងមិនអាចធ្វើអ្វីបានឡើយ ទាល់តែលោកទៅដល់ទីនោះសិន»។ ហេតុដូច្នេះហើយបានជាគេហៅទីក្រុងនោះថា សូអារ។
23ពេលលោកឡុតទៅដល់ក្រុងសូអារ ថ្ងៃបានរះឡើងមកលើផែនដី។24បន្ទាប់មក ព្រះអម្ចាស់បានធ្វើឲ្យភ្លៀងធ្លាក់ជាស្ពាន់ធ័រ និងភ្លើងធ្លាក់ចុះមកលើក្រុងសូដុម
និងក្រុងកូម៉ូរ៉ាពីព្រះអម្ចាស់មកគឺធ្លាក់ចេញពីលើមេឃមក។25ព្រះអង្គបំផ្លាញទីក្រុងទាំងនោះ ហើយគ្រប់ទាំងទីវាល ហើយនិងប្រជាជនដែលរស់នៅទីក្រុងនោះ
ហើយទីវាលដែលមានស្មៅដុះដែរ។
26ប៉ុន្តែ ភរិយារបស់លោកឡុត ដែលដើរតាមក្រោយគាត់ បានសម្លឹងក្រោយ ហើយនាងបានក្លាយជាសសរអំបិល។27លោកអប្រាហាំក្រោកតាំងពីព្រលឹម
ហើយចេញទៅកន្លែងដែលគាត់បានឈរជាមួយនៅចំពោះព្រះអម្ចាស់។28គាត់បានសម្លឹងមើលទៅឯក្រុងសូដុម និងក្រុងកូម៉ូរ៉ា
និងសម្លឹងមើលទៅឯទីវាលនៅក្នុងទឹកដីនោះ។ គាត់បានសម្លឹងមើល ឃើញផ្សែងហុយឡើងពីដីដូចជាផ្សែងរបស់គុកភ្លើង។
29ដូច្នេះ នៅពេលព្រះជាម្ចាស់បំផ្លាញទីក្រុងទាំងប៉ុន្មាន នៅទីវាល ព្រះជាម្ចាស់បាននឹងចាំពីលោកអប្រាហាំ។ ព្រះអង្គបានបញ្ជូនលោកឡុតចេញពីគ្រោះមហន្តរាយ
នៅពេលព្រះអង្គបំផ្លាញទីក្រុងផ្សេងៗ ដែលលោកឡុតបានរស់នៅ។
30ប៉ុន្តែ លោកឡុតបានឡើងទៅក្រុងសូអារ ទៅរស់នៅតាមតំបន់ភ្នំ ជាមួយកូនស្រីពីរនាក់ ដោយព្រោះគាត់មានការភ័យខ្លាចក្នុងការរស់នៅក្នុងក្រុងសូអារ។ ដូច្នេះ
គាត់និងកូនស្រីទាំងពីររបស់គាត់ បានទៅរស់នៅក្នុងរូងភ្នំវិញ ។
31កូនស្រីច្បងនិយាយទៅកូនស្រីប្អូនថា៖ «ឪពុករបស់យើងចាស់ហើយ ហើយគ្មានប្រុសណាមកគេងជាមួយយើង ដូចគេដូចឯងនៅក្នុងលោកនេះទេ។32មក
តោះយើងទៅបង្អកស្រាឪពុករបស់យើង ហើយយើងនឹងគេងជាមួយគាត់ ដូច្នេះយើងអាចបន្តពូជឪពុករបស់យើង»។33ដូច្នេះ
ពួកគេបានធ្វើឲ្យឪពុករបស់ពួកគេស្រវឹងនៅយប់នោះ។ បន្ទាប់មក កូនស្រីច្បងបានចូលទៅក្នុង ហើយគេងជាមួយឪពុងរបស់នាង
ហើយគាត់មិនដឹងថានាងចូលទៅគេងជាមួយគាត់នៅពេលណា ឬពេលណានាងក្រោកឡើងទេ។
34នៅថ្ងៃបន្ទាប់ បងស្រីច្បងនិយាយទៅកាន់ប្អូនស្រីពៅថា៖ «សូមស្តាប់ យប់មិញ បងបានទៅគេងជាមួយឪពុករួចហើយ។ តោះ យើងធ្វើឲ្យគាត់ស្រវឹងនៅយប់នេះទៀត
ហើយអូនត្រូវទៅក្នុងហើយគេងជាមួយគាត់ ដើម្បីឲ្យយើងអាចបន្តពូជពីឪពុករបស់យើង»។35ដូច្នេះ ពួកគេបានធ្វើឲ្យឪពុករបស់ពួកគេស្រវឹងនៅយប់នោះ
ហើយប្អូនស្រីពៅបានចូលទៅ ហើយគេងជាមួយគាត់។ គាត់មិនដឹងពេលណានាងគេង ឬពេលណានាងចេញពីគាត់នោះទេ។
36ដូច្នេះ កូនស្រីទាំងពីររបស់លោកឡុតក៏មានកូនដោយសារឪពុករបស់ពួកគេ។37កូនស្រីច្បងបង្កើតបានកូនប្រុសមួយ ហើយដាក់ឈ្មោះថា ម៉ូអាប់។ គាត់បានក្លាយជា
បុព្វបុរសរបស់ជនជាតិម៉ូអាប់សព្វថ្ងៃនេះ។38ចំណែក ប្អូនស្រីពៅក៏បង្កើតបានកូនប្រុសមួយដែរ ហើយ ដាក់ឈ្មោះកូននោះថា បេន អាំមី។ គាត់បានក្លាយជាបុព្វបុរសរបស់
ជនជាតិអាំម៉ូនសព្វថ្ងៃនេះ។

## ជំពូក ២០

1លោកអប្រាហាំបានធ្វើដំណើរពីទីនោះ ឆ្ពោះទៅទឹកដីណេកិប ហើយគាត់រស់នៅចន្លោះក្រុងកាដេស និងក្រុងស៊ើរ។ បន្ទាប់មក គាត់បានទៅនៅក្រុង
កេរ៉ាក្នុងនាមជាជនបរទេស។2លោកអប្រាហាំនិយាយទាក់ទងនឹងភរិយារបស់គាត់ថា៖ «នាងជាប្អូនស្រីរបស់ខ្ញុំ»។ ដូច្នេះ ព្រះបាទអប៊ីម៉ាឡិច ជាស្ដេចនៅក្រុងកេរ៉ា បាន
ចាត់អ្នកបម្រើឲ្យទៅ ហើយយកនាងសារ៉ាមក។3ប៉ុន្តែ ព្រះជាម្ចាស់បានមកជួបព្រះបាទអប៊ីម៉ាឡិចនៅក្នុងសុបិនយប់នោះ ដោយមានបន្ទូលថា៖ «មើល អ្នកនឹងត្រូវស្លាប់
ដោយព្រោះស្ត្រីដែលអ្នកបានយកមក ដ្បិតនាងជាភរិយារបស់គេទេ»។


generated on Wed Mar 12 15:32:40 2025

4ព្រះបាទអប៊ីម៉ាឡិចមិនទាន់បានចូលទៅជិតនាងនៅឡើយទេ ហើយស្ដេចបានមានបន្ទូលថា៖ «ព្រះអម្ចាស់អើយ តើព្រះអង្គសម្លាប់ សូម្បីតែប្រជាជាតិសុចរិត?
5តើមិនមែនគាត់ខ្លួនឯងទេឬអីដែលនិយាយមកទូលបង្គំថា នាងជាប្អូនស្រីរបស់ខ្ញុំ? សូម្បីតែនាងខ្លួនឯងផ្ទាល់និយាយថា គាត់គឺជាបងប្រុសរបស់ខ្ញុំ។
ទូលបង្គំបានធ្វើការនេះដោយស្មោះត្រង់ចេញពីចិត្តរបស់ទូលបង្គំ និងពីដៃរបស់អ្នកដែលឥតកំហុស»។
6បន្ទាប់មក ព្រះជាម្ចាស់មានបន្ទូលទៅស្ដេចនៅក្នុងសុបិនថា៖ «ពិតមែនហើយ យើងក៏ដឹងដែរថា ដួងចិត្តរបស់ទ្រង់ស្មោះត្រង់ក្នុងការធ្វើការនេះ
ហើយយើងក៏បានការពារទ្រង់មិនឲ្យធ្វើបាបទាស់នឹងយើងដែរ។ ហេតុដូច្នេះហើយ បានជាយើងហាមមិនឲ្យអ្នកប៉ះពាល់នាងឡើយ។7ដូច្នេះ
ចូរប្រគល់នាងទៅស្វាមីរបស់នាងវិញចុះ ដ្បិត គាត់គឺជាព្យាការីម្នាក់។ គាត់នឹងអធិស្ឋានឲ្យអ្នក ហើយអ្នកនឹងបានរស់។ ប៉ុន្តែ ប្រសិនបើ ទ្រង់មិនប្រគល់នាងឲ្យគាត់វិញទេ
ចូរដឹងថា ទ្រង់និងអស់អ្នកដែលនៅជាមួយទ្រង់ស្លាប់»។
8ព្រះបាទអប៊ីម៉ាឡិចបានក្រោកតាំងពីព្រលឹម ហើយកោះហៅអ្នកបម្រើរបស់ស្ដេចទាំងអស់មកគាល់ព្រះអង្គ។ ព្រះអង្គបានប្រាប់ការទាំងអស់នេះទៅកាន់ពួកគេ
ហើយពួកគេមានការភ័យខ្លាចជាខ្លាំង។9បន្ទាប់មក ព្រះបាទអប៊ីម៉ាឡិចបានហៅលោកអប្រាហាំមក ហើយមានរាជឱង្ការទៅគាត់ថា៖
«ហេតុអ្វីបានជាលោកធ្វើដូច្នេះជាមួយយើង? តើយើងបានធ្វើបាបអ្វីដល់លោក បានជាលោកនាំយើង និងអាណាចក្ររបស់យើងទៅធ្វើបាបយ៉ាងធំដូច្នេះ?
អ្វីដែលលោកបានធ្វើចំពោះយើងនេះ គឺជាអ្វីដែលលោកមិនគួរធ្វើទេ»។
10ព្រះបាទអប៊ីម៉ាឡិចមានបន្ទូលទៅកាន់លោកអប្រាហាំថា៖ «តើលោកមានគោលបំណងអ្វីបានជាធ្វើការនេះ?11លោកអប្រាហាំទូលថា៖ «ដោយព្រោះទូលបង្គំគិតថា
ប្រហែលជាគ្មានការកោតខ្លាចព្រះទេនៅទីនេះ ហើយថា គេនឹងសម្លាប់ទូលបង្គំ ដោយសារតែភរិយាទូលបង្គំមិនខាន។12ម្យ៉ាងវិញទៀត នាងគឺជាប្អូនស្រីរបស់ទូលបង្គំមែន
នាងគឺជាកូនស្រីរបស់ឪពុកទូលបង្គំ ប៉ុន្តែមិនមែនជាកូនស្រីម្ដាយរបស់ទូលបង្គំទេ ហើយទូលបង្គំបានរៀបការជាមួយនាង។
13នៅពេលដែលព្រះជាម្ចាស់បានឲ្យទូលបង្គំចាកចេញពីផ្ទះឪពុករបស់ទូលបង្គំហើយធ្វើដំណើរចេញពីកន្លែងមួយទៅកន្លែងមួយ ទូលបង្គំបានប្រាប់នាងថា៖
«អូនត្រូវបង្ហាញពីភាពស្មោះត្រង់ក្នុងនាមជាភរិយារបស់បង គឺនៅទីណាដែលយើងទៅ សូមប្រាប់គេថា៖ «គាត់ជាបងប្រុសរបស់ខ្ញុំ»។14បន្ទាប់មក
ព្រះបាទអប៊ីម៉ាឡិចបានយកចៀម និងគោ ព្រមទាំងអ្នកបម្រើប្រុសស្រីជាច្រើន ហើយប្រគល់ពួកគេឲ្យទៅលោកអប្រាហាំ។ បន្ទាប់មក ព្រះអង្គបានប្រគល់នាងសារ៉ា
ភរិយារបស់លោកអប្រាហាំទៅគាត់វិញ។
15ព្រះបាទអប៊ីម៉ាឡិចមានរាជឱង្ការថា៖ «មើល៍ ទឹកដីរបស់យើងនៅចំពោះលោកហើយ។16ចូរនៅកន្លែងណាតាមតែលោកចូលចិត្តចុះ»។
ព្រះអង្គមានរាជឱង្ការទៅនាងសារ៉ាថា៖ «មើល៍ យើងប្រគល់ដល់បងប្រុសដែលជាស្វាមីរបស់នាងប្រាក់ចំនួនមួយពាន់តម្លឹង។
ដើម្បីគ្រប់បាំងកំហុសដែលបានធ្វើទាស់នឹងនាងនៅក្នុងភ្នែករបស់មនុស្សគ្រប់គ្នាដែលនៅជាមួយនាង និងនៅចំពោះមុខរបស់មនុស្សគ្រប់គ្នា
អ្នកមិនបានបាត់បង់កិត្តិយសអ្វីឡើយ»។
17លោកអប្រាហាំអធិស្ឋានទៅព្រះជាម្ចាស់ ហើយព្រះជាម្ចាស់បានប្រោសព្រះបាទអប៊ីម៉ាឡិច មហេសីរបស់ព្រះអង្គ និងអ្នកបម្រើប្រុសស្រី
ដើម្បីឲ្យពួកគេបានបង្កើតកូនចៅបាន។18ដ្បិត ព្រះអម្ចាស់បានធ្វើឲ្យស្ត្រីទាំងអស់នៅក្នុងព្រះរាជវង្សរបស់ព្រះបាទអប៊ីម៉ាឡិចទាំងមូល ក្លាយទៅជាស្ត្រីអារ ព្រោះតែនាង
សារ៉ាជាភរិយារបស់លោកអប្រាហាំ។

## ជំពូក ២១

1ព្រះអម្ចាស់យកព្រះទ័យទុកដាក់ជាមួយនាងសារ៉ា ដូចដែលព្រះអង្គបានមានបន្ទូលថាព្រះអង្គនឹងធ្វើ ហើយព្រះអម្ចាស់បានធ្វើសម្រាប់នាងសារ៉ា
ដូចដែលព្រះអង្គបានសន្យា។2នាងសារ៉ាមានផ្ទៃពោះ ហើយបង្កើតបានកូនប្រុសមួយឲ្យលោកអប្រាហាំក្នុងការដែលគាត់ចាស់ណាស់ហើយ
តាមពេលកំណត់ដែលព្រះអង្គបានមានបន្ទូលជាមួយគាត់។3លោកអប្រាហាំដាក់ឈ្មោះកូនប្រុសនោះថា អ៊ីសាក។
4លោកអប្រាហាំបានកាត់ស្បែកអ៊ីសាកកូនប្រុសរបស់គាត់ នៅពេលគាត់មានអាយុបានប្រាំបីថ្ងៃ ដូចដែលព្រះជាម្ចាស់បានបង្គាប់ដល់គាត់។
5លោកអប្រាហាំមានអាយុមួយរយឆ្នាំ ពេលគាត់មានអ៊ីសាកកូនប្រុសរបស់គាត់។6នាងសារ៉ានិយាយថា៖ «ព្រះជាម្ចាស់បានធ្វើឲ្យខ្ញុំសើច
មនុស្សគ្រប់គ្នាដែលឮនឹងសើចជាមួយខ្ញុំ»។7នាងក៏និយាយផងដែរថា៖ «តើអ្នកណាអាចនិយាយជាមួយលោកអប្រាហាំថា នាងសារ៉ាបំបៅកូន មិនត្រឹមតែប៉ុណ្ណោះ
ខ្ញុំបានបង្កើតកូនប្រុសមួយនៅក្នុងកាលដែលគាត់មានវ័យចាស់ណាស់ហើយដែរ»។
8កូនបានធំឡើង ហើយបានផ្ដាច់ដោះ លោកអប្រាហាំបានធ្វើពិធីជប់លៀងយ៉ាងធំនៅថ្ងៃដែលអ៊ីសាកបានផ្ដាច់ដោះនោះ។9នាងសារ៉ាឃើញកូននាងហាកាជនជាតិអេស៊ីប
ដែលនាងបានបង្កើតឲ្យលោកអប្រាហាំ កំពុងចំអកដល់កូននាង។
10ដូច្នេះ នាងបានប្រាប់លោកអប្រាហាំថា៖ «ចូរបណ្ដេញស្ត្រីបម្រើ និងកូនប្រុសរបស់នាងចេញទៅ ដើម្បីកូនប្រុសរបស់ស្រីបម្រើនោះ
មិនអាចគ្រងមរត៌កជាមួយអ៊ីសាកបានទេ»។11ការនេះ បានធ្វើឲ្យលោកអប្រាហាំពិបាកចិត្តយ៉ាងខ្លាំងដោយព្រោះកូនប្រុសរបស់គាត់។
12ប៉ុន្តែ ព្រះជាម្ចាស់មានបន្ទូលជាមួយលោកអប្រាហាំថា៖ «កុំពិបាកចិត្តដោយព្រោះក្មេង និងអ្នកបម្រើស្រីរបស់អ្នកឡើយ។
ចូរស្ដាប់តាមសម្ដីទាំងអស់ដែលនាងប្រាប់អ្នកពីបញ្ហាចុះ ពីព្រោះ តាមរយៈអ៊ីសាកដែលពូជពង្សរបស់ដែលនឹងស្នងត្រកូលពីនាក់។
13យើងនឹងធ្វើឲ្យកូនស្រីបម្រើបានក្លាយជាប្រជាជាតិមួយ ព្រោះគាត់គឺជាពូជពង្សរបស់អ្នក»។
14លោកអប្រាហាំបានក្រោកឡើងតាំងពីព្រលឹម យកនំប៉័ង និងថង់ស្បែកមានទឹក ហើយប្រគល់វាទៅឲ្យនាងហាកា ដាក់លើស្មារបស់នាង។
គាត់បានប្រគល់កូនប្រុសទៅនាង ហើយក៏ចាត់នាងឲ្យចេញទៅ។ នាងបានចាកចេញ ហើយបានវង្វេងនៅទីរហោស្ថានបៀរសេបា។
15នៅពេលទឹកនៅក្នុងថង់ស្បែកអស់ទៅ នាងបានទុកកូនប្រុសចោលនៅក្រោមដើមឈើតូចមួយ។16បន្ទាប់មក នាងក៏ចេញទៅ ហើយបានអង្គុយឆ្ងាយបន្តិចពីគាត់
ប្រហែលជាមួយសន្ទុះព្រួញ នាងនិយាយថា៖ «ខ្ញុំមិនចង់ឃើញកូនស្លាប់នៅចំពោះមុខខ្ញុំទេ»។ ក្នុងកាលដែលនាងអង្គុយទល់មុខនឹងកូននោះ នាងបានស្រែក
ហើយយំជាខ្លាំង។
17ព្រះជាម្ចាស់បានឮសម្លេងក្មេងនោះ ហើយទេវតារបស់ព្រះជាម្ចាស់បានហៅនាងហាកាពីស្ថានសួគ៌មក ហើយនិយាយទៅនាងថា៖ «ហាកាអើយ តើនាងមានរឿងអ្វី?
កុំខ្លាចអ្វីឡើយ ដ្បិត ព្រះជាម្ចាស់បានឮសម្លេងរបស់ក្មេងពីកន្លែងរបស់វាហើយ។18ចូរក្រោកឡើង លើកក្មេងនោះ ហើយលើកទឹកចិត្តគាត់ ដ្បិត
យើងនឹងធ្វើឲ្យគាត់ក្លាយជាប្រជាជាតិមួយដ៏ធំ»។
19បន្ទាប់មក ព្រះជាម្ចាស់បានបើកភ្នែករបស់នាង ហើយនាងបានឃើញអណ្ដូងទឹកមួយ។ នាងបានទៅ ហើយដងទឹកដាក់ក្នុងថង់ស្បែកដាក់ទឹក
ហើយបានឲ្យទៅក្មេងនោះផឹក។20ព្រះជាម្ចាស់គង់ជាមួយក្មេងនោះ ហើយគាត់បានធំឡើង។ គាត់រស់នៅក្នុងទីវាលរហោស្ថាន ហើយបានក្លាយជាអ្នកពូកែបាញ់ធ្នូ។
21គាត់រស់នៅក្នុងទីរហោស្ថាននៅក្នុងទឹកដីប៉ារ៉ាន ហើយម្ដាយរបស់គាត់បានការប្រពន្ធឲ្យគាត់ជាមួយនឹងជនជាតិអេស៊ីប។
22នៅគ្រានោះ ព្រះបាទអប៊ីម៉ាឡិច និងលោកភីកុល ជាមេទ័ពរបស់ព្រះអង្គពោលទៅលោកអប្រាហាំថា៖ «ព្រះជាម្ចាស់គង់ជាមួយលោកនៅក្នុងគ្រប់ការទាំងលោកធ្វើ។
23ឥឡូវនេះ ចូរស្បថជាមួយយើងនៅទីនេះក្នុងនាមព្រះជាម្ចាស់ថា អ្នកនឹងមិនប្រព្រឹត្តមិនត្រឹមត្រូវជាមួយយើង ឬជាមួយកូនចៅរបស់យើង
ឬជាមួយពូជពង្សរបស់យើងឡើយ។ ចូរប្រព្រឹត្តជាមួយយើង
និងជាមួយទឹកដីដែលលោកស្នាក់នៅដោយសម្ពន្ធមេត្រីដ៏ស្មោះត្រង់ដែលយើងបានប្រព្រឹត្តជាមួយនឹងលោកដែរ។24លោកអប្រាហាំពោលថា៖ «ខ្ញុំស្បថ»។


generated on Wed Mar 12 15:32:40 2025

[25]លោកអប្រាហាំបានប្តឹងព្រះបាទអប៊ីម៉ាឡិចទាក់ទងនឹងអណ្តូងទឹកដែលអ្នកបម្រើរបស់ព្រះបាទអប៊ីម៉ាឡិចបានយកពីគាត់។[26]ព្រះបាទអប៊ីម៉ាឡិចមានបន្ទូលថា៖
«យើងមិនដឹងថា អ្នកណាជាអ្នកធ្វើការនេះទេ។ ព្រោះលោកមិនបានប្រាប់ឲ្យយើងដឹងផង យើងមិនបានដឹងរហូតដល់សព្វថ្ងៃនេះ»។[27]ដូច្នេះ លោកអប្រាហាំបានយកចៀម
និងគោ ហើយថ្វាយដល់ព្រះបាទអប៊ីម៉ាឡិច ហើយអ្នកទាំងពីរបានធ្វើសម្ពន្ធមេត្រីនឹងគ្នា។
[28]បន្ទាប់មក លោកអប្រាហាំបានរៀបចំចៀមញីពីហ្វូងសត្វទុកដោយឡែក។[29]ព្រះបាទអប៊ីម៉ាឡិចមានបន្ទូលទៅលោកអប្រាហាំថា៖ «តើសត្វចៀមញីទាំងប្រាំពីរនេះ
មានន័យយ៉ាងដូចម្តេច ដែលលោកបានញែកដោយឡែកបែបនេះ?»[30]គាត់ឆ្លើយថា៖ «ព្រះអង្គនឹងទទួលចៀមញីទាំងប្រាំពីរនេះ ពីដៃរបស់ទូលបង្គំ
ដើម្បីធ្វើជាសាក្សីសម្រាប់ទូលបង្គំ ថាទូលបង្គំជាអ្នកជីកអណ្តូងនេះ»។
[31]ដូច្នេះ គាត់បានហៅកន្លែងនោះថា បៀរសេបា ព្រោះអ្នកទាំងពីរបានស្បថសច្ចានៅទីនោះ។[32]ពួកគេបានចងសម្ពន្ធមេត្រីនៅបៀរសេបា ហើយបន្ទាប់មកព្រះបាទអប៊ីម៉ាឡិច
និងលោកភីកុល ជាមេទ័ពរបស់ព្រះអង្គ បានត្រឡប់ទៅទឹកដីភីលីស្ទីនវិញ។
[33]លោកអប្រាហាំបានដាំដើមអំពិលមួយដើមនៅបៀរសេបា។ គាត់ថ្វាយបង្គំព្រះជាអម្ចាស់ ជាព្រះដ៏នូវអស់កល្បនៅទីនោះ។
[34]លោកអប្រាហាំនៅជាជនបរទេសនៅក្នុងទឹកដីភីលីស្ទីនជាច្រើនឆ្នាំ។

ជំពូក ២២

[1]បន្ទាប់ពីការទាំងនោះមក ព្រះជាម្ចាស់បានល្បងលលោកអប្រាហាំ។ ព្រះអង្គមានបន្ទូលទៅគាត់ថា៖ «អប្រាហាំ!» លោកអប្រាហាំទូលថា៖ «ទូលបង្គំនៅទីនេះ»។
[2]បន្ទាប់មក ព្រះជាម្ចាស់មានបន្ទូលថា៖ «ចូរយកកូនប្រុស គឺកូនប្រុសតែមួយគត់របស់អ្នក ជាកូនដែលអ្នកស្រឡាញ់ ហើយទៅទឹកដីម៉ូរីយ៉ា។
ថ្វាយគាត់ជាយញ្ញបូជាដុតនៅលើភ្នំមួយនៅទីនោះ ដែលយើងនឹងប្រាប់ដល់អ្នក»។[3]ដូច្នេះ លោកអប្រាហាំបានក្រោកតាំងពីព្រលឹម ចងកែបលារបស់គាត់
ហើយយកអ្នកបម្រើរបស់គាត់ពីរនាក់ទៅជាមួយគាត់ រួមទាំងអ៊ីសាកកូនប្រុសរបស់គាត់។ គាត់បានកាប់អុសដើម្បីជាតង្វាយដុត បន្ទាប់មក
រៀបចំចេញដំណើរទៅកន្លែងដែលបានប្រាប់ដល់គាត់។
[4]នៅថ្ងៃទីបី លោកអប្រាហាំបានងើយទៅលើ ហើយមើលឃើញកន្លែងនោះពីចម្ងាយ។[5]គាត់បាននិយាយទៅកាន់អ្នកបម្រើរបស់គាត់ថា៖
«ចូរនៅទីនេះជាមួយនឹងសត្វលាហើយ យើង និងក្មេងនឹងទៅទីនោះ។ យើងនឹងទៅថ្វាយបង្គំព្រះ ហើយនឹងត្រឡប់មករកអ្នកវិញ»។[6]បន្ទាប់មក
លោកអប្រាហាំបានយកអុសសម្រាប់ជាតង្វាយដុត ហើយដាក់វាឲ្យអ៊ីសាកកូនប្រុសរបស់គាត់លី។ គាត់បានកាន់ភ្លើង និងកាំបិតដោយដៃរបស់គាត់ផ្ទាល់ ហើយទាំងឪពុក
ទាំងកូនដើរទៅជាមួយគ្នា ហើយពួកគេទាំងពីរបានទៅជាមួយគ្នា។
[7]អ៊ីសាកនិយាយទៅកាន់លោកអប្រាហាំជាឪពុករបស់គាត់ថា៖ «ពុក» ហើយគាត់ឆ្លើយថា៖ «មានការអីកូន»។ គាត់និយាយថា៖ «មើល៍ នៅទីនេះ មានអុស និងភ្លើង ប៉ុន្តែ
តើកូនចៀមសម្រាប់ជាតង្វាយដុតនៅឯណា?»[8]លោកអប្រាហាំប្រាប់ថា៖ «កូនអើយ ព្រះជាម្ចាស់នឹងផ្គត់ផ្គង់កូនចៀមសម្រាប់ជាតង្វាយដុត»។ ដូច្នេះ
ពួកគេក៏បន្តដំណើរទៅមុខទៀត ជាមួយគ្នា។
[9]នៅពេលពួកគេទៅដល់កន្លែងដេលព្រះជាម្ចាស់បានប្រាប់ដល់គាត់ លោកអប្រាហាំបានសង់អាសនៈមួយនៅទីនោះ ហើយដាក់អុសនៅលើវា។ បន្ទាប់មក
ចងអ៊ីសាក់កូនប្រុសរបស់គាត់ ហើយផ្តេកគាត់នៅលើអាសនៈនៅលើអុសនោះ។[10]លោកអប្រាហាំបានលូកដៃរបស់គាត់យកកាំបិត ដើម្បីសម្លាប់កូនប្រុសរបស់គាត់។
[11]បន្ទាប់មក ទេវតារបស់ព្រះអម្ចាស់បានហៅកាត់ពីស្ថានសួគ៌ ដោយមានបន្ទូលថា៖ «អប្រាហាំ អប្រាហាំអើយ! ហើយគាត់បានទូលឆ្លើយថា៖ «ទូលបង្គំនៅទីនេះហើយ»។
[12]ព្រះអង្គមានបន្ទូលថា៖ «កុំលូកដៃរបស់អ្នកលើក្មេង ឬធ្វើអ្វីឲ្យគាត់មានរបួសឡើយ ដ្បិត ឥឡូវនេះ យើងដឹងហើយថា អ្នកកោតខ្លាចព្រះជាម្ចាស់ មើល
អ្នកមិនបានសំចៃសូម្បីតែកូនប្រុសរបស់អ្នក គឺកូនប្រុសតែមួយរបស់អ្នក ពីយើងទេ»។
[13]លោកអប្រាហាំងើយទៅលើ ហើយមើល៍ នៅខាងក្រោយគាត់មានចៀមមួយ ដោយស្នែងរបស់វានៅជាប់នឹងព្រៃ។ លោកអប្រាហាំបានទៅ ហើយយកចៀម
ហើយថ្វាយចៀមនោះជាតង្វាយដុត ជំនួសឲ្យកូនរបស់គាត់។[14]ដូច្នេះ លោកអប្រាហាំបានហៅកន្លែងនោះថា៖ «ព្រះអម្ចាស់ផ្គត់ផ្គង់»។
ហើយគេបានហៅកន្លែងនោះរហូតមកដល់សព្វថ្ងៃនេះថា នៅលើភ្នំរបស់ព្រះអម្ចាស់ ព្រះអង្គនឹងផ្គត់ផ្គង់»។
[15]ទេវតារបស់ព្រះអម្ចាស់បានហៅលោកអប្រាហាំពីស្ថានសួគ៌ជាលើកទីពីរ ហើយមានបន្ទូលថា[16]នេះគឺជាព្រះបន្ទូលរបស់ព្រះអម្ចាស់
យើងស្បថនឹងខ្លួនយើងដោយព្រោះអ្នកបានធ្វើការនេះ ហើយអ្នកមិនបានសំចៃ សូម្បីតែកូនប្រុស គឺកូនប្រុសតែមួយរបស់អ្នក[17]យើងនឹងឲ្យពរដល់អ្នក
ហើយយើងនឹងធ្វើឲ្យពូជពង្សរបស់បានចម្រើនកើនឡើងដូចជាផ្កាយនៅលើមេឃ ហើយដូចជាខ្សាច់នៅមាត់សមុទ្រ
ហើយពូជពង្សរបស់អ្នកនឹងគ្រប់គ្រងលើទ្វារខ្មាំងសត្រូវរបស់ពួកគេ។
[18]តាមរយៈពូជពង្សរបស់អ្នក ប្រជាជាតិនៅលើផែនដីទាំងមូលនឹងបានពរ ព្រោះអ្នកបានស្តាប់តាមសម្លេងរបស់យើង»។[19]ដូច្នេះ
លោកអប្រាហាំបានត្រឡប់ទៅអ្នកបម្រើរបស់គាត់វិញ ហើយពួកគេបានចាកចេញ ហើយឆ្ពោះទៅបៀរសេបាជាមួយគ្នា។
[20]បន្ទាប់ពីការទាំងអស់នេះហើយ មានគេមកប្រាប់លោកអប្រាហាំថា៖ «នាងមីលកាក៏បង្កើតបានកូនឲ្យលោកណាឃរ ជាប្អូនរបស់លោកដែរ»។[21]គឺអ៊ូសជាកូនច្បង ប៊ូសជា
ប្អូនប្រុសរបស់គាត់ កេមូអែលជាឪពុករបស់អើរ៉ាម[22]កេសែឌ ហាសូរ ពីលដាស យីដឡាប និងបេធូអែល។
[23]លោកបេធូអែលបង្កើតបាននាងរេបិកា។ ទាំងនេះគឺជាកូនៗទាំងប្រាំបីដែលនាងមីលកាបង្កើតឲ្យលោកណាឃរ ជាប្អូនប្រុសរបស់លោកអប្រាហាំ។[24]ចំណែក ប្រពន្ធទីពីរ
របស់លោកណាឃរ ឈ្មោះនាងរេយូម៉ា ក៏មានកូនដែរ គឺធេបា កាហាំ ថាហាស និងម្អាកា។

ជំពូក ២៣

[1]នាងសារ៉ារស់បានមួយរយម្ភៃប្រាំពីរឆ្នាំ។ ទាំងនេះគឺចំនួនឆ្នាំនៃជីវិតរបស់នាងសារ៉ា។[2]នាងសារ៉ាបានស្លាប់នៅក្រុងគារយ៉ាត់ អើបា គឺនៅក្រុងហេប្រូន ក្នុងទឹកដីកាណាន។
លោកអប្រាហាំបានកាត់ទុក្ខ និងយំសោកចំពោះនាងសារ៉ា។
[3]បន្ទាប់មក លោកអប្រាហាំក្រោកឡើង ហើយចេញពីសេចក្តីស្លាប់របស់ភរិយារបស់គាត់ ហើយបាននិយាយទៅកូនចៅប្រុសលោកហេត ពោលថា៖
[4]«ខ្ញុំជាជនបរទេសនៅក្នុងចំណោមអ្នករាល់គ្នា។ សូមចែកដីសម្រាប់កន្លែងបញ្ចុះសពនៅក្នុងចំណោមអ្នករាល់គ្នា ដើម្បីឲ្យខ្ញុំអាចបញ្ចុះសពខ្ញុំផង។
[5]កូនចៅរបស់លោកសេតឆ្លើយទៅលោកអប្រាហាំដោយនិយាយថា៖[6]«លោកម្ចាស់ សូមស្តាប់យើងខ្ញុំ។ លោកគឺជាព្រះអង្គម្ចាស់របស់ព្រះជាម្ចាស់នៅចំណោមយើង។
សូមបញ្ចុះសាកសពរបស់លោកនៅក្នុងផ្នូរដែលល្អបំផុតរបស់យើង។ នៅក្នុងចំណោមយើងគ្មាននរណាបដិសេធមិនឲ្យផ្នូររបស់គេឡើយ ដូច្នេះ
លោកអាចបញ្ចុះសាកសពរបស់លោកហើយ។
[7]លោកអប្រាហាំក្រោកឡើយ ហើយលុតជង្គង់ចុះចំពោះម្ចាស់ទឹកដី គឺចំពោះកូនចៅរបស់លោកសេត។[8]គាត់បាននិយាយទៅពួកគេ ដោយពោលថា៖ «ប្រសិនបើ
អ្នករាល់គ្នាយល់ព្រម ឲ្យខ្ញុំបានបញ្ចុះសពរបស់ខ្ញុំមែន ដូច្នេះ សូមស្តាប់ខ្ញុំ ហើយជួយនិយាយជាមួយលោកអេប្រូន ជាកូនរបស់លោកសូហារឲ្យខ្ញុំផង។[9]សូមឲ្យគេលក់រូងភ្នំ
ម៉ាកពេឡារបស់គាត់ឲ្យខ្ញុំមក។ សូមឲ្យគាត់លក់ក្នុងតម្លៃពេញដល់ខ្ញុំជាសាធារណៈ ជាទ្រព្យសម្បត្តិសម្រាប់ជាកន្លែងបញ្ចុះសព»។


generated on Wed Mar 12 15:32:40 2025

[10]លោកអេប្រូនអង្គុយនៅក្នុងចំណោមកូនចៅរបស់លោកហេត ហើយលោកអេប្រូន ជាជនជាតិបានឆ្លើយទៅលោកអប្រាហាំនៅចំពោះមុខរបស់កូនចៅហេត
នៃអស់អ្នកដែលមកក្នុងទ្វារក្រុង និយាយថា៖[11]«អត់ទេ លោកម្ចាស់ សូមស្តាប់ខ្ញុំសិន។ ខ្ញុំប្រគល់ដី និងរូងភ្នំនៅក្នុងនោះឲ្យលោក។ ខ្ញុំនឹងប្រគល់វាឲ្យលោកនៅចំពោះមុខ
ប្រជាជនរបស់ខ្ញុំទាំងអស់។ ខ្ញុំនឹងប្រគល់វាជូនលោក ដើម្បីបញ្ចុះសពរបស់លោក»។
[12]បន្ទាប់មក លោកអប្រាហាំលុតជង្គង់ចុះនៅចំពោះអ្នកស្រុកនោះ។[13]គាត់និយាយទៅលោកអេប្រូន ហើយអ្នកស្រុកទាំងអស់ក៏បានឮផងដែរ ថា៖ «សូមស្តាប់ខ្ញុំ ប្រសិនបើ
លោកព្រម ខ្ញុំនឹងបង់ថ្លៃសម្រាប់ដីនេះ។ សូមយកលុយពីខ្ញុំចុះ ហើយខ្ញុំនឹងបញ្ចុះសពខ្ញុំនៅទីនោះ»។
[14]លោកអេប្រូនឆ្លើយទៅលោកអប្រាហាំថា៖[15]«លោកម្ចាស់ សូមមេត្តាស្តាប់ខ្ញុំសិន។ ដីមួយដុំនេះមានតម្លៃបួនរយសេកែល តើតម្លៃនេះមានអ្វីសំខាន់រវាងលោកម្ចាស់ និង
ខ្ញុំ? សូមលោកម្ចាស់បញ្ចុះសពចុះ!»។[16]លោកអប្រាហាំបានស្តាប់លោកអេប្រូន ហើយលោកអប្រាហាំបានថ្លឹងប្រគល់ឲ្យលោកអេប្រូននូវចំនួនប្រាក់ដែលគាត់បាននិយាយ
ហើយអ្នកស្រុកហេតបានឮទាំងអស់គ្នា គឺប្រាក់ចំនួនបួនរយសេកែល គិតតាមតម្លៃដែលគេលក់ដីនៅសម័យនោះ។
[17]ដូច្នេះ ដីរបស់លោកអេប្រូន ដែលនៅម៉ាកពេឡា ហើយនៅជិតម៉ាមរេ គឺទាំងដីចម្ការ ដែលមានរូងភ្នំ និងដើមឈើទាំងប៉ុន្មាននៅក្នុងចម្ការ
ព្រមទាំងដើមឈើដែលនៅព័ទ្ធជុំវិញចម្ការផង[18]បានប្រគល់ឲ្យលោកអប្រាហាំដែលគាត់បានទិញ នៅចំពោះមុខអស់អ្នកដែលនៅទ្វារក្រុងរបស់គាត់ផង។
[19]បន្ទាប់ពីនេះ លោកអប្រាហាំបានបញ្ចុះនាងសារ៉ាភរិយារបស់គាត់នៅក្នុងដីរូងភ្នំម៉ាកពេឡា ដែលនៅក្បែរម៉ាមរេ គឺក្នុងក្រុងហេប្រុន ក្នុងទឹកដីកាណាន។[20]ដូច្នេះ ដី
និងរូងភ្នំបានប្រគល់ទៅឲ្យលោកអប្រាហាំធ្វើជាទ្រព្យសម្បត្តិសម្រាប់ជាកន្លែងបញ្ចុះសព ពីកូនចៅរបស់លោកហេត។

ជំពូក ២៤

[1]ឥឡូវ លោកអប្រាហាំក៏ចាស់ណាស់ហើយ ហើយព្រះអម្ចាស់បានប្រទានពរដល់លោកអប្រាហាំនៅក្នុងគ្រប់ការទាំងអស់។[2]លោកអប្រាហាំនិយាយទៅអ្នបម្រើរបស់គាត់
ជាម្នាក់ដែលចាស់ទុំជាងគេនៅក្នុងគ្រួសាររបស់គាត់ ហើយជាម្នាក់ដែលមើលខុសត្រូវលើអ្វីៗទាំងអស់ដែលគាត់មានថា៖
«ចូរដាក់ដៃរបស់ឯងនៅលើភ្លៅរបស់យើង[3]ហើយយើងសូមឲ្យឯងស្បថដោយជាមួយព្រះអម្ចាស់ ជាព្រះជាម្ចាស់នៃស្ថានសួគ៌ និងជាព្រះជាម្ចាស់នៃផែនដីថា
ឯងនឹងមិនយកភរិយាឲ្យកូនប្រុសយើងពីកូនស្រីរបស់ជនជាតិកាណាន គឺនៅក្នុងចំណោមអស់អ្នកដែលយើងបានសង់ផ្ទះនៅជាមួយឡើយ។[4]ប៉ុន្តែ
ឯងត្រូវទៅប្រទេសរបស់យើង ហើយទៅរកសាច់ញាតិរបស់យើង ហើយរកភរិយាឲ្យកូនប្រុសរបស់យើងនៅទីនោះ»។
[5]អ្នកបម្រើបាននិយាយទៅគាត់ថា៖ «ចុះប្រសិនបើស្រីនោះមិនព្រមតាមខ្ញុំមកទឹកដីនេះ?
តើគួរឲ្យខ្ញុំយកកូនប្រុសរបស់លោកម្ចាស់ត្រឡប់ទៅទឹកដីដែលលោកម្ចាស់បានចេញមកដែរទេ?»[6]លោកអប្រាហាំនិយាយទៅគាត់ថា៖
«សូមកុំនាំកូនប្រុសរបស់ខ្ញុំទៅទីនោះឡើយ![7]ព្រះអម្ចាស់ គឺជាព្រះជាម្ចាស់នៃស្ថានសួគ៌ ព្រះអង្គដែលនាំខ្ញុំមកទីនេះ ពីផ្ទះឪពុកម្តាយរបស់ខ្ញុំ
និងពីទឹកដីនៃញាតិសន្តានរបស់ខ្ញុំ ព្រះអង្គបានសន្យាជាមួយខ្ញុំដោយស្បថថា៖ «ព្រះអង្គនឹងប្រគល់ទឹកនេះដល់ពូជពង្សរបស់ខ្ញុំ
ហើយព្រះអង្គនឹងចាត់ទេវតារបស់ព្រះអង្គទៅមុនអ្នក ហើយអ្នកនឹងរកភរិយាសម្រាប់កូនប្រុសរបស់ខ្ញុំនៅទីនោះ។
[8]ប៉ុន្តែប្រសិនបើ ស្ត្រីនោះមិនព្រមមកជាមួយអ្នកទេ ដូចនេះអ្នកបានរួចពីសម្បថជាមួយខ្ញុំហើយ។ តែសូមកុំយកកូនប្រុសរបស់ខ្ញុំទៅទីនោះឡើយ។[9]ដូច្នេះ
អ្នកបម្រើបានយកដៃដាក់នៅលើភ្លៅរបស់លោកអប្រាហាំជាម្ចាស់របស់គាត់ ហើយបានស្បថជាមួយគាត់ទាក់ទងនឹងរឿងនេះ។
[10]អ្នកបម្រើបានយកសត្វអូដ្ឋរបស់ចៅហ្វាយគាត់ដប់ក្បាល ហើយបានចាកចេញទៅ។ គាត់បានយកអំណោយជាច្រើនផ្សេងទៀតពីចៅហ្វាយរបស់គាត់ទៅជាមួយគាត់។
គាត់បានចេញដំណើរ ហើយទៅតំបន់អើរ៉ាម ណាហារ៉ាម គឺទៅទីក្រុងរបស់លោកណាឃរ។[11]គាត់បានឲ្យសត្វអូដ្ឋលុតជង្គង់នៅខាងក្រៅក្រុង នៅក្បែរអណ្តូងទឹក។
គឺនៅពេលល្ងាច ពេលនោះពួកស្រីៗបានចេញមកដងទឹក។
[12]បន្ទាប់មក គាត់អធិស្ឋានថា៖ «ឱព្រះអម្ចាស់ ជាព្រះរបស់លោកអប្រាហាំចៅហ្វាយទូលបង្គំអើយ សូមឲ្យទូលបង្គំបានជោគជ័យនៅថ្ងៃនេះ
ហើយសូមបង្ហាញពីភាពស្មោះត្រង់នៃសម្ពន្ធមេត្រីចំពោះចៅហ្វាយរបស់ទូលបង្គំផង។[13]មើល៍ ទូលបង្គំឈរនៅទីនេះ ក្បែរអណ្តូងទឹក
ហើយពួកស្រីៗនៅក្នុងក្រុងនេះមកចេញមកដងទឹកពីអណ្តូងនេះ។ សូមឲ្យវាកើតឡើយយ៉ាងដូច្នេះ។[14]នៅពេល ទូលបង្គំនិយាយទៅកាន់ស្ត្រីណាថា៖ «សូមនាងដាក់ក្អមចុះ
មកឲ្យខ្ញុំបានផឹកផង» ហើយនាងនិយាយមកទូលបង្គំថា៖ «ចូរផឹកចុះ ហើយខ្ញុំនឹងដងទឹកឲ្យសត្វអូដ្ឋរបស់លោកផឹកដែរ»
នោះសូមឲ្យនាងគឺជាម្នាក់ដែលព្រះអង្គបានចាត់ត្រៀមសម្រាប់អ្នកបម្រើព្រះអង្គឈ្មោះអ៊ីសាក។ នោះ ទូលបង្គំនឹងដឹងថា
ព្រះអង្គបានបង្ហាញពីភាពស្មោះត្រង់ចំពោះសម្ពន្ធមេត្រីដល់ចៅហ្វាយរបស់ទូលបង្គំ»។
[15]កាលគាត់អធិស្ឋានមិនទាន់ចប់ផង មើល៍ នាងរេបិកា កាន់ក្អមលីនៅលើស្មារបស់នាង។ នាងរេបេកាជាកូនស្រីរបស់លោកបេធូអែល ចៅរបស់លោកស្រីមីលកា និង
លោកណាឃរ ដែលជាប្អូនរបស់លោកអប្រាហាំ។[16]នាងជាក្មេងស្រីដែលមានរូបស្រស់ស្អាតណាស់ ហើយជាស្រីក្រមុំផង។ គ្មានបុរសណារស់នៅជាមួយនាងនៅឡើយ។
នាងបានចុះទៅប្រភពទឹក ហើយដងទឹកដាក់ក្អមរបស់នាង ហើយត្រឡប់មកវិញ។
[17]បន្ទាប់មក អ្នកបម្រើនោះបានរត់ទៅជួបនាង ហើយនិយាយថា៖ «សូមឲ្យទឹកនៅក្នុងក្អមរបស់អ្នកឲ្យខ្ញុំផឹកបន្តិចមក»។[18]នាងឆ្លើយថា៖ «លោកម្ចាស់អើយ
សូមពិសាចុះ»។ ហើយនាងបានដាក់ក្អមពីលើស្មារបស់នាងយ៉ាងលឿនមកដាក់លើដៃរបស់នាង ហើយប្រគល់ឲ្យគាត់ផឹក។
[19]នៅពេលនាងបានឲ្យទឹកគាត់ផឹករួចហើយ នាងនិយាយថា៖ «ខ្ញុំនឹងដងទឹកឲ្យសត្វអូដ្ឋរបស់លោកផឹកដែរ រហូតទាល់តែអូដ្ឋឈប់ផឹក»។[20]ដូច្នេះ នាងបានទៅជាប្រញាប់
ហើយចាក់ទឹកអស់ពីក្អមទៅក្នុងស្នូក បន្ទាប់មក នាងបានរត់ម្តងទៀតទៅឯអណ្តូង ដើម្បីដងទឹក ហើយដងទឹកឲ្យសត្វអូដ្ឋទាំងអស់របស់គាត់ផឹក។
[21]បុរសនោះបានមើលនាងពីទីស្ងាត់ មើល៍ដើម្បីឲ្យដឹងថា តើព្រះអម្ចាស់ប្រោសឲ្យដំណើររបស់គាត់បានជោគជ័យឬយ៉ាងណា។[22]បន្ទាប់ពីសត្វអូដ្ឋផឹករួចហើយ
បុរសនោះបានយកមាសមកពាក់នៅនឹងច្រមុះរបស់នាងមានទម្ងន់កន្លះសេកែល និងកងដៃមាសពីរពាក់នៅដៃរបស់នាងមានទំងន់ ដប់សេកែល[23]ហើយសួរថា៖
«តើនាងជាកូនស្រីរបស់អ្នកណា? សូមប្រាប់ខ្ញុំមើល៍ តើនៅផ្ទះឪពុករបស់នាងមានកន្លែងសម្រាប់ឲ្យយើងបានសម្រាកមួយយប់ទេ?
[24]នាងនិយាយទៅគាត់ថា៖ «ខ្ញុំជាកូនស្រីរបស់លោកបេធូអែល ជាកូនរបស់នាងមីលកា បង្កើតឲ្យលោកណាឃរ»។[25]នាងក៏និយាយទៅគាត់ទៀតថា៖ «យើងមានទាំង
ចំបើង និងស្មៅស្ងួតយ៉ាងច្រើនបរិបូរ ហើយក៏មានកន្លែងសម្រាប់អស់លោកស្នាក់នៅដែរ»។
[26]បន្ទាប់មក បុរសនោះបានលុតជង្គង់ ហើយថ្វាយបង្គំព្រះអម្ចាស់។[27]គាត់និយាយថា៖ «សូមថ្វាយព្រះពរដល់ព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់លោកអប្រាហាំ
ជាចៅហ្វាយរបស់ទូលបង្គំ ព្រះអង្គមិនបានបោះបង់ចោលសម្ពន្ធមេត្រីដ៏ស្មោះត្រង់ និងគួរឲ្យទុកចិត្ត ចំពោះលោកម្ចាស់ទូលបង្គំជានិច្ច។ ចំណែក ទូលបង្គំវិញ
ព្រះអម្ចាស់បាននាំទូលបង្គំ រហូតមកដល់ផ្ទះសាច់ញាតិរបស់ចៅហ្វាយរបស់ទូលបង្គំ»។
[28]បន្ទាប់មក នាងក្រមុំបានរត់ ហើយទៅប្រាប់ក្រុមគ្រួសារម្តាយរបស់នាងអំពីការទាំងអស់នេះ។[29]នាងរេបិកាមានបងប្រុសម្នាក់ ហើយគាត់ឈ្មោះថា ឡាបាន់។
លោកឡាបាន់រត់ទៅបុរសនោះ ដែលនៅខាងក្រៅតាមផ្លូវ ក្បែរប្រភពទឹក។[30]នៅពេលគាត់បានឃើញក្រវិលនៅនឹងច្រមុះ ហើយកងដៃនៅលើកដៃប្អូនស្រីរបស់គាត់
ហើយនៅពេលគាត់បានឮពាក្យរបស់នាងរេបេកាប្អូនស្រីរបស់លោកថា៖ «គឺបុរសនេះហើយដែលនិយាយមកកាន់ខ្ញុំ»។ គាត់បានទៅជួបបុរសនោះ ហើយមើល៍
គាត់បានឈរនៅក្បែរអូដ្ឋនៅជិតអណ្តូង។
[31]បន្ទាប់មក លោកឡាបាន់និយាយថា៖ «សូមអញ្ជើញចូលមក ឱអ្នកដែលប្រកបដោយព្រះពរនៃព្រះអម្ចាស់អើយ ហេតុអ្វីបានជាឈរនៅខាងក្រៅដូច្នេះ? ខ្ញុំបានត្រៀមផ្ទះ
និងកន្លែងសម្រាប់អូដ្ឋរួចហើយ»។[32]ដូច្នេះ បុរសនោះក៏ចូលទៅផ្ទះ ហើយគាត់បានដោះយកឥវ៉ានចេញពីអូដ្ឋ។ ហើយបានឲ្យចំបើង និងស្មៅទៅអូដ្ឋស៊ី
ហើយយកទឹកមកលាងជើងគាត់ និងលាងជើងប្រុសៗដែលមកជាមួយគាត់។


generated on Wed Mar 12 15:32:40 2025

[33]ពួកគេបានរៀបចំអាហារដាក់នៅចំពោះមុខគាត់ដើម្បីឲ្យពួកគាត់ហូប ប៉ុន្តែ គាត់និយាយថា៖ «ខ្ញុំនឹងមិនហូបទេ ទាល់តែខ្ញុំបាននិយាយអ្វីដែលខ្ញុំត្រូវនិយាយសិន»។
[34]ដូច្នេះ លោកឡាបាន់និយាយថា៖ «សូមនិយាយមកចុះ»។ គាត់និយាយថា៖ «ខ្ញុំជាអ្នកបម្រើរបស់លោកអប្រាហាំ។
[35]ព្រះអម្ចាស់បានប្រទានពរដល់ចៅហ្វាយរបស់ខ្ញុំយ៉ាងខ្លាំង ហើយគាត់បានក្លាយជាអ្នកមាន។ គាត់បានប្រគល់ហ្វូងចៀម និងហ្វូងគោ ប្រាក់ និងមាស អ្នកបម្រើប្រុស
និងអ្នកបម្រើស្រី ព្រមទាំងសត្វអូដ្ឋ និងសត្វលាផង។
[36]លោកស្រីសារ៉ា ជាភរិយាចៅហ្វាយរបស់ខ្ញុំ បានបង្កើតកូនប្រុសមួយជូនចៅហ្វាយរបស់ខ្ញុំ នៅពេលនាងមានអាយុចាស់ណាស់ហើយ
ចៅហ្វាយរបស់ខ្ញុំបានប្រគល់អ្វីៗទាំងអស់ដែលគាត់មានឲ្យទៅគាត់។
[37]ចៅហ្វាយរបស់ខ្ញុំបានឲ្យខ្ញុំស្បថជាមួយគាត់ ដោយនិយាយថា៖
«អ្នកមិនត្រូវយកភរិយាឲ្យកូនប្រុសខ្ញុំ ពីពួកកូនស្រីរបស់ជនជាតិកាណាន គឺនៅក្នុងទឹកដីដែលខ្ញុំរស់នៅ។
[38]ផ្ទុយទៅវិញ អ្នកត្រូវទៅរកក្រុមគ្រួសារឪពុករបស់ខ្ញុំ
ហើយទៅរកសាច់ញាតិរបស់ខ្ញុំ ព្រមទាំងរកភរិយាឲ្យកូនប្រុសរបស់ខ្ញុំពីទីនោះ»។
[39]ខ្ញុំបាននិយាយទៅចៅហ្វាយរបស់ខ្ញុំថា៖ «ប្រហែលជាស្ត្រីនោះមិនមកតាមខ្ញុំទេ»។
[40]ប៉ុន្តែ គាត់បានប្រាប់ខ្ញុំថា៖ «ព្រះអម្ចាស់នឹងយាងទៅមុនខ្ញុំ
ព្រះអង្គនឹងចាត់ទេវតារបស់ព្រះអង្គទៅជាមួយខ្ញុំ ហើយព្រះអង្គនឹងធ្វើឲ្យដំណើររបស់ខ្ញុំបានជោគជ័យ
ដើម្បីឲ្យអ្នកអាចរកភរិយាសម្រាប់កូនប្រុសខ្ញុំពីចំណោមសាច់ញាតិរបស់ខ្ញុំ និងពីវង្សត្រកូលក្រុមគ្រួសាររបស់ខ្ញុំ។
[41]ប៉ុន្តែ អ្នកនឹងរួចផុតពីសម្បថរបស់ខ្ញុំ ប្រសិនបើ
អ្នកបានទៅដល់សាច់ញាតិរបស់ខ្ញុំហើយ ហើយពួកគេមិនប្រគល់នាងឲ្យមកអ្នក។ នោះអ្នកនឹងរួចផុតពីសម្បថរបស់ខ្ញុំហើយ»។
[42]នៅថ្ងៃនេះ ខ្ញុំបានធ្វើដំណើរមកដល់ប្រភពទឹក ហើយខ្ញុំអធិស្ឋានថា៖ «ឱព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់លោកអប្រាហាំចៅហ្វាយរបស់ទូលបង្គំអើយ សូមមេត្តា
ប្រសិនបើ ព្រះអង្គប្រាកដជាចង់ឲ្យដំណើររបស់ទូលបង្គំបានជោគជ័យមែន
[43]ទូលបង្គំនៅទីនេះហើយ កំពុងឈរនៅក្បែរអណ្តូងទឹក សូមឲ្យក្មេងស្រី ដែលបានមកដងទឹក
គឺជាកូនស្រី ដែលទូលបង្គំនិយាយទៅកាន់នាងថា៖ «សូមឲ្យទឹកពីក្អមរបស់នាងឲ្យខ្ញុំផឹកបន្តិចមក»។
[44]ហើយក្មេងស្រីណាដែលនិយាយមកទូលបង្គំថា៖
«សូមអញ្ជើញពិសាចុះ ហើយខ្ញុំនឹងទៅដងទឹកឲ្យអូដ្ឋរបស់លោកផឹកដែរនោះ សូមឲ្យក្មេងស្រីម្នាក់នោះ ជាអ្នកដែលព្រះអម្ចាស់
បានជ្រើសរើសសម្រាប់កូនប្រុសចៅហ្វាយរបស់ទូលបង្គំ»។
[45]ខ្ញុំអធិស្ឋាននៅក្នុងចិត្តរបស់ខ្ញុំមិនទាន់ចប់ផង មើល៍ នាងរេបិកាបានចេញមកជាមួយនឹងក្អមនៅលើស្មារបស់នាង ហើយនាងបានចុះទៅប្រភពទឹក ព្រមទាំងដងទឹកនោះ។
ដូច្នេះ ខ្ញុំបាននិយាយទៅនាងថា៖ «សូមឲ្យទឹកខ្ញុំផឹកបន្តិចមក»។
[46]នាងឆ្លើយយ៉ាងលឿនថា ហើយបានដាក់ក្អមពីលើស្មានាង ហើយនិយាយថា៖ «សូមអញ្ជើញពិសាចុះ
ហើយខ្ញុំនឹងឲ្យអូដ្ឋរបស់លោកផឹកដែរ»។ ដូច្នេះ ខ្ញុំក៏ផឹក ហើយនាងបានដងទឹកឲ្យអូដ្ឋខ្ញុំផឹកដែរ។
[47]ខ្ញុំបានសួរនាង ហើយនិយាយថា៖ «តើអ្នកជាកូនរបស់នរណា?» នាងឆ្លើយថា៖ «កូនស្រីរបស់លោកបេធូអែល ជាកូនរបស់លោកណាឃរ និងនាងមីលកា»។ បន្ទាប់មក
ខ្ញុំបានបំពាក់ក្រវិលនៅនឹងច្រមុះរបស់នាង ហើយបំពាក់កងដៃនៅនឹងដៃរបស់នាង។
[48]បន្ទាប់មក ខ្ញុំបានក្រាបចុះ ហើយថ្វាយបង្គំព្រះអម្ចាស់
ហើយថ្វាយព្រះពរដល់ព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់លោកអប្រាហាំចៅហ្វាយរបស់ខ្ញុំ ដែលបាននាំខ្ញុំឲ្យដើរតាមផ្លូវត្រូវ
ដើម្បីស្វែងរកកូនស្រីសាច់ញាតិចៅហ្វាយរបស់ខ្ញុំឲ្យទៅកូនប្រុសរបស់គាត់។
[49]ឥឡូវនេះ ប្រសិនបើ លោកបានរៀបចំ ដើម្បីប្រព្រឹត្តដល់ក្រុមគ្រួសារចៅហ្វាយរបស់ខ្ញុំនូវភក្ដីភាព និង ទឹកចិត្តស្មោះត្រង់ចំពោះចៅហ្វាយខ្ញុំ នោះសូមប្រាប់ខ្ញុំមកចុះ។ ប៉ុន្តែ
ប្រសិនបើ មិនព្រមទេ នោះខ្ញុំអាចនឹងងាកទៅខាងស្តាំ ឬខាងឆ្វេងទៀត»។
[50]បន្ទាប់មក លោកឡាបាន់ និងលោកបេធូអែលបានឆ្លើយ ហើយនិយាយថា៖ «អ្វីដែលមកព្រះអម្ចាស់ យើងមិនអាចនិយាយទៅកាន់អ្នកថាអាក្រក់ ឬល្អបានឡើយ។
[51]មើល៍ នាងរេបិកានៅចំពោះអ្នកហើយ។ ចូរយកនាង ហើយចេញទៅ ដូច្នេះ នាងអាចធ្វើជាភរិយាកូនប្រុសចៅហ្វាយរបស់លោកហើយ ដូចព្រះអម្ចាស់មានបន្ទូល»។
[52]នៅពេលអ្នកបម្រើរបស់លោកអប្រាហាំបានឮពាក្យរបស់ពួកគេហើយ គាត់លុតជង្គង់ហើយក្រាបចុះដល់ដីចំពោះព្រះអម្ចាស់។
[53]អ្នកបម្រើនោះបានយកគ្រឿងអលង្ការ ជា
ប្រាក់ ជាមាស ព្រមទាំងសម្លៀកបំពាក់ចេញមក ហើយជូននាងរេបិកា។ ហើយគាត់ក៏ជូនអំណោយដ៏មានតម្លៃផ្សេងៗទៀត ទៅបងប្រុស និងទៅម្តាយរបស់នាងដែរ។
[54]បន្ទាប់មក គាត់និងពួកប្រុសៗដែលនៅជាមួយគាត់បានហូបបាយទឹក។ ពួកគេស្នាក់នៅទីនោះមួយយប់ ហើយនៅពេលពួកគេក្រោកឡើងតាំងពីព្រលឹម គាត់និយាយថា៖
«ខ្ញុំសូមលាត្រឡប់ទៅចៅហ្វាយរបស់ខ្ញុំវិញហើយ»។
[55]បងប្រុស និងម្តាយរបស់នាងនិយាយថា៖ «សូមឲ្យនាងនៅជាមួយយើងបន្តិចទៀតសិនចុះ
យ៉ាងហោចណាស់ដប់ថ្ងៃ។ បន្ទាប់មក នាងអាចទៅបានហើយ»។
[56]ប៉ុន្តែ គាត់និយាយទៅពួកគេថា៖ «កុំឃាត់ខ្ញុំឡើយ ដ្បិតព្រះអម្ចាស់បានធ្វើឲ្យដំណើររបស់ខ្ញុំជោគជ័យ។
[57]ពួកគេនិយាយថា៖ «យើងនឹងហៅនាង ហើយសួរនាង»។
[58]ពួកគេក៏ហៅនាងរេបិកាមក ហើយសួរនាងថា៖ «តើនាងព្រមទៅជាមួយបុរសនេះទេ?» នាងឆ្លើយថា៖ «ខ្ញុំព្រម»។
[59]ដូច្នេះ ពួកគេក៏ជូនដំណើរនាងរេបិកាប្អូនស្រីរបស់ពួកគេ ជាមួយនឹងអ្នកបម្រើស្រីរបស់នាង ដើម្បីធ្វើដំណើរជាមួយអ្នកបម្រើរបស់លោកអប្រាហាំ
និងពួកដែលមកជាមួយគាត់។
[60]ពួកគេឲ្យពរដល់នាងរេបិកា ហើយនិយាយទៅនាងថា៖ «ប្អូនស្រីរបស់បងអើយ សូមឲ្យប្អូនជាម្តាយនៃមនុស្សរាប់ពាន់រាប់ម៉ឺន
ហើយសូមឲ្យពូជពង្សរបស់ប្អូនគ្រប់គ្រងទ្វាររបស់ពួកអ្នកដែលស្អប់ពួកគេ»។
[61]បន្ទាប់មក នាងរេបិកាបានក្រោកឡើង ហើយនាង និងអ្នកបម្រើស្រីរបស់នាងឡើងជិះអូដ្ឋ ហើយទៅតាមអ្នកបម្រើនោះ។ អ្នកបម្រើនោះបានយកនាងរេបិកា
ហើយចេញដំណើរទៅ។
[62]លោកអ៊ីសាកកំពុងតែរស់នៅក្នុងក្រុង ណេកិប ហើយទើបតែត្រឡប់មកពីអណ្តូងទឹកឡាហាយរយ។
[63]លោកអ៊ីសាកបានចេញក្រៅ ដើម្បីជញ្ជឹងគិតនៅឯវាលនាពេលល្ងាច។ នៅពេលគាត់ងើយមុខឡើង ហើយឃើញ មើល៍ ហ្វូងអូដ្ឋកំពុងតែមក។
[64]នាងរេបិកាបានមើល
ហើយពេលនាងឃើញលោកអ៊ីសាក នាងបានលោតចុះពីអូដ្ឋ។
[65]នាងសួរទៅកាន់អ្នកបម្រើថា៖ «តើបុរសដែលកំពុងដើរនៅឯវាលមកជួបយើងនោះជានរណា?»
អ្នកបម្រើឆ្លើយថា៖ «គាត់គឺជាចៅហ្វាយរបស់ខ្ញុំ»។ ដូច្នេះ នាងក៏យកស្បៃរបស់នាងមក ហើយគ្របមុខនាង។
[66]អ្នកបម្រើបានរៀបរាប់ប្រាប់លោកអ៊ីសាកគ្រប់រឿងរ៉ាវទាំងអស់ដែលគាត់បានធ្វើ។
[67]បន្ទាប់មក
លោកអ៊ីសាកបាននាំនាងរេបិកាចូលទៅនាងសារ៉ាជាម្តាយរបស់គាត់នៅក្នុងត្រសាល ហើយនាងបានក្លាយជាភរិយារបស់លោក ហើយលោកបានស្រឡាញ់នាង។ ដូច្នេះ
លោកអ៊ីសាកបានទទួលការកម្សាន្តចិត្ត បន្ទាប់ពីម្តាយរបស់គាត់ស្លាប់ទៅ។

## ជំពូក ២៥

[1]លោកអប្រាហាំបានយកភរិយាមួយទៀត នាងឈ្មោះថា កិទូរ៉ា។
[2]នាងបង្កើតបានសីមរ៉ាន យ៉ុកសាន មីដាន ម៉ាឌាន អ៊ីសបាក់ និងស៊ូអា។ លោកយ៉ុកសានបង្កើតបាន
សេបា និងដេដាន់។
[3]ពូជពង្សរបស់ដេដាន់ គឺជនជាតិអាសស៊ើរ ជនជាតិលេទូស និងជនជាតិលេវមី។ ហើយពូជពង្សរបស់ម៉ាឌាន គឺអេផា អេភើរ ហេណុក អ័ប៊ីដា និង
អែលដ្អា។
[4]អ្នកទាំងអស់នេះ គឺជាពូជពង្សរបស់នាងកិទូរ៉ា។
[5]លោកអប្រាហាំបានប្រគល់អ្វីៗទាំងអស់ដែលគាត់មានឲ្យទៅលោកអ៊ីសាក។
[6]ប៉ុន្តែ នៅក្នុងពេលដែលគាត់រស់នៅ
គាត់បានឲ្យអំណោយផ្សេងៗទៅកូនប្រុសៗរបស់គាត់ជាមួយភរិយាទីពីររបស់គាត់ ហើយចាត់ទៅពួកគេទៅទឹកដីភាគខាងកើត ឆ្ងាយពីលោកអ៊ីសាក កូនប្រុសរបស់គាត់។
[7]ទាំងនេះគឺជាចំនួនថ្ងៃនៃអាយុរបស់លោកអប្រាហាំដែលគាត់រស់នៅបាន ១៧៥ ឆ្នាំ។
[8]លោកអប្រាហាំបានផុតដង្ហើមហើយស្លាប់នៅក្នុងអាយុដ៏វែង ហើយប្រកបដោយ
សុភមង្គល មានអាយុយឺនយូរមក លោកបានទៅជួបជុំនឹងបុព្វបុរសរបស់លោកវិញ។


generated on Wed Mar 12 15:32:40 2025

[9]លោកអ៊ីសាក និងលោកអ៊ីស្មាអែល បានបញ្ចុះសពគាត់នៅក្នុងរូងភ្នំម៉ាកពេឡា នៅក្នុងចម្ការរបស់លោកអេប្រូន កូនរបស់លោកសូហារជនជាតិហេត ដែលស្ថិតនៅជិត
ម៉ាមរេ។[10]ចម្ការនេះហើយដែលលោកអប្រាហាំបានទិញពីជនជាតិហេតមក។ សពរបស់លោកអប្រាហាំត្រូវបានបញ្ចុះនៅទីនោះជាមួយនិងនាងស្រីសារ៉ា
ជាភរិយារបស់គាត់។[11]បន្ទាប់ពីលោកអប្រាហាំបានស្លាប់ទៅ ព្រះជាម្ចាស់បានប្រទានពរឲ្យអ៊ីសាក កូនប្រុសរបស់គាត់ ដែលរស់នៅក្បែរបៀរឡាហាយរយ។
[12]អ្នកទាំងនេះគឺជាពូជពង្សរបស់លោកអ៊ីស្មាអែល កូនប្រុសរបស់លោកអប្រាហាំ ដែលជាកូនរបស់នាងហាការ អ្នកបម្រើរបស់នាងសារ៉ា បង្កើតឲ្យលោកអប្រាហាំ។
[13]ទាំងនេះគឺជាឈ្មោះកូនប្រុសៗរបស់លោកអ៊ីស្មាអែល ទៅតាមកំណើតរបស់ពួកគេ នេបាយ៉ូត គឺជាកូនច្បងរបស់លោកអ៊ីស្មាអែល កេដារ អ័ឌបែល មីបសាម[14]មីសម៉ា
ឌូម៉ា ម៉ាសា[15]ហាដាឌ ថេម៉ា យេធើរ ណាភីស និងកេដម៉ា។[16]អ្នកទាំងនេះហើយគឺជាកូនប្រុសៗរបស់លោកអ៊ីស្មាអែល អ្នកទាំងនេះហើយដែលមានឈ្មោះតាមភូមិ និងតាម
ជំរំរបស់ពួកគេរៀងៗខ្លួន គឺជាមេដប់ពីរនាក់ តាមកុលសម្ព័ន្ធរបស់ពួកគេ។
[17]ទាំងនេះគឺជាចំនួនអាយុនៃជីវិតរបស់លោកអ៊ីស្មាអែល ១៣៧ឆ្នាំ គាត់បានផុតដង្ហើម ហើយស្លាប់ទៅ រួចបានទៅជួបជុំជាមួយបុព្វបុរសរបស់គាត់វិញ។[18]ពួកគេរស់
នៅជិតអេស៊ីប រហូតដល់ស្រុកស៊ើរ។ ពួកគេរស់នៅមិនសូវត្រូវគ្នាជាមួយបងប្អូនរបស់ខ្លួនទេ។
[19]ទាំងនេះគឺជារឿងរ៉ាវទាក់ទងនឹងលោកអ៊ីសាក កូនប្រុសរបស់លោកអប្រាហាំ លោកអប្រាហាំជាឪពុករបស់អ៊ីសាក។[20]លោកអ៊ីសាកមានអាយុសែសិបឆ្នាំ
នៅពេលគាត់យកនាងរេបិកាជាភរិយា កូនស្រីរបស់លោកបេធូអែលជាជនជាតិអើរ៉ាម នៅក្នុងទឹកដីប៉ាដាន់អើរ៉ាម និងត្រូវជាប្អូនស្រីរបស់លោកឡាបាន់ ជនជាតិអើរ៉ាម។
[21]លោកអ៊ីសាកបានអធិស្ឋានទៅព្រះជាម្ចាស់សម្រាប់ភរិយារបស់គាត់ ព្រោះនាងគ្មានកូនសោះ ហើយព្រះអម្ចាស់បានឆ្លើយតបសេចក្តីអធិស្ឋានរបស់គាត់
ហើយនាងរេបិកាភរិយារបស់គាត់ក៏មានផ្ទៃពោះ។[22]កូនដែលនៅក្នុងផ្ទៃចេះតែធាក់នៅក្នុងពោះនាងខ្លាំងពេក ហើយនិយាយថា៖
«ហេតុអ្វីបានជាការនេះកើតឡើងចំពោះខ្ញុំ?» នាងបានទៅទូលសួរព្រះអម្ចាស់ពីរឿងនេះ។
[23]ព្រះអម្ចាស់មានបន្ទូលមកនាងថា៖ «ប្រជាជាតិពីរនៅក្នុងផ្ទៃនាង ហើយមនុស្សពីរអ្នកនឹងបែកបាក់គ្នានៅក្នុងអ្នក។ មនុស្សម្នាក់ខ្លាំងជាងម្នាក់ទៀត
ហើយកូនច្បងនិងបម្រើកូនប្អូន»។
[24]ដល់ពេលដែលនាងសម្រាលកូន មើល៍ មានកូនភ្លោះនៅក្នុងផ្ទៃរបស់នាង។[25]កូនទីមួយបានកើតមកមានពណ៌ក្រហម ហើយមានរោមដូចជារោមសត្វ។[26]បន្ទាប់មកទៀត
ប្អូនប្រុសរបស់គាត់បានកើតមកដែរ។ ដៃរបស់គាត់បានកាន់កែងជើងរបស់អេសាវ។ គេហៅគាត់ថា យ៉ាកុប។ លោកអ៊ីសាកមានអាយុហុកសិបឆ្នាំ
នៅពេលភរិយាររបស់គាត់បង្កើតពួកគេ។
[27]កូនប្រុសបានធំឡើង ហើយ អេសាវបានក្លាយទៅជាអ្នកប្រមាញ់ដ៏ស្ទាត់ជំនាញ ជាអ្នកចម្ការ ប៉ុន្តែ លោកយ៉ាកុបវិញជាមនុស្សស្ងៀមស្ងាត់
ចូលចិត្តចំណាយពេលនៅក្នុងត្រសាល។[28]លោកអ៊ីសាកស្រឡាញ់អេសាវ ព្រោះគាត់បានហូបសត្វដែលគាត់រកបាន ប៉ុន្តែ នាងរេបិកាវិញស្រឡាញ់យ៉ាកុប។
[29]លោកយ៉ាកុបបានស្លសម្ល។ លោកអេសាវបានមកដល់ពីវាលវិញ ហើយគាត់ខ្សោយដោយព្រោះឃ្លានខ្លាំង។[30]លោកអេសាវនិយាយទៅយ៉ាកុបថា៖
«សូមឲ្យបងហូបសម្លក្រហមផង។ បងអស់កម្លាំងណាស់»។ ហេតុដូច្នេះហើយ បានជាគេហៅគាត់ថា អេដុម។
[31]លោកយ៉ាកុបនិយាយថា៖ «សូមលក់សិទ្ធិកូនច្បងរបស់អ្នកឲ្យខ្ញុំសិនមក»។[32]លោកអេសាវឆ្លើយថា៖ «បងជិតស្លាប់ហើយ។
តើសិទ្ធិកូនច្បងមានអ្វីល្អសម្រាប់បង?»[33]លោកយ៉ាកុបឆ្លើយថា៖ «សូមស្បថឲ្យខ្ញុំសិនមក» លោកអេសាវក៏ស្បថ សម្បថ
ក្នុងរបៀបដែលគាត់លក់សិទ្ធិកូនច្បងឲ្យទៅលោកយ៉ាកុប។[34]លោកយ៉ាកុបបានឲ្យនំប៉័ងទៅលោកអេសាវ និងសម្លសណ្តែកក្រហម។
គាត់បានហូបរួចរាល់ហើយក៏ចេញទៅ។ លោកអេសាវបានមើលងាយសិទ្ធិកូនច្បងរបស់គាត់បែបនេះឯង។

## ជំពូក ២៦

[1]នៅគ្រានោះ មានទុរ្ភិក្សកើតឡើងនៅក្នុងទឹកដី ជាគ្រោះអត់ឃ្លានមួយទៀតដែលធ្លាប់បានកើតឡើងនៅក្នុងសម័យលោកអប្រាហាំ។ លោកអ៊ីសាកបានទៅរកព្រះបាទ
ព្រះបាទអប៊ីម៉ាឡិច ជាស្តេចនៃជនជាតិភីលីស្ទីននៅឯក្រុងកេរ៉ា។
[2]ព្រះអម្ចាស់បានយាងមកជួបគាត់ ហើយមានបន្ទូលថា៖ «កុំទៅអេស៊ីបឡើយ ចូររស់នៅក្នុងទឹកដីដែលយើងបានប្រាប់អ្នកឲ្យរស់នៅចុះ។[3]ចូរស្នាក់នៅក្នុងទឹកដីនេះ
ហើយយើងនឹងនៅជាមួយអ្នក និងឲ្យពរដល់អ្នក ដើម្បីយើងបានប្រគល់ទឹកដីទាំងអស់នេះដល់អ្នក
និងពូជពង្សរបស់អ្នកហើយយើងនឹងធ្វើឲ្យសម្បថដែលយើងបានស្បថជាមួយអប្រាហាំឪពុករបស់អ្នកបានសម្រេច។
[4]យើងនឹងធ្វើឲ្យពូជពង្សរបស់អ្នកមានចំនួនច្រើនឡើង ដូចជាផ្កាយនៅលើមេឃ ហើយនឹងឲ្យទឹកដីទាំងអស់នេះដល់ពូជពង្សរបស់អ្នក។ តាមរយៈពូជពង្សរបស់អ្នក
ប្រជាជាតិទាំងអស់នៅផែនដីទាំងមូលនឹងបានពរ។[5]យើងនឹងធ្វើការនេះ ដោយសារអប្រាហាំបានស្តាប់បង្គាប់តាមពាក្យ និងបានប្រព្រឹត្តសេចក្តីបង្គាប់ តាមបញ្ញត្តិ
តាមច្បាប់ និងតាមក្រឹត្យវិន័យរបស់យើង»។
[6]ដូច្នេះ លោកអ៊ីសាកក៏តាំងលំនៅនៅក្នុងក្រុងកេរ៉ា។[7]នៅពេលបុរសនៅក្នុងក្រុងនោះសួរគាត់ពីភរិយារបស់គាត់ គាត់ប្រាប់ថា៖ «នាងគឺជាប្អូនស្រីរបស់ខ្ញុំ»។
គាត់ខ្លាចក្នុងការនិយាយថា៖ «នាងជាភរិយារបស់ខ្ញុំ» ព្រោះគាត់គិតថា៖ «ពួកប្រុសៗនៅទីនេះ នឹងសម្លាប់ខ្ញុំ ដើម្បីយកនាងរេបិកា ដោយសារនាងស្រស់ស្អាតណាស់»។
[8]បន្ទាប់ពី លោកអ៊ីសាកនៅទីបានយូរបន្តិចមក ព្រះបាទអប៊ីម៉ាឡិចជាស្តេចរបស់ជនជាតិភីលីស្ទីន បានមើលតាមបង្អួច។ ស្តេចឃើញ មើល៍
លោកអ៊ីសាកកំពុងប្រឡែងនាងរេបិកា ភរិយារបស់គាត់។
[9]ព្រះបាទអប៊ីម៉ាឡិចបានកោះហៅលោកអ៊ីសាកទៅគាល់ស្តេច ហើយមានរាជឱង្ការថា៖ «មើល៍ នាងគឺជាភរិយារបស់លោកមែន។ ហេតុអ្វីបានជាលោកនិយាយថា៖
«នាងគឺជាប្អូនស្រីរបស់ខ្ញុំដូច្នេះ?» លោកអ៊ីសាកទូលទៅស្តេចថា៖ «ដោយសារទូលបង្គំគិតថា នឹងមាននរណាម្នាក់សម្លាប់ទូលបង្គំ ដើម្បីយកនាង»។[10]ព្រះបាទ
អប៊ីម៉ាឡិចមានរាជឱង្ការថា៖ «ហេតុអ្វីបានជាលោកធ្វើដូច្នេះចំពោះយើង? ប្រសិនបើ រាស្ត្ររបស់យើងងាយនឹងគេងជាមួយភរិយារបស់លោក
ហើយលោកនឹងនាំទុក្ខទោសដល់យើង»។[11]ដូច្នេះ ព្រះបាទអប៊ីម៉ាឡិចបានហាមបុរសទាំងអស់ ដោយមានរាជឱង្ការថា៖ «អស់អ្នកណាដែលប៉ះពាល់បុរសនេះ
ឬភរិយារបស់គាត់ នឹងត្រូវសម្លាប់»។
[12]លោកអ៊ីសាកបានសាបព្រោះស្រូវនៅស្រុកនោះ ហើយបានច្រូតកាត់នៅក្នុងឆ្នាំនោះដដែល មួយជាមួយរយ ពីព្រោះព្រះអម្ចាស់បានប្រទានពរដល់គាត់។
[13]គាត់បានក្លាយជាអ្នកមាន ហើយកាន់តែច្រើនឡើង ហើយចម្រើនឡើង រហូតក្លាយជាអ្នកមានស្តុកស្តម្ភ។[14]គាត់មានចៀម និងហ្វូងសត្វ ព្រមទាំងអ្នកបម្រើជាច្រើន។
ជនជាតិភីលីស្ទីនបានច្រណែននឹងគាត់។
[15]ឥឡូវនេះ អណ្តូងទាំងអស់ដែលអ្នកបម្រើឪពុករបស់គាត់បានជីកនៅសម័យលោកអប្រាហាំ ឪពុករបស់គាត់ ជនជាតិភីលីស្ទីនបានបញ្ឈប់ពួកគេលែងឲ្យប្រើ
ដោយចាក់ដីបំពេញ។[16]ព្រះបាទអប៊ីម៉ាឡេកមានរាជឱង្ការទៅកាន់លោកអ៊ីសាកថា៖ «ចូរចេញពីយើងទៅ ដ្បិត លោកមានអំណាចជាងយើងទៅទៀត»។[17]ដូច្នេះ
លោកអ៊ីសាកក៏ចាកចេញពីទឹកដីនោះ ហើយទៅតាំងទីលំនៅតាមជ្រលងភ្នំកេរ៉ា ហើយរស់នៅទីនោះវិញ។
[18]លោកអ៊ីសាកបានស្តារអណ្តូង ដែលពួកគេបានជីកនៅសម័យលោកអប្រាហាំ ឪពុករបស់គាត់។ ជនជាតិភីលីស្ទីនបានបញ្ឈប់លែងឲ្យពួកគេប្រើ
បន្ទាប់ពីលោកអប្រាហាំបានស្លាប់។ លោកអ៊ីសាកបានហៅអណ្តូងទាំងនោះតាមឈ្មោះដែលឪពុករបស់គាត់បានដាក់ដែរ។
[19]នៅពេលអ្នកបម្រើរបស់លោកអ៊ីសាកជីកអណ្តូងនៅតាមជ្រលងភ្នំ ពួកគេបានរកឃើញប្រភពទឹកនៅទីនោះ។
[20]ពួកអ្នកគង្វាលសត្វនៅក្រុងកេរ៉ាឈ្លោះប្រកែកគ្នាជាមួយពួកអ្នកគង្វាលរបស់លោកអ៊ីសាក ហើយនិយាយថា៖ «ទឹកនេះជារបស់យើង»។ ដូច្នេះ
លោកអ៊ីសាកបានហៅអណ្តូងនោះថា អេសេក ព្រោះគេបានឈ្លោះប្រកែកជាមួយនឹងគាត់។

21បន្ទាប់មក ពួកគេបានជីកអណ្តូងផ្សេងទៀត ហើយពួកគេក៏មានការឈ្លោះប្រកែកនៅទីនោះដែរ ដូច្នេះ គាត់បានដាក់ឈ្មោះអណ្តូងនោះថា ស៊ីតណា។
22គាត់បានចាកចេញពីទីនោះ ហើយបានទៅជីកនៅកន្លែងមួយទៀត ប៉ុន្តែ ពួកគេមិនបានរករឿងនៅទីនោះទេ។ ដូច្នេះ គាត់បានដាក់ឈ្មោះអណ្តូងនោះថា រេហូបូត ដ្បិត
គាត់និយាយថា៖ «ឥឡូវនេះ ព្រះអម្ចាស់បើកផ្លូវឲ្យយើងហើយ យើងនឹងបានចម្រុងចម្រើនក្នុងទឹកដីនេះ»។
23បន្ទាប់មក លោកអ៊ីសាកបានចេញពីទីនោះ ឡើងទៅបៀរសេបា។24ព្រះអម្ចាស់បានយាងមកជួបគាត់នៅយប់នោះ ហើយមានបន្ទូលថា៖
«យើងជាព្រះជាម្ចាស់របស់លោកអប្រាហាំ ឪពុករបស់អ្នក។ កុំភ័យខ្លាចឡើយ ដ្បិត យើងនឹងនៅជាមួយអ្នក ហើយនិងឲ្យពរដល់អ្នក
ព្រមទាំងធ្វើឲ្យពូជពង្សរបស់អ្នកបានចម្រើនឡើង ដោយយល់ដល់លោកអប្រាហាំជាអ្នកបម្រើរបស់យើង។25លោកអ៊ីសាកបានសង់អាសនៈមួយនៅទីនោះ
ហើយបានអំនាវរកព្រះនាមរបស់ព្រះអម្ចាស់។ គាត់បានសង់ត្រសាល ហើយអ្នកបម្រើរបស់គាត់បានជីកអណ្តូងមួយនៅទីនោះ។
26បន្ទាប់មក ព្រះបាទអប៊ីម៉ាឡិចបានចេញពីក្រុងកេរ៉ាទៅរកគាត់ ជាមួយលោកអហ៊ូសាត ជាមិត្តសម្លាញ់របស់ស្តេច និងលោកភីកុល ជាមេទ័ពរបស់ស្តេចទៅជាមួយផង។
27លោកអ៊ីសាកនិយាយទៅពួកគេថា៖ «ហេតុអ្វីបានជាអស់លោកមករកខ្ញុំ ក្រែងអស់លោកស្អប់ខ្ញុំ ហើយបណ្តេញខ្ញុំពីអស់លោកមែនទេ?»
28បន្ទាប់មក ពួកគេនិយាយថា៖ «យើងបានឃើញយ៉ាងច្បាស់ថា ព្រះអម្ចាស់គង់ជាមួយអ្នក។ ដូច្នេះ យើងសម្រេចចិត្តថា គួរតែមានសម្បថរវាងយើងទាំងពីរនាក់
ពិតមែនហើយ គឺរវាងយើង និងអ្នក។29ដូច្នេះ ចូរយើងចងសម្ពន្ធមេត្រីជាមួយអ្នក ថាអ្នកនឹងធ្វើទុក្ខដល់យើងទេ ដូចដែលយើងមិនបានធ្វើទុក្ខដល់អ្នក
ហើយដូចយើងបានប្រព្រឹត្តល្អជាមួយអ្នក ព្រមទាំងបានឲ្យអ្នកចេញទៅដោយសន្តិភាពផងដែរ។
30ដូច្នេះ លោកអ៊ីសាកបានជប់លៀងឲ្យពួកគេ ហើយពួកគេបានទទួលទានអាហារ។31ពួកគេបានក្រោកឡើងតាំងពីព្រលឹម ហើយស្បថសច្ចាជាមួយគ្នា។ បន្ទាប់មក
លោកអ៊ីសាកបានជូនដំណើរពួកគេ ហើយពួកគេបានចេញពីគាត់ទៅដោយសុខសាន្ត។
32នៅថ្ងៃដដែលនោះ អ្នកបម្រើរបស់លោកអ៊ីសាកបានមក ហើយប្រាប់គាត់ពីអណ្តូងដែលពួកគេបានជីក។ ពួកគេប្រាប់ថា៖ «យើងបានរកឃើញទឹកហើយ»។
33គាត់បានដាក់ឈ្មោះអណ្តូងនោះថា សេបា ហេតុនេះហើយ បានជាគេហៅឈ្មោះរបស់ទីនោះថា បៀរសេបា រហូតមកដល់សព្វថ្ងៃនេះ។
34បន្ទាប់ពី លោកអេសាវមានអាយុសែសិបឆ្នាំ គាត់បានរៀបការជាមួយនាងយូឌីត កូនស្រីរបស់លោកបេរី ជនជាតិហេត ព្រមទាំងបានរៀបការជាមួយនឹងនាងបាសម៉ាត់
កូនស្រីរបស់លោកអេឡូន ជនជាតិហេត។35ពួកគេបានធ្វើឲ្យលោកអ៊ីសាក និងនាងរេបិកាពិបាកចិត្តជាខ្លាំង។

## ជំពូក ២៧

1នៅពេលលោកអ៊ីសាកចាស់ទៅ ហើយភ្នែករបស់គាត់ក៏ស្រអាប់ រហូតដល់គាត់មិនអាចមើលឃើញ គាត់បានហៅលោកអេសាវ កូនច្បងរបស់គាត់
ហើយនិយាយទៅកាន់គាត់ថា៖ «កូនអើយ»។2លោកអេសាវឆ្លើយថា៖ «បាទ លោកឪពុក»។ គាត់ប្រាប់ថា៖ «មើល៍ ពុកចាស់ណាស់ហើយ។ ឪពុកមិនដឹងថា
ឪពុកស្លាប់ពេលណាទេ។
3ដូច្នេះ ចូរយកប្រដាប់បរបាញ់របស់កូន ព្រួញ និងធ្នូរបស់កូន ហើយចេញទៅឯវាល ហើយបរបាញ់សត្វមកឲ្យឪពុក។4ចូរធ្វើម្ហូបឲ្យឆ្ងាញ់ឲ្យឪពុក ជាម្ហូបដែលឪពុកចូលចិត្ត
ហើយនាំវាមកឲ្យឪពុក ដើម្បីឲ្យឪពុកបានហូប ហើយឲ្យពរដល់កូនមុនពេលឪពុកស្លាប់»។
5នាងរេបិកាបានឮ ពេលលោកអ៊ីសាកប្រាប់លោកអេសាវ កូនប្រុសរបស់គាត់។ លោកអេសាវបានចេញទៅវាល ដើម្បីបរបាញ់សត្វ ហើយយកមកឲ្យឪពុក។
6នាងរេបិកាបានប្រាប់ទៅយ៉ាកុប កូនប្រុសរបស់នាង ហើយនិយាយថា៖ «មើល៍ ម្តាយបានឮឪពុករបស់កូនប្រាប់ទៅអេសាវបងប្រុសរបស់កូន។ គាត់ប្រាប់ថា៖
7«ចូរទៅបរបាញ់សត្វនៅវាលយកមក ហើយធ្វើម្ហូបយ៉ាងឆ្ងាញ់ឲ្យឪពុកហូប ហើយឪពុកនឹងឲ្យពរកូននៅមុខព្រះអម្ចាស់ មុនពេលឪពុកស្លាប់»។
8ដូច្នេះ កូនអើយ ចូរស្តាប់ពាក្យម្តាយ ដែលបានបង្គាប់ដល់កូន។9ចូរទៅឯហ្វូងសត្វ ហើយយកពពែស្ទាវល្អៗពីរមក ហើយម្តាយនឹងធ្វើម្ហូបយ៉ាងឆ្ងាញ់ពីសត្វនោះ
ឲ្យឪពុករបស់កូន តាមដែលគាត់ចូលចិត្ត។10កូននឹងយកម្ហូបនោះទៅជូនឪពុករបស់កូន ដើម្បីឲ្យគាត់បានហូប ហើយគាត់នឹងឲ្យពរដល់កូនមុនពេលគាត់ស្លាប់»។
11លោកយ៉ាកុបនិយាយទៅកាន់នាងរេបិកា ម្តាយរបស់គាត់ថា៖ «មើល៍ អេសាវបងប្រុសរបស់ខ្ញុំមានរោមពេញខ្លួន ហើយខ្ញុំអត់មានរោមសោះ។12ប្រហែលជាឪពុកប៉ះកូន
ហើយគាត់នឹងដឹងថា កូនជាអ្នកបោកប្រាសគាត់។ កូននឹងនាំបណ្តាសាមកដាក់ខ្លួនកូន ជំនួសឲ្យព្រះពរ»។
13ម្តាយរបស់គាត់ និយាយទៅគាត់ថា៖ «កូនអើយ សូមឲ្យបណ្តាសាធ្លាក់លើម្តាយចុះ។ គ្រាន់តែស្តាប់តាមពាក្យម្តាយ ហើយទៅយកវាមកឲ្យម្តាយ»។14ដូច្នេះ
លោកយ៉ាកុបបានទៅ ហើយយកពពែស្ទាវ ហើយយកវាឲ្យម្តាយរបស់គាត់ ហើយម្តាយរបស់គាត់បានធ្វើម្ហូបយ៉ាងឆ្ងាញ់ តាមដែលឪពុកចូលចិត្ត។
15នាងរេបិកាបានយកសម្លៀកបំពាក់ដែលល្អបំផុតរបស់លោកអេសាវ កូនប្រុសច្បងរបស់នាង ដែលនៅក្នុងផ្ទះជាមួយនាង ហើយបានពាក់អាវនោះឲ្យយ៉ាងកុប
កូនប្រុសពៅរបស់នាង។16នាងពាក់រោមពពែស្ទាវនៅនឹងដៃរបស់គាត់ ហើយរុំករបស់យ៉ាកុបនៅកន្លែងដែលគ្មានរោម។17នាងបានដាក់ម្ហូបដ៏ឆ្ងាញ់
ហើយនិងនំប៉័ងដែលនាងបានរៀបចំទៅឲ្យយ៉ាកុបកូនប្រុសរបស់នាង។
18លោកយ៉ាកុបបានចូលទៅឪពុករបស់គាត់ ហើយនិយាយថា៖ «លោកឪពុក»។ គាត់ឆ្លើយថា៖ «ឪពុកនៅទីនេះ តើកូនមួយណាហ្នឹង
កូនអើយ?»19លោកយ៉ាកុបឆ្លើយទៅឪពុករបស់គាត់ថា៖ «កូនគឺអេសាវ កូនច្បងរបស់លោកឪពុក កូនបានធ្វើតាម លោកឪពុកប្រាប់ដល់កូនហើយ។ សូមលោកឪពុក
ក្រោកឡើង ហើយពិសាសាច់ដែលកូនបានបាញ់ពីវាល រួចសូមឲ្យពរកូន»។
20លោកអ៊ីសាកនិយាយទៅកូនគាត់ថា៖ «កូនអើយ កូនឯងរកសត្វអីបានលឿនម្ល៉េះ?» គាត់ឆ្លើយថា៖ «ពីព្រោះ ព្រះអម្ចាស់
ជាព្រះជាម្ចាស់របស់លោកឪពុកបានយកវាមកឲ្យកូន»។21លោកអ៊ីសាកនិយាយទៅលោកយ៉ាកុបថា៖ «កូនអើយ មកជិតឪពុកបន្តិចមក ដើម្បីឲ្យឪពុកបានពាល់កូនឯង
ហើយបានដឹងថា កូនឯងពិតជាអេសាវកូនឪពុក ឬយ៉ាងណា»។
22លោកយ៉ាកុបបានចូលទៅជិតលោកអ៊ីសាកជាឪពុករបស់គាត់ ហើយលោកអ៊ីសាកបានពាល់គាត់ ហើយនិយាយថា៖ «សម្លេងគឺជាសម្លេងរបស់យ៉ាកុប ប៉ុន្តែ
ដៃជាដៃរបស់អេសាវ»។23លោកអ៊ីសាកមិនបានស្គាល់គាត់ទេ ព្រោះដៃរបស់គាត់ពាក់រោម ដូចដៃអេសាវកូនប្រុសច្បងរបស់គាត់ ដូច្នេះ
លោកអ៊ីសាកបានឲ្យពរដល់គាត់ទៅ។
24គាត់និយាយថា៖ «តើកូនឯងពិតជាអេសាវកូនរបស់ឪពុកពិតមែន?» គាត់ឆ្លើយថា៖ «បាទ លោកឪពុក»។25លោកអ៊ីសាកបាននិយាយថា៖ «យកម្ហូបមកឲ្យឪពុក
ហើយឪពុកនឹងហូបម្ហូបនោះ ហើយឪពុកនឹងឲ្យពរដល់កូន»។ លោកយ៉ាកុបបានយកម្ហូបជូនគាត់។ លោកអ៊ីសាកបានហូប ហើយលោកយ៉ាកុបបានយកស្រាជូនគាត់
ហើយគាត់ក៏ពិសាដែរ។
26បន្ទាប់មក លោកអ៊ីសាកជាឪពុករបស់គាត់និយាយទៅគាត់ថា៖ «ចូលមកជិត ហើយថើបឪពុក កូនអើយ»។27លោកយ៉ាកុបចូលទៅជិត
ហើយបានថើបឪពុករបស់គាត់ ហើយគាត់បានធំក្លិនសម្លៀកបំពាក់របស់គាត់ ហើយបានឲ្យពរដល់គាត់។ គាត់និយាយថា៖ «មើល៍ ក្លិនកូនប្រុសខ្ញុំ
ដូចក្លិនរបស់វាលស្រែដែលព្រះអម្ចាស់បានប្រទានពរ។
28សូមព្រះជាម្ចាស់ប្រទានឲ្យមានទឹកសន្សើមពីលើមេឃ ហើយប្រទានដីមានជីជាតិដល់ផែនដី ហើយប្រទានឲ្យកូនមានស្រូវ និងមានស្រាទំពាំងបាយជូរថ្មីយ៉ាងបរិបូរ។
29សូមឲ្យមនុស្សបម្រើកូន និងប្រជាជាតិជាច្រើនលុតជង្គង់ចំពោះកូន។ ចូរធ្វើជាចៅហ្វាយលើបងប្អូនរបស់កូន ហើយសូមឲ្យម្តាយរបស់កូនបានលុតជង្គង់ចំពោះកូនដែរ។
សូមឲ្យមនុស្សគ្រប់គ្នា ដែលដាក់បណ្តាសាកូន ត្រូវបណ្តាសា សូមឲ្យមនុស្សគ្រប់គ្នាដែលឲ្យពរដល់កូន បានពរដែរ»។

30បន្ទាប់ពីលោកអ៊ីសាកឲ្យពរដល់លោកយ៉ាកុបមិនទាន់រួចពីមាត់ផង លោកយ៉ាកុបមានការភ័យខ្លាច ហើយបានចេញពីវត្តមានលោកអ៊ីសាកជាឪពុករបស់ខ្លួន
ហើយលោកអេសាវក៏ត្រឡប់ពីការបរបាញ់វិញផងដែរ។ 31គាត់ក៏បានធ្វើម្ហូបយ៉ាងឆ្ងាញ់ ហើយយកមកជូនឪពុករបស់គាត់ដែរ។ គាត់និយាយទៅឪពុករបស់គាត់ថា៖
«លោកឪពុក សូមក្រោកឡើង ហើយពិសាម្ហូបដែលកូនធ្វើ ហើយសូមលោកឪពុកឲ្យពរដល់កូន»។
32លោកអ៊ីសាក ឪពុករបស់គាត់និយាយទៅគាត់ថា៖ «តើឯងជានរណា?» គាត់ឆ្លើយថា៖ «ខ្ញុំជាអេសាវ កូនប្រុសច្បងរបស់លោកឪពុក»។ 33លោកអ៊ីសាកញ័រខ្លួនជាខ្លាំង
ហើយនិយាយថា៖ «តើនរណាបានបរបាញ់សត្វ ហើយយកសាច់មកឲ្យឪពុក? ឪពុកបានហូបវាអស់ហើយ មុនពេលកូនឯងមកដល់ ហើយឪពុកបានឲ្យពរដល់គាត់ផង។
ហើយគាត់នឹងបានពរជាប្រាកដ»។
34ពេលលោកអេសាវឮពាក្យរបស់ឪពុកគាត់បែបនេះ គាត់បានស្រែកយំ ហើយឈឺផ្សាជាខ្លាំង ព្រមទាំងនិយាយទៅកាន់ឪពុករបស់គាត់ថា៖ «លោកឪពុកអើយ
សូមឲ្យពរខ្ញុំផង»។ 35លោកអ៊ីសាកនិយាយថា៖ «ប្អូនប្រុសរបស់កូនបានមកទីនេះបោកប្រាស់ ហើយបានយកពររបស់កូនអស់ហើយ»។
36លោកអេសាវនិយាយថា៖ «តើមិនត្រឹមត្រូវទេឬអី ដែលគេដាក់ឈ្មោះថា យ៉ាកុប? ដ្បិត វាបានបោកប្រាស់ខ្ញុំ ពីរលើកហើយ។ វាបានដណ្តើមយកសិទ្ធិកូនច្បង
ហើយមើល៍ ឥឡូវនេះ វាបានយកពរព្រះខ្ញុំទៀត»។ បន្ទាប់មក គាត់និយាយថា៖ «តើលោកឪពុកមិនបានត្រៀមពរអ្វីផ្សេងទៀតឲ្យកូនទេឬអី?» 37លោកអ៊ីសាកឆ្លើយ
ហើយនិយាយទៅលោកអេសាវថា៖ «មើល៍ ឪពុកបានធ្វើឲ្យវាក្លាយជាចៅហ្វាយរបស់ឯង ហើយឪពុកបានឲ្យបងប្អូនទាំងអស់របស់វា ក្លាយជាអ្នកបម្រើរបស់វា
ហើយឪពុកបានឲ្យវាមានស្រូវ និងស្រាទំពាំងបាយជូរថ្មី។ កូនអើយ តើឪពុកមានអ្វីច្រើនជាងនេះឲ្យកូន?»
38លោកអេសាវនិយាយទៅឪពុករបស់គាត់ថា៖ «លោកឪពុកអើយ តើលោកឪពុក អត់មានសល់ពរណាមួយឲ្យកូនទេឬ? សូមឲ្យពរដល់កូនផង លោកឪពុកអើយ»។
លោកអេសាវយំជាខ្លាំង។
39លោកអ៊ីសាក ឪពុករបស់គាត់ឆ្លើយ ហើយនិយាយថា៖ «មើល៍ ទីកន្លែងដែលកូនរស់នៅនឹងគ្មានជីជាតិនៅលើផែនដី នឹងមិនមានសន្សើមធ្លាក់ពីលើមេឃ។
40កូននឹងរស់នៅដោយដាវរបស់កូន ហើយកូននឹងបម្រើប្អូនប្រុសរបស់កូន។ ប៉ុន្តែ នៅពេលកូនប្រឆាំងបះបោរ កូននឹងអង្រួននឹមរបស់វាពីករបស់កូន»។
41លោកអេសាវស្អប់លោកយ៉ាកុប ដោយសារតែពរដែលឪពុករបស់គាត់បានឲ្យដល់គាត់។ លោកអេសាវនិយាយនៅក្នុងចិត្តរបស់គាត់ថា៖
«ថ្ងៃកាន់ទុក្ខរបស់ឪពុកខ្ញុំជិតមកដល់ហើយ បន្ទាប់ពីនោះ ខ្ញុំនឹងសម្លាប់យ៉ាកុប ប្អូនប្រុសរបស់ខ្ញុំ»។ 42ពាក្យរបស់លោកអេសាវ កូនច្បងរបស់នាងរេបិកា
ត្រូវបានគេយកទៅប្រាប់ដល់នាង។ ដូច្នេះ នាងបានចាត់គេ ហើយទៅហៅលោកយ៉ាកុប កូនប្រុសពៅរបស់នាង ហើយប្រាប់គាត់ថា៖ «មើល៍ អេសាវ បងប្រុសរបស់កូន
មានផែនការចង់សម្លាប់កូន ដើម្បីរំសាយកំហឹង»។
43ដូច្នេះហើយ កូនអើយ ស្តាប់ម្តាយ ចូររត់ទៅឡាបាន ជាបងប្រុសរបស់ម្តាយ នៅទឹកដីខារ៉ានទៅ។
44ចូររស់នៅជាមួយគាត់មួយរយៈ 45រហូតទាល់តែបងប្រុសរបស់កូនរសាយកំហឹង ហើយភ្លេចអ្វីដែលកូនបានធ្វើជាមួយវាហើយ។
នោះម្តាយនឹងចាត់គេឲ្យទៅនាំកូនពីទីនោះមកវិញ។ តើត្រូវឲ្យម្តាយបាត់បង់កូនទាំងពីរនៅថ្ងៃតែមួយឬអី?
46នាងរេបិកានិយាយទៅកាន់លោកអ៊ីសាកថា៖ «ខ្ញុំធុញនឹងជីវិតនេះណាស់ ដោយសារកូនស្រីរបស់ជនជាតិហេតនេះ។ ប្រសិនបើ យ៉ាកុបយកកូនស្រីរបស់ជនជាតិ
ហេតមកធ្វើជាភរិយានៅក្នុងទឹកដីនេះ នោះជីវិតខ្ញុំនឹងលែងមានន័យអ្វីទៀតហើយ»។

## ជំពូក ២៨

1លោកអ៊ីសាកបានហៅលោកយ៉ាកុប ឲ្យពរដល់គាត់ ហើយបង្គាប់គាត់ថា៖ «កូនមិនត្រូវយកភរិយាពីស្ត្រីជនជាតិកាណានឡើយ។ 2ចូរក្រោកឡើង
ទៅប៉ាដាន់អើរ៉ាមគឺទៅផ្ទះរបស់លោកបេធូអែល ជាឪពុករបស់ម្តាយរបស់កូន ហើយយកភរិយាពីទីនោះ ពីកូនស្រីម្នាក់ក្នុងចំណោមកូនស្រីរបស់លោកឡាបាន
បងប្រុសម្តាយរបស់កូន។
3សូមព្រះជាម្ចាស់ដ៏មានគ្រប់ព្រះចេស្តាប្រទានពរដល់កូន ធ្វើឲ្យកូនបង្កើតផលផ្លែជាបរិបូរ ហើយចម្រើនច្រើនឡើង ដើម្បីឲ្យកូនមានគ្នាជាច្រើន។
4សូមព្រះអង្គប្រទានពររបស់លោកអប្រាហាំដល់កូន និងដល់ពូជពង្សបន្ទាប់ពីកូន នោះកូននឹងទទួលទឹកដីជាមរត៌ក នៅកន្លែងដែលកូនរស់នៅ
ដែលព្រះជាម្ចាស់បានប្រទានដល់លោកអប្រាហាំ»។
5ដូច្នេះ លោកអ៊ីសាកបានឲ្យលោកយ៉ាកុបចេញទៅ។ លោកយ៉ាកុបបានទៅទឹកដីប៉ាដាន់អើរ៉ាម ទៅរកលោកឡាបាន់ជាកូនរបស់លោកបេធូអែល ជនជាតិអារ៉ាម ដែលត្រូវ
ជាបងប្រុសរបស់នាងរេបិកា ជាម្តាយរបស់លោកយ៉ាកុប និងលោកអេសាវ។
6លោកអេសាវបានឃើញលោកអ៊ីសាកឲ្យពរដល់លោកយ៉ាកុប ហើយចាត់ឲ្យគាត់ទៅទឹកដីប៉ាដាន់អើរ៉ាម ដើម្បីយកភរិយានៅទីនោះ។ គាត់ក៏បានឃើញថា
លោកអ៊ីសាកឲ្យពរដល់គាត់ ហើយបានបង្គាប់ដល់គាត់ ដោយនិយាយថា៖ «កូនមិនត្រូវយកភរិយាពីពួកកូនស្រីរបស់ជនជាតិកាណានឡើយ»។
7លោកអេសាវក៏បានឃើញថា លោកយ៉ាកុបបានស្តាប់បង្គាប់ឪពុក និងម្តាយរបស់គាត់ ហើយបានចេញទៅទឹកដីប៉ាដាន់អើរ៉ាម។
8លោកអេសាវបានឃើញថា លោកអ៊ីសាកមិនពេញចិត្តនឹងស្ត្រីជនជាតិកាណានឡើយ។ 9ដូច្នេះ គាត់បានទៅរកលោកអ៊ីស្មាអែល ហើយយកភរិយា
ក្រៅពីភរិយាដែលគាត់មាន គឺនាងម៉ាហាឡាត ជាបងរបស់នាងនេបាយ៉ូត ជាកូនស្រីរបស់លោកអ៊ីស្មាអែលដែលកូនរបស់លោកអប្រាហាំ មកធ្វើជាភរិយារបស់គាត់។
10លោកយ៉ាកុបបានចាកចេញពីបៀរសេបា ហើយឆ្ពោះដំណើរទៅទឹកដីខារ៉ាន។ គាត់បានទៅដល់កន្លែងមួយ ហើយបានសម្រាកនៅទីនោះពេញមួយយប់
ដោយសារថ្ងៃបានលិចបាត់ហើយ។ 11គាត់បានយកថ្មមួយនៅកន្លែងនោះ មកកើយនៅក្រោមក្បាលរបស់គាត់ ហើយបានដេកលក់នៅកន្លែងនោះទៅ។
12គាត់បានយល់សុបិន ហើយឃើញមានជណ្តើរមួយបញ្ឈរលើផែនដី។ ចុងវាខ្ពស់រហូតដល់មេឃ ហើយពួកទេវតារបស់ព្រះជាម្ចាស់បានហោះចុះ ហោះឡើងនៅពីលើវា។
13មើល៍ ព្រះអម្ចាស់បានឈរនៅពីលើវា ហើយមានបន្ទូលថា៖ «យើងគឺជាព្រះអម្ចាស់ ជាព្រះជាម្ចាស់របស់លោកអប្រាហាំឪពុករបស់អ្នក
ហើយជាព្រះជាម្ចាស់របស់លោកអ៊ីសាកដែរ។ យើងនឹងប្រគល់ទឹកដីដែលអ្នកកំពុងតែគេងនេះឲ្យទៅអ្នក និងពូជពង្សរបស់អ្នក។
14ពូជពង្សរបស់អ្នកនឹងដូចជាធូលីដីនៅលើផែនដី ហើយទឹកដីរបស់អ្នកនឹងលាតសន្ធឹងពីលិច ទៅកើត ហើយពីជើងទៅត្បូង។ តាមរយៈអ្នក និងតាមរយៈពូជពង្សរបស់អ្នក
គ្រប់ទាំងគ្រួសារទាំងអស់នៅលើផែនដីនឹងបានពរ។ 15មើល៍ យើងនៅជាមួយអ្នក ហើយយើងនឹងការពារអ្នក នូវគ្រប់កន្លែងដែលអ្នកទៅ។
យើងនឹងនាំអ្នកមកទឹកដីនេះម្តងទៀត ដើម្បីយើងមិនបោះបង់អ្នកចោលឡើយ។ យើងនឹងធ្វើការទាំងអស់ ដែលយើងបានសន្យាដល់អ្នក»។
16លោកយ៉ាកុបបានក្រោកពីគេងឡើង ហើយគាត់និយាយថា៖ «ប្រាកដណាស់ ព្រះអម្ចាស់គង់នៅកន្លែងនេះ ហើយខ្ញុំមិនបានដឹងសោះ»។ 17គាត់មានការភ័យខ្លាច
ហើយនិយាយថា៖ «ទីកន្លែងនេះគួរឲ្យភ័យខ្លាចណាស់! ទីនេះគ្មានអ្វីផ្សេងទៀតទេ គឺក្រៅពីដំណាក់របស់ព្រះជាម្ចាស់។ នេះគឺជាទ្វាររបស់ស្ថានសួគ៌ពិតប្រាកដមែន»។
18លោកយ៉ាកុបបានក្រោកឡើងនៅពេលព្រឹក ហើយគាត់បានយកថ្មដែលគាត់បានដាក់កើយនៅក្រោមក្បាលគាត់នោះ។ 19ហើយបានបញ្ឈរដូចជាសសរ
ហើយបានចាក់ប្រេងនៅពីលើថ្មនោះ។ គាត់បានហៅកន្លែងនោះ បេតអែល ប៉ុន្តែពីដើមឈ្មោះរបស់ទីក្រុងនេះគឺ លូស។
20លោកយ៉ាកុបបានស្បថសម្បថដោយនិយាយថា៖ «ប្រសិនបើ ព្រះជាម្ចាស់គង់ជាមួយទូលបង្គំ ហើយការពារទូលបង្គំនៅតាមផ្លូវដែលខ្ញុំកំពុងដើរនេះ
ហើយប្រទាននំប៉័ងឲ្យខ្ញុំហូប និងសម្លៀកបំពាក់ឲ្យខ្ញុំពាក់ បើខ្ញុំត្រឡប់ទៅផ្ទះរបស់ឪពុកខ្ញុំវិញដោយសុខសាន្ត 21ដូច្នេះ ព្រះអម្ចាស់នឹងត្រូវជាព្រះរបស់ទូលបង្គំ។
22បន្ទាប់មកថ្មដែលគាត់បានបញ្ឈរដូចជាសសរនោះបានត្រឡប់ទៅជាថ្មសក្ការៈ។ ទូលបង្គំប្រាកដជាថ្វាយមួយភាគដប់
ពីអ្វីៗដែលព្រះអង្គប្រទានដល់ទូលបង្គំទៅព្រះអង្គវិញ។


generated on Wed Mar 12 15:32:40 2025

## ជំពូក ២៩

1បន្ទាប់មក លោកយ៉ាកុបបានធ្វើដំណើរ ហើយទៅដល់ទឹកដីរបស់ប្រជាជនដែលនៅភាគខាងកើត។2នៅពេលគាត់សម្លឹងមើល គាត់បានឃើញអណ្តូងនៅឯវាល
ហើយមើល៍ មានសត្វចៀមបីហ្វូងដេកនៅក្បែរអណ្តូងនោះ។ ព្រោះហ្វូងសត្វទាំងអស់នោះ ផឹកទឹកពីអណ្តូងនោះ ហើយមានថ្មមួយយ៉ាងធំបិទមាត់អណ្តូងនោះ។
3នៅពេលហ្វូងសត្វបានមកជុំគ្នានៅទីនោះហើយ ពួកអ្នកគង្វាលនឹងរមៀលថ្មចេញពីមាត់អណ្តូងនោះ ហើយដងទឹកឲ្យចៀមផឹក ហើយ
រមៀលថ្មមកដាក់នៅមាត់អណ្តូងទៅកន្លែងរបស់វាវិញ។
4លោកយ៉ាកុបនិយាយទៅកាន់ពួកគេថា៖ «បងប្អូនអើយ តើបងប្អូនមកពីណា?» ពួកគេឆ្លើយថា៖ «យើងមកពីខារ៉ាន»។5គាត់និយាយទៅកាន់ពួកគេថា៖
«តើបងប្អូនស្គាល់លោកឡាបាន់ កូនប្រុសរបស់លោកណាឃរទេ?»។6គាត់និយាយទៅកាន់ពួកគេថា៖ «តើគាត់សុខសប្បាយជាទេ?» ពួកគេឆ្លើយថា៖
«គាត់សុខសប្បាយទេ ហើយមើល៍នោះ នាងរ៉ាជែល កូនស្រីរបស់គាត់មកជាមួយចៀមផង?»។
7លោកយ៉ាកុបឆ្លើយថា៖ «មើល៍ ឥឡូវនេះថ្ងៃត្រង់ហើយ។ វាមិនមែនជាពេលដែលហ្វូងសត្វត្រូវប្រមូលផ្តុំឡើយ។ អ្នកគួរតែឲ្យចៀមផឹកទឹក ហើយបន្ទាប់មក
លែងពួកវាឲ្យទៅស៊ីស្មៅចុះ»។8ពួកគេនិយាយថា៖ «យើងមិនអាចឲ្យពួកវាផឹកទឹក លុះត្រាតែពួកវាជួបជុំគ្នាសិន។ បន្ទាប់មក ពួកប្រុសៗបានរមៀលថ្មចេញពីមាត់អណ្តូង
ហើយ យើងនឹងឲ្យទឹកចៀមផឹក»។
9កាលលោកយ៉ាកុបកំពុងនិយាយជាមួយពួកគេនៅឡើយ នាងរ៉ាជែល បានដើរមកជាមួយហ្វូងចៀមឪពុកនាង ដ្បិតនាងឃ្វាលពួកវា។
10ពេលលោកយ៉ាកុបឃើញនាងរ៉ាជែល កូនស្រីរបស់លោកឡាបាន់ ត្រូវជាប្អូនប្រុសម្តាយរបស់គាត់ និងហ្វូងចៀមរបស់លោកឡាបាន់ ប្អូនប្រុសម្តាយរបស់គាត់
គាត់បានចូលទៅជិត ហើយរមៀលថ្មចេញពីមាត់អណ្តូង ហើយបានដងទឹកឲ្យហ្វូងចៀមរបស់លោកឡាបាន់ ប្អូនប្រុសម្តាយរបស់គាត់។
11លោកយ៉ាកុបបានថើបនាងរ៉ាជែល ហើយយំខ្លាំងៗ។12លោកយ៉ាកុបបានប្រាប់នាងរ៉ាជែលថា គាត់គឺជាសាច់ញាតិឪពុករបស់នាង ហើយថា
គាត់គឺជាកូនប្រុសរបស់នាងរេបិកា។ បន្ទាប់មក នាងបានរត់ ហើយទៅប្រាប់ឪពុករបស់នាង។
13ពេលលោកឡាបាន់បានឮដំណឹងពីលោកយ៉ាកុប កូនប្រុសបងស្រីរបស់គាត់ គាត់បានរត់ទៅជួប ហើយឱប ថើប ព្រមទាំងនាំគាត់មកផ្ទះរបស់គាត់ផង។
លោកយ៉ាកុបប្រាប់លោកឡាបាន់ពីគ្រប់រឿងរ៉ាវទាំងអស់។14លោកឡាបាន់និយាយទៅគាត់ថា៖ «ក្មួយពិតជាជាប់សាច់ឈាមរបស់អ៊ំមែន។ បន្ទាប់មក
លោកឡាបាន់បានស្នាក់នៅជាមួយគាត់អស់រយៈពេលមួយខែ។
15បន្ទាប់មក លោកឡាបាន់និយាយទៅកាន់លោកយ៉ាកុបថា៖ «តើក្មួយមិនត្រូវធ្វើការឲ្យអ៊ំ ដោយមិនបានកម្រៃឬអី? ប្រាប់អ៊ំមក
តើក្មួយចង់បានថ្លៃឈ្នួលប៉ុន្មាន?»16លោកឡាបាន់មានកូនស្រីពីនាក់។ កូនស្រីច្បងឈ្មោះនាងលេអា ហើយកូនស្រីពៅឈ្មោះនាងរ៉ាជែល។17នាងលេអាមានភ្នែកស្រទន់
ប៉ុន្តែ នាងរ៉ាជែលវិញមានរូបឆោមស្រស់ស្អាតណាស់។18លោកយ៉ាកុបស្រឡាញ់នាងរ៉ាជែល ដូច្នេះ គាត់និយាយថា៖ «ខ្ញុំនឹងបម្រើអ៊ំប្រាំពីរឆ្នាំ ដើម្បីឲ្យបាននាងរ៉ាជែល
កូនស្រីពៅរបស់អ៊ំ»។
19លោកឡាបាន់និយាយថា៖ «អ៊ំលើកកូនឲ្យឯង ប្រសើរជាអ៊ំលើកកូនឲ្យអ្នកផ្សេង។ នៅជាមួយអ៊ំហើយ»។20ដូច្នេះ លោកយ៉ាកុបបានបម្រើប្រាំពីរឆ្នាំ
ដើម្បីឲ្យបាននាងរ៉ាជែល ហើយប្រាំពីរឆ្នាំ ហាក់បីដូចជាប៉ុន្មានថ្ងៃប៉ុណ្ណោះ ដ្បិត គាត់ស្រឡាញ់នាងជាខ្លាំង។
21បន្ទាប់មក លោកយ៉ាកុបនិយាយកាន់លោកឡាបាន់ថា៖ «ខ្ញុំបានបម្រើអ៊ំគ្រប់ប្រាំពីរឆ្នាំហើយ សូមប្រគល់នាងឲ្យខ្ញុំមក ដើម្បីឲ្យខ្ញុំអាចរៀបការជាមួយនាង!»22ដូច្នេះ
លោកឡាបាន់បានប្រមូលពួកប្រុសៗទាំងអស់នៅកន្លែងរបស់គាត់ ហើយធ្វើពិធីជប់លៀង។
23នៅពេលល្ងាច លោកឡាបាន់បានយកនាងលេអា កូនស្រីច្បងរបស់គាត់ ហើយយកនាងទៅឲ្យលោកយ៉ាកុប ដើម្បីគេងជាមួយនាង។
24លោកឡាបាន់បានប្រគល់អ្នកបម្រើស្រីរបស់គាត់ឲ្យទៅកូនស្រីរបស់គាត់ ឈ្មោះនាងស៊ីលផា ដើម្បីបម្រើនាង។25នៅពេលព្រឹក មើល៍ នាងជាលេអាទៅវិញ
លោកយ៉ាកុបបាននិយាយទៅកាន់លោកឡាបាន់ថា៖ «តើអ៊ំធ្វើដូច្នេះដាក់ខ្ញុំធ្វើអ្វី? តើខ្ញុំមិនបានបម្រើអ៊ំ ដើម្បីឲ្យបាននាងរ៉ាជែលជាឬ?
ហេតុអ្វីបានជាអ៊ំបោកប្រាស់ខ្ញុំដូច្នេះ?»។
26លោកឡាបាន់និយាយថា៖ «នេះមិនមែនជាទម្លាប់របស់យើងទេ ដែលប្អូនស្រីពៅរៀបការមុនបងស្រីច្បងនោះ។27ចូរនៅជាមួយកូនស្រីនេះមួយសប្តាហ៍សិនទៅ
ហើយយើងនឹងប្រគល់កូនស្រីមួយទៀតឲ្យ ទុកដូចជាថ្លៃឈ្នួលនៃការបម្រើអ៊ំប្រាំពីរឆ្នាំទៀត»។
28លោកយ៉ាកុបក៏ធ្វើតាម ហើយបាននៅជាមួយនាងលេអាគ្រប់មួយសប្តាហ៍។ បន្ទាប់មក លោកឡាបាន់បានប្រគល់នាងរ៉ាជែល កូនស្រីរបស់គាត់
ឲ្យធ្វើជាភរិយារបស់គាត់ផងដែរ។29លោកឡាបាន់បានប្រគល់នាងប៊ីលហាដល់នាងរ៉ាជែលជាកូនស្រីរបស់គាត់ ដើម្បីបម្រើនាង។30ដូច្នេះ
លោកយ៉ាកុបបានគេងជាមួយនាងរ៉ាជែលផងដែរ ប៉ុន្តែ គាត់ស្រឡាញ់នាងរ៉ាជែលខ្លាំងជាងនាងលេអា។ ដូច្នេះ
លោកយ៉ាកុបបានបម្រើលោកឡាបាន់អស់រយៈពេលប្រាំពីឆ្នាំទៀត។
31ព្រះអម្ចាស់បានឃើញថា នាងលេអាមិនបានទទួលសេចក្តីស្រឡាញ់ ដូច្នេះ ព្រះអង្គបានធ្វើឲ្យនាងមានកូន ប៉ុន្តែ នាងរ៉ាជែលវិញគ្មានកូនទេ។32នាងលេអាមានផ្ទៃពោះ
ហើយបង្កើតបានកូនប្រុសមួយ ហើយនាងដាក់ឈ្មោះកូនប្រុសនោះថា រូបេន។ នាងបាននិយាយថា៖ «ព្រះអម្ចាស់បានឃើញពីទុក្ខលំបាករបស់ខ្ញុំ ដូច្នេះ
ស្វាមីរបស់ខ្ញុំមុខជាស្រឡាញ់ខ្ញុំមិនខាន»។
33បន្ទាប់មក នាងក៏មានផ្ទៃពោះ ហើយបង្កើតបានកូនប្រុសមួយទៀត។ នាងនិយាយថា៖ «ព្រះជាម្ចាស់ជ្រាបថា ស្វាមីខ្ញុំមិនស្រឡាញ់ខ្ញុំទេ ហេតុដូច្នេះហើយ
បានជាព្រះអង្គប្រទានកូនប្រុសមួយទៀតឲ្យខ្ញុំ» ហើយនាងបានដាក់ឈ្មោះកូនប្រុសនោះថា ស៊ីម្មាន។34បន្ទាប់មក នាងក៏មានផ្ទៃពោះ
ហើយបង្កើតបានកូនប្រុសមួយទៀត។ នាងនិយាយថា៖ «ឥឡូវនេះ ដល់ពេលដែលស្វាមីរបស់ខ្ញុំ ជាប់ចិត្តនឹងខ្ញុំវិញហើយ ព្រោះខ្ញុំបានបង្កើតកូនប្រុសបីដល់គាត់»។
ដូច្នេះហើយបានជាដាក់ឈ្មោះឲ្យកូនប្រុសនោះថា លេវី។
35នាងមានផ្ទៃពោះ ហើយបង្កើតបានកូនប្រុសមួយទៀត។ នាងនិយាយថា៖ «ខ្ញុំនឹងសរសើរព្រះអម្ចាស់នៅពេលនេះ»។
ហេតុដូច្នេះហើយបានជានាងដាក់ឈ្មោះកូនប្រុសនោះថា យូដា។ បន្ទាប់មក នាងលែងមានកូនទៀត។

## ជំពូក ៣០

1នៅពេលនាងរ៉ាជែលឃើញថា មិនបានបង្កើតកូនឲ្យលោកយ៉ាកុបសោះ នាងរ៉ាជែលបានច្រណែននឹងបងស្រីរបស់នាង។ នាងនិយាយទៅលោកយ៉ាកុបថា៖
«បើមិនឲ្យខ្ញុំមានកូនផង ខ្ញុំនឹងស្លាប់»។2លោកយ៉ាកុបខឹងជាមួយនឹងនាងរ៉ាជែលជាខ្លាំង។ គាត់និយាយថា៖ «តើបងព្រះជាម្ចាស់មែនទេ
ដែលបង្ខាំងអូនមិនឲ្យមានកូន?»។
3នាងនិយាយថា៖ «មើល៍នែ៎ ប៊ីលហា ជាអ្នកបម្រើស្រីរបស់អូន ចូរគេងជាមួយនាងទៅ ដើម្បីឲ្យនាងអាចបង្កើតកូនមកដាក់លើជង្គង់អូន ហើយអូននឹងមានកូន
ដោយសារនាង»។4ដូច្នេះ នាងបានប្រគល់នាងប៊ីលហា ជាអ្នកបម្រើស្រីរបស់នាង ឲ្យធ្វើជាភរិយា ហើយលោកយ៉ាកុបក៏គេងជាមួយនាង។
5នាងប៊ីលហាមានផ្ទៃពោះ ហើយបង្កើតកូនប្រុសមួយឲ្យលោកយ៉ាកុប។6បន្ទាប់មក នាងរ៉ាជែលនិយាយថា៖ «ព្រះជាម្ចាស់រកយុត្តិធម៌ឲ្យខ្ញុំ។
ព្រះអង្គបានស្តាប់សេចក្តីអធិស្ឋានរបស់ខ្ញុំ ហើយប្រទានកូនប្រុសមួយឲ្យខ្ញុំ»។ ដោយហេតុនេះ បានជានាងដាក់ឈ្មោះកូនប្រុសនោះថា ដាន់។


generated on Wed Mar 12 15:32:40 2025

7នាងប៊ីហា ជាអ្នកបម្រើស្រីរបស់នាងរ៉ាជែល មានផ្ទៃពោះម្ដងទៀត ហើយបង្កើតប្រុសទីពីរឲ្យលោកយ៉ាកុប។8នាងរ៉ាជែលនិយាយថា៖ «ខ្ញុំខំប្រឹងតទល់យ៉ាងខ្លាំងជាមួយ
នឹងបងស្រីខ្ញុំ ហើយខ្ញុំបានឈ្នះ»។ នាងបានដាក់ឈ្មោះកូនប្រុសនោះថា ណែបថាលី។
9នៅពេលនាងលេអាឃើញថា នាងលែងមានកូនបានទៀត នាងបានយកនាងស៊ីលផា ជាអ្នកបម្រើស្រីរបស់នាង ហើយប្រគល់នាងឲ្យលោកយ៉ាកុប ធ្វើជាភរិយា។
10នាងស៊ីលផា អ្នកបម្រើស្រីរបស់នាងលេអា បានបង្កើតកូនប្រុសមួយឲ្យលោកយ៉ាកុប។11នាងលេអានិយាយថា៖ «មានសំណាងហើយ!» ដូច្នេះ
នាងបានដាក់ឈ្មោះកូនប្រុសនោះថា កាដ។
12បន្ទាប់មកនាងស៊ីលផា អ្នកបម្រើរបស់នាងលេអា បានបង្កើតកូនទីពីរឲ្យលោកយ៉ាកុប។13នាងលេអានិយាយថា៖ «ខ្ញុំរីករាយហើយ! ដ្បិតស្ត្រីទាំងឡាយនឹងហៅខ្ញុំថា
រីករាយ»។ ដូច្នេះ នាងបានដាក់ឈ្មោះកូនប្រុសនោះថា អេស៊ើរ។
14លោករូបេនបានចេញទៅចម្ការនៅក្នុងរដូវច្រូតស្រូវ ហើយបេះបានផ្លែស្នេហ៍នៅក្នុងចម្ការ។ កាត់បានយកផ្លែឈើទាំងនោះមកជូននាងលេអាជាម្ដាយរបស់គាត់។
បន្ទាប់មក នាងរ៉ាជែលបាននិយាយទៅនាងលេអាថា៖ «សូមឲ្យផ្លែស្នេហ៍កូនប្រុសបងមកខ្ញុំខ្លះមក»។15នាងលេអានិយាយទៅនាងថា៖
«តើវាជារឿងតូចតាចសម្រាប់ឯងមែនទេ ដែលឯងមកយកប្ដីរបស់យើងទៅ? ហើយឥឡូវ ឯងចង់មកយកផ្លែស្នេហ៍ពីកូនប្រុសយើងទៀត?» នាងរ៉ាជែលនិយាយថា៖
«អ៊ីចឹង ខ្ញុំនឹងឲ្យគាត់ទៅគេងជាមួយបងយប់នេះ ដើម្បីប្ដូរយកផ្លែស្នេហ៍កូនប្រុសរបស់បងនេះ»។
16លោកយ៉ាកុបមកដល់ពីស្រែនៅពេលល្ងាច។ នាងលេអាបានចេញទៅជួបគាត់ ហើយនិយាយថា៖ «បងត្រូវគេងជាមួយអូនយប់នេះ
ព្រោះអូនបានជួលបងដោយថ្លៃផ្លែស្នេហ៍កូនប្រុសរបស់អូន»។ ដូច្នេះ លោកយ៉ាកុបក៏ទៅគេងជាមួយនាងលេអានៅយប់នោះ។17ព្រះជាម្ចាស់ស្ដាប់តាមនាងលេអា
ហើយនាងក៏មានផ្ទៃពោះ ហើយបានបង្កើតកូនប្រុសទីប្រាំឲ្យលោកយ៉ាកុប។18នាងលេអានិយាយថា៖ «ព្រះជាម្ចាស់ប្រទានរង្វាន់ដល់ខ្ញុំ
ព្រោះខ្ញុំបានប្រគល់អ្នកបម្រើស្រីរបស់ខ្ញុំឲ្យទៅស្វាមីរបស់ខ្ញុំ»។ នាងបានដាក់ឈ្មោះកូនប្រុសនោះថា អ៊ីសាខា។
19នាងលេអាមានផ្ទៃពោះម្ដងទៀត ហើយបង្កើតបានកូនប្រុសទីប្រាំមួយ ឲ្យលោកយ៉ាកុប។ នាងលេអានិយាយថា៖ «ព្រះជាម្ចាស់បានប្រទានអំណោយយ៉ាងល្អដល់ខ្ញុំ»។
20ឥឡូវនេះ ស្វាមីខ្ញុំនឹងគោរពខ្ញុំ ដោយសារខ្ញុំបានបង្កើតកូនប្រុសទីប្រាំមួយឲ្យគាត់»។21នាងដាក់ឈ្មោះកូនប្រុសនោះថា សាប់យូឡូន។ បន្ទាប់មក
នាងបានបង្កើតបានកូនស្រីមួយ ហើយនាងបានដាក់ឈ្មោះកូនស្រីនោះថា ឌីណា។
22ព្រះជាម្ចាស់បាននឹកចាំពីនាងរ៉ាជែល ហើយបានស្ដាប់តាមនាង។ ព្រះអង្គបានធ្វើឲ្យនាងមានផ្ទៃពោះ។23នាងមានកូន ហើយបង្កើតបានកូនប្រុសមួយ។ នាងនិយាយថា៖
«ព្រះជាម្ចាស់បានដកភាពអាម៉ាសចេញរបស់ខ្ញុំចេញ»។24នាងដាក់ឈ្មោះកូនប្រុសនោះថា យ៉ូសែប ដោយនិយាយថា៖
«ព្រះអម្ចាស់បានបន្ថែមកូនប្រុសមួយទៀតដល់ខ្ញុំ»។
25បន្ទាប់ពីនាងរ៉ាជែលបង្កើតយ៉ូសែបហើយ លោកយ៉ាកុបបាននិយាយទៅកាន់លោកឡាបាន់ថា៖ «សូមឲ្យខ្ញុំបានចេញទៅ ដើម្បីខ្ញុំអាចចេញទៅផ្ទះរបស់ខ្ញុំ
និងប្រទេសរបស់ខ្ញុំវិញ។26សូមប្រគល់ភរិយា និងកូនៗ ព្រោះខ្ញុំបានបម្រើលោកឪពុក ហើយសូមអនុញ្ញាតឲ្យខ្ញុំទៅ
ដើម្បីលោកឪពុកដឹងពីកិច្ចការដែលខ្ញុំបានធ្វើជូនលោកឪពុកហើយ»។
27លោកឡាបាន់តបទៅគាត់ថា៖ «ប្រសិនបើកូនយោគយល់ដល់ពុក ឪពុកបានដឹងដោយសារការទស្សន៍ទាយថាព្រោះតែកូន ព្រះអម្ចាស់បានប្រទានពរពុក»។28ដូច្នេះ
គាត់បាននិយាយថា៖ «កូនចង់បានថ្លៃឈ្នួលប៉ុន្មាន ពុកនឹងប្រគល់ឲ្យ»។
29លោកយ៉ាកុបនិយាយទៅគាត់ថា៖ «លោកឪពុកជ្រាបពីការដែលកូនបានបម្រើឲ្យឪពុក និងពីហ្វូងសត្វរបស់លោកឪពុកបានកើនចំនួនច្រើនយ៉ាងណានោះ។30ដ្បិត
មុនពេលខ្ញុំមក លោកឪពុកមានតែបន្តិចទេ ហើយឥឡូវ វាចម្រើនច្រើនឡើយជាបរិបូរ។ ព្រះអម្ចាស់បានប្រទានពរដល់លោកឪពុក នៅគ្រប់ពេលដែលខ្ញុំធ្វើការ។ ឥឡូវនេះ
តើពេលណាទើបខ្ញុំអាចផ្គត់ផ្គង់គ្រួសាររបស់ខ្ញុំម្ដង?»
31ដូច្នេះ លោកឡាបាន់និយាយថា៖ «តើកូនត្រូវការថ្លៃឈ្នួលប៉ុន្មាន?» លោកយ៉ាកុបឆ្លើយថា៖ «លោកឪពុក មិនចាំបាច់ឲ្យថ្លៃឈ្នួលកូនអ្វីទេ។ ប្រសិនបើ
លោកឪពុកធ្វើការមួយនេះជាមួយខ្ញុំ ខ្ញុំនឹងមើលថែទាំហ្វូងសត្វរបស់លោកឪពុកតទៅមុខទៀត។32សូមឲ្យខ្ញុំបានដើរកាត់ហ្វូងសត្វនៅថ្ងៃនេះ ដើម្បីញែកសត្វចៀមពព្លាក់
ពពាល និងសត្វខ្មៅទាំងអស់ក្នុងកូនចៀមទាំងអស់ ព្រមទាំងសត្វដែលពពាល ពព្លាក់ក្នុងហ្វូងពពែផង។ ទាំងនឹងទុកជាថ្លៃឈ្នួលសម្រាប់ខ្ញុំ។
33ភាពស្មោះត្រង់របស់ខ្ញុំនឹងធ្វើបន្ទាល់ពីខ្ញុំនៅពេលក្រោយ នៅពេលលោកឪពុកទៅពិនិត្យពីថ្លៃឈ្នួលរបស់ខ្ញុំ។ ចៀមណាដែលមិនពពាល ពព្លាក់ក្នុងហ្វូងពពែ ហើយដែល
មិនខ្មៅក្នុងហ្វូងចៀម នោះចាត់ទុកថាខ្ញុំបានលួចហើយ»។34លោកឡាបាន់និយាយថា៖ «យល់ព្រម។ សូមធ្វើតាមសម្ដីរបស់កូនចុះ»។
35នៅថ្ងៃនោះ លោកឡាបាន់បានយកពពែឈ្មោលដែលឆ្នូតៗ ពពាល និងពពែញីដែលពព្លាក់ និងពពាល គ្រប់ទាំងសត្វដែលមានសម្បុរសដុំៗ និងអស់ទាំងសត្វខ្មៅក្នុង
ហ្វូងចៀមទាំងអស់ ប្រគល់ទៅឲ្យកូនៗរបស់គាត់មើលថែ។36លោកឡាបាន់បានធ្វើដំណើរអស់រយៈពេលបីថ្ងៃពីកន្លែងគាត់ទៅលោកយ៉ាកុប។ ដូច្នេះ លោកយ៉ាកុបបាន
ឃ្វាលហ្វូងសត្វដែលនៅសល់ទាំងអស់របស់លោកឡាបាន់។
37លោកយ៉ាកុបបានកាត់យកមែករលួស និងមែកចំបក់ ព្រមទាំងក្រចៅស្រស់ៗ និងមកបកសំបកជាកង់ៗ ឲ្យឃើញសាច់សៗ។38បន្ទាប់មក គាត់យកមែកដែលមានឆ្នូតៗ
នោះ ទៅដាក់នៅក្នុងចង្អូរ និងស្នូកជាកន្លែងដែលសត្វតែងមកផឹកទឹក ដើម្បីឲ្យសត្វទាំងនោះឃើញ ដ្បិត វាតែងតែពាក់គ្នានៅពេលផឹកទឹក។
39ហ្វូងសត្វដែលពាក់គ្នានៅមុខមែកឈើ ហើយហ្វូងសត្វនឹងបង្កើតកូនមានសម្បុរឆ្នូតៗ ពពាល និងពព្លាក់។ លោកយ៉ាកុបបានញែកកូនចៀមទាំងនោះ ប៉ុន្តែ តម្រង់
ឈ្មោលទាំងអស់បែរមុខទៅឯពួកចៀមឆ្នូត និងចៀមខ្មៅទាំងអស់ក្នុងហ្វូងសត្វរបស់ឡាបាន់។40បន្ទាប់មកគាត់ញែកហ្វូងសត្វរបស់គាត់ឲ្យនៅដោយឡែក
ហើយមិនបានដាក់ពួកគេឲ្យនៅជាមួយហ្វូងសត្វរបស់លោកឡាបាន់ឡើយ។
41នៅពេលណាចៀមណាខ្លាំងជាងនៅក្នុងហ្វូងដោយពាក់គ្នា ដូច្នេះ លោកយ៉ាកុបបានដាក់មែកឈើទាំងនោះនៅក្នុងប្រឡាយ មុនចំពោះភ្នែករបស់ហ្វូងសត្វនោះ
ដើម្បីពួកវាអាចពាក់គ្នានៅចំពោះមុខមែកឈើទាំងនោះ។42ប៉ុន្តែ នៅពេលសត្វណាខ្សោយចូលមកនៅក្នុងហ្វូងសត្វ គាត់មិនបានដាក់មែកឈើនៅចំពោះមុខពួកវាឡើយ។
ដូច្នេះ សត្វណាដែលខ្សោយជារបស់លោកឡាបាន់ ហើយសត្វណាដែលខ្លាំងជារបស់លោកយ៉ាកុប។
43លោកយ៉ាកុបបានក្លាយជាអ្នកមានយ៉ាងខ្លាំង។ គាត់មានហ្វូងសត្វយ៉ាងធំ មានអ្នកបម្រើស្រី និងអ្នកបម្រើប្រុស ហើយនិងសត្វអូដ្ឋ និងសត្វលាជាច្រើនផង។

## ជំពូក ៣១

1លោកយ៉ាកុបបានឮសម្ដីកូនប្រុសៗរបស់លោកឡាបាន់ ពួកគេនិយាយថា៖ «លោកយ៉ាកុបបានយកអ្វីៗទាំងអស់ដែលឪពុកយើងមានអស់ហើយ
ហើយទ្រព្យសម្បត្តិដែលគាត់មានគឺបានយកទ្រព្យសម្បត្តិឪពុកយើងទាំងអស់»។2លោកយ៉ាកុបមើលឃើញនៅលើទឹកមុខរបស់លោកឡាបាន់។ គាត់បានឃើញថា
ឥរិយាបថរបស់លោកឡាបាន់ចំពោះគាត់បានផ្លាស់ប្ដូរ។3បន្ទាប់មក ព្រះអម្ចាស់មានបន្ទូលទៅលោកយ៉ាកុបថា៖ «ចូរត្រឡប់ទៅទឹកដីឪពុក និងសាច់ញាតិរបស់អ្នកវិញចុុះ
ខ្ញុំនឹងនៅជាមួយអ្នក»។
4លោកយ៉ាកុបបានចាត់ ហើយបានហៅនាងរ៉ាជែល និងលេអាឲ្យមកឯវាលកន្លែងហ្វូងសត្វរបស់គាត់5ហើយនិយាយទៅពួកគេថា៖
«បងបានឃើញឥរិយាបថឪពុករបស់អូនចំពោះបងបានផ្លាស់ប្ដូរ ប៉ុន្តែ ព្រះជាម្ចាស់ឪពុករបស់បងបានគង់ជាមួយបង។6អូនដឹងហើយថា
បងបម្រើឪពុករបស់អូនអស់ពីកម្លាំងរបស់បង។


generated on Wed Mar 12 15:32:40 2025

## ជំពូក ៣១

7ឪពុករបស់អូនបានបោកប្រាស់បង ហើយបានប្តូរប្រាក់ឈ្នួលដប់ដង ប៉ុន្តែ ព្រះជាម្ចាស់មិនអនុញ្ញាតឲ្យគាត់ធ្វើទុក្ខបងបានទេ។8ប្រសិនបើ គាត់និយាយថា៖ «សត្វដែល
មានសម្បុរពពាល នឹងបានជាថ្លៃឈ្នួលរបស់ឯង» ដូច្នេះ ហ្វូងសត្វទាំងអស់ក៏បង្កើតកូនសុទ្ធតែសម្បុរពពាល ហើយប្រសិនបើគាត់និយាថា៖ «សត្វដែលមានសម្បុរឆ្នូតៗ
នឹងបានជាថ្លៃឈ្នួលរបស់ឯង» ដូច្នេះ ហ្វូងសត្វទាំងអស់បង្កើតកូនមកសុទ្ធតែឆ្នូតៗ។9ព្រះជាម្ចាស់បានយកហ្វូងសត្វរបស់ឪពុកអូនមកឲ្យបងរបៀបនេះឯង។
10នៅពេលដល់រដូវសត្វពាក់គ្នា បងបានយល់សុបិន ចៀមឈ្មោលដែលពាក់ហ្វូងសត្វទាំងអស់។ ពពែឈ្មោលសុទ្ធតែមានសម្បុរឆ្នូតៗ ពពាល និងមានសម្បុរអុជៗទាំង
អស់។11ទេវតារបស់ព្រះជាម្ចាស់និយាយមកកាន់បងក្នុងសុបិនថា៖ «យ៉ាកុបអើយ!»។ បងឆ្លើយថា៖ «បាទ!»។
12គាត់និយាយថា៖ «ចូរសម្លឹងហើយមើលពពែឈ្មោលទាំងអស់ដែលពាក់ជាមួយហ្វូងសត្វចុះ។ ពួកវាមានសម្បុរឆ្នូតៗ ពពាល និងមានសម្បុរអុជៗទាំងអស់ ដ្បិត
យើងបានឃើញពីកិច្ចការដែលលោកឡាបាន់បានធ្វើចំពោះអ្នកគ្រប់យ៉ាង។13យើងជាព្រះជាម្ចាស់នៅបេតអែល ជាកន្លែងដែលអ្នកបានចាក់ប្រេងលើសសរ
ហើយអ្នកបានស្បថជាមួយយើងនៅទីនោះ។ ចូរក្រោកឡើង ហើយចាកចេញពីស្រុកកំណើត ហើយត្រឡប់ទៅទឹកដីកំណើតរបស់អ្នកចុះ»។
14នាងរ៉ាជែល និងនាងលេអាបានឆ្លើយ ហើយនិយាយទៅគាត់ថា៖ «តើមានចំណែកណា ឬមរតកសម្រាប់យើង នៅក្នុងផ្ទះរបស់យើងទេ?
15តើយើងមិនបានប្រព្រឹត្តជាមួយគាត់ដូចជាជនបរទេសទេឬ? ដ្បិត គាត់បានលក់យើង ហើយបានយកប្រាក់របស់យើងថែមទៀតផង។16ដ្បិត
ទ្រព្យសម្បត្តិដែលព្រះជាម្ចាស់បានយកពីគាត់នៅពេលនេះ គឺជាទ្រព្យសម្បត្តិរបស់យើង និងកូនៗរបស់យើងទាំងអស់។ ដូច្នេះ ឥឡូវនេះ ប្រសិនបើ
ព្រះជាម្ចាស់មានបន្ទូលអ្វីមកកាន់បង ចូរធ្វើវាចុះ»។
17បន្ទាប់មក លោកយ៉ាកុបបានក្រោកឡើង ហើយដាក់កូនប្រុសៗ និងភរិយាទាំងពីររបស់គាត់នៅលើសត្វអូដ្ឋ។18គាត់បាននាំហ្វូងសត្វទាំងអស់នៅខាងមុខគាត់
ជាមួយនឹងទ្រព្យសម្បត្តិទាំងអស់របស់គាត់ បូករួមទាំងហ្វូងសត្វដែលគាត់មាននៅក្នុងទឹកដីប៉ាដាន់អើរ៉ាម។ បន្ទាប់មក
គាត់បានចាត់គេទៅរកឪពុករបស់គាត់នៅក្នុងទឹកដីកាណាន។
19នៅពេលលោកឡាបាន់បានចាកចេញទៅកាត់រោមចៀមរបស់គាត់ នាងរ៉ាជែលបានលួចរូបព្រះឪពុករបស់នាង។20លោកយ៉ាកុបបានលួចរត់ចេញពីលោកឡាបាន់ ជា
ជនជាតិអើរ៉ាម ដោយមិនបានប្រាប់ឲ្យគាត់ដឹងថាគាត់ចាកចេញឡើយ។21ដូច្នេះ គាត់បានរត់ចេញជាមួយនឹងអ្វីៗដែលគាត់មាន ហើយបានឆ្លងទន្លេយ៉ាងលឿន
ហើយឆ្ពោះទៅទឹកដីតំបន់ភ្នំកាឡាដ។
22នៅថ្ងៃទីបី ទើបលោកឡាបាន់ដឹងថា លោកយ៉ាកុបបានរត់។23ដូច្នេះ គាត់បាននាំយកសាច់ញាតិទៅជាមួយគាត់ ហើយដេញតាមពីក្រោយ អស់រយៈពេលប្រាំពីរថ្ងៃ។
គាត់បានទៅទាន់លោកយ៉ាកុបនៅតំបន់ភ្នំកាឡាដ។
24ព្រះជាម្ចាស់បានយាងមកឯលោកឡាបាន់ជនជាតិអើរ៉ាម នៅក្នុងសុបិននៅពេលយប់ ហើយមានបន្ទូលទៅគាត់ថា៖ «ចូរប្រយ័ត្ន
ជាមួយអ្វីដែលអ្នកនិយាយទៅកាន់យ៉ាកុប ទោះបើល្អ ឬអាក្រក់ក្តី»។25លោកឡាបាន់បានដេញទាន់លោកយ៉ាកុប។
ហើយលោកយ៉ាកុបបានសង់ត្រសាលរបស់គាត់នៅតំបន់ភ្នំកាឡាត។
26លោកឡាបាន់និយាយទៅលោកយ៉ាកុបថា៖ «ហេតុដូចម្តេចបានជាឯងធ្វើដូច្នេះ គឺប្រោកប្រាស់ខ្ញុំ ហើយបាននាំយកកូនស្រីរបស់ឪពុកមកដូចជាអ្នកទោសសង្គ្រាមដូច្នេះ?
27ហេតុអ្វីបានជាឯងលួចរត់ដោយសម្ងាត់ដូច្នេះ ហើយប្រើឧបាយកលជាមួយឪពុក ព្រមទាំងមិនប្រាប់ឪពុកដូច្នេះ? ដើម្បីឲ្យឪពុកបានជូនដំណើរដោយការអបអរសាទរ
ហើយនិងច្រៀង វាយក្រាប់ ព្រមទាំងចាប់ស៊ុងផង។28កូនមិនបានឲ្យឪពុកថើបលាចៅៗ និងកូនស្រីៗរបស់ឪពុកសោះ។ កូនបានធ្វើការដ៏ល្ងីល្ងើហើយ។
29ឪពុកមានអំណាចនឹងធ្វើទុក្ខដល់កូនបាន ប៉ុន្តែ ព្រះជាម្ចាស់ជាព្រះឪពុករបស់កូនមានបន្ទូលមកឪពុកកាលពីយប់មិញ ដោយមានបន្ទូលថា៖ «ចូរប្រយ័ត្ន
ជាមួយអ្វីដែលអ្នកនិយាយទៅកាន់យ៉ាកុប ទោះបើល្អ ឬអាក្រក់ក្តី»។30កូនបានធ្វើបែបនេះ ដោយសារកូនចង់ត្រឡប់ទៅផ្ទះឪពុករបស់កូនវិញ។ ប៉ុន្តែ
ហេតុអ្វីបានជាកូនលួចរូបព្រះរបស់ឪពុក?»
31លោកយ៉ាកុបឆ្លើយ ហើយនិយាយទៅកាន់លោកឡាបាន់ថា៖ «ដោយសារខ្ញុំខ្លាច ហើយគិតថា លោកឪពុកអាចនឹងយកកូនស្រីរបស់លោកឪពុកចេញពីខ្ញុំវិញ
ដោយប្រើកម្លាំង ដូច្នេះ ហើយខ្ញុំចេញដោយសម្ងាត់។32អ្នកណាក្តីដែលលួចរូបព្រះរបស់លោកឪពុក អ្នកនោះមិនអាចរស់ទៀតបានទេ។
សូមឆែកមើលនៅក្នុងវត្តនាមរបស់សាច់ញាតិចុះ បើរកឃើញអ្នកណាដែលនៅជាមួយខ្ញុំ សូមយករបស់លោកឪពុកទៅវិញចុះ»។ ដ្បិត លោកយ៉ាកុបមិនបានដឹងថា
នាងរ៉ាជែលបានលួចវាទេ។
33លោកឡាបាន់បានចូលទៅក្នុងត្រសាលរបស់លោកយ៉ាកុប ទៅក្នុងត្រសាលរបស់នាងលេអា និងចូលទៅក្នុងត្រសាលរបស់អ្នកបម្រើស្រីទាំងពីរ ប៉ុន្តែ
គាត់រកវាមិនឃើញទេ។ គាត់បានចេញពីត្រសាលរបស់នាងលេអា ហើយចូលទៅក្នុងត្រសាលរបស់នាងរ៉ាជែល។
34នាងរ៉ាជែលបានយករូបព្រះពីផ្ទះរបស់ឪពុកនាង ដាក់វានៅក្រោមកែបអូដ្ឋ ហើយអង្គុយពីលើវា។ លោកឡាបាន់បានរុករកពេញត្រសាលទាំងមូល ប៉ុន្តែ
រករូបព្រះទាំងនោះមិនឃើញទេ។35នាងនិយាយទៅកាន់ឪពុករបស់នាងថា៖ «លោកឪពុកអើយ សូមកុំខឹងអី ព្រោះកូនមិនអាចឈរនៅចំពោះលោកឪពុកបាន
ដើម្បីកូនកំពុងមករដូវ»។
36លោកយ៉ាកុបខឹង ហើយឈ្លោះនឹងលោកឡាបាន់។ គាត់និយាយទៅលោកឡាបាន់ថា៖ «តើកូនមានទោសអ្វី? តើកូនបានធ្វើបាបអ្វី
បានជាលោកឪពុកដេញតាមកូនពីក្រោយដូច្នេះ?37ដ្បិត លោកឪពុកបានរុករកទ្រព្យសម្បត្តិទាំងអស់របស់ខ្ញុំ។
តើលោកឪពុកបានរករូបព្រះរបស់គ្រួសារលោកឪពួកឃើញទេ? ចូរដាក់វានៅចំពោះមុខសាច់ញាតិរបស់យើង ដើម្បីពួកគេបានកាត់ក្តីរវាងយើងទាំងពីរ។
38ដ្បិត កូនបាននៅជាមួលលោកឪពុកអស់រយៈពេលម្ភៃឆ្នាំ។ គ្មានមេចៀម និងមេពពែត្រូវរលូតឡើយ ឬខ្ញុំបានហូបចៀមឈ្មោលពីហ្វូងសត្វរបស់លោកឪពុកឡើយ។
39សត្វណាដែលសត្វសាហាវស៊ី ខ្ញុំមិនបានយកទៅជូនលោកឪពុក ផ្ទុយទៅវិញ ខ្ញុំបានសងជំនួសអ្វីដែលបាត់បង់ទៅវិញ។
លោកឪពុកតែងតែឲ្យកូនសងសត្វដែលបាត់ទាំងអស់ មិនបាត់ដោយសារគេលួចនៅពេលយប់ ឬនៅពេលថ្ងៃក្តី។40នៅពេលថ្ងៃ កូននៅក្រោមកម្តៅថ្ងៃ
ហើយនៅពេលយប់កូនរងារ ហើយមើលមិនបានដេកឡើយ។
41ក្នុងរយៈពេលម្ភៃឆ្នាំនេះ កូនបាននៅក្នុងផ្ទះរបស់លោកឪពុក។ កូនធ្វើការជូនលោកឪពុកដប់បួនឆ្នាំ ដើម្បីឲ្យបានកូនស្រីទាំងពីររបស់លោកឪពុក
ហើយធ្វើការប្រាំមួយឆ្នាំដើម្បីឲ្យបានហ្វូងសត្វ។ លោកឪពុងបានបន្លំថ្លៃឈ្នួលរបស់ខ្ញុំដប់ដង។42ប្រសិនបើ ព្រះជាម្ចាស់របស់ឪពុកខ្ញុំ ជាព្រះជាម្ចាស់របស់លោកអប្រាហាំ
ហើយជាព្រះដែលលោកអ៊ីសាកគោរពបម្រើ បានគង់នៅជាមួយខ្ញុំទេ ប្រាកដណាស់ លោកឪពុកនឹងបណ្តេញកូនឲ្យទៅដោយដៃទទេមិនខាន។
ព្រះជាម្ចាស់បានឃើញពីទុក្ខលំបាករបស់ខ្ញុំ ហើយទតឃើញពីការខំប្រឹងធ្វើការរបស់ខ្ញុំ ហើយព្រះអង្គបានដាស់តឿនលោកឪពុកកាលពីយប់មិញ»។
43លោកឡាបាន់ឆ្លើយ ហើយនិយាយថា៖ «កូនស្រីៗគឺជាកូនស្រីៗរបស់ឪពុក ហើយចៅៗគឺជាចៅៗរបស់ឪពុក ព្រមទាំងហ្វូងសត្វក៏ជាហ្វូងសត្វរបស់ឪពុកដែរ។
អ្វីៗទាំងអស់ដែលកូនឃើញជារបស់ឪពុក។ ប៉ុន្តែ អ្វីដែលកូនឯងត្រូវធ្វើនៅថ្ងៃនេះ ចំពោះកូនស្រីរបស់ឪពុក ឬទៅកាន់ក្មេងៗរបស់ពួកគេដែលពួកគេបានបង្កើតមក?
44ដូច្នេះ នៅពេលនេះ ចូរយើងចងសម្ពន្ធមេត្រី រវាងកូននិងឪពុក ហើយសូមឲ្យវាធ្វើជាបន្ទាល់រវាងកូននិងឪពុកដែរ»។
45ដូច្នេះ លោកយ៉ាកុបបានយកថ្ម ហើយតាំងវាឡើងជាសសរ។ លោកយ៉ាកុបនិយាយទៅកាន់សាច់ញាតិរបស់គាត់ថា៖ «ចូរប្រមូលថ្មដាក់មួយដុំ»។46ដូច្នេះ ពួកគេក៏យកថ្ម
មកធ្វើជាបង្គោល។ បន្ទាប់មក ពួកគេហូបក្បែរបង្គោលនៅទីនោះ។47លោកឡាបាន់ហៅវាថា យេការសាហាឌូថា តែលោកយ៉ាកុបហៅវាថា កាលេឌ វិញ។
48លោកឡាបាន់និយាយថា៖ «បង្គោលនេះជាសាក្សីរវាងឪពុកនិងកូននៅថ្ងៃនេះ»។ ហេតុដូច្នេះហើយបានជាគេដាក់ឈ្មោះថា កាឡេដ។
49គេក៏បានដាក់ឈ្មោះមីសប៉ាផងដែរ ដោយសារលោកឡាបាន់និយាយថា៖ «សូមព្រះអម្ចាស់ទតមើលរវាងកូននិងឪពុក នៅពេលយើងលែងឃើញមុខគ្នាទៀត។
50ប្រសិនបើ កូនប្រព្រឹត្តមិនត្រឹមត្រូវជាមួយនឹងកូនស្រីរបស់ឪពុក ឬប្រសិនបើ កូនមានភរិយាផ្សេងក្រៅពីកូនស្រីរបស់ឪពុក ទោះបីជាកូនគ្មាននរណានៅជាមួយយើងក្តី
មើល ព្រះជាម្ចាស់គឺជាសាក្សីរវាងកូននិងឪពុក»។

[51]លោកឡាបាន់និយាយទៅលោកយ៉ាកុបថា៖ «ចូរមើលទៅបង្គោល ហើយមើលទៅឯសសរ ដែលឪពុកបានដាក់តាំងរវាងកូននិងឪពុក។[52]បង្គោលនេះគឺជាសាក្សី
ហើយសសរគឺជាទីបន្ទាល់ ដែលកូនមិនត្រូវរំលង បង្គោល និងសសរនេះមករកឪពុក ដើម្បីធ្វើទុក្ខដល់ឪពុកឡើយ។ សូមព្រះជាម្ចាស់នៃលោកអប្រាហាំ
និងព្រះរបស់លោកណាឃរ ជាព្រះរបស់ឪពុកពួកគេរៀងខ្លួន កាត់ក្តីរវាងពួកយើង»។[53]លោកយ៉ាកុបបានស្បថនឹងព្រះ ជាមួយព្រះជាម្ចាស់លោកអ៊ីសាកជាឪពុករបស់គាត់
កោតខ្លាច។
[54]លោកយ៉ាកុបបានថ្វាយយញ្ញបូជានៅលើភ្នំ ហើយហៅសាច់ញាតិរបស់គាត់មកហូបសាច់នៅទីនោះ។ ពួកគេហូប ហើយចំណាយពេលមួយយប់នៅលើភ្នំនោះ។
[55]ព្រឹកព្រលឹម លោកឡាបាន់បានក្រោកឡើង បានថើបចៅៗ និងកូនស្រីៗរបស់គាត់ ហើយឲ្យពរដល់ពួកគេ។ បន្ទាប់មក លោកឡាបាន់បានចាកចេញ
ហើយត្រឡប់ទៅផ្ទះវិញ។

## ជំពូក ៣២

[1]លោកយ៉ាកុបក៏បន្តដំណើរទៅមុខទៀត ហើយទេវតារបស់ព្រះជាម្ចាស់បានមកជួបគាត់។[2]នៅពេលលោកយ៉ាកុបឃើញពួកគេ គាត់និយាយថា៖
«នេះគឺជាជំរំរបស់ព្រះជាម្ចាស់» ដូច្នេះ គាត់បានដាក់ឈ្មោះកន្លែងនោះថា ម៉ាហាណែម។
[3]លោកយ៉ាកុបបានចាត់អ្នកនាំសារទៅមុនគាត់ដើម្បីជួបលោកអេសាវ បងប្រុសរបស់គាត់ នៅក្នុងទឹកដីសៀរ នៅក្នុងតំបន់អេដុម។[4]គាត់បានបង្គាប់ដល់ពួកគេ
ដោយនិយាយថា៖ «នេះគឺជាអ្វីដែលអ្នកត្រូវនិយាយទៅកាន់លោកអេសាវ បងប្រុសរបស់ខ្ញុំគឺ លោកយ៉ាកុប ជាអ្នកបម្រើរបស់លោក បាននិយាយថា៖
«ខ្ញុំបានស្នាក់នៅក្នុងផ្ទះរបស់លោកឡាបាន់ ហើយបានពន្យាពេលនៃការត្រឡប់មកវិញរហូតមកដល់សព្វថ្ងៃនេះ។[5]ខ្ញុំមានគោឈ្មោល សត្វលា និងហ្វូងសត្វ
អ្នកបម្រើប្រុសៗ និងអ្នកបម្រើស្រីៗ។ ខ្ញុំសូមផ្ញើសារនេះទៅលោកម្ចាស់មុន ដើម្បីឲ្យខ្ញុំបានជាទីគាត់ចិត្តនៅចំពោះលោកម្ចាស់»។
[6]អ្នកនាំសារបានត្រឡប់មកឯលោកយ៉ាកុបវិញ ហើយនិយាយថា៖ «យើងបានទៅជួបលោកអេសាវបងប្រុសរបស់លោកហើយ។ គាត់កំពុងតែមកជួបលោក
ហើយមានមនុស្សបួនរយនាក់មកជាមួយគាត់»។[7]បន្ទាប់មកលោកយ៉ាកុបមានការភ័យខ្លាច ហើយព្រួយចិត្តជាខ្លាំង។ ដូច្នេះ
គាត់បានបំបែកមនុស្សដែលនៅក្នុងជំរំជាមួយគាត់ជាពីរ ហើយនិងហ្វូងសត្វ ហ្វូងចៀម និងសត្វអូដ្ឋ។[8]គាត់និយាយថា៖ «ប្រសិនបើ បងអេសាវមកដល់ជំរំមួយ
ហើយវាយប្រហារវា នោះជំរំដែលនៅសល់នឹងរួចជីវិត»។
[9]លោកយ៉ាកុបទូលថា៖ «ព្រះជាម្ចាស់របស់លោកឪពុកអប្រាហាំ និងជាព្រះជាម្ចាស់របស់លោកអ៊ីសាកជាឪពុករបស់ទូលបង្គំអើយ
គឺព្រះអម្ចាស់ដែលបានមានបន្ទូលមកទូលបង្គំថា៖ «ចូរត្រឡប់ទៅស្រុកកំណើត និងទៅញាតិសណ្តាន យើងនឹងធ្វើឲ្យអ្នកចម្រុងចម្រើន»។
[10]ទូលបង្គំមិនស័ក្តសមនឹងទទួលការចងសម្ពន្ធមេត្រីដ៏ស្មោះត្រង់ ហើយអាចទុកចិត្តបាន ដែលព្រះអង្គបានធ្វើសម្រាប់អ្នកបម្រើព្រះអង្គទេ។ ដ្បិត
កាលទូលបង្គំឆ្លងកាត់ទន្លេយ័រដាន់នេះទៅ ទូលបង្គំមានតែដំបងមួយ ហើយឥឡូវនេះ ទូលបង្គំមានជំរំពីរ។
[11]សូមសង្គ្រោះទូលបង្គំពីដៃបងប្រុសរបស់ទូលបង្គំ គឺពីដៃរបស់បងអេសាវ ដើម្បីទូលបង្គំខ្លាចគាត់ ក្រែងគាត់មក ហើយវាយប្រហារទូលបង្គំ និងភរិយារបស់ទូលបង្គំ។
[12]ប៉ុន្តែ ព្រះអង្គមានបន្ទូលថា៖ «យើងនឹងធ្វើឲ្យអ្នកចម្រុងចម្រើនជាប្រាកដ។ យើងនឹងធ្វើឲ្យពូជពង្សរបស់អ្នកដូចជាខ្សាច់សមុទ្រ ដែលមានចំនួនច្រើនឥតគណនា»។
[13]លោកយ៉ាកុបស្នាក់នៅទីនោះមួយយប់។ គាត់បានយកពីអ្វីដែលគាត់មានខ្លះទៅជាមួយគាត់ទុកជាអំណោយដល់លោកអេសាវ បងប្រុសរបស់គាត់។[14]មានពពែញីពីររយ
និងពពែឈ្មោលម្ភៃ ចៀមញីពីររយ និងចៀមឈ្មោលម្ភៃ[15]អូដ្ឋញីដែលបំបៅដោះសាមសិប ព្រមទាំងកូនវា គោញីសែសិប និងគោបាដប់ លាញីម្ភៃ និងលាឈ្មោលដប់។
[16]គាត់បានប្រគល់សត្វទាំងនោះទៅដៃអ្នកបម្រើរបស់គាត់ តាមហ្វូងរបស់វារៀងៗខ្លួន។ គាត់ប្រាប់ទៅអ្នកបម្រើរបស់គាត់ថា៖ «ចូរទៅមុនខ្ញុំ
ហើយដាក់ហ្វូងសត្វឲ្យនៅដាច់ពីគ្នា»។
[17]គាត់បានបង្គាប់ដល់អ្នកបម្រើទីមួយរបស់គាត់ ដោយប្រាប់ថា៖ «នៅពេលលោកអេសាវ បងប្រុសរបស់ខ្ញុំជួបអ្នក ហើយសួរអ្នក ដោយនិយាយថា៖
«តើអ្នកជាអ្នកបម្រើនរណា? តើអ្នកទៅណា? តើសត្វទាំងអស់ដែលនៅចំពោះមុខអ្នកនេះ ជារបស់នរណា?[18]ដូច្នេះ អ្នកត្រូវប្រាប់ថា៖ «សត្វទាំងអស់នេះ
ជារបស់លោកយ៉ាកុប។ ពួកវាជាអំណោយយកមកជូនលោកអេសាវ ជាចៅហ្វាយរបស់ខ្ញុំ។ មើល៍ គាត់ក៏មកជាមួយយើងដែរ»។
[19]លោកយ៉ាកុបក៏បានណែនាំដល់ក្រុមទីពីរ និងទីបី ព្រមទាំងពួកអ្នកបម្រើទាំងអស់ដែលដើរតាមហ្វូងសត្វដែរ។ គាត់ប្រាប់ថា៖
«អ្នករាល់គ្នាត្រូវនិយាយដូចគ្នាទៅកាន់លោកអេសាវ នៅពេលអ្នកជួបគាត់។[20]អ្នករាល់គ្នាត្រូវតែនិយាយថា៖
«លោកយ៉ាកុបជាអ្នកបម្រើលោកកំពុងតែមកតាមក្រោយយើងខ្ញុំដែរ»។ ដ្បិត គាត់គិតថា៖ «ពេលខ្ញុំមកជួបគាត់ ជាមួយនឹងអំណោយបានខ្ញុំបានចាត់ទៅមុនខ្ញុំនេះ។ នោះ
ពេលគាត់បានឃើញ ប្រហែលជាគាត់នឹងទទួលខ្ញុំមិនខាន»។[21]ដូច្នេះ គាត់បានបញ្ជូនអំណោយទៅមុនគាត់។ គាត់ខ្លួនឯងស្នាក់នៅជំរំមួយយប់ទៀត។
[22]លោកយ៉ាកុបក្រោកឡើងនៅពេលយប់ ហើយយកភរិយាទាំងពីរ និងអ្នកបម្រើស្រីទាំងពីររបស់គាត់ ព្រមទាំងកូនទាំងដប់មួយនាក់របស់គាត់។
[23]គាត់បានបញ្ជូនពួកគេឲ្យឆ្លងទឹកជាមួយនឹងទ្រព្យសម្បត្តិទាំងអស់របស់គាត់។
[24]លោកយ៉ាកុបបាននៅតែម្នាក់ឯង ហើយបានបោកចំបាប់ជាមួយអ្នកនោះមួយយប់។[25]នៅពេលបុរសនោះឃើញថា គាត់មិនអាចយកឈ្នះលោកយ៉ាកុបបាន គាត់បានក៏
វាយចំត្រគាករបស់លោកយ៉ាកុប។ ពេលលោកយ៉ាកុបបោកចំបាប់គ្នានោះ គាត់បានផ្លោះត្រគាក។[26]បុរសនោះនិយាយថា៖ «សូមឲ្យខ្ញុំទៅចុះ ដ្បិតជិតភ្លឺហើយ»។
លោកយ៉ាកុបនិយាយថា៖ «ខ្ញុំមិនឲ្យលោកទៅទេ លុះត្រាតែលោកឲ្យពរខ្ញុំសិន»។
[27]បុរសនោះនិយាយទៅគាត់ថា៖ «តើអ្នកឈ្មោះអ្វី?» លោកយ៉ាកុបឆ្លើយថា៖ «យ៉ាកុប»។[28]បុរសនោះនិយាយថា៖ «ឈ្មោះរបស់អ្នកលែងជាយ៉ាកុបទៀតហើយ
ប៉ុន្តែត្រូវប្តូរទៅឈ្មោះអ៊ីស្រាអែលវិញ។ ដ្បិត អ្នកបានបោកចំបាប់ជាមួយព្រះជាម្ចាស់ ហើយនឹងមនុស្ស ហើយអ្នកបានឈ្នះ»។
[29]លោកយ៉ាកុបសួរគាត់ថា៖ «សូមប្រាប់ឈ្មោះរបស់អ្នកឲ្យខ្ញុំផង»។ គាត់ប្រាប់ថា៖ «ហេតុអ្វីបានជាអ្នកសួរឈ្មោះខ្ញុំ?» បន្ទាប់មក
គាត់ក៏ឲ្យពរដល់លោកយ៉ាកុបនៅទីនោះ។[30]លោកយ៉ាកុបដាក់ឈ្មោះកន្លែងនោះថា ព្នីអែល ដ្បិត គាត់និយាយថា៖ «ខ្ញុំបានឃើញព្រះភក្ត្រព្រះជាម្ចាស់មុខទល់នឹងមុខ
ហើយព្រះអង្គបានរំដោះជីវិតខ្ញុំ»។
[31]ថ្ងៃបានរះឡើងចំលោកយ៉ាកុប នៅពេលគាត់ដើរកាត់ព្នីអែល។ គាត់ដើរខ្ញើចៗ ព្រោះផ្លោះត្រគាករបស់គាត់។[32]ហេតុដូច្នេះហើយ
បានជាជនជាតិអ៊ីស្រាអែលមិនហូបសាច់នៅត្រង់ត្រគាកជាកន្លែងដែលព្រះជាម្ចាស់បានធ្វើឲ្យគាត់ផ្លោះនៅត្រង់ត្រគាកនោះ។

## ជំពូក ៣៣

[1]លោកយ៉ាកុបបានងើបមុខឡើង ហើយមើល៍ លោកអេសាវកំពុងតែមករក មានប្រុសៗបួនរយនាក់មកជាមួយគាត់ផង។ លោកយ៉ាកុបបានបំបែកកូនៗរបស់នាងលេអា
នាងរ៉ាជែល និងកូនៗរបស់ស្រីបម្រើទាំងពីរផងដែរ។[2]បន្ទាប់មក គាត់បានដាក់កូនៗរបស់អ្នកបម្រើរបស់គាត់នៅខាងមុខ បន្ទាប់មក នាងលេអា និងកូនៗរបស់នាង
ហើយបន្ទាប់មកកូនរបស់នាងរ៉ាជែល ហើយយ៉ូសែបដាក់នៅក្រោយគេបង្អស់។[3]គាត់ខ្លួនឯងបានទៅមុខពួកគេ។ គាត់បានលុតជង្គង់ចុះ ផ្កាប់មុខទៅដីប្រាំពីរដង
រហូតទាល់តែបងប្រុសរបស់គាត់មកជិត។
[4]លោកអេសាវបានរត់មកជួបគាត់ ឱបកគាត់ហើយថើបគាត់។ ពួកគេយំ។[5]ពេលលោកអេសាវងើបមុខឡើង គាត់ឃើញស្រីៗ និងកូនៗ។ គាត់សួរថា៖
«តើអ្នកនៅជាមួយប្អូននេះជានរណា?» លោកយ៉ាកុបប្រាប់ថា៖ «កូនៗដែលព្រះជាម្ចាស់មេត្តាប្រទានដល់ខ្ញុំជាអ្នកបម្រើរបស់បង»។

[6]បន្ទាប់មក អ្នកបម្រើស្រីៗបានចេញមកខាងមុខជាមួយនឹងកូនៗរបស់ពួកគេ ហើយពួកគេបានក្រាបចុះ។[7]បន្ទាប់មក នាងលេអា និងកូនៗរបស់នាង
ក៏បានចេញមកខាងមុខ ហើយក្រាបចុះដែរ។ ចុងក្រោយ យ៉ូសែប និងនាងរ៉ាជែលបានចេញមកខាងមុខ ហើយលុតជង្គងចុះដែរ។[8]លោកអេសាវសួរថា៖
«តើអ្នកដែលបងបានជួបទាំងនេះ ជានរណា?» លោកយ៉ាកុបប្រាប់ថា៖ «ដើម្បីសូមក្ដីមេត្តាពីបង»។
[9]លោកអេសាវនិយាយថា៖ «ប្អូនអើយ បងមានគ្រប់គ្រាន់ហើយ។ ទុកវាសម្រាប់ខ្លួនឯងទៅ»។[10]លោកយ៉ាកុបនិយាយថា៖ «អត់ទេបង ប្រសិនបើបងមេត្តាដល់ខ្ញុំមែន
សូមទទួលយកពីខ្ញុំផង តាមពិតទៅ ពេលខ្ញុំបានជួបមុខបង ប្រៀបបីដូចជា ខ្ញុំបានជួបព្រះភក្ត្រព្រះជាម្ចាស់ដូច្នោះដែរ ហើយបងបានទទួលស្គាល់ខ្ញុំ។
[11]សូមទទួលអំណោយដែលបាននាំយកមកជូនបងចុះ ព្រោះព្រះជាម្ចាស់បានផ្ដល់ក្ដីមេត្តាដល់ខ្ញុំ ហើយខ្ញុំក៏មានគ្រប់គ្រាន់ដែរ»។ ដោយសារលោកយ៉ាកុបទទូចគាត់ពេក
លោកអេសាវក៏ទទួល។
[12]បន្ទាប់មក លោកអេសាវនិយាយថា៖ «តោះយើងចេញដំណើរទាំងអស់គ្នា។ បងនឹងទៅពីមុខប្អូន»។[13]លោកយ៉ាកុបនិយាយទៅគាត់ថា៖ «បងអើយ បងដឹងហើយថា
កូនៗរបស់ខ្ញុំនៅក្មេង ហើយ ចៀម និងហ្វូងគោ ក៏មានកូនបៅដោះដែរ។ ប្រសិនបើ ពួកគេខំប្រឹងតាមបងពេក តែមួយថ្ងៃ សត្វទាំងអស់មុខជាស្លាប់អស់មិនខាន។
[14]សូមបងទៅមុនខ្ញុំចុះ។ ខ្ញុំនឹងធ្វើដំណើរយឺតៗជាមួយហ្វូងសត្វ និងក្មេងៗ រហូតទៅដល់ទីលំនៅរបស់បង នៅទឹកដីសៀរ»។
[15]លោកអេសាវនិយាយថា៖ «អ៊ីចឹង បងនឹងទុកពួកប្រុសៗដែលមកជាមួយបង នៅជាមួយប្អូនខ្លះ»។ ប៉ុន្តែ លោកយ៉ាកុបនិយាយថា៖ «មិនបាច់ធ្វើអ៊ីចឹងទេ?
បងបានធ្វើល្អចំពោះខ្ញុំគ្រប់គ្រាន់រួចមកហើយ»។[16]ដូច្នេះ លោកអេសាវបានធ្វើដំណើរត្រឡប់មកទឹកដីសៀរវិញ នៅថ្ងៃដដែលនោះ។
[17]លោកយ៉ាកុបបានធ្វើដំណើរទៅទឹកដីស៊ូកូថ សង់ផ្ទះ ហើយធ្វើជម្រកសម្រាប់ហ្វូងសត្វរបស់គាត់នៅទីនោះ។ ហេតុដូច្នេះហើយ គេបានហៅឈ្មោះនៅទីនោះថា ស៊ូកូថ។
[18]ពេលលោកយ៉ាកុបចេញទឹកដីប៉ាដាន់អើរ៉ាម គាត់បានមកដល់ទីក្រុងស៊ីគែមដោយសុវត្ថិភាព ជាទឹកដីរបស់ស្រុកកាណាន។ គាត់បានបោះជំរំនៅក្បែរទីក្រុងនោះ។
[19]បន្ទាប់មក គាត់បានទិញដីមួយកន្លែង គាត់បានសង់ត្រសាលរបស់គាត់នៅក្នុងចំណោមកូនចៅរបស់លោកហាម៉ោរ ត្រូវជាឪពុករបស់លោកស៊ីគែម ក្នុងតម្លៃប្រាក់សុទ្ធ
មួយរយស្លឹង។[20]គាត់បានសង់អាសនៈមួយ ហើយបានហៅវាថា អែល អែឡូហេអ៊ីស្រាអែល។

ជំពូក ៣៤

[1]នាងឌីណា ជាកូនស្រីរបស់នាងលេអា ដែលនាងបានបង្កើតឲ្យលោកយ៉ាកុប នាងបានទៅជួបស្ត្រីវ័យក្មេងនៅក្នុងទឹកដី។[2]ពេលនោះ លោកស៊ីគែមជាកូនរបស់លោក
ហាម៉ោរ ជនជាតិហេវី ដែលជាមេនៅស្រុកនោះ បានឃើញនាង ហើយចាប់នាងរំលោភផង។[3]គាត់ជាប់ចិត្តនឹងនាងឌីណា កូនស្រីរបស់លោកយ៉ាកុបជាខ្លាំង។
គាត់បានស្រឡាញ់ ហើយថ្នាក់ថ្នមនាងជាខ្លាំង។
[4]លោកស៊ីគែមបាននិយាយជាមួយលោកហាម៉ោរ ជាឪពុករបស់គាត់ ដោយប្រាប់ថា៖ «សូមយកនាងឲ្យធ្វើជាភរិយារបស់ខ្ញុំមក»។[5]លោកយ៉ាកុបបានឮថា
គាត់បានបង្ខូចកិត្តិយសនាងឌីណាកូនស្រីរបស់គាត់។ កូនប្រុសៗ និងហ្វូងសត្វរបស់គាត់នៅឯវាល ដូច្នេះ លោកយ៉ាកុបក៏នៅស្ងៀមរហូតដល់ពួកគេមក។
[6]លោកហាម៉ោរ ជាឪពុករបស់លោកស៊ីគែមបានចេញទៅជួបលោកយ៉ាកុប ដើម្បីនិយាយជាមួយគាត់។[7]កាលកូនប្រុសៗរបស់លោកយ៉ាកុបបានមកដល់ពីវាលវិញ
ពួកគេបានឮរឿងនេះ។ ពួកគេរវាតចិត្ត។ ពួកគេខឹងជាខ្លាំង ពីព្រោះគាត់បានប្រមាថលោកអ៊ីស្រាអែល ដោយបង្ខំខ្លួនគាត់ជាមួយកូនស្រីរបស់លោកយ៉ាកុប
គឺជារឿងដែលមិនគួរឲ្យធ្វើឡើយ។
[8]លោកហាម៉ោរបាននិយាយជាមួយពួកគេ ដោយពោលថា៖ «ស៊ីគែម កូនប្រុសរបស់ខ្ញុំ ស្រឡាញ់កូនស្រីរបស់លោក។ សូមប្រគល់នាងឲ្យកូនប្រុសខ្ញុំ ធ្វើជាភរិយាចុះ។
[9]សូមភ្ជាប់សាច់ឈាមជាមួយយើង ដោយប្រគល់កូនស្រីរបស់លោកមកយើង ហើយយកពួកកូនស្រីរបស់យើងទៅធ្វើជាភរិយារបស់អ្នករាល់គ្នាចុះ។
[10]អ្នករាល់នឹងរស់នៅជាមួយយើង ហើយទឹកដីនេះ នឹងបើកចំហសម្រាប់អ្នករាល់គ្នារស់នៅ និងធ្វើជំនួញ ព្រមទាំងអាចទិញដីនៅក្នុងស្រុកនេះបាន។
[11]លោកស៊ីគែមនិយាយទៅកាន់ឪពុក និងបងប្អូនរបស់នាងថា៖ «សូមមេត្តាដល់ខ្ញុំផង ហើយអ្វីៗដែលលោកប្រាប់ដល់ខ្ញុំនឹងប្រគល់ឲ្យ។
[12]សូមទាមទារពីខ្ញុំនៅតម្លៃបណ្ណាការ និងអំណោយតាមដែលលោកទាមទារ ខ្ញុំនឹងប្រគល់អ្វីៗតាមដែលលោកបង្គាប់ដល់ខ្ញុំ ប៉ុន្តែ
សូមប្រគល់កូនស្រីរបស់លោកឲ្យខ្ញុំធ្វើជាភរិយាចុះ»។[13]កូនប្រុសៗរបស់លោកយ៉ាកុបឆ្លើយទៅលោកស៊ីគែម និងលោកហាម៉ោរ ឪពុករបស់គាត់ដោយល្បិចកល
ព្រោះលោកស៊ីគែមបានបង្ខូចកិត្តិយសនាងឌីណា ប្អូនស្រីរបស់ពួកគេ។
[14]កូនៗរបស់លោកយ៉ាកុបនិយាយទៅពួកគេថា៖ «យើងមិនអាចធ្វើការនេះបានទេ ក្នុងការប្រគល់ប្អូនស្រីរបស់យើងដល់នរណាម្នាក់ដែលមិនបានកាត់ស្បែកឡើយ
បើធ្វើបែបនេះនឹងបង្ខូចកិត្តិយសរបស់យើង។[15]មានតែលក្ខខណ្ឌមួយនេះទេ ទើបយើងយល់ព្រមជាមួយលោក ប្រសិនបើ
ពួកប្រុសៗទាំងអស់ក្នុងចំណោមអស់លោកកាត់ស្បែកដូចយើង ។[16]ដូច្នេះ យើងនឹងប្រគល់កូនស្រីរបស់យើងដល់លោក
ហើយយើងនឹងយកកូនស្រីរបស់អស់លោកមកឯយើងដែរ ហើយយើងនឹងរស់នៅជាមួយលោក និងក្លាយទៅជាមនុស្សតែមួយ។[17]ប៉ុន្តែ ប្រសិនបើ
លោកមិនព្រមស្ដាប់តាមយើងទេ ហើយមិនព្រមកាត់ស្បែក ដូច្នេះ យើងនឹងយកប្អូនស្រីរបស់យើងទៅវិញ ហើយយើងនឹងចាកចេញពីទីនេះ។
[18]លោកហាម៉ោរ និងលោកស៊ីគែមបំពេញចិត្តនឹងពាក្យសំដីរបស់ពួកគេ។[19]បុរសវ័យក្មេងនោះមិនបង្អង់ក្នុងការធ្វើតាមអ្វីដែលពួកគេបាននិយាយ
ព្រោះគាត់ស្រឡាញ់កូនស្រីរបស់លោកយ៉ាកុបណាស់ ហើយនៅក្នុងផ្ទះរបស់ឪពុកគាត់ គេគោរពលោកស៊ីគែមជាងគេបំផុត។
[20]លោកហាម៉ោរ និងលោកស៊ីគែម កូនប្រុសរបស់គាត់បានទៅទ្វារក្រុងរបស់ពួកគេ ហើយនិយាយទៅកាន់ពួកប្រុសៗទាំងអស់គ្នា ដោយពោលថា៖
[21]«បុរសទាំងនេះចង់បានសុខជាមួយយើង ដូច្នេះ ចូរឲ្យពួកគេរស់នៅក្នុងទឹកដី ហើយធ្វើជំនួញនៅក្នុងស្រុកជាមួយយើង ទឹកដីរបស់យើងធំល្មមសម្រាប់ពួកគេ។
ចូរឲ្យយើងយកកូនស្រីរបស់ពួកគេមកធ្វើជាប្រពន្ធ ហើយឲ្យពួកគេយកកូនស្រីរបស់យើងធ្វើជាប្រពន្ធវិញ។
[22]មានលក្ខខណ្ឌតែមួយគត់ដើម្បីឲ្យពួកគេរស់នៅជាមួយយើង ហើយក្លាយជាជនជាតិតែមួយរបស់យើងគឺ ប្រសិនបើ បុរសទាំងអស់ដែលនៅក្នុងចំណោមយើងកាត់ស្បែក
ដូចពួកគេបានកាត់ស្បែកដែរ។[23]តើហ្វូងសត្វ និងទ្រព្យសម្បត្តិរបស់ពួកគេ ហ្វូងសត្វទាំងអស់របស់ពួកគេមិនមែនជារបស់យើងទេឬអី? ដូច្នេះ ចូរយើងព្រមជាមួយពួកគេ
ហើយពួកគេនឹងរស់នៅក្នុងចំណោមយើង»។
[24]ពួកប្រុសៗទាំងអស់ដែលនៅក្នុងក្រុងនោះបានស្ដាប់តាមលោកហាម៉ោរ និងលោកស៊ីគែម កូនប្រុសរបស់គាត់។[25]ពួកប្រុសៗត្រូវបានកាត់ស្បែកទាំងអស់គ្នា។ នៅថ្ងៃទីបី
នៅពេលពួកគេកំពុងតែឈឺ កូនប្រុសរបស់លោកយ៉ាកុបពីរនាក់ (លោកស៊ីម្មាន និងលោកលេវី ត្រូវជាបងរបស់នាងឌីណា) ម្នាក់ៗយកដាវរបស់គាត់រៀងខ្លួន
ហើយពួកគេបានប្រហារទីក្រុងដែលមានសុវត្ថិភាព ហើយពួកគេបានសម្លាប់ប្រុសៗទាំងអស់។[26]ពួកគេបានសម្លាប់លោកហាម៉ោរ និងលោកស៊ីគែម កូនប្រុសរបស់គាត់
ដោយមុខដាវ។ ពួកគេបានយកនាងឌីណា ពីផ្ទះរបស់លោកស៊ីគែម ហើយបានចេញទៅ។
[27]កូនប្រុសម្នាក់ទៀតរបស់លោកយ៉ាកុបបានចូលទៅឯសាកសព ហើយរឹមអូសទ្រព្យសម្បត្តិនៅក្នុងទីក្រុងនោះ
ដោយព្រោះអ្នកក្រុងនោះបានបង្ខូចកិត្តិយសប្អូនស្រីរបស់ពួកគេ។[28]ពួកគេបានយកហ្វូងចៀម និងហ្វូងគោ ព្រមទាំងលារបស់អ្នកស្រុកនោះ
និងអ្វីៗទាំងអស់ដែលនៅទីក្រុងនោះ ព្រមទាំងអ្វីៗដែលនៅទីវាលផង[29]គឺទ្រព្យសម្បត្តិរបស់ពួកគេទាំងអស់។ ពួកគេបានចាប់ទាំងកូនក្មេង និងប្រពន្ធរបស់ពួកគេ។
ពួកគេបានយក សូម្បីតែអ្វីៗដែលនៅក្នុងផ្ទះផង។
[30]លោកយ៉ាកុបនិយាយទៅកាន់លោកស៊ីម្មាន និងលោកលេវីថា៖ «កូនប្រុសទាំងពីរ នាំបញ្ហាដល់ឪពុកហើយ
កូនបានបង្ខូចឈ្មោះរបស់ឪពុកនៅក្នុងចំណោមជនជាតិកាណាន និងជនជាតិពេរិស៊ីត។ ឪពុកក៏មានគ្នាតិច។ ប្រសិនបើ ពួកគេប្រមូលគ្នាទាស់នឹងឪពុក


generated on Wed Mar 12 15:32:40 2025

ហើយប្រហារឪពុក ដូច្នេះ ឪពុកនឹងត្រូវវិនាសហើយ ហើយឪពុក និងអ្នកផ្ទះរបស់ឪពុកមិនខាន»។ 31ប៉ុន្តែ លោកស៊ីម្មាន និងលោកលេវីនិយាយថា៖
«តើគួរឲ្យលោកស៊ីគែមធ្វើជាមួយប្អូនស្រីរបស់យើងដូចជាស្រីពេស្យា?»។

## ជំពូក ៣៥

1ព្រះជាម្ចាស់មានបន្ទូលទៅលោកយ៉ាកុបថា៖ «ចូរក្រោកឡើង ឡើងទៅបេតអែលចុះ ហើយស្នាក់នៅទីនោះ។ ចូរសង់អាសនៈមួយនៅទីនោះថ្វាយព្រះជាម្ចាស់
ដែលបានយាងមកជួបអ្នក នៅពេលអ្នករត់គេចពីអេសាវ បងប្រុសរបស់អ្នក»។ 2បន្ទាប់មក លោកយ៉ាកុបនិយាយទៅកាន់ក្រុមគ្រួសាររបស់គាត់
និងអ្នកដែលនៅជាមួយគាត់ថា៖ «ចូរបោះបង់ព្រះដទៃនៅក្នុងចំណោមអ្នករាល់គ្នាចោល ចូរសម្អាតខ្លួនរបស់អ្នករាល់គ្នា
ហើយផ្លាស់ប្តូរសម្លៀកបំពាក់របស់អ្នករាល់គ្នាចេញ។ 3បន្ទាប់មក យើងចេញដំណើរ ហើយឡើងទៅបេតអែល។ ខ្ញុំនឹងសង់អាសនៈមួយនៅទីនោះថ្វាយព្រះជាម្ចាស់
ដែលបានឆ្លើយតបខ្ញុំនៅថ្ងៃដែលខ្ញុំមានទុក្ខ ហើយបានគង់នៅជាមួយខ្ញុំ គ្រប់កន្លែងដែលខ្ញុំទៅ»។
4ដូច្នេះ ពួកគេបានប្រគល់រូបព្រះរបស់សាសន៍ដទៃដែលនៅក្នុងដៃរបស់ពួកគេទាំងអស់ឲ្យដល់លោកយ៉ាកុប ហើយនិងចិញ្ចៀនដែលពួកគេពាក់នៅនឹងត្រចៀក។
5លោកយ៉ាកុបបានកប់វានៅក្រោមដើមជ្រៃដែលនៅជិតទីកដីស៊ីគែម។ នៅពេលពួកគេធ្វើដំណើរ ព្រះជាម្ចាស់បានធ្វើឲ្យទីក្រុងផ្សេងៗដែលនៅជុំវិញពួកគេមានការភ័យខ្លាច
ដូច្នេះ គ្មាននរណាហ៊ានដេញតាមកូនចៅរបស់លោកយ៉ាកុបទេ។
6ដូច្នេះ លោកយ៉ាកុបបានមកដល់ លូស (គឺជាបេតអែល) ដែលនៅក្នុងទឹកដីកាណាន គាត់ និងមនុស្សគ្រប់គ្នាដែលនៅជាមួយគាត់។ 7គាត់បានសង់អាសនៈមួយនៅទីនោះ
តាមដែលព្រះជាម្ចាស់បានបង្ហាញអង្គទ្រង់ដល់គាត់ នៅពេលគាត់កំពុងតែរត់គេចពីបងប្រុសរបស់គាត់។ 8នាងស្រីដេបូរ៉ា ដែលត្រូវជាមេដោះរបស់នាងស្រីរេបិកា បានស្លាប់
ហើយគេបញ្ចុះសពនាងនៅជើងភ្នំបេតអែលនោះ គឺនៅក្រោមដើមជ្រៃមួយ ដែលគេហៅថា អាឡូន បាគូថ។
9នៅពេលលោកយ៉ាកុបមកពីស្រុកប៉ាដាន់ អើរ៉ាមវិញ ព្រះជាម្ចាស់បានយាងមកជួបគាត់សារជាថ្មី ហើយបានឲ្យពរដល់គាត់។ 10ព្រះជាម្ចាស់មានបន្ទូលទៅគាត់ថា៖
«អ្នកឈ្មោះយ៉ាកុប ប៉ុន្តែ ឈ្មោះរបស់អ្នកលែងហៅថាយ៉ាកុបទៀតហើយ។ អ្នកនឹងមានឈ្មោះថា អ៊ីស្រាអែល»។ ដូច្នេះ ព្រះជាម្ចាស់បានហៅឈ្មោះរបស់គាត់ថា
អ៊ីស្រាអែល។
11ព្រះជាម្ចាស់មានបន្ទូលទៅគាត់ថា៖ «យើងជាព្រះដ៏មានគ្រប់ព្រះចេស្តា។ ចូរបង្កើតផល ហើយបានចម្រើនឡើង។ ជាប្រជាជាតិមួយ
ដែលមានប្រជាជាតិជាច្រើនកើតចេញពីអ្នក ហើយនិងស្តេចដែលកើតឡើងចេញពីក្នុងចំណោមពូជពង្សរបស់អ្នក។ 12ទឹកដីដែលយើងបានប្រគល់ឲ្យលោកអប្រាហាំ
និងលោកអ៊ីសាក យើងនឹងប្រគល់ដល់អ្នក។ យើងក៏ប្រគល់ទឹកដីឲ្យដល់ពូជពង្សរបស់អ្នកដែលនៅតាមក្រោយអ្នកដែរ»។
13ព្រះជាម្ចាស់បានយាងចេញពីគាត់គឺចេញពីកន្លែងដែលព្រះអង្គមានបន្ទូលជាមួយគាត់។
14លោកយ៉ាកុបបានរៀបចំបង្គោលមួយ នៅកន្លែងដែលព្រះជាម្ចាស់បានមានបន្ទូលជាមួយគាត់ គឺជាសសរថ្ម។គាត់បានច្រួចតង្វាយពីលើវា
ហើយក៏បានចាក់ប្រេងពីលើវាដែរ។ 15លោកយ៉ាកុបដាក់ឈ្មោះកន្លែងដែលព្រះជាម្ចាស់មានបន្ទូលមកគាត់ថា បេតអែល។
16ពួកគេបានចេញដំណើរពីបេតអែល។ កាលពួកគេនៅឆ្ងាយ មិនទាន់ទៅដល់អេប្រាតានៅឡើយ នាងរ៉ាជែលបានឈឺពោះសម្រាលកូន ហើយគាត់សម្រាលកូនយ៉ាង
លំបាក 17កាលដែលនាងកំពុងដែលសម្រាលកូនយ៉ាងលំបាកបំផុតនោះ ឆ្មបបាននិយាយទៅនាងថា៖ «កុំខ្លាចអ្វីឡើយ
ដ្បិតឥឡូវនាងបង្កើតបានកូនប្រុសមួយទៀតហើយ»។ 18ពេលនាងរៀបនឹងស្លាប់ នៅដង្ហើមចុងក្រោយ នាងបានដាក់ឈ្មោះកូនប្រុសនោះថា បេន អូនី ប៉ុន្តែ
ឪពុករបស់គាត់ដាក់ឈ្មោះថា បេនយ៉ាមីនវិញ។ 19នាងរ៉ាជែលបានស្លាប់ ហើយបានបញ្ចុះនៅតាមផ្លូវទៅអេប្រាតា (គឺជាបេថ្លេហិម)។
20លោកយ៉ាកុបបានដំឡើងបង្គោលមួយឲ្យនាងនៅលើផ្នូររបស់នាង។ គឺជាសញ្ញាសម្គាល់ផ្នូររបស់នាងរហូតមកដល់សព្វថ្ងៃនេះ។
21លោកអ៊ីស្រាអែលបានបន្តដំណើរទៅមុខទៀត ហើយបានសង់ត្រសាលរបស់គាត់ខ្ពស់ជាងប៉មរបស់ហ្វូងសត្វទៅទៀត។
22ក្នុងកាលដែលលោកអ៊ីស្រាអែលរស់នៅក្នុងទឹកដីនោះ លោករូបេនរួមបានដំណេកជាមួយនាងប៊ីលហា ជាប្រពន្ធចុងរបស់ឪពុកគាត់ ហើយលោកអ៊ីស្រាអែលបានដឹងរឿង
នេះ។ ហើយលោកយ៉ាកុបមានកូនប្រុសដប់ពីរនាក់។
23កូនប្រុសៗរបស់គាត់តាមរយៈនាងស្រីលេអាគឺ រូបេន ជាកូនច្បងរបស់លោកយ៉ាកុប ស៊ីម្មាន លេវី យូដា អ៊ីសាខារ និងសាប់យូឡូន។
24កូនប្រុសៗរបស់គាត់តាមរយៈនាងរ៉ាជែល មាន យ៉ូសែប និងបេនយ៉ាមីន។ 25កូនប្រុសៗរបស់គាត់តាមរយៈនាងប៊ីលហា ជាអ្នកបម្រើស្រីរបស់នាងរ៉ាជែល មានដាន់ និង
ណែបថាលី។
26កូនប្រុសៗរបស់គាត់តាមរយៈនាងស៊ីលផា ជាអ្នកបម្រើស្រីរបស់នាងលេអា មានកាដ និងអេស៊ើរ។ កូនទាំងអស់នេះជាកូនប្រុសៗរបស់លោកយ៉ាកុប ដែលកើត
នៅក្នុងទឹកដីប៉ាដាន់អើរ៉ាម។ 27លោកយ៉ាកុបបានមករកលោកអ៊ីសាកជាឪពុកវិញ នៅត្រង់ដើមជ្រៃម៉ាមរេ នៅគារយ៉ាត អើបា (គឺនៅហេប្រូន) ជាទឹកដីដែលលោកអប្រាហាំ
និងលោកអ៊ីសាកបានធ្លាប់បានរស់នៅ។
28លោកអ៊ីសាកមានអាយុមួយរយប៉ែតសិបឆ្នាំ។ 29លោកអ៊ីសាកបានផុតដង្ហើម ហើយបានស្លាប់ ព្រមទាំងបានទៅជួបជុំជាមួយបុព្វបុរសរបស់គាត់
ហើយគាត់បានស្កប់ស្កល់នៅក្នុងជីវិតរបស់គាត់។ លោកអេសាវ និងលោកយ៉ាកុប កូនប្រុសរបស់គាត់ បានបញ្ចុះសពគាត់។

## ជំពូក ៣៦

1អ្នកទាំងនេះគឺជាពូជពង្សរបស់លោកអេសាវ (ដែលហៅថាអេដុមផងដែរ)។ 2លោកអេសាវយកប្រពន្ធពីជនជាតិកាណាន។ អ្នកទាំងនេះគឺជាប្រពន្ធរបស់គាត់គឺនាងអដា ជា
កូនស្រីរបស់លោកអេឡូន ជនជាតិហេត នាងអហូលីបាម៉ា កូនស្រីរបស់លោកអណា ជាជីតារបស់លោកស៊ីបៀន ជនជាតិហេវី 3និងនាងបាសម៉ាត ជាកូនស្រីរបស់លោក
អ៊ីស្មាអែល ជាប្អូនស្រីរបស់លោកនេបាយ៉ូត។
4នាងអដាបង្កើតបានអេលីផាសឲ្យលោកអេសាវ ហើយនាងបាសម៉ាតបង្កើតរេហួល។ 5នាងអហូលីបាម៉ាបង្កើតបានយេអ៊ូស យ៉ាឡាម និងកូរេ។ អ្នកទាំងនេះជាកូនប្រុស
របស់លោកអេសាវ ដែលកើតនៅទឹកដីកាណាន។
6លោកអេសាវបានយកភរិយា និងកូនប្រុសៗរបស់គាត់ ព្រមទាំងសមាជិកគ្រួសាររបស់គាត់ និងហ្វូងសត្វរបស់គាត់ និងទ្រព្យសម្បត្តិរបស់គាត់ទាំងអស់
ដែលគាត់រកបាននៅក្នុងទឹកដីកាណាន ហើយគាត់បានចាកចេញពីទឹកដីដែលលោកយ៉ាកុប ប្អូនប្រុសរបស់គាត់រស់នៅ។ 7គាត់ធ្វើបែបនេះ
ដោយសារទ្រព្យសម្បត្តិរបស់ពួកគេច្រើនពេក ធ្វើឲ្យពួកគេមិនអាចនៅជាមួយគ្នាបាន។ ទឹកដីដែលពួកគេរស់នៅមិនអាចផ្គត់ផ្គង់ដល់ហ្វូងសត្វរបស់ពួកគេបានឡើយ។
8ដូច្នេះ លោកអេសាវ ដែលបានស្គាល់ជាជនជាតិអេដុមផងនោះ បានទៅតាំងលំនៅក្នុងតំបន់ភ្នំសៀរ។
9ទាំងនេះគឺជាពូជពង្សរបស់លោកអេសាវ ជាជូនតារបស់ជនជាតិអេដុម នៅក្នុងតំបន់ភ្នំសៀរ។ 10ទាំងនេះគឺជាឈ្មោះកូនប្រុសៗរបស់លោកអេសាវ អេលីផាស ជាកូនរបស់
នាងអដា ភរិយារបស់លោកអេសាវ។ រេហួល ជាកូនរបស់នាងបាសម៉ាត ភរិយារបស់លោកអេសាវ។ 11កូនប្រុសៗរបស់អេលីផាស គឺថេម៉ាន អូម៉ារ សេផូរ កាថាម និង
កេណាស។ 12នាងធីមណា ជាប្រពន្ធចុងរបស់លោកអេលីផាស ជាកូនប្រុសរបស់លោកអេសាវ បង្កើតអាម៉ាឡេក។ ទាំងនេះជាកូនចៅរបស់នាងអដា ភរិយារបស់លោក
អេសាវ។

13អ្នកទាំងនេះគឺកូនប្រុសៗរបស់លោករេហួល ណាហាត់ សេរ៉ាស សាំម៉ា និងមីសសា។ អ្នកទាំងនេះគឺជាចៅប្រុសៗរបស់នាងបាសម៉ាត ភរិយារបស់លោកអេសាវ។
14ទាំងនេះគឺជាកូនប្រុសៗរបស់នាងអហូលីបាម៉ា ភរិយារបស់លោកអេសាវ ដែលត្រូវជាកូនរបស់លោកអណា និងជាចៅរបស់លោកស៊ីបៀន ។ នាងបង្កើតឲ្យលោកអេសាវ
គឺយេអ៊ូស យ៉ាឡាម និងកូរេ។
15អ្នកទាំងនេះគឺជាកុលសម្ព័ន្ធនៅក្នុងចំណោមពូជពង្សរបស់លោកលោកអេសាវ៖ ពូជពង្សរបស់លោកអេលីផាស ជាកូនច្បងរបស់លោកអេសាវ មានលោកថេម៉ាន លោក
អូម៉ារ លោកសេផូ លោកកេណាស 16លោកកូរេ លោកកាថាម លោកអាម៉ាឡេក។ អ្នកទាំងនេះត្រូវជាមេនៃពូជពង្សអេលីផាស នៅក្នុងទឹកអេដុម ហើយ
ពួកគេគឺជាចៅប្រុសៗរបស់នាងអដា។
17ទាំងនេះគឺជាអំបូររបស់លោករេហួល ជាកូនប្រុសរបស់លោកអេសាវ មានលោកណាហាត់ លោកសេរ៉ាស លោកសាំម៉ា លោកមីសសា។ អ្នកទាំងនេះជាមេ
នៃអំបូររបស់លោករេហួល នៅក្នុងទឹកដីអេដុម។ 18ពួកគេគឺជាចៅប្រុសៗរបស់នាងបាសម៉ាត ភរិយារបស់លោកអេសាវ។ អ្នកទាំងនេះគឺមេនៃអំបូររបស់នាងអហូលីបាម៉ា ជា
ភរិយារបស់លោកអេសាវ កូនស្រីរបស់លោកអណា។ 19អ្នកទាំងនេះគឺជាកូនចៅរបស់លោកអេសាវ ហើយពួកគេទាំងនេះជាមេនៃអំបូររបស់ពួកគេរៀងខ្លួន។
20ទាំងនេះគឺជាកូនប្រុសៗរបស់លោកសៀរ ជនជាតិហូរី ជាប្រជាជនដែលរស់នៅក្នុងទឹកដីនេះ មានឡូថាន សូបាល ស៊ីបៀន អណា 21ឌីសុន អេស៊ើរ និងឌីសាន។ អ្នកទាំង
នេះជាមេនៃជនជាតិហូរី ជាប្រជាជនរបស់លោកសៀរ នៅក្នុងទឹកដីអេដុម។ 22អ្នកទាំងនេះគឺជាកូនប្រុសរបស់លោកឡូថាន មាន ហូរី និងហេម៉ាម ហើយនាង
ធីមណាគឺជាប្អូនស្រីរបស់លោកឡូថាន។
23អ្នកទាំងនេះគឺជាកូនប្រុសៗរបស់លោកសូបាល មាន អាល់វ៉ាន ម៉ាណាហាត់ អេបាល សេផូ និងអូណាំ។ 24អ្នកទាំងនេះគឺជាកូនប្រុសៗរបស់លោកស៊ីបៀនមាន អៃយ៉ា
និងអណា។ លោកអណានេះហើយដែលបានរកឃើញប្រភពទឹកនៅទីរហោស្ថាន ក្នុងពេលដែលគាត់កំពុងតែឃ្វាលលារបស់លោកស៊ីបៀន ឪពុករបស់គាត់។
25អ្នកទាំងនេះគឺជាកូនចៅរបស់លោកអណាមាន ឌីសុន និងនាងអហូលីបាម៉ា កូនស្រីរបស់លោកអណា។ 26អ្នកទាំងនេះគឺជាកូនប្រុសៗរបស់លោកឌីសុនមាន ហែមដាន់
អែសបាន់ យីតរ៉ាន និងកេរ៉ាន។ 27អ្នកទាំងនេះគឺជាកូនប្រុសៗរបស់លោកអេស៊ើរមាន ប៊ីលហាន សាវ៉ាន និងយ៉ាកាន។ 28អ្នកទាំងនេះគឺជាកូនប្រុសៗរបស់លោកឌីសាន
មាន អ៊ូស និងអរ៉ាន។
29អ្នកទាំងនេះគឺជាអំបូររបស់លោកហូរីមានឡូថាន សូបាល ស៊ីបៀន អ័ណា ឌីសុន អេស៊ើរ និងឌីសាន។ 30អ្នកទាំងនេះជាពូជអំបូរដែលកើតពីជនជាតិហូរី តាមអំបូររបស់
គេនៅក្នុងទឹកដីសៀរ។
31ទាំងនេះគឺជាស្ដេចគ្រងរាជ្យនៅក្នុងទឹកដីអេដុម មុនពេលស្ដេចផ្សេងគ្រងរាជ្យនៅក្នុងទឹកដីអ៊ីស្រាអែល 32ព្រះបាទបេឡា ជាបុត្ររបស់លោកបេអ៊រ បានគ្រងរាជ្យនៅក្រុង
ឌីនហាបារបស់ព្រះអង្គ ក្នុងទឹកដីអេដុម។ 33នៅពេលព្រះបាទបេឡាបានសុគតទៅ ព្រះបាទយ៉ូបាប ជាបុត្ររបស់លោកសេរ៉ាស អ្នកក្រុងបូសរ៉ា បានឡើងគ្រងរាជ្យ
ជំនួសព្រះអង្គ។
34នៅពេលព្រះបាទយ៉ូបាបសុគតទៅ ព្រះបាទហ៊ូសាំ ជាអ្នកក្រុងថេម៉ាន បានឡើងគ្រងរាជ្យជំនួសព្រះអង្គ។ 35នៅពេលព្រះបាទហ៊ូសាំសុគតទៅ ព្រះបាទហាដាឌ ជាបុត្រ
របស់លោកបេដាឌ ស្ដេចនេះហើយដែលបានវាយឈ្នះជនជាតិម៉ាឌាន នៅស្រុកម៉ូអាប់ បានឡើងគ្រងរាជ្យជំនួសព្រះអង្គ។ ទីក្រុងរបស់ព្រះអង្គគឺអាវីត។ 36នៅពេលព្រះបាទ
ហាដាឌសុគតទៅ ព្រះបាទសាំឡា ជាអ្នកស្រុកម៉ាសរេកា បានឡើងគ្រងរាជ្យជំនួសព្រះអង្គ។
37នៅពេលព្រះបាទសាំឡាសុគតទៅ នោះព្រះបាទសូល ជាអ្នកក្រុងរ៉េហូបូត ដែលនៅជាប់នឹងទន្លេ បានឡើងគ្រងរាជ្យជំនួសព្រះអង្គ។ 38នៅពេលព្រះបាទសូលសុគតទៅ
ព្រះបាទបាលហាណាន់ ជាបុត្ររបស់លោកអកបោរ បានឡើងគ្រងរាជ្យជំនួសព្រះអង្គ។ 39នៅពេលព្រះបាទបាលហាណាន់ ជាបុត្ររបស់លោកអកបោរសុគតទៅ ព្រះបាទ
ហាដារ ជាអ្នកក្រុងប៉ាវ បានឡើងគ្រងរាជ្យជំនួសព្រះអង្គ។ មហេសីរបស់ស្ដេចមាននាមថា មហេថាបែល ជាបុត្រីរបស់លោកម៉ាតរេឌ និងជាចៅរបស់លោកម៉េសាហាប់។
40អ្នកទាំងនេះគឺជាឈ្មោះមេនៃអំបូររបស់ជនជាតិអេសាវ តាមអំបូរ និងតាមទឹកដីរបស់ពួកគេ តាមឈ្មោះរបស់ពួកគេគឺ លោកធីមណា លោកអាលវ៉ា លោក
យេថេត 41លោកអហូលីបាម៉ា លោកអេឡា លោកពីណូន 42លោកកេណាស លោកថេម៉ាន លោកមីបសារ 43លោកម៉ាកឌាល និងលោកអ៊ីរ៉ាម។ អ្នកទាំងនេះគឺជាមេនៃ
ជនជាតិអេដុម ទៅតាមទីលំនៅ និងទៅតាមតំបន់ដែលជាទឹកដីរបស់គេ។ នេះគឺលោកអេសាវជាបុព្វបុរសរបស់ជនជាតិអេដុម។

ជំពូក ៣៧

1លោកយ៉ាកុបបានរស់នៅក្នុងទឹកដី ដែលឪពុករបស់គាត់រស់នៅ គឺនៅក្នុងទឹកដីកាណាន។ 2ទាំងនេះ គឺជាព្រឹត្តិការណ៍ដែលកើតឡើងទាក់ទងនឹងលោកយ៉ាកុប។
លោកយ៉ូសែប នៅក្មេង អាយុដប់ប្រាំពីរឆ្នាំ បានទៅឃ្វាលហ្វូងសត្វជាមួយបងៗរបស់គាត់។ គាត់បានទៅជាមួយកូនប្រុសរបស់នាងប៊ីលហា និងនាងស៊ីលផា ប្រពន្ធចុង
របស់ឪពុកគាត់។ លោកយ៉ូសែបបានរាយការណ៍មិនល្អពីបងៗដល់ឪពុករបស់ពួកគេ។
3លោកអ៊ីស្រាអែលស្រឡាញ់យ៉ូសែបជាងកូនប្រុសៗទាំងអស់របស់គាត់ដោយសារគាត់មានកូនប្រុសនេះ ពេលគាត់មានអាយុច្រើនហើយ។
លោកអ៊ីស្រាអែលបានធ្វើសម្លៀកបំពាក់យ៉ាងស្អាតឲ្យគាត់។ 4បងប្រុសរបស់គាត់បានឃើញថា ឪពុករបស់ពួកគេស្រឡាញ់គាត់ច្រើនជាងបងៗទាំងអស់។
ពួកគេបានស្អប់គាត់ ហើយមិនបាននិយាយពាក្យល្អដាក់គាត់ឡើយ។
5លោកយ៉ូសែបបានសុបិនរឿងមួយ ហើយគាត់បានប្រាប់ដល់បងៗរបស់គាត់ពីរឿងនោះ។ ពួកគេស្អប់គាត់កាន់តែខ្លាំង។ 6គាត់និយាយទៅពួកគេថា៖ «សូមស្ដាប់សុបិន
ដែលខ្ញុំបានសុបិន។
7មើល៍ កាលយើងទាំងអស់គ្នាកំពុងតែចងកណ្ដាប់ស្រូវ នៅវាលស្រែ ពេលនោះ ស្រាប់តែកណ្ដាប់របស់ខ្ញុំងើបឈរឡើងយ៉ាងត្រង់ ហើយមើល៍ កណ្ដាប់របស់បងៗបានមក
ព័ទ្ធជុំវិញកណ្ដាប់ខ្ញុំ ហើយនាំគ្នាលុតជង្គង់ចំពោះកណ្ដាប់របស់ខ្ញុំ»។ 8បងៗរបស់គាត់និយាយទៅកាន់គាត់ថា៖ «តើឯងនឹងគ្រងរាជ្យលើយើងឬ? តើឯងនឹងគ្រប់គ្រងលើ
យើងឬ?»។ ពួកគេរឹតតែស្អប់គាត់កាន់តែខ្លាំងឡើយ ដោយព្រោះតែសុបិនដែលគាត់យកមកប្រាប់ពួកគេ។
9គាត់បានសុបិនឃើញរឿងមួយផ្សេងទៀត ហើយបានប្រាប់សុបិនដល់បងៗរបស់គាត់ដែរ។ គាត់និយាយថា៖ «មើល៍ ខ្ញុំបានសុបិនឃើញរឿងមួយទៀត
គឺឃើញដួងអាទិត្យ និងដួងច័ន្ទ ហើយផ្កាយទាំងដប់មួយលុតជង្គង់ចំពោះខ្ញុំ»។ 10គាត់បានប្រាប់ការនេះទៅកាន់ឪពុករបស់គាត់ ដូចបានប្រាប់ដល់បងៗដែរ
ហើយឪពុករបស់គាត់បានបន្ទោសដល់គាត់។ លោកអ៊ីស្រាអែលប្រាប់ទៅគាត់ថា៖ «តើកូនសុបិនអ្វីចម្លែកម្លេៈ? តើម្ដាយរបស់ឯង និងឪពុក
ព្រមទាំងបងៗរបស់ឯងលុតជង្គង់ថ្វាយបង្គំឯងមែនទេ? 11បងៗច្រណែននឹងគាត់ប៉ុន្តែឪពុករបស់គាត់រក្សារឿងនេះនៅក្នុងគំនិតរបស់គាត់។
12បងៗរបស់គាត់បានទៅកន្លែងមើលថែហ្វូងសត្វរបស់ឪពុកគាត់នៅក្នុងក្រុងស៊ីគែម។ 13លោកអ៊ីស្រាអែលប្រាប់យ៉ូសែបថា៖
«តើកូនឯងមិនទៅកន្លែងមើលហ្វូងសត្វជាមួយបងៗកូនឯងនៅស៊ីគែមទេឬ? មក ហើយឪពុកនឹងឲ្យកូនឯងទៅជាមួយពួកគេ»។ យ៉ូសែបប្រាប់គាត់វិញថា៖
«ខ្ញុំរួចរាល់ហើយ»។ 14លោកអ៊ីស្រាអែលប្រាប់គាត់ថា៖ «ទៅឥឡូវនេះទៅ មើល៍ ឲ្យដឹងថាតើបងៗរបស់កូនឯង និងហ្វូងសត្វយ៉ាងណា
ហើយនាំយកដំណឹងមកប្រាប់ឪពុកវិញ»។ ដូច្នេះ លោកយ៉ាកុបបានឲ្យគាត់ចេញទៅជ្រលងភ្នំហេប្រុន ហើយយ៉ូសែបបានទៅក្រុងស៊ីគែម។
15មានបុរសម្នាក់បានជួបយ៉ូសែប។ មើល៍ យ៉ូសែបបានវង្វេងនៅឯវាល។ បុរសនោះបានសួរគាត់ថា៖ «តើឯងរកអ្វី?» 16យ៉ូសែបឆ្លើយថា៖ «ខ្ញុំរកបងៗរបស់ខ្ញុំ
សូមជួយប្រាប់ខ្ញុំផង តើពួកគាត់មើលថែហ្វូងសត្វនៅឯណា»។ 17បុរសនោះប្រាប់ថា៖ «ពួកគេបានចេញពីទីនេះហើយ ដ្បិត យើងបានឮពួកគេនិយាយថា៖ «តោះ! យើង
ទៅដូថាន។ យ៉ូសែបបានទៅតាមរកបងៗរបស់គាត់ ហើយជួបពួកគេនៅដូថាន។


generated on Wed Mar 12 15:32:40 2025

18ពួកគេឃើញគាត់ពីចម្ងាយ ហើយមុនពេលគាត់ជិតទៅដល់ពួកគេ ពួកគេបានឃុបឃិតគ្នាសម្លាប់គាត់។ 19បងៗបាននិយាយទៅកាន់គ្នាគាត់ថា៖ «មើល
អាមេសុបិនមកហើយ។ 20ដូច្នេះ មក! ចូរយើងសម្លាប់វា ហើយកប់វាទៅក្នុងរណ្តៅមួយនោះទៅ។ យើងនឹងប្រាប់គេថា៖ «សត្វព្រៃបានសម្លាប់វា»
យើងនឹងមើលថាតើសុបិនរបស់វានឹងទៅជាយ៉ាងណា?»។
21លោករូបេនបានឮ ហើយសង្គ្រោះគាត់ពីដៃរបស់ពួកគេ។ គាត់បានប្រាប់ថា៖ «សូមយើងកុំសម្លាប់វាអី»។ 22លោករូបេនប្រាប់ទៅពួកគេថា៖ «កុំបង្ហូរឈាមឡើយ។
ចូរបោះវាទៅក្នុងរណ្តៅដែលនៅក្នុងទីរហោស្ថាននេះទៅ ប៉ុន្តែ សូមកុំសម្លាប់វាអី»។ ដើម្បីឲ្យគាត់អាចសង្គ្រោះគាត់ចេញពីកណ្តាប់ដៃរបស់ពួកគេ
ហើយនាំគាត់ត្រឡប់ទៅឪពុករបស់គាត់វិញ។
23នៅពេលយ៉ូសែបបានទៅដល់បងៗរបស់គាត់ ពួកគេបានដោះអាវស្អាតរបស់គាត់។ 24ពួកគេបានចាប់គាត់ ហើយបោះគាត់ចូលទៅក្នុងរណ្តៅ។
រណ្តៅនោះទទេស្អាតគ្មានទឹកនៅក្នុងនឹងទេ។
25ពួកគេបានអង្គុយចុះ ហើយហូបនំប៉័ង។ ពួកគេបានងើបភ្នែកគេឡើង ហើយសម្លឹងមើល ហើយឃើញជនជាតិអ៊ីស្មាអែលមកពីកាឡាដ ជាមួយនឹងសត្វអូដ្ឋរបស់ពួកគេ
ដឹកគ្រឿងក្រអូប ជ័រពិដោរ និងជ័រល្វីងទេស។ ពួកគេកំពុងធ្វើដំណើរ យករបស់ទាំងនោះទៅទឹកដីអេស៊ីប។ 26លោកយូដានិយាយទៅបងៗរបស់គាត់ថា៖
«តើមានប្រយោជន៍អ្វី ប្រសិនបើ យើងសម្លាប់ប្អូនរបស់យើង ហើយលាក់ឈាមរបស់វា?
27មក ចូរយើងលក់វាឲ្យទៅជនជាតិអ៊ីស្មាអែល ហើយកុំសម្លាប់វាឡើយ។ ដ្បិត វាក៏ជាកូនរបស់ឪពុកយើង និងជាសាច់ឈាមរបស់យើងដែរ»។
បងៗរបស់គាត់ក៏ស្តាប់តាមគាត់។ 28មានឈ្មួញជាតិម៉ាឌានមកដល់ ពួកគេក៏យកយ៉ូសែបចេញពីរណ្តៅ។ ពួកគេបានលក់យ៉ូសែបទៅឲ្យជនជាតិអ៊ីស្មាអែល ក្នុងតម្លៃជា
ប្រាក់ម្ភៃស្លឹង។ ជនជាតិអ៊ីស្មាអែលនាំយ៉ូសែបទៅទឹកដីអេស៊ីប។
29លោករូបេនបានត្រឡប់មកឯរណ្តៅវិញ ហើយមើល៍ យ៉ូសែបមិនបាននៅក្នុងរណ្តៅនោះទៀតទេ។ គាត់បានហែកសម្លៀកបំពាក់របស់គាត់។
30គាត់បានត្រឡប់ទៅប្អូនៗរបស់គាត់ហើយប្រាប់ថា៖ «ក្មេងប្រុសនោះមិននៅទីនោះទេ! ហើយខ្ញុំ តើខ្ញុំអាចទៅណា?»
31ពួកគេបានសម្លាប់សត្វពពែមួយ បន្ទាប់មកបានយកសម្លៀកបំពាក់យ៉ូសែប ហើយជ្រលក់វាទៅក្នុងឈាមនោះ។ 32បន្ទាប់មក
ពួកគេបានយកវាទៅឯឪពុករបស់ពួកគេហើយនិយាយថា៖ «យើងបានរកឃើញអាវនេះ។ សូមមើល ថាតើវាជាសម្លៀកបំពាក់របស់កូនលោកឪពុកមែនរឺមិនមែន»។
33លោកយ៉ាកុបបានស្គាល់វា ហើយនិយាយថា៖ «វាគឺជាសម្លៀកបំពាក់កូនប្រុសរបស់ឪពុក។ សត្វព្រៃបានសម្លាប់កូនខ្ញុំ។ វាបានញែកស៊ីយ៉ូសែបជាចំណែកៗ»។
34លោកយ៉ាកុបបានហែកសម្លៀកបំពាក់របស់គាត់ ហើយស្លៀកសំពត់ធ្មៃរបស់គាត់ ហើយបានកាន់ទុក្ខកូនប្រុសរបស់គាត់ជាច្រើនថ្ងៃ។ 35កូនប្រុស
កូនស្រីរបស់គាត់បានក្រោកឡើងហើយកម្សាន្តចិត្តគាត់ ប៉ុន្តែ គាត់បដិសេធមិនទទួលការកម្សាន្តចិត្តរបស់គាត់ឡើយ។ គាត់និយាយថា៖
«ខ្ញុំពិតជាចង់ទៅស្ថានឃុំព្រលឹងមនុស្សស្លាប់ ដើម្បីកាន់ទុក្ខដល់កូនប្រុសខ្ញុំ»។ ឪពុករបស់គាត់បានកាន់ទុក្ខនឹងកូនប្រុសរបស់គាត់។
36ជនជាតិម៉ាឌានបានលក់គាត់ឲ្យលោកប៉ូទីផារជាមន្ត្រីរបស់ព្រះចៅផារ៉ោន ជាមេបញ្ជាការលើកងអង្គរក្សរបស់ស្តេច។

## ជំពូក ៣៨

1នៅគ្រានោះ លោកយូដាបានចាកចេញពីបងប្អូនរបស់គាត់ ទៅនៅជាមួយបុរសម្នាក់ក្នុងអាឌូឡាម ដែលមានឈ្មោះហ៊ីរ៉ា។ 2គាត់បានឃើញកូនស្រីរបស់លោកស៊ូអា ជា
ជនជាតិកាណាននៅទីនោះ។ គាត់រៀបការជាមួយនាង ហើយគេងជាមួយនាង។
3នាងមានផ្ទៃពោះ ហើយបង្កើតបានកូនប្រុសមួយ។ គាត់បានដាក់ឈ្មោះថា អ៊ើរ។ 4នាងមានផ្ទៃពោះម្តងទៀត ហើយបង្កើតបានកូនប្រុសមួយទៀត។
5នាងបានដាក់ឈ្មោះកូនប្រុសនោះថា អូណាន់។ ហើយនាងបានបង្កើតកូនប្រុសមួយទៀត ហើយដាក់ឈ្មោះកូនប្រុសនោះថា សេឡា។
នាងបង្កើតកូនទាំងអស់នោះនៅក្នុងភូមិកេស៊ីប។
6លោកយូដារកភរិយាមួយឲ្យអ៊ើរ កូនប្រុសច្បងរបស់គាត់។ នាងឈ្មោះថា តាម៉ារ។ 7លោកអ៊ើរ កូនច្បងរបស់គាត់ ជាមនុស្សអាក្រក់ មិនគាប់ព្រះហឫទ័យព្រះអម្ចាស់ទេ
ដូច្នេះ ព្រះអម្ចាស់ក៏បានសម្លាប់គាត់ចោលទៅ។
8លោកយូដាបាននិយាយទៅកាន់លោកអូណាន់ថា៖ «ចូរទៅគេងជាមួយភរិយាបងប្រុសរបស់កូនទៅ។ ចូរធ្វើតួនាទីជាប្អូនថ្លៃរបស់នាង ហើយបន្តពូជពង្សឲ្យបងប្រុស
របស់កូនទៅ»។ 9ដោយលោកអូណាន់ដឹងថាកូនដែលនឹងកើតមក គ្មានឈ្មោះជាពូជពង្សរបស់គាត់ ដូច្នេះ ពេលណាគាត់រួមដំណេកជាមួយបងថ្លៃ គាត់តែងតែសម្រក់
ចោលទៅដី ដូច្នេះហើយគាត់មិនអាចមានកូនដើម្បីបន្តពូជឲ្យបងប្រុសរបស់គាត់។ 10អ្វីដែលគាត់បានធ្វើ អាក្រក់នៅចំពោះព្រះអម្ចាស់។
ព្រះអម្ចាស់ក៏សម្លាប់គាត់ចោលទៅដែរ។
11លោកយូដាប្រាប់នាងតាម៉ារ កូនប្រសារស្រីរបស់គាត់ថា៖ «ចូរនៅជាស្រ្តីមេម៉ាយសិនចុះ ហើយទៅរស់នៅផ្ទះឪពុករបស់កូនសិនទៅ ទម្រាំសេឡាកូនរបស់ពុកធំពេញ
វ័យសិន»។ ដ្បិត គាត់ខ្លាចថា៖ «កូនមួយនេះអាចស្លាប់ដូចបងៗដែរ»។ នាងតាម៉ារក៏ទៅហើយទៅរស់នៅផ្ទះឪពុកនាងវិញ។
12យូរថ្ងៃក្រោយមក កូនស្រីរបស់លោកស៊ូអា ត្រូវជាភរិយារបស់លោកយូដា បានទទួលមរណភាព។ លោកយូដាបានធូរស្បើយហើយ គាត់ក៏ធ្វើដំណើរទៅ មើលពួកអ្នក
កាត់រោមចៀមរបស់គាត់ ភូមិធីមណា គាត់និងមិត្តភក្តិរបស់គាត់ គឺលោកហ៊ីរ៉ា ជាអ្នកស្រុកអាឌូឡាមទៅជាមួយដែរ។ 13គេប្រាប់នាងតាម៉ារថា៖ «មើល៍
ឪពុកក្មេករបស់នាងឡើងទៅធីមណា ដើម្បីកាត់រោមចៀម»។ 14នាងបានដោះស្លៀកសម្លៀកបំពាក់ជាស្រីមេម៉ាយរបស់នាងចេញ ហើយស្លៀកសម្លៀកបំពាក់
ហើយយកស្បៃហើយបាំងមុខរបស់នាង។ នាងអង្គុយនៅទ្វារចូលភូមិអេណែម ដែលនៅជិតផ្លូវទៅភូមិធីមណា។ ហើយនាងបានឃើញសេឡាពេញវ័យហើយ ប៉ុន្តែ
លោកមិនបានប្រគល់គាត់មកឲ្យធ្វើប្តីរបស់នាងឡើយ។
15គាត់គិតថាជាស្រ្តីពេស្យា ព្រោះនាងមានស្បៃបាំងមុខរបស់នាង។ 16គាត់បានទៅរកនាងដែលនៅក្បែរផ្លូវនោះ ហើយនិយាយថា៖ «មក៍ សូមឲ្យខ្ញុំបានគេងជាមួយនាង!»
ដ្បិត គាត់មិនបានដឹងថា នាងជាកូនប្រសាស្រីរបស់គាត់ទេ។ នាងតបថា៖ «តើលោកនឹងឲ្យអ្វីដល់ខ្ញុំ ប្រសិនបើខ្ញុំគេងជាមួយលោក?»។
17គាត់ប្រាប់ថា៖ «ខ្ញុំនឹងឲ្យគេយកពពែមួយពីហ្វូងសត្វរបស់ខ្ញុំមកឲ្យនាង»។ នាងបានសួរថា៖ «តើលោកមានអ្វីបញ្ចាំខ្ញុំឬទេ ទម្រាំតែលោកឲ្យគេយកវាមកឲ្យខ្ញុំ?»។
18គាត់សួរថា៖ «តើឲ្យខ្ញុំបញ្ចាំអ្វីដល់នាង?» នាងឆ្លើយថា៖ «សូមប្រគល់ត្រា ខ្សែ និងដំបងដែលលោកកាន់នៅដៃនោះមក»។ គាត់បានប្រគល់របស់ទាំងនោះឲ្យនាង
ហើយបានគេងជាមួយនាង ហើយនាងក៏មានផ្ទៃពោះដោយសារគាត់។
19នាងបានក្រោកឡើង ហើយចេញពីគាត់ទៅ។ នាងបានយកស្បៃចេញពីមុងនាង ហើយពាក់សម្លៀកបំពាក់ជាស្រ្តីមេម៉ាយវិញ។
20លោកយូដាបានផ្ញើពពែស្ទាវមួយពីហ្វូងសត្វតាមរយៈមិត្តភក្តិរបស់គាត់ គឺលោកអាឌូឡាំ ហើយយករបស់បញ្ចាំពីដៃរបស់ស្រ្តីនោះមកវិញ ប៉ុន្តែ គាត់រកនាងមិនឃើញទេ។
21បន្ទាប់មក លោកអាឌូឡាំសួរពួកប្រុសៗនៅកន្លែងនោះថា៖ «តើស្រ្តីពេស្យាដែលនៅមាត់ផ្លូវចូលភូមិអេណែមនោះ នៅឯណា?»។ គេតបមកវិញថា៖ «មិនដែលមានស្រ្តី
ពេស្យានៅទីនេះទេ»។ 22គាត់ក៏ត្រឡប់ទៅលោកយូដាវិញ ហើយប្រាប់ថា៖ «ខ្ញុំរកនាងមិនឃើញទេ។ ហើយពួកប្រុសៗនៅទីនោះប្រាប់ថា៖
«មិនដែលមានស្រ្តីពេស្យានៅទីនេះទេ»។ 23លោកយូដាប្រាប់ថា៖ «សូមឲ្យនាងទុករបស់នោះចុះ ដើម្បីកុំឲ្យយើងខ្មាស់គេ។ តាមពិត ខ្ញុំបានផ្ញើពពែស្ទាវមួយរួចហើយ
តែឯងរកនាងមិនឃើញ»។
24ប្រហែលជាបីខែក្រោយមក មានគេប្រាប់លោកយូដាថា៖ «នាងតាម៉ារកូនប្រសាស្រីរបស់លោកបានប្រព្រឹត្តអំពើពេស្យា ហើយឥឡូវនេះ
នាងមានផ្ទៃពោះដោយសារអំពើនោះហើយ»។ លោកយូដាប្រាប់ថា៖ «ចូរនាំនាងមកទីនេះ ហើយដុតនាងចោលទៅ»។ 25នៅពេលគេនាំនាងមក
នាងបានផ្ញើសាររបស់នាងទៅឪពុកក្មេករបស់នាងថា៖ «បុរសដែលជាម្ចាស់របស់ទាំងនេះ បានធ្វើឲ្យខ្ញុំមានផ្ទៃពោះ»។ នាងប្រាប់ថា៖


generated on Wed Mar 12 15:32:40 2025

«សូមរកមើលថាតើនរណាជាម្ចាស់របស់ទាំងនេះ ដែលមានដូចជាត្រា ខ្សែ និងដំបងជាដើម»។26លោកយូដាស្គាល់របស់ទាំងនោះ ហើយនិយាយថា៖
«នាងសុចរិតជាងខ្ញុំទៀត ខ្ញុំមិនបានប្រគល់សេឡា កូនប្រុសរបស់ខ្ញុំ ឲ្យធ្វើជាស្វាមីរបស់នាងឡើយ»។ គាត់មិនបានរួមដំណេកជាមួយនាងទៀតឡើយ។
27នៅគ្រានាងសម្រាលកូននោះ មើល៍នាងកូនភ្លោះនៅក្នុងផ្ទៃរបស់នាង។28ពេលសម្រាលកូនមានកូនមួយចេញដៃមកមុន ហើយឆ្មបក៏យកអំបោះក្រហមចងដៃទារកនោះ
ហើយនិយាយថា៖ «កូនមួយនេះកើតមុន»។
29ប៉ុន្តែ ទារកនោះបានដកដៃរបស់វាចូលទៅវិញ ហើយប្អូនរបស់វាក៏កើតចេញមកមុយ។ ពេលនោះ ឆ្មបនិយាយថា៖ «ឯងបានបើកប្រឡោះដណ្តើមចេញមុន!» ដូច្នេះ
គាត់បានដាក់ឈ្មោះកូននោះថា ពេរេស។30បន្ទាប់មក បងប្រុសរបស់វាក៏កើតចេញមក គឺជាអ្នកដែលបានមានអំបោះក្រហមនៅដៃរបស់វា
ហើយគាត់បានដាក់ឈ្មោះកូននោះថា សេរ៉ាស។

ជំពូក ៣៩

1យ៉ូសែបត្រូវបាននាំទៅឯស្រុកអេស៊ីប។ លោកប៉ូទីផារជាមន្ត្រីជនជាតិអេស៊ីបម្នាក់ ដែលជាមេលើកកងអង្គរក្សស្តេចរបស់ផារ៉ោន បានទិញគាត់ពីពួកអ៊ីស្មាអែល ដែលនាំ
ចុះមកស្រុកអេស៊ីបនេះ។2ព្រះអម្ចាស់គង់ជាមួយយ៉ូសែប ហើយគាត់បានក្លាយជាអ្នកមាន។ គាត់រស់នៅក្នុងផ្ទះរបស់លោកប៉ូទីផារចៅហ្វាយរបស់គាត់។
3ចៅហ្វាយរបស់គាត់បានឃើញថា ព្រះអម្ចាស់គង់នៅជាមួយគាត់ ហើយឃើញថា ព្រះជាម្ចាស់បានធ្វើឲ្យគាត់ចម្រុងចម្រើនអ្វីៗដែលគាត់បានធ្វើ។
4ចៅហ្វាយរបស់លោកលោកយ៉ូសែបពេញចិត្តនឹងគាត់ណាស់។ លោកយ៉ូសែបបានបម្រើលោកប៉ូទីផារ។ លោកប៉ូទីផារបានលើកគាត់ឲ្យគ្រប់គ្រងលើផ្ទះរបស់គាត់
និងអ្វីៗដែលជាទ្រព្យសម្បត្តិ ហើយបានដាក់នៅក្រោមការមើលថែរបស់គាត់ទាំងអស់។
5នៅពេលដែលគាត់បានលើកលោកយ៉ូសែបឲ្យគ្រប់គ្រងលើផ្ទះសម្បែង និងទ្រព្យសម្បត្តិទាំងអស់របស់គាត់
នោះព្រះអម្ចាស់បានប្រទានពរដល់ផ្ទះសម្បែងរបស់ជនជាតិអេស៊ីបនេះ ដោយសារតែលោកយ៉ូសែប។
ព្រះពររបស់ព្រះអម្ចាស់មកលើអ្វីៗដែលលោកប៉ូទីផារមាននៅក្នុងផ្ទះសម្បែង និងនៅឯស្រែចម្ការ។
6លោកប៉ូទីផារបានដាក់អ្វីៗដែលគាត់មាននៅក្រោមការមើលថែរបស់លោកយ៉ូសែប។ គាត់មិនចាំបាច់ខ្វល់ខ្វាយអ្វីឡើយ លើកលែងតែអាហារដែលគាត់ហូបប៉ុណ្ណោះ។
ហើយលោកយ៉ូសែបក៏សង្ហា ហើយទាក់ទាញផងដែរ។
7បន្ទាប់ពីគាត់បានទទួលកិច្ចការទាំងនេះហើយ នោះភរិយារបស់ចៅហ្វាយក៏ចង់បានលោកយ៉ូសែប។ នាងបាននិយាយថា៖ «មកគេងជាមួយខ្ញុំ»។8ប៉ុន្តែ គាត់បានបដិសេធ
ហើយនិយាយទៅកាន់ភរិយារបស់ចៅហ្វាយគាត់ថា៖ មើល៍ ចៅហ្វាយរបស់ខ្ញុំ មិនបានខ្វល់ខ្វាយពីអ្វីៗដែលខ្ញុំធ្វើនៅក្នុងផ្ទះនេះទេ
ហើយគាត់បានប្រគល់អ្វីៗដែលជារបស់គាត់ឲ្យនៅក្រោមការមើលថែរបស់ខ្ញុំ។9គ្មាននរណានៅក្នុងផ្ទះនេះធំជាងខ្ញុំទេ។ លោកមិនបានហួងហែងអ្វីពីខ្ញុំទេ
លើកលែងតែចៅហ្វាយស្រី ព្រោះចៅហ្វាយស្រីគឺជាភរិយារបស់គាត់។ តើខ្ញុំអាចនឹងធ្វើការអាក្រក់ដ៏ធំនេះ ហើយអាចធ្វើបាបទាស់នឹងព្រះជាម្ចាស់ដែរឬ?»
10ពីមួយថ្ងៃទៅមួយថ្ងៃ នាងនិយាយទៅលោកយ៉ូសែប ប៉ុន្តែ គាត់បានបដិសេធមិនព្រមគេងជាមួយនាង ឬនៅជាមួយនាងឡើយ។11នៅថ្ងៃមួយ
នៅពេលគាត់បានចូលទៅក្នុងផ្ទះ ដើម្បីធ្វើការងាររបស់គាត់។ គ្មានបុរសណាម្នាក់នៅក្នុងផ្ទះនោះទេ។12នាងបានចាប់គាត់ ហើយទាញអាវរបស់គាត់ ហើយនិយាយថា៖
«មកគេងជាមួយខ្ញុំ»។ គាត់បានបន្សល់ទុកនូវសម្លៀកបំពាក់នៅក្នុងដៃរបស់នាង ដោយរត់ ហើយចេញទៅក្រៅវិញ។
13នៅពេលនាងបានឃើញថា គាត់បានចាកចេញហើយសន្សល់សម្លៀកបំពាក់របស់គាត់នៅក្នុងដៃរបស់នាង
ហើយបានរត់ចេញទៅក្រៅ14នោះនាងបានហៅពួកប្រុសៗដែលនៅក្នុងផ្ទះរបស់នាង ហើយបានប្រាប់ដល់ពួកគេថា៖ «មើល
លោកប៉ូទីផារបាននាំជនជាតិហេព្រើរមកមើលងាយខ្ញុំ។ គាត់បានមករកខ្ញុំ ដើម្បីគេងជាមួយខ្ញុំ ហើយខ្ញុំក៏ស្រែកឡើង។15ហើយនៅពេលគាត់បានឮខ្ញុំស្រែក
នោះគាត់បានបន្សល់សម្លៀកបំពាក់របស់គាត់នៅជាមួយខ្ញុំ រត់ ហើយចេញទៅក្រៅ»។
16នាងបានដាក់សម្លៀកបំពាក់របស់គាត់នៅជិតនាង រហូតទាល់តែចៅហ្វាយរបស់គាត់ត្រឡប់មកផ្ទះវិញ។17នាងបានពន្យល់ប្រាប់គាត់ថា៖ «អ្នកបម្រើជនជាតិហេព្រើរ
ដែលនៅលោកបាននាំមកឯយើង បានមកមើលងាយខ្ញុំ។18នៅពេលដែលខ្ញុំស្រែក គាត់បានបន្សល់សម្លៀកបំពាក់របស់គាត់នៅជាមួយខ្ញុំ ហើយរត់ចេញទៅក្រៅ»។
19នៅពេលចៅហ្វាយរបស់គាត់បានស្តាប់ភរិយារបស់គាត់ពន្យល់ ហើយប្រាប់គាត់ «នេះគឺជាអ្វីដែលអ្នកបម្រើរបស់លោកបានធ្វើចំពោះខ្ញុំ» គាត់ខឹងយ៉ាងខ្លាំង។
20ចៅហ្វាយរបស់លោកយ៉ូសែបបានចាប់គាត់ ហើយយកគាត់ទៅដាក់គុក នៅកន្លែងអ្នកទោសរបស់ស្តេច។ គាត់បាននៅក្នុងគុកនោះ។
21ប៉ុន្តែ ព្រះអម្ចាស់គង់នៅជាមួយលោកយ៉ូសែប ហើយសម្តែងភាពស្មោះត្រង់ចំពោះសម្ពន្ធមេត្រីចំពោះគាត់។ ព្រះអង្គបានផ្តល់មេត្តាដល់គាត់
គឺបានធ្វើឲ្យមេគុកអាណិតមេត្តាដល់គាត់។22លោកមេគុកបានប្រគល់អ្នកទោសដែលនៅក្នុងគុកទាំងអស់ទៅក្នុងដៃរបស់លោកយ៉ូសែប។ អ្វីៗដែលពួកគេធ្វើនៅទីនោះ
លោកយ៉ូសែបជាអ្នកទទួលខុសត្រូវទាំងអស់។23មេគុកមិនបានខ្វល់ខ្វាយអំពីអ្វីៗទាំងអស់ ដែលនៅក្នុងដៃរបស់គាត់ឡើយ ព្រោះព្រះអម្ចាស់គង់នៅជាមួយគាត់។
អ្វីដែលគាត់ធ្វើ ព្រះអម្ចាស់បានធ្វើឲ្យចម្រើនឡើងទាំងអស់។

ជំពូក ៤០

1បន្ទាប់ពីការទាំងនេះហើយ អ្នកថ្វាយ ពែងនិងអ្នកដុតនំរបស់ស្តេចរបស់អេស៊ីប បានធ្វើឲ្យស្តេចស្រុកអេស៊ីបជាម្ចាស់របស់ខ្លួនខ្វាល់ព្រះហឫទ័យ។
2ស្តេចផារោនមានព្រះហឫទ័យខ្វាល់នឹងមន្ត្រីទាំងពីរនេះ គឺលើមេនៃអ្នកថ្វាយពែង និងមេនៃអ្នកដុតនំ។
3ស្តេចបានឃុំពួកគេនៅក្នុងគុកនៅក្នុងផ្ទះរបស់មេនៃអង្គរក្សរបស់ស្តេច នៅក្នុងគុកដែលបានឃុំឃាំងលោកយ៉ូសែបដែរ។
4មេនៃកងអង្គរក្សស្តេចបានតាំងលោកយ៉ូសែប ដើម្បីឲ្យបម្រើដល់ពួកគេ។ ពួកគេនៅជាប់ឃុំឃាំងនៅក្នុងពេលតែមួយដូចគ្នា។5អ្នកទាំងពីរនាក់នោះបានសុបិន
គឺអ្នកថ្វាយពែង និងអ្នកដុតនំថ្វាយស្តេចអេស៊ីប ដែលជាប់ឃុំនៅក្នុងគុកនោះ ម្នាក់ៗសុបិនរៀងៗខ្លួន នៅយប់តែមួយនោះ
ហើយសុបិនរបស់ម្នាក់ៗមានការបកស្រាយរៀងៗខ្លួនដែរ។
6លោកយ៉ូសែបបានចូលទៅរកពួកគេនៅពេលព្រឹក ហើយបានឃើញពួកគេ។ មើល៍ ពួកគេក្រៀមក្រំ។7គាត់បានសួរមន្ត្រីរបស់ស្តេចផារោនដែលនៅជាប់ឃុំជាមួយគាត់
នៅក្នុងផ្ទះចៅហ្វាយរបស់គាត់ថា៖ «ហេតុអ្វីបានជាលោកក្រៀមក្រំម្លេ៉ះថ្ងៃនេះ?»8ពួកគេនិយាយទៅគាត់ថា៖ «យើងទាំងពីរនាក់បានយល់សុបិនមួយ
ហើយគ្មាននរណាអាចបកស្រាយវាបានទេ»។ លោកយ៉ូសែបនិយាយទៅពួកគេថា៖ «តើការបកស្រាយមិនមែនជារបស់ព្រះជាម្ចាស់ទេឬ? សូមប្រាប់ខ្ញុំមក»។
9មេនៃអ្នកថ្វាយពែងប្រាប់សុបិនរបស់គាត់ដល់លោកយ៉ូសែប។ លោកនិយាយទៅគាត់ថា៖ «នៅក្នុងសុបិនរបស់ខ្ញុំ មើល៍ មានដើមទំពាំងបាយជូរនៅមុខខ្ញុំ។
នៅដើមទំពាំងបាយជូរមានមែកបី។10ក្នុងការដែលមានពន្លកលេចចេញមក ផ្កាវាក៏លាស់ចេញមកដែរ ហើយមានផ្លែទុំផង។11ពែងរបស់ស្តេចផារោននៅក្នុងដៃរបស់គាត់។
ខ្ញុំបានបេះផ្លែទំពាំងបាយជូរមកគាបដាក់ពែងរបស់ស្តេចផារ៉ោន ហើយខ្ញុំបានយកពែងទៅថ្វាយដល់ព្រះហស្តរបស់ផារ៉ោន»។
12លោកយ៉ូសែបនិយាយទៅគាត់ថា៖ «នេះគឺជាការបកស្រាយរបស់សុបិននេះ។ មែងបី គឺបីថ្ងៃ។13ក្នុងកំឡុងពេលបីថ្ងៃស្តេចផារោននឹងលើកលោកឡើង
ហើយនឹងស្តារតំណែងរបស់លោកឡើងវិញ។ អ្នកនឹងថ្វាយពែងរបស់ព្រះបាទផារោននៅក្នុងព្រះហស្តរបស់ព្រះអង្គ
ដូចពេលដែលលោកនៅជាអ្នកថ្វាយពែងរបស់ព្រះអង្គដូចមុន។


generated on Wed Mar 12 15:32:40 2025

14ប៉ុន្តែ សូមនឹកចាំពីខ្ញុំផង នៅពេលលោកបានសុខសប្បាយ ហើយសូមផ្តល់មេត្តាដល់ខ្ញុំផង។ សូមដំណាលខ្ញុំនៅចំពោះព្រះបាទផារោន ហើយនាំខ្ញុំចេញពីគុកនេះផង។
15ដ្បិត គេបានចាប់ខ្ញុំពីទឹកដីហេព្រើរមក។ ហើយនៅទីនេះ ខ្ញុំមិនបានធ្វើអ្វីខុសគួរឲ្យពួកគេយកខ្ញុំមកឃុំឃាំងដូច្នេះឡើយ»។
16នៅពេលមេនៃអ្នកដុតនំឃើញថា ការបកស្រាយរបស់លោកយ៉ូសែបគាត់ពេញចិត្តជាខ្លាំង នោះគាត់ក៏និយាយទៅកាន់លោកយ៉ូសែបថា៖ «ខ្ញុំក៏មានសុបិនមួយដែរ ហើយ
មើល៍ មាននំប៉័ងបីកន្ត្រក់នៅលើក្បាលខ្ញុំ។ 17នៅលើកន្ត្រក់នោះមាននំដុតជាច្រើនប្រភេទសម្រាប់ថ្វាយស្តេចផារោន ប៉ុន្តែ
មានសត្វហើរមកស៊ីនំទាំងនោះអស់ពីកន្ត្រក់នៅលើក្បាលរបស់ខ្ញុំ»។
18លោកយ៉ូសែបឆ្លើយ ហើយប្រាប់ថា៖ «នេះគឺជាការបកស្រាយ។ កន្ត្រក់បីគឺបីថ្ងៃ។ 19កំឡុងពេលបីថ្ងៃ ព្រះបាទផារោននឹងកាត់ក្បាលរបស់លោកចេញពីលោក
ហើយព្យួរលោកនឹងដើមឈើមួយដើម។ សត្វនឹងស៊ីសាច់លោក។
20បីថ្ងៃក្រោយមក ជាថ្ងៃបុណ្យចម្រើនព្រះជន្មរបស់ព្រះបាទផារ៉ោន។ ស្តេចបានរៀបចំពិធីជប់លៀងសម្រាប់ពួកមន្ត្រីទាំងអស់របស់ស្តេច។ ហើយស្តេចបានលើកមុខមេ
ថ្វាយពែង និងមេដុតនំ នៅក្នុងចំណោមមន្ត្រីរបស់ស្តេច។ 21ស្តេចបានស្តារមេនៃអ្នកថ្វាយពែងទៅកាន់តំណែងរបស់ខ្លួនឡើងវិញ
ហើយស្តេចបានប្រគល់ពែងរបស់ព្រះអង្គឲ្យទៅដៃរបស់គាត់វិញ។ 22ប៉ុន្តែ ស្តេចបានព្យួរមេនៃអ្នកដុតនំ ដូចដែលលោកយ៉ូសែបបានបកស្រាយដល់ពួកគេ។ 23ប៉ុន្តែ
មេនៃអ្នកថ្វាយពែងស្តេចមិនបាននឹកចាំពីលោកយ៉ូសែបទេ គឺបានភ្លេចគាត់។

## ជំពូក ៤១

1ពីរឆ្នាំក្រោយមក ព្រះបាទផារោនបានសុបិន។ មើល៍ ស្តេចគង់នៅក្បែរទន្លេនីល។ 2មើល៍ មានគោធាត់ៗប្រាំពីរបានចេញពីទន្លេនីលមក ហើយគួរឲ្យចង់បាន
ព្រមទាំងស៊ីស្មៅតាមមាត់ច្រាំងនោះ។ 3មើល៍ មានគោប្រាំពីរផ្សេងទៀត បានឡើងមកតាមក្រោយគោទាំងនោះពីទន្លេនីល ស្គមៗ ហើយមិនគួរឲ្យចង់បានទេ។
ពួកវាឈរនៅជិតគោទាំងប្រាំពីរដែលនៅមាត់ច្រាំងទន្លេនោះ។
4បន្ទាប់មក គោដែលស្គម មិនគួរឲ្យចង់បានទាំងប្រាំពីរនោះបានស៊ីគោធាត់ៗដែលគួរឲ្យចង់បាននោះ។ បន្ទាប់មក ព្រះបាទផារោនបានតើនឡើង។ 5ពេលនោះ
ស្តេចបានផ្ទំសារជាថ្មី ហើយបានសុបិនលើកទីពីរ។ មើល៍ មានស្រូវប្រាំពីរកួរដុះចេញពីស្រូវមួយដើម មានគ្រាប់ថ្លោស ហើយល្អ។ 6មើល៍ក៏មានកួរស្រូវប្រាំពីរទៀត ស្គម
និងស្កកដោយសារខ្យល់ពីទិសខាងកើត លូតចេញមកតាមក្រោយបន្ទាប់ពីកួរស្រូវនោះ។
7កួរស្រូវស្គមបានលេបកួរស្រូវថ្លោស ហើយល្អទាំងប្រាំពីរនោះ។ ព្រះបាទផារោនបានតើនឡើង ហើយមើល៍ វាជាសុបិន។ 8នៅពេលព្រឹកឡើង
វិញ្ញាណរបស់ស្តេចខ្វល់ខ្វាយជាខ្លាំង។ ស្តេចបានចាត់ ហើយឲ្យគេទៅហៅពួកគ្រូទាយ ហើយនិងអ្នកប្រាជ្ញរបស់ជនជាតិអេស៊ីបទាំងអស់មក។
ព្រះបាទផារោនប្រាប់ពួកគេពីសុបិនរបស់ព្រះអង្គ ប៉ុន្តែ គ្មាននរណាអាចបកស្រាយសុបិននោះថ្វាយព្រះបាទផារោនបានទេ។
9បន្ទាប់មក មេនៃអ្នកថ្វាយពែងបានទូលទៅព្រះបាទផារោនថា៖ «ថ្ងៃនេះ ទូលបង្គំបានគិតអំពីកំហុសរបស់ទូលបង្គំ។
10ព្រះបាទផារោនមានព្រះហឫទ័យខ្ញាល់ជាមួយពួកមន្ត្រីរបស់ព្រះអង្គ ហើយព្រះអង្គបានឃុំទូលបង្គំនៅក្នុងផ្ទះរបស់មេអង្គរក្ស មានមេនៃអ្នកដុតនំ និងទូលបង្គំ។
11យើងបានយល់សប្តិមួយនៅក្នុងយប់តែមួយ គាត់ និងទូលបង្គំ។ យើងម្នាក់ៗសុបិនរៀងខ្លួន មានការបកស្រាយរៀងខ្លួនដែរ។
12មានក្មេងប្រុសជនជាតិហេព្រើរម្នាក់ ជាអ្នកបម្រើមេនៃអង្គរក្ស។ យើងបានប្រាប់គាត់ ហើយគាត់បានបកស្រាយសុបិននោះដល់យើង។
គាត់បានបកស្រាយឲ្យយើងម្នាក់ៗ ទៅតាមសុបិនរបស់យើងរៀងខ្លួន។ 13ហើយអ្វីដែលគាត់បានបកស្រាយនោះ បានកើតឡើងយ៉ាងនោះមែន។
ព្រះបាទផារោនបានប្រគល់តំណែងរបស់ទូលបង្គំឲ្យទូលបង្គំវិញ ប៉ុន្តែ ម្នាក់ទៀតត្រូវបានព្យួរក»។
14បន្ទាប់មក ព្រះបាទផារោនបានចាត់ ហើយឲ្យគេទៅហៅលោកយ៉ូសែប។ ពួកគេបានទៅយកគាត់ចេញពីទីឃុំឃាំងយ៉ាងលឿន។
កាលគាត់បានកោរពុកមាត់របស់គាត់រួចហើយ គាត់បានប្តូរសម្លៀកបំពាក់របស់គាត់ ហើយចូលមកគាល់ព្រះបាទផារោន។
15ព្រះបាទផារោនមានរាជឱង្ការទៅលោកយ៉ូសែបថា៖ «យើងមានសុបិនមួយ ប៉ុន្តែ គ្មាននរណាអាចបកស្រាយសុបិនរបស់យើងបានទេ។ ប៉ុន្តែ យើងបានឮពីអ្នកថា
ពេលអ្នកឮពីសុបិន អ្នកអាចបកស្រាយវាបាន»។ 16លោកយ៉ូសែបទូលទៅព្រះបាទផារោនថា៖ «មិនមែនជាទូលបង្គំទេ។ ព្រះជាម្ចាស់នឹងឆ្លើយចំពោះព្រះបាទផារោន»។
17ព្រះបាទផារោនមានរាជឱង្ការនឹងលោកយ៉ូសែបថា៖ «សុបិនរបស់យើងដូច្នេះ មើល៍ កាលយើងគង់នៅមាត់ច្រាំងទន្លេនីល។ 18មានគោធាត់ៗ
ហើយថ្លោសល្អឡើងចេញពីទន្លេនីលមក ហើយពួកវាស៊ីស្មៅក្បែរមាត់ច្រាំងនោះ។
19មើល៍ ក៏មានគោស្គម ហើយអាក្រក់មើលណាស់ឡើងមកដែរ។ យើងមិនដែលឃើញនៅក្នុងទឹកដីអេស៊ីបឡើយ។ 20គោស្គម អាក្រក់ៗទាំងនោះមកស៊ីគោធាត់ៗ
ហើយល្អៗទាំងអស់។ 21នៅពេលពួកគេបានស៊ីគោទាំងនោះអស់ហើយ ក៏គ្មាននរណាដឹងថាគោស្គមៗបានស៊ីគោធាត់ទាំងអស់នោះ ព្រោះគោនោះនៅតែស្គមអាក្រក់ដូចមុន
ដដែល។ ពេលនោះ យើងក៏ភ្ញាក់ឡើង។
22យើងបានមើលទៅក្នុងសុបិនរបស់យើង ហើយមើល៍ កួរស្រូវទាំងប្រាំពីរបានលេចមក មានគ្រាប់ធំៗថ្លោសល្អ លូតចេញពីដើមតែមួយ។ 23ហើយមើល៍ក៏មានកួរស្រូវប្រាំពីរ
ទៀត មានគ្រាប់តូចៗ ហើយស្កកដោយសារខ្យល់ពីទិសខាងកើត លូតចេញមកតាមក្រោយ។ 24កួរស្រូវមានគ្រាប់តូចៗបានលេបកួរស្រូវមានគ្រាប់ធំៗទាំងប្រាំពីរ។
យើងបានប្រាប់សុបិននេះ ដល់ពួកគ្រូទាយទាំងឡាយ ប៉ុន្តែ គ្មាននរណាអាចបកស្រាយឲ្យយើងបានទេ»។
25លោកយ៉ូសែបទូលទៅព្រះបាទផារោនថា៖ «សុបិនរបស់ព្រះអង្គដូចគ្នាទេ។ ជាអ្វីដែលព្រះជាម្ចាស់បម្រុងនឹងធ្វើ ព្រះអង្គបានប្រកាសដល់ព្រះបាទផារោន។ 26គោល្អ
ហើយធាត់ៗប្រាំពីរ និងកួរស្រូវល្អប្រាំពីរគឺប្រាំពីរឆ្នាំ។ សុបិននេះដូចគ្នាទេ។
27ចំណែក គោស្គម ហើយអាក្រក់ៗប្រាំពីរ បានឡើងមកបន្ទាប់នោះគឺជាប្រាំពីរឆ្នាំ ក្រោយមកទៀត
ហើយនិងកួរស្រូវស្កកប្រាំពីរដោយសារខ្យល់មកពីទិសខាងកើតគឺនឹងមានគ្រោះទុរ្ភិក្សប្រាំពីរឆ្នាំកើតឡើងដែរ។ 28នោះគឺជាអ្វីដែលខ្ញុំនឹងទូលទៅព្រះបាទផារោន។
ពីអ្វីដែលព្រះជាម្ចាស់នឹងធ្វើ ហើយបានបង្ហាញដល់ស្តេចផារោន។ 29មើល៍ នឹងមានភាពសម្បូរហូរហៀរ រយៈពេលប្រាំពីរឆ្នាំនៅក្នុងទឹកដីអេស៊ីប។
30នឹងមានគ្រោះទុរ្ភិក្សកើតឡើងបន្ទាប់ពីនេះ ហើយភាពសម្បូរហូរហៀរនៅក្នុងទឹកដីអេស៊ីបនឹងត្រូវភ្លេចបាត់។ ហើយគ្រោះទុរ្ភិក្សនោះនឹងបំផ្លាញទឹកដីទាំងមូល។
31ភាពសម្បូរហូរហៀរនឹងភ្លេចបាត់ នៅក្នុងទឹកដីអេស៊ីប ដោយសារគ្រោះទុរ្ភិក្សខ្លាំងពេក។ 32ព្រះបាទផារោនសុបិនឃើញរឿងនេះម្តងហើយម្តងទៀត ដោយសាររឿងនេះ
ព្រះជាម្ចាស់ជាអ្នកដែលធ្វើឲ្យកើតឡើង ហើយព្រះជាម្ចាស់នឹងធ្វើវាជាឆាប់។
33ឥឡូវនេះ សូមព្រះបាទផារោនស្វែងរកមនុស្សដែលមានយោបល់ និងប្រាជ្ញា ហើយលើកគាត់ឲ្យគ្រប់គ្រងលើទឹកដីអេស៊ីប។ 34សូមព្រះបាទផារោនធ្វើការនេះ
សូមឲ្យស្តេចបានតែងតាំងគាត់ឲ្យគ្រប់គ្រងនៅលើទឹកដី។ ឲ្យគេជកហូតយកមួយភាគក្នុងប្រាំ ពីភោគផលក្នុងទឹកដីអេស៊ីប នៅក្នុងរវាងប្រាំពីរឆ្នាំដែលសម្បូរហូរហៀរនេះ។
35សូមឲ្យអ្នកនោះប្រមូលអាហារនៅក្នុងឆ្នាំល្អទាំងអស់ក្នុងឆ្នាំល្អដែលនៅខាងមុខ ហើយទុកស្រូវក្នុងឃ្លាំងនៅក្រោមអំណាចរបស់ព្រះអង្គ ដើម្បីធ្វើជាស្បៀងនៅតាមទីក្រុង
នានា។ 36ពួកគេរក្សាទុកអាហារទាំងនោះ។ ស្បៀងទាំងនោះនឹងត្រូវផ្គត់ផ្គង់សម្រាប់រយៈពេលទុរ្ភិក្សប្រាំពីរឆ្នាំ នៅទឹកដីអេស៊ីប។ ធ្វើបែបនេះ ដើម្បីកុំឲ្យប្រជាជនត្រូវស្លាប់
ដោយអត់ឃ្លាន»។
37យោបល់នេះល្អនៅចំពោះស្តេចផារោន ហើយនិងចំពោះមន្ត្រីរបស់ស្តេចទាំងអស់។ 38ព្រះបាទផារោនមានរាជឱង្ការទៅកាន់មន្ត្រីរបស់ព្រះអង្គថា៖
«តើយើងអាចរកបានមនុស្សដូចម្នាក់នេះទេ ដែលនៅក្នុងគាត់មានព្រះវិញ្ញាណរបស់ព្រះជាម្ចាស់»។


generated on Wed Mar 12 15:32:40 2025

# ជំពូក ៤២

39 ដូច្នេះ ព្រះបាទផារោនមានរាជឱង្ការទៅលោកយ៉ូសែបថា៖ «ព្រះជាម្ចាស់បានបង្ហាញដល់លោកគ្រប់ការទាំងអស់នេះហើយ គ្មាននរណាមានយោបល់
និងប្រាជ្ញាដូចលោកឡើយ។ 40 លោកនឹងហើយត្រូវគ្រប់គ្រងដំណាក់របស់យើង ហើយស្របតាមពាក្យរបស់លោក គឺលោកនឹងគ្រប់គ្រងលើប្រជារាស្ត្ររបស់យើង។
មានតែយើងទេដែលធំជាងលោក»។ 41 ព្រះបាទផារោនមានរាជឱង្ការទៅលោកយ៉ូសែបទៀតថា៖ «មើល៍ យើងបានតាំងលោកឲ្យគ្រប់គ្រងលើទឹកដីអេស៊ីបទាំងមូល»។
42 ព្រះបាទផារោនបានដោះចិញ្ចៀនរបស់ព្រះអង្គពីព្រះហស្ត ហើយពាក់នឹងដៃរបស់លោកយ៉ូសែប។ ព្រះអង្គបានយកអាវមួយដ៏ល្អប្រណិតមកឲ្យលោក និងយកខ្សែកមាស
មួយខ្សែពាក់ឲ្យលោកផងដែរ។ 43 ព្រះអង្គបានឲ្យលោកជិះរាជរថតាមពីក្រោយបន្ទាប់ពីស្តេច។ ពួកប្រុសៗស្រែកនៅពីមុខលោកថា៖ «ចូរក្រាបចុះ»។
ព្រះបាទផារោនបានតាំងលោកឲ្យគ្រប់គ្រងលើទឹកដីអេស៊ីបទាំងមូល។
44 ព្រះបាទផារោនមានរាជឱង្ការទៅលោកយ៉ូសែបថា៖ «យើងជាស្តេចផារ៉ោន នៅក្នុងទឹកដីអេស៊ីបទាំងមូល គ្មាននរណាម្នាក់មានសិទ្ធិធ្វើអ្វីមួយ ដោយគ្មានការអនុញ្ញាតពី
លោកជាមុននោះឡើយ»។ 45 ព្រះបាទផារ៉ោនប្រទាននាមឲ្យលោកយ៉ូសែបថា៖ «សាប់ណាត់ផានា»។ ស្តេចបានលើកនាងអាសណាត់ កូនស្រីរបស់លោកប៉ូទីផេរ៉ា ជា
បូជាចារ្យនៅក្រុងអូន ធ្វើជាភរិយា។ លោកយ៉ូសែបបានចេញទៅត្រួតពិនិត្យមើលលើទឹកអេស៊ីបទាំងមូល។
46 លោកយ៉ូសែបមានអាយុសាមសិបឆ្នាំ នៅពេលគាត់ឈរនៅចំពោះព្រះបាទផារ៉ោន ស្តេចរបស់អេស៊ីប។ លោកយ៉ូសែបបានចេញពីស្តេចផារ៉ោន
ហើយចេញទៅពេញទឹកដីអេស៊ីបទាំងមូល។ 47 នៅក្នុងរយៈពេលសម្បូរហូរហៀរប្រាំពីរឆ្នាំនោះ ដីបានបង្កើតផលជាបរិបូរ។
48 គាត់បានប្រមូលស្បៀងក្នុងរយៈពេលប្រាំពីរឆ្នាំ នៅក្នុងទឹកដីអេស៊ីប ហើយបានទុកនៅតាមក្រុងនានា។
គាត់បានទុកស្បៀងនៅតាមក្រុងនីមួយៗពីស្រែនៅនៅជុំវិញនោះ។ 49 លោកយ៉ូសែបបានរក្សាស្រូវដូចជាខ្សាច់នៅតាមសមុទ្រយ៉ាងច្រើន និងមិនអាចរាប់បាន
ព្រោះច្រើនពេកដែលមិនអាចរាប់បាន។
50 លោកយ៉ូសែបមានកូនប្រុសពីរនាក់ មុនពេលគ្រោះទុរ្ភិក្សកើតឡើង នាងអាសណាត់ជាកូនរបស់លោកប៉ូទីផេរ៉ា បូជាចារ្យនៅក្រុងអូន បានបង្កើតកូនប្រុសឲ្យគាត់។
51 លោកយ៉ូសែបដាក់ឈ្មោះកូនបងថា ម៉ាណាសេ ដ្បិត លោកពោលថា៖ «ព្រះជាម្ចាស់បានប្រោសឲ្យខ្ញុំភ្លេចទុក្ខវេទនាទាំងប៉ុន្មាន និងភ្លេចញាតិសន្តានទាំងប៉ុន្មានរបស់
ឪពុកខ្ញុំដែរ»។ 52 លោកបានដាក់ឈ្មោះកូនបន្ទាប់ថា អេប្រាអ៊ីម ដ្បិត លោកពោលថា៖ «ព្រះជាម្ចាស់ប្រទានឲ្យខ្ញុំមានកូនចៅក្នុងទឹកដីដែលខ្ញុំបានរងទុក្ខវេទនានេះ»។
53 ប្រាំពីរឆ្នាំនៃភាពសម្បូរហូរហៀរដែលនៅក្នុងទឹកដីអេស៊ីបបានបញ្ចប់។ ហើយប្រាំពីរឆ្នាំនៃគ្រោះទុរ្ភិក្សបានចាប់ផ្តើម ដូចលោកយ៉ូសែបបាននិយាយ។ 54 មានគ្រោះ
ទុរ្ភិក្សកើតឡើងនៅក្នុងទឹកដីអេស៊ីបទាំងមូល ប៉ុន្តែ មានស្បៀងនៅក្នុងទឹកដីអេស៊ីបទាំងមូល។
55 នៅពេលគ្រោះទុរ្ភិក្សនៅក្នុងទឹកដីអេស៊ីប មនុស្សនាំគ្នាស្រែកសុំអាហារពីស្តេចផារ៉ោន។ ស្តេចផារោនបានមានបន្ទូលទៅកាន់ជនជាតិអេស៊ីបទាំងអស់ថា៖
«ចូរទៅលោកយ៉ូសែប ហើយធ្វើតាមអ្វីដែលគាត់និយាយចុះ»។ 56 គ្រោះទុរ្ភិក្សបានកើតឡើងនៅពាសពេញទឹកដីទាំងមូល។
លោកយ៉ូសែបបានបើកឃ្លាំងទាំងអស់របស់លោក ហើយលក់ឲ្យជនជាតិអេស៊ីប។ គ្រោះទុរ្ភិក្សបានកើតឡើងជាខ្លាំងនៅក្នុងអេស៊ីប។
57 ពិភពលោកទាំងមូលបានចូលមកអេស៊ីប ដើម្បីទិញស្រូវពីលោកយ៉ូសែប ព្រោះគ្រោះទុរ្ភិក្សបានកើតឡើងជាខ្លាំងនៅលើផែនដីទាំងមូល។

## ជំពូក ៤២

1 លោកយ៉ាកុបបានដឹងថា មានស្រូវនៅក្នុងអេស៊ីប។ គាត់បានប្រាប់ទៅកូនប្រុសៗរបស់គាត់ថា៖ «ហេតុអ្វីបានជាកូនៗមើលមុខគ្នាទៅវិញទៅមកដូច្នេះ?» 2 គាត់ប្រាប់ថា៖
«មើល៍ យើងបានឮថាមានស្រូវនៅអេស៊ីប។ ចូរចុះទៅអេស៊ីប ហើយទិញស្រូវពីនោះមក ដើម្បីកុំឲ្យយើងស្លាប់ តែដើម្បីឲ្យយើងបានរស់វិញ»។
3 បងប្រុសទាំងដប់របស់លោកយ៉ូសែបបានចុះទៅទិញស្រូវពីអេស៊ីប។ 4 ប៉ុន្តែ បេនយ៉ាមីន ជាប្អូនប្រុសរបស់លោកយ៉ូសែប លោកយ៉ាកុបមិនឲ្យទៅជាមួយបងៗរបស់គាត់ទេ
ព្រោះគាត់ខ្លាចថា មានគ្រោះថ្នាក់ដល់គាត់។
5 កូនប្រុសៗរបស់លោកអ៊ីស្រាអែលបានមកទិញស្រូវជាមួយអ្នកផ្សេងៗទៀត ដ្បិត មានគ្រោះទុរ្ភិក្សនៅក្នុងទឹកដីកាណានដែរ។ 6 លោកយ៉ូសែបជាអ្នកគ្រប់គ្រងនៅលើទឹកដី។
គាត់ជាម្នាក់ដែលបានលក់ដល់មនុស្សគ្រប់គ្នានៅក្នុងប្រទេស។ បងៗរបស់លោកយ៉ូសែបបានមក ហើយលុតជង្គង់ចុះចំពោះគាត់ ហើយឱនមុខរបស់ពួកគេទល់នឹងដី។
7 លោកយ៉ូសែបបានឃើញបងៗរបស់គាត់ ហើយស្គាល់ពួកគេ ប៉ុន្តែ គាត់ធ្វើជាមិនស្គាល់ពួកគេ ហើយនិយាយគំរោះគំរើយជាមួយពួកគេថា៖
«តើអ្នកទាំងអស់គ្នាមកពីណា?» ពួកគេឆ្លើយថា៖ «មកពីទឹកដីកាណាន ដើម្បីទិញអាហារ»។ 8 លោកយ៉ូសែបស្គាល់បងៗ ប៉ុន្តែ ពួកគេមិនស្គាល់លោកទេ។
9 នោះ លោកយ៉ូសែបបានចាំពីសុបិនដែលគាត់បានសុបិនពីពួកគេ ហើយគាត់និយាយទៅពួកគេថា៖ «តើអស់លោកជាអ្នកស៊ើបការណ៍មែនទេ?»។ 10 ពួកគេឆ្លើយថា៖
«អត់ទេ លោកម្ចាស់។ យើងខ្ញុំមកទីនេះ ដើម្បីទិញស្បៀងតែប៉ុណ្ណោះ។ យើងមានឪពុកតែមួយ។ 11 យើងជាមនុស្សស្មោះត្រង់។ យើងខ្ញុំមិនមែនជាអ្នកស៊ើបការណ៍ទេ»។
12 គាត់និយាយទៅពួកគេថា៖ «អត់ទេ អ្នករាល់គ្នាមកដើម្បីមកស៊ើបការណ៍ទឹកដីនេះមែន!»។ 13 ពួកគេនិយាយថា៖ «យើងខ្ញុំមានបងប្អូនដប់ពីរនាក់
ជាកូនរបស់បុរសម្នាក់ដែលរស់នៅទឹកដីកាណាន។ មើល ប្អូនប្រុសពៅរបស់យើងនៅជាមួយឪពុករបស់យើង ហើយម្នាក់ទៀតបានស្លាប់បាត់ហើយ»។
14 លោកយ៉ូសែបនិយាយទៅពួកគេថា៖ «នោះជាអ្វីដែលអ្នករាល់គ្នានិយាយ អ្នករាល់គ្នាគឺជាអ្នកស៊ើបការណ៍។ 15 ដោយហេតុនេះ ខ្ញុំនឹងល្បងលអ្នករាល់គ្នា។ ដរាបណា
ផារ៉ោននៅមានព្រះជន្ម នោះអ្នករាល់គ្នានឹងមិនអាចចេញពីទីនេះបានឡើយ។ 16 ចូរចាត់នរណាម្នាក់ឲ្យទៅហើយនាំប្អូនពៅរបស់អ្នករាល់ឯងមកដល់ទីនេះសិន។
អ្នកនឹងត្រូវជាប់គុក រហូតទាល់តែបានល្បងលមើលដឹងថា ពាក្យរបស់អ្នករាល់គ្នាពិតមែន»។ 17 គាត់បានឃុំខ្លួនអ្នកទាំងអស់នោះអស់រយៈពេលបីថ្ងៃ។
18 លោកយ៉ូសែបនិយាយទៅពួកគេនៅថ្ងៃទីបីថា៖ «ចូរធ្វើដូច្នេះ ហើយអ្នករាល់គ្នានឹងបានរស់ ដ្បិត ខ្ញុំក៏ជាអ្នកគោរពកោតខ្លាចព្រះជាម្ចាស់ដែរ។ 19 ប្រសិនបើ
អ្នករាល់គ្នាជាសមនុស្សស្មោះត្រង់មែន ចូរឲ្យបងប្អូនរបស់អ្នករាល់គ្នាណាម្នាក់នៅជាប់ក្នុងគុកនេះហើយ ប៉ុន្តែ អ្នករាល់គ្នាអាចទៅ
នាំយកស្រូវទៅផ្ទះរបស់អ្នករាល់គ្នាព្រោះមានភាពអត់ឃ្លាននៅទីនោះ។ 20 ហើយនាំប្អូនប្រុសពៅរបស់អ្នកមកឲ្យខ្ញុំ ដើម្បីបញ្ជាក់ថាអ្នករាល់គ្នាស្មោះត្រង់
ហើយអ្នករាល់គ្នាមិនត្រូវស្លាប់ឡើយ»។ ដូច្នេះ ពួកគេក៏ធ្វើតាម។
21 ពួកគេនិយាយគ្នានឹងគ្នាថា៖ «យើងពិតជាមានកំហុសមែន ទាក់ទងនឹងប្អូនប្រុសរបស់យើង ដែលយើងឃើញពីទុក្ខកង្វល់នៃព្រលឹងរបស់គាត់
នៅពេលយើងគាត់អង្វរយើង ហើយយើងមិនស្តាប់គាត់ទេ។ ដូច្នេះហើយ បានជាទុក្ខកង្វល់របស់គាត់បានធ្លាក់មកលើយើង»។ 22 លោករូបេនឆ្លើយទៅពួកគេថា៖
«តើបងមិនបានប្រាប់អ្នកទាំងអស់គ្នាទេឬអីថា កុំធ្វើបាបទាស់នឹងប្អូនប្រុសឡើយ ប៉ុន្តែ អ្នករាល់គ្នាមិនស្តាប់សោះ? ឥឡូវមើល៍
ឈាមរបស់វាបានទាមទារពីយើងវិញហើយ»។
23 ពួកគេមិនបានដឹងថា លោកយ៉ូសែបយល់សម្តីពួកគេទេ ដើម្បីមានអ្នកបកប្រែឲ្យពួកគេ។ 24 គាត់បានបែរមុខពីពួកគេ ហើយយំ។ គាត់បានត្រឡប់មកវិញ
ហើយនិយាយទៅកាន់ពួកគេ។ គាត់បានយកលោកស៊ីម្មានពីចំណោមពួកគេ ហើយចងគាត់នៅចំពោះមុខពួកគេ។ 25 បន្ទាប់មក
លោកយ៉ូសែបបានបង្គាប់ដល់អ្នកបម្រើរបស់គាត់ឲ្យដាក់ស្រូវពេញបាវរបស់ពួកគេរៀងៗខ្លួន ហើយបានដាក់ប្រាក់ត្រឡប់ទៅថង់លុយរបស់ពួកគេគ្រប់គ្នាវិញ
ហើយផ្គត់ផ្គង់ដល់ដំណើររបស់ពួកគេដែរ។ គាត់បានធ្វើដូច្នេះជាមួយបងៗគាត់។
26 បងៗបានលើកស្រូវរបស់ពួកគេដាក់លើសត្វលា ហើយបានចេញពីទីនោះទៅ។ 27 ម្នាក់ក្នុងចំណោមពួកគេបានបើកបាវរបស់គាត់ដើម្បីឲ្យស្មៅលាស៊ីនៅពេលសម្រាក
គាត់បានឃើញលុយរបស់គាត់។ មើល៍ ឃើញលុយនៅក្នុងបាវរបស់គាត់។ 28 គាត់ប្រាប់បងៗរបស់គាត់ថា៖ «គេដាក់លុយខ្ញុំមកវិញ។ មើលនែ៎ វានៅក្នុងបាវខ្ញុំឯនេះ»។
ពួកគេមានការភ័យខ្លាចជាខ្លាំង ហើយពួកគេរត់រកគ្នាទាំងញាប់ញ័រ ដោយនិយាយថា៖ «ហេតុអ្វីបានជាព្រះជាម្ចាស់ធ្វើដាក់យើងដូច្នេះ?»។
29 ពួកគេបានទៅជួបលោកយ៉ាកុប ឪពុករបស់ពួកគេរស់នៅក្នុងទឹកដីកាណាន ហើយបានប្រាប់គាត់ នូវអ្វីៗដែលបានកើតឡើងជាមួយពួកគេ។ ពួកគេប្រាប់ថា៖
30 «លោកដែលជាចៅហ្វាយរបស់ទឹកដីនោះ បាននិយាយសម្លុតយើង ហើយគិតថា យើងគឺជាអ្នកស៊ើបការណ៍នៅក្នុងទឹកដីរបស់គេ។ 31 យើងប្រាប់គាត់ថា៖


generated on Wed Mar 12 15:32:40 2025

«យើងជាមនុស្សស្មោះត្រង់។ យើងមិនមែនជាអ្នកស៊ើបការណ៍ទេ។[32]យើងមានបងប្អូនដប់ពីរនាក់ ជាកូនដែលចេញពីឪពុកតែមួយ។ ម្នាក់បានស្លាប់បាត់ហើយ
ហើយប្អូនប្រុសពៅនៅជាមួយឪពុករបស់យើង នៅក្នុងទឹកដីកាណានឯណោះ»។
[33]បុរសដែលជាម្ចាស់ទឹកដីនោះ និយាយមកយើងថា៖ «ទុកប្អូនប្រុសម្នាក់របស់អ្នករាល់គ្នានៅជាមួយយើងម្នាក់ បើធ្វើដូច្នេះ យើងដឹងថាអ្នកពិតជាមនុស្សស្មោះត្រង់មែន
ហើយយកស្រូវទៅដោយព្រោះគ្រោះអត់ឃ្លាននៅក្នុងផ្ទះរបស់អ្នក ហើយចាកចេញទៅ។[34]ចូរនាំប្អូនប្រុសពៅរបស់អ្នកមកឲ្យខ្ញុំ។ បន្ទាប់មក ខ្ញុំនឹងដឹងថា
អ្នករាល់គ្នាប្រាកដជាមិនមែនអ្នកស៊ើបការណ៍ទេ ហើយដឹងថាអ្នកគឺជាមនុស្សស្មោះត្រង់មែន។ បន្ទាប់មក យើងនឹងដោះលែងប្អូនរបស់អ្នករាល់គ្នា
ហើយអ្នករាល់គ្នាអាចប្រកបរបរនៅក្នុងទឹកដីនេះបាន»។
[35]នៅពេលពួកគេបានចាក់ស្រូវចេញពីបាវហើយ មើល៍ នៅក្នុងបាវរបស់ម្នាក់ៗមានប្រាក់នៅក្នុងបាវនោះ។ នៅពេលពួកគេ
និងឪពុករបស់ពួកគេបានឃើញបាវមានប្រាក់នោះ ពួកគេភ័យខ្លាចយ៉ាងខ្លាំង។[36]លោកយ៉ាកុប ឪពុករបស់ពួកគេបាននិយាយទៅពួកគេថា៖
«ឯងរាល់គ្នាបានធ្វើឲ្យឪពុកបាត់កូនអស់ហើយ។ ឯងរាល់គ្នាបានធ្វើឲ្យយ៉ូសែប និងស៊ីម្មានបានស្លាប់ ហើយឥឡូវនេះ
ឯងរាល់គ្នាចង់យកបេនយ៉ាមីនចេញពីយើងទៀតមែនទេ។ ការទាំងអស់នេះទាស់នឹងឪពុកហើយ»។
[37]លោករូបេនបាននិយាយទៅកាន់ឪពុករបស់គាត់ថា៖ «លោកឪពុកអាចសម្លាប់កូនប្រុសទាំងពីររបស់ខ្ញុំ ប្រសិនបើ ខ្ញុំមិននាំបេនយ៉ាមីនមកឲ្យលោកឪពុកវិញ។
សូមឲ្យវាមកក្នុងដៃរបស់ខ្ញុំចុះ ហើយខ្ញុំនឹងនាំវាត្រឡប់មករកឪពុកវិញ»។[38]លោកយ៉ាកុបនិយាយថា៖ «យើងមិនឲ្យកូនរបស់យើងទៅជាមួយឯងទេ។ ដ្បិត
បងប្រុសរបស់វាបានស្លាប់ហើយ នៅសល់តែវាទេ។ ប្រសិនបើ វាមានគ្រោះថ្នាក់អ្វីនៅតាមផ្លូវដែលទៅជាមួយឯង ដូច្នេះ
ឯងរាល់គ្នាមុខជានាំសក់ស្កូវរបស់ឪពុកជាមួយនឹងភាពសោកសៅទៅស្ថានឃុំព្រលឹងហើយ»។

## ជំពូក ៤៣

[1]គ្រោះទុរ្ភិក្សបានកើតមាននៅក្នុងស្រុកកាន់តែខ្លាំងឡើង។[2]នៅពេលពួកគេបានហូបស្រូវដែលបានទិញពីអេស៊ីបមកអស់ហើយ
ឪពុករបស់ពួកគេបាននិយាយទៅពួកគេថា៖ «ចូរទៅម្តងទៀតចុះ ទៅទិញអាហារខ្លះសម្រាប់យើង»។
[3]លោកយូដាប្រាប់គាត់ថា៖ «បុរសនោះបានប្រាប់ពួកយើងយ៉ាងច្បាស់ថា៖ «ប្រសិនបើ មិននាំប្អូនប្រុសរបស់យើងទៅទេ កុំមកជួបមុខយើងទៀត»។[4]ប្រសិនបើ
លោកឪពុកឲ្យប្អូនប្រុសទៅជាមួយយើង យើងនឹងចុះទៅម្តងទៀត ហើយទិញអាហារជូនលោកឪពុក»។[5]ប៉ុន្តែ ប្រសិនបើ លោកឪពុកមិនឲ្យប្អូនប្រុសទៅជាមួយយើងទេ
យើងនឹងមិនទៅទេ។ ដ្បិត បុរសនោះបានប្រាប់យើងរួចហើយថា៖ «ប្រសិនបើ មិននាំប្អូនប្រុសរបស់យើងទៅទេ កុំមកជួបមុខយើងទៀត»។
[6]លោកអ៊ីស្រាអែលប្រាប់ថា៖ «ហេតុអ្វីបានជាឯងរាល់គ្នាប្រព្រឹត្តនឹងយើងអាក្រក់យ៉ាងដូច្នេះ ដោយប្រាប់បុរសនោះថា ឯងមានប្អូនម្នាក់ទៀត?»[7]ពួកគេ និយាយថា៖
«បុរសនោះសួរយ៉ាងលម្អិតពីយើង និងគ្រួសាររបស់យើង។ គាត់សួរថា៖ «តើឪពុករបស់អ្នករាល់គ្នានៅរស់ទេ? តើអ្នករាល់គ្នាមានបងប្អូនផ្សេងទៀតទេ?
ពួកយើងឆ្លើយទៅគាត់តាមសំនួររបស់គាត់។ ធ្វើដូចម្តេចយើងខ្ញុំអាចដឹងបានថាគាត់សួរបែបនឹងថា៖ «ចូរនាំប្អូនប្រុសរបស់អ្នករាល់គ្នាមកផង?»
[8]លោកយូដាឆ្លើយទៅលោកអ៊ីស្រាអែល ឪពុករបស់គាត់ថា៖ «ឲ្យប្អូនប្រុសទៅជាមួយខ្ញុំទៅ។ យើងនឹងក្រោក ហើយចេញទៅ ដើម្បីឲ្យយើងបានរស់ មិនស្លាប់ឡើយ
ទាំងយើងខ្ញុំ ទាំងលោកឪពុក និងទាំងកូនៗរបស់យើងដែរ។[9]ខ្ញុំធានាមើលថែវា។ ខ្ញុំនឹងទទួលខុសត្រូវចំពោះលោកឪពុក។ ប្រសិនបើ ខ្ញុំមិននាំវាត្រឡប់មករកលោកឪពុក
ហើយយកវាមកដាក់នៅចំពោះលោកឪពុកវិញទេ ខ្ញុំនឹងទទួលកំហុសរហូត។[10]ដ្បិត ប្រសិនបើ លោកឪពុកមិនពន្យាពេលទេនោះ
ម្ល េះយើងបានត្រឡប់មកវិញជាលើទីពីរបានទៅហើយ»។
[11]លោកអ៊ីស្រាអែល ឪពុករបស់ពួកគេប្រាប់ពួកគេថា៖ «បើដូច្នោះមែន ចូរធ្វើដូច្នោះទៅ។ ចូរយកផលិតផលពីទឹកដីនេះ ដាក់នៅក្នុងបាវរបស់កូនៗទៅ។
យកវាទៅទុកជាអំណោយដល់បុរសនោះ មានត្នោត និងទឹកឃ្មុំ គ្រឿងម្ហូប ជ័រល្វីងទេស គ្រាប់ធញ្ញជាតិ និងគ្រាប់ចំបក់ខ្លះផង។
[12]ចូរយកប្រាក់មួយទ្វេជាពីរនៅក្នុងដៃរបស់ឯងរាល់គ្នា។ ប្រាក់ដែលបានដាក់ត្រឡប់មកនៅក្នុងបាវរបស់កូនៗនោះ ចូរយកវាទៅជាមួយកូនៗម្តងទៀត។
ប្រហែលជាច្រឡំហើយមើលទៅ។
[13]ចូរយកប្អូនប្រុសរបស់កូនៗទៅជាមួយផង។ ចូរក្រោកឡើង ហើយចេញទៅរកបុរសនោះចុះ។
[14]សូមព្រះជាម្ចាស់ដ៏មានគ្រប់ព្រះចេស្តាប្រទានព្រះគុណដល់កូនៗនៅចំពោះបុរសនោះ ដើម្បីឲ្យគាត់បានដោះលែងប្អូនប្រុសរបស់កូនៗមកកូនវិញ
ព្រមទាំងបេនយ៉ាមីនផង។ ប្រសិនបើ ឪពុកបាត់បង់កូន សូមឲ្យវាបាត់ទៅចុះ»។[15]ពួកគេបានយកអំណោយនេះ ហើយនៅក្នុងដៃរបស់ពួកគេ ពួកគេបានយកប្រាក់ទ្វេដង
ហើយបេនយ៉ាមីនក៏ទៅជាមួយដែរ។
[16]នៅពេលលោកយ៉ូសែបឃើញបេនយ៉ាមីននៅជាមួយពួកគេ គាត់ប្រាប់ទៅអ្នកបម្រើនៅក្នុងផ្ទះរបស់គាត់ថា៖ «ចូរនាំបុរសទាំងនោះមកក្នុងផ្ទះខ្ញុំមក ហើយសម្លាប់សត្វ
ហើយចម្អិនវា សម្រាប់ពួកគេហូបពេលថ្ងៃត្រង់នេះ»។[17]អ្នកបម្រើបានធ្វើតាមលោកយ៉ូសែបបង្គាប់។ គាត់បាននាំពួកគេទៅក្នុងផ្ទះរបស់លោកយ៉ូសែប។
[18]បុរសទាំងនោះមានការភ័យខ្លាចជាខ្លាំង ដោយសារពួកគេបាននាំចូលទៅក្នុងផ្ទះរបស់លោកយ៉ូសែប។ ពួកគេនិយាយថា៖
«ដោយសារប្រាក់ដែលនៅក្នុងបាវលើកទីមួយដែលយើងបាននាំទៅនេះដឹង ហើយប្រហែលជាគាត់រកឱកាសដើម្បីប្រឆាំងជាមួយយើងហើយ។
គាត់ប្រហែលជាចាប់ពួកយើង ហើយយកពួកយើងធ្វើជាឈ្លើយ ហើយយកទាំងលារបស់យើងទៀត»។[19]ពួកគេបាននិយាយទៅអ្នកបម្រើនៅក្នុងផ្ទះរបស់លោកយ៉ូសែប
ហើយពួកគេបាននិយាយទៅគាត់នៅមាត់ទ្វារផ្ទះ[20]ដោយពោលថា៖ «លោកម្ចាស់ យើងចុះមកនេះ លើកទីមួយដើម្បីទិញស្បៀង។
[21]នៅពេលទៅដល់កន្លែងសម្រាក នោះពួកគេហើយបានបើកបាវរបស់ពួកយើង ហើយមើល៍ មានប្រាក់នៅក្នុងបាវរបស់យើងគ្រប់គ្នា ប្រាក់របស់យើងនៅគ្រប់គីឡូ។
យើងបាននាំវាត្រឡប់មកជាមួយយើងដែរ។[22]ហើយប្រាក់ផ្សេងទៀត យើងក៏បានយកមកនៅក្នុងដៃរបស់យើងដែរ ដើម្បីទិញស្បៀង។
យើងមិនដឹងថានរណាបានដាក់ប្រាក់របស់យើងទៅក្នុងបាវរបស់យើងវិញនោះទេ»។[23]អ្នកបម្រើនោះនិយាយថា៖ «សូមសេចក្តីសុខសាន្តនៅជាមួយអ្នកចុះ កុំខ្លាចអ្វី
ឡើយ។ ព្រះជាម្ចាស់របស់អ្នករាល់គ្នា និងជាព្រះជាម្ចាស់នៃឪពុករបស់អ្នករាល់គ្នាទេ ដែលបានដាក់ប្រាក់ក្នុងបាវរបស់អ្នករាល់គ្នាវិញនោះ ឯប្រាក់របស់អ្នករាល់គ្នា គឺខ្ញុំបាន
ទទួលហើយ»។ បន្ទាប់មក អ្នកបម្រើនោះបាននាំលោកស៊ីម្មានចេញមករកពួកគេដែរ។
[24]អ្នកបម្រើបាននាំបុរសទាំងអស់នោះចូលទៅក្នុងផ្ទះរបស់លោកយ៉ូសែប។ គាត់ឲ្យទឹកពួកគេពិសា ហើយលាងជើងរបស់ពួកគេ។ គាត់ឲ្យស្មៅទៅសត្វលារបស់ពួកគេ។
[25]ពួកគេបានរៀបចំអំណោយជូនលោកយ៉ូសែបមកដល់ពេលថ្ងៃត្រង់ ដ្បិត ពួកគេបានឮថា ពួកគេនឹងហូបអាហារនៅទីនោះ។
[26]នៅពេលលោកយ៉ូសែបមកដល់ផ្ទះវិញ ពួកគេបាននាំយកអំណោយដែលនៅក្នុងដៃរបស់ពួកគេចូលមកក្នុងផ្ទះ ហើយលុតជង្គង់ចុះនៅចំពោះមុខគាត់ ឱនមុខទៅដី។
[27]គាត់បានសួរពួកគេពីសុខទុក្ខរបស់ពួកគេ ដោយនិយាយថា៖ «តើឪពុករបស់អ្នករាល់គ្នាសុខសប្បាយជាទេ គាត់សួរទៅបងច្បង? តើគាត់នៅរស់ទេ?»
[28]ពួកគេឆ្លើយថា៖ «បាទលោកម្ចាស់ ឪពុកយើងខ្ញុំសុខសប្បាយជាទេ គាត់ក៏នៅរស់ដែរ»។ ពួកគេឱន ហើយលុតជង្គងចុះ។[29]នៅពេលគាត់ក្រឡេកភ្នែករបស់គាត់ឡើង
គាត់បានឃើញបេនយ៉ាមីន ប្អូនប្រុសរបស់គាត់ កូនរបស់ម្តាយគាត់ ហើយគាត់និយាយថា៖ «តើគាត់នោះគឺជាប្អូនប្រុសពៅដែលអ្នករាល់គ្នាបានប្រាប់ខ្ញុំ?»
បន្ទាប់មកគាត់និយាយថា៖ «សូមព្រះជាម្ចាស់ផ្តល់ព្រះគុណដល់អ្នក កូនប្រុស»។
[30]លោកយ៉ូសែបប្រញាប់ចេញទៅក្រៅបន្ទប់ ដ្បិតគាត់មានចិត្តក្តុកក្តួលជាមួយប្អូនប្រុសរបស់គាត់។ គាត់បានស្វែងរកន្លែងដើម្បីយំ។ គាត់បានទៅបន្ទប់របស់គាត់
ហើយយំនៅទីនោះ។[31]គាត់បានលាងមុខរបស់គាត់ ហើយចេញមកក្រៅវិញ។ គាត់បានគ្រប់គ្រងខ្លួនឯង ដោយនិយាយថា៖ «លើកម្ហូបអាហារមក»។


generated on Wed Mar 12 15:32:40 2025

[32]អ្នកបម្រើរបស់លោកយ៉ូសែបបានលើកម្ហូបជូនលោកយ៉ូសែបដោយផ្ទាល់ ហើយឲ្យបងៗដួសម្ហូបខ្លួនឯង។
ជនជាតិអេស៊ីបនៅទីនោះហូបអាហារជាមួយគាត់ដោយឡែកដោយខ្លួនរបស់ពួកគេ ព្រោះជនជាតិអេស៊ីបមិនហូបនំប៉័ងជាមួយជនជាតិហេព្រើរទេ
ដ្បិតជនជាតិអេស៊ីបខ្ពើមនឹងការនោះ។[33]បងៗអង្គុយទល់មុខគាត់ ពួកគេអង្គុយតាមលេខរៀងពីបងច្បងទៅប្អូនពៅ តាមអាយុរបស់ពួកគេ។ ពួកគេមានការឆ្ងល់ទាំងអស់
គ្នា។[34]លោកយ៉ូសែបបានដាក់ចំណែកអាហារដល់ពួកគេនៅចំពោះពួកគេ។ ប៉ុន្តែ ចំណែករបស់បេនយ៉ាមីន ប្អូនប្រុសរបស់គាត់វិញ ប្រាំដងលើសបងៗរបស់គាត់។ ពួកគេ
ផឹកស្រាយ៉ាងសប្បាយរីករាយជាមួយគាត់។

## ជំពូក ៤៤

[1]លោកយ៉ូសែបបានបង្គាប់អ្នកបម្រើនៅក្នុងផ្ទះរបស់គាត់ ដោយពោលថា៖ «ចូរយកស្បៀងដាក់បាវ ច្រើនតាមដែលអាច ពួកគេអាចយកបាន
ហើយដាក់ប្រាក់នៅក្នុងបាវរបស់បុរសម្នាក់ៗវិញ។[2]ដាក់ពែងរបស់ខ្ញុំ ពែងប្រាក់នៅក្នុងប្អូនពៅ ហើយនិងប្រាក់ថ្លៃទិញស្រូវរបស់គាត់ទៅក្នុងបាវរបស់គាត់វិញ»។
អ្នកបម្រើបានធ្វើដូចដែលលោកយ៉ូសែបបានបង្គាប់។
[3]ពេលព្រឹកព្រលឹម ហើយគេបានឲ្យបុរសទាំងនោះត្រឡប់ទៅវិញ ទាំងពួកគេ និងលារបស់ពួកគេ។[4]នៅពេលពួកគេចេញក្រៅក្រុង ប៉ុន្តែ មិនទាន់ឆ្ងាយប៉ុន្មានទេ
លោកយ៉ូសែបប្រាប់ទៅអ្នកបម្រើរបស់គាត់ថា៖ «ចូរក្រោកឡើង ដេញតាមពួកគេ ហើយនៅពេលតាមពួកគេទាន់ ចូរនិយាយទៅពួកគេថា៖
ហេតុអ្វីបានជាអ្នករាល់គ្នាធ្វើអាក្រក់ស្នងនឹងការល្អដូច្នេះ?[5]តើនេះមិនមែនជាពែងដែលចៅហ្វាយរបស់ខ្ញុំផឹក និងជាពែងដែលគាត់ប្រើសម្រាប់ទស្សន៍ទាយទេឬ?
ការដែលអ្នកធ្វើនេះ អ្នករាល់គ្នាបានធ្វើអាក្រក់ហើយ»។
[6]អ្នកបម្រើបានដេញតាមទាន់ពួកគេ ហើយនិយាយការទាំងនេះជាមួយពួកគេ។[7]ពួកគេនិយាយទៅគាត់វិញថា៖ «ហេតុអ្វីបានជាលោកម្ចាស់មានប្រសាសន៍បែបនេះ?
យើងខ្ញុំមិនបានធ្វើការយ៉ាងដូច្នេះឡើយ។
[8]មើល៍ ប្រាក់ដែលយើងខ្ញុំបានឃើញនៅក្នុងបាវរបស់យើងខ្ញុំ យើងបានយកវាមកពីទឹកដីកាណានមកជូនលោកវិញ។ បើដូច្នេះមែន ធ្វើដូចម្ដេចឲ្យយើងខ្ញុំអាចលួចប្រាក់
និងមាសពីផ្ទះចៅហ្វាយរបស់លោកបានទៅ?[9]ប្រសិនបើ ឃើញនៅក្នុងបាវរបស់នរណា ចូរឲ្យអ្នកនោះស្លាប់ចុះ
ហើយយើងខ្ញុំនឹងធ្វើជាអ្នកបម្រើរបស់ចៅហ្វាយរបស់លោក»។[10]អ្នកបម្រើនោះពោលថា៖ «សូមឲ្យវាកើតឡើងតាមសម្ដីរបស់លោកចុះ។ ប្រសិនបើ
រកឃើញពែងនៅក្នុងបាវរបស់នរណា អ្នកនោះនឹងក្លាយជាអ្នកបម្រើរបស់ខ្ញុំ ហើយអ្នកផ្សេងទៀតនឹងរួចខ្លួន»។
[11]បន្ទាប់មក ពួកគេប្រញាប់ ហើយយកបាវរបស់ពួកគេចុះដល់ដី ហើយពួកគេម្នាក់បានបើកបាវរបស់ពួកគេ។ អ្នកបម្រើបានបានឆែកឆេរ។
[12]គាត់បានចាប់ផ្ដើមឆែកឆេរតាំងពីបងប្រុសច្បងរហូតដល់ប្អូនពៅ ហើយពែងនោះត្រូវបានរកឃើញនៅក្នុងបាវរបស់បេនយ៉ាមីន។[13]ពួកគេបានហែកអាវរបស់ពួកគេ។
ពួកគេម្នាក់ៗបានលើកបាវដាក់លើខ្នងលាវិញ ហើយត្រឡប់ទៅទីក្រុងវិញ។
[14]លោកយូដា និងបងប្អូនរបស់គាត់បានមកឯផ្ទះរបស់លោកយ៉ូសែបវិញ ហើយពួកគេបានលុតជង្គង់នៅចំពោះមុខគាត់ដល់ដី។[15]លោកយ៉ូសែបនិយាយទៅពួកគេថា៖
«ហេតុអ្វីបានជាអ្នករាល់គ្នាធ្វើដូច្នេះ? តើអ្នករាល់គ្នាមិនដឹងទេថា មនុស្សដូចខ្ញុំនេះចេះទស្សន៍ទាយទេឬ?»។
[16]លោកយូដាប្រាប់ថា៖ «តើយើងខ្ញុំអាចឆ្លើយនឹងលោកម្ចាស់បានយ៉ាងដូចម្ដេច? តើយើងអាចនិយាយអ្វីបាន? ឬតើយើងអាចបង្ហាញថាត្រឹមត្រូវបានយ៉ាងដូចម្ដេច?
ព្រះជាម្ចាស់បានរកឃើញកំហុសរបស់យើងខ្ញុំហើយ។ មើល យើងខ្ញុំជាអ្នកបម្រើរបស់លោកម្ចាស់ហើយ ទាំងយើងខ្ញុំ
និងអ្នកដែលត្រូវបានគេរកឃើញពែងនៅនឹងដៃដែរ»។[17]លោកយ៉ូសែបនិយាយថា៖ «ទេ ខ្ញុំមិនធ្វើដូច្នេះទេ។ នរណាដែលត្រូវបានគេរកឃើញពែងនៅនឹងដៃ
អ្នកនោះហើយនឹងក្លាយជាអ្នកបម្រើរបស់ខ្ញុំ ប៉ុន្តែ សម្រាប់លោក និងអ្នកផ្សេងៗទៀត ចូរទៅផ្ទះរបស់ឪពុកអ្នករាល់គ្នាឲ្យបានសុខចុះ»។
[18]បន្ទាប់មក លោកយូដាបានមកជិតគាត់ ហើយប្រាប់ថា៖ «លោកម្ចាស់ សូមលោកម្ចាស់ស្ដាប់ពាក្យខ្ញុំដែលជាអ្នកបម្រើរបស់លោកសិន
ហើយសូមលោកម្ចាស់ខឹងនឹងអ្នកបម្រើរបស់លោកចុះ ដ្បិត លោកប្រៀបដូចជាស្ដេចផារោនទៅហើយ។[19]លោកម្ចាស់បានសួរយើងខ្ញុំជាអ្នកបម្រើថា៖ «អ្នករាល់គ្នាមាន
ឪពុក មានប្អូនឬទេ?»
[20]យើងខ្ញុំជម្រាបលោកម្ចាស់ហើយថា៖ «យើងមានឪពុកម្នាក់ គាត់ចាស់ហើយ ហើយគាត់មានកូនមួយក្នុងការដែលគាត់មានអាយុច្រើនហើយ មានកូនតូចមួយ។ ប៉ុន្តែ
បងប្រុសរបស់គាត់បានស្លាប់ហើយ ហើយមានគាត់តែម្នាក់ទេដែលម្ដាយរបស់គាត់បានសន្សល់ទុកឲ្យគាត់ ហើយឪពុករបស់គាត់ស្រឡាញ់គាត់ណាស់។
[21]ពេលលោកម្ចាស់មានប្រសាសន៍មកយើងខ្ញុំជាអ្នកបម្រើរបស់លោកម្ចាស់ ឲ្យនាំគាត់ចុះមកជាមួយខ្ញុំ ដើម្បីឲ្យលោកម្ចាស់បានឃើញគាត់»។[22]បន្ទាប់មកទៀត
យើងបានជម្រាបលោកម្ចាស់ហើយថា៖ «ក្មេងប្រុសនេះមិនអាចចាកចេញពីឪពុករបស់គាត់បានឡើយ។ ដ្បិត ប្រសិនបើ គាត់ចេញពីឪពុករបស់
នោះឪពុករបស់គាត់នឹងស្លាប់»។
[23]បន្ទាប់មក លោកម្ចាស់មានប្រសាសន៍មកកាន់យើងខ្ញុំថា៖ «លុះត្រាតែប្អូនប្រុសពៅរបស់យើងខ្ញុំចុះមករកលោកម្ចាស់ បានលោកម្ចាស់ព្រមជួបមុខយើងខ្ញុំម្ដងទៀត»។
[24]បន្ទាប់មក យើងខ្ញុំបានត្រឡប់ទៅរកឪពុករបស់យើងខ្ញុំវិញ យើងខ្ញុំបានប្រាប់គាត់តាមពាក្យរបស់លោកម្ចាស់។[25]ឪពុករបស់យើងខ្ញុំប្រាប់ថា៖
«ចូរកូនៗទៅទិញស្បៀងឲ្យយើងម្ដងទៀតចុះ»។[26]នៅពេលយើងប្រាប់គាត់ថា៖ «យើងមិនអាចទៅបានទេ។ ប្រសិនបើ ប្អូនប្រុសពៅទៅជាមួយយើង ទើបយើងចុះទៅ
ដើម្បីយើងនឹងមិនអាចឃើញមុខលោកម្ចាស់បានទេ លុះត្រាតែប្អូនប្រុសពៅទៅជាមួយយើង»។
[27]ឪពុករបស់យើងខ្ញុំប្រាប់មកយើងខ្ញុំថា៖ «កូនដឹងទេថា ភរិយារបស់ឪពុកបង្កើតកូនប្រុសពីរនេះឲ្យឪពុក។[28]ម្នាក់ក្នុងចំណោមពួកគេបានចាកចាញពីឪពុក
ហើយឪពុកប្រាប់ថា៖ «ប្រាកដណាស់ គាត់ត្រូវសត្វហែកស៊ីអស់ហើយ ហើយឪពុកក៏លែងឃើញគាត់ទៀតដែរ»។[29]ឥឡូវ ប្រសិនបើ
កូនយកកូនប្រុសម្នាក់ទៀតចេញពីឪពុក ហើយកូនរបស់ឪពុកមានគ្រោះថ្នាក់អ្វីនោះ កូននឹងនាំឪពុកដែលចាស់សក់ស្កូវម្នាក់នេះកើតទុក្ខនៅក្នុងស្ថានឃុំព្រលឹងហើយ»។
[30]ដូច្នេះ នៅពេលយើងខ្ញុំទៅជួបឪពុករបស់យើងខ្ញុំ ដែលជាអ្នកបម្រើលោកម្ចាស់ ក្មេងប្រុសនេះមិននៅជាមួយយើងខ្ញុំទេ
ក្មេងនេះជាទីស្រឡាញ់នៅក្នុងជីវិតរបស់គាត់ណាស់ ហើយនៅពេលគាត់ដឹងថា ក្មេងនេះមិននៅជាមួយយើងខ្ញុំ គាត់មុខជាស្លាប់មិនខាន។
[31]យើងខ្ញុំជាអ្នកបម្រើលោកម្ចាស់នឹងធ្វើឲ្យឪពុកដែលចាស់សក់ស្កូវ កើតទុក្ខនៅក្នុងស្ថានឃុំព្រលឹងមិនខាន។[32]ដ្បិត
យើងខ្ញុំដែលជាអ្នកបម្រើលោកម្ចាស់បានធានាការពារកូនប្រុសនេះ ចំពោះឪពុករបស់យើងខ្ញុំហើយ ដោយនិយាយថា៖ «ប្រសិនបើ
កូនមិននាំក្មេងនេះមកជូនលោកឪពុកវិញទេ កូននឹងមានកំហុសចំពោះលោកឪពុករហូត»។
[33]ដូច្នេះ សូមលោកម្ចាស់ មេត្តាដល់យើងខ្ញុំជាអ្នកបម្រើលោកម្ចាស់ ជំនួសឲ្យ ក្មេងប្រុសនេះធ្វើជាអ្នកបម្រើលោកម្ចាស់ សូមអនុញ្ញាតឲ្យក្មេងប្រុសនេះ
បានឡើងទៅជាមួយបងប្អូនរបស់គាត់ទៅ។[34]តើឲ្យខ្ញុំអាចឡើងទៅរកឪពុករបស់ខ្ញុំបានយ៉ាងដូចម្ដេច ប្រសិនបើ ក្មេងប្រុសនេះមិននៅជាមួយខ្ញុំទេនោះ? ខ្ញុំខ្លាច
មានរឿងអាក្រក់ដែលអាចនឹងកើតឡើងចំពោះឪពុករបស់ខ្ញុំ»។

## ជំពូក ៤៥

[1]បន្ទាប់មក លោកយ៉ូសែបមិនអាចគ្រប់គ្រងខ្លួនឯងបានទៀតនៅចំពោះអ្នកបម្រើទាំងអស់ដែលឈរនៅក្បែរគាត់។ គាត់និយាយខ្លាំងៗថា៖ «ទាំងអស់គ្នា
ចូរចេញពីយើងភ្លាម»។ ដូច្នេះ គ្មានអ្នកបម្រើណានៅក្បែរគាត់ទៀតទេ នៅពេលលោកយ៉ូសែបបង្ហាញខ្លួនគាត់ឲ្យបងប្អូនរបស់គាត់បានស្គាល់។[2]គាត់យំខ្លាំងៗ

 generated on Wed Mar 12 15:32:40 2025

ជនជាតិអេស៊ីបបានឮ ហើយនៅក្នុងដំណាក់របស់ស្ដេចផារោនក៏ឮដែរ។3លោកយ៉ូសែបប្រាប់បងប្អូនរបស់គាត់ថា៖ «ខ្ញុំគឺយ៉ូសែប។ តើឪពុករបស់ខ្ញុំនៅរស់ទេ?»
បងៗរបស់គាត់មិនអាចឆ្លើយបានទេ ព្រោះពួកគេរន្ធត់ជាខ្លាំងនៅចំពោះគាត់។
4បន្ទាប់មក លោកយ៉ូសែបនិយាយទៅបងៗរបស់គាត់ថា៖ «សូមមកជិតខ្ញុំមក៍»។ ពួកគេបានចូលទៅជិត។ គាត់ប្រាប់ថា៖ «ខ្ញុំគឺយ៉ូសែប ជាប្អូនប្រុស
ដែលបងៗលក់ទៅឲ្យអេស៊ីប។5កុំព្រួយបារម្ភ ឬខឹងនឹងខ្លួនឯង ដែលបងៗបានលក់ខ្ញុំមកទីនេះឡើយ ដ្បិត ព្រះជាម្ចាស់បានចាត់ខ្ញុំមកមុនបងៗ ដើម្បីការពារជីវិត។6ដ្បិត
គ្រោះអត់ឃ្លានកើតឡើងនៅក្នុងទឹកដីពីរឆ្នាំហើយ និងនៅប្រាំឆ្នាំទៀតដែលនឹងមិនមានការភ្ជួររាស់ ឬច្រូតកាត់ឡើយ។
7ព្រះជាម្ចាស់បានចាត់ខ្ញុំមកមុនបងៗ ដើម្បីការពារជីវិតរបស់បងៗ ដែលនៅសល់នៅលើផែនដីនេះ ហើយការពារអាយុជីវិត ដោយការប្រោសលោះដ៏អស្ចារ្យ។8ដូច្នេះ
នៅពេលនេះ មិនមែនជាបងៗទេ ដែលចាត់ខ្ញុំមកទីនេះ ប៉ុន្តែ គឺជាព្រះជាម្ចាស់ ហើយព្រះអង្គបានធ្វើឲ្យខ្ញុំ ដូចជាឪពុកនៅចំពោះស្ដេចផារោន
ជាម្ចាស់នៅលើដំណាក់របស់ស្ដេចទាំងមូល និងជាអ្នកគ្រប់គ្រងនៅលើទឹកដីអេស៊ីបទាំងមូលដែរ។
9ចូរឡើងទៅរកឪពុករបស់ខ្ញុំជាប្រញាប់ ហើយប្រាប់គាត់ថា៖ «នេះគឺជាអ្វីដែលយ៉ូសែប កូនប្រុសរបស់លោកឪពុក បានផ្ដាំ
«ព្រះជាម្ចាស់បានធ្វើឲ្យខ្ញុំបានក្លាយជាម្ចាស់លើទឹកដីអេស៊ីបទាំងមូល។ សូមចុះមករកខ្ញុំជាប្រញាប់ កុំបង្អង់ឡើយ។10លោកឪពុកនឹងរស់នៅក្នុងទឹកដីកូសែន
ហើយលោកឪពុកនឹងបាននៅជិតកូន គឺលោកឪពុក និងកូនៗរបស់លោកឪពុក ព្រមទាំងចៅៗរបស់លោកឪពុក និងហ្វូងចៀម ហ្វូងគោ
និងអ្វីៗទាំងអស់ដែលលោកឪពុកមាន។11ខ្ញុំនឹងផ្គត់ផ្គង់លោកឪពុកឲ្យនៅទីនោះ ដ្បិត គ្រោះអត់ឃ្លានមានរយៈពេលប្រាំឆ្នាំទៀត ដូច្នេះ លោកឪពុកនឹងមិនខ្វះខាតអ្វីឡើយ
គឺលោកឪពុក និងគ្រួសារ ព្រមទាំងអ្វីៗដែលលោកឪពុកមាន»។
12មើល៍ លោកឪពុកនឹងឃើញដោយភ្នែក ហើយលោកឪពុកនឹងឃើញបេនយ៉ាមីនផ្ទាល់ភ្នែកដែរ នោះគឺជាសម្ដីដែលកូននិយាយទៅគាត់លោកឪពុក។
13បងៗត្រូវប្រាប់ឪពុករបស់ខ្ញុំអំពីកេរ្តិ៍ឈ្មោះរបស់ខ្ញុំទាំងអស់នៅអេស៊ីប និងអ្វីៗទាំងអស់ដែលបងៗបានឃើញ។ ចូរបងៗប្រញាប់ទៅ
ហើយនាំឪពុករបស់ខ្ញុំចុះមកទីនេះចុះ»។
14គាត់បានឱបកបេនយ៉ាមីន ប្អូនប្រុសរបស់គាត់ ហើយយំ ហើយបេនយ៉ាមីនបានឱបកគាត់យំដែរ។15គាត់បានថើបបងៗរបស់គាត់ទាំងអស់ ហើយយំជាមួយគ្នា។
បន្ទាប់មក បងប្រុសរបស់គាត់បាននិយាយជាមួយគាត់។
16ដំណឹងពីរឿងនេះ បានឮដល់ដំណាក់របស់ស្ដេចផារោនថា «បងៗរបស់លោកយ៉ូសែបបានមក»។ ស្ដេចផារោនក៏គាត់ព្រះហឫទ័យ
ហើយពួកមន្ត្រីរបស់ព្រះអង្គក៏ពេញចិត្តជាខ្លាំងដែរ។17ស្ដេចផារោនមានរាជឱង្ការទៅកាន់លោកយ៉ូសែបថា៖ «ចូរប្រាប់ទៅបងៗរបស់អ្នកទៅ៖ «ចូរធ្វើការនេះ ដឹកនាំសត្វ
ហើយនាំយកទៅទឹកដីកាណាចុះ។18យកទៅជូនឪពុក និងក្រុមគ្រួសាររបស់អ្នក ហើយចាំត្រឡប់មកវិញ។ យើងនឹងឲ្យដីល្អៗនៅអេស៊ីបដល់អ្នក
ហើយអ្នកនឹងរស់នៅក្នុងទឹកដីល្អនៅក្នុងទឹកដីនេះ»។
19អ្នកត្រូវបង្គាប់គេ ដូច្នេះចូរធ្វើតាមចុះ គឺយករទេះចេញពីទឹកដីអេស៊ីបទៅរកកូនចៅ ហើយនឹងភរិយារបស់អ្នករាល់គ្នា។ ទៅយកឪពុករបស់អ្នករាល់ហើយត្រឡប់មកវិញ។
20សូមកុំបារម្ភពីទ្រព្យសម្បត្តិ ដើម្បីដីល្អៗទាំងអស់នៅក្នុងទឹកដីអេស៊ីបជារបស់អ្នក»។
21កូនប្រុសៗរបស់លោកអ៊ីស្រាអែលក៏ធ្វើដូច្នេះ។ លោកយ៉ូសែបបានប្រគល់រទេះដល់ពួកគេ តាមសេចក្ដីបង្គាប់របស់ស្ដេចផារោន
ហើយឲ្យស្បៀងអាហារសម្រាប់ពួកគេធ្វើដំណើរផងដែរ។22គាត់បានប្រគល់សម្លៀកបំពាក់ដល់ពួកគេម្នាក់ៗប្ដូរ ប៉ុន្តែ ចំពោះបេនយ៉ាមីន គាត់បានឲ្យប្រាក់បីរយដុំ
ហើយសម្លៀកបំពាក់ប្រាំបន្លាស់។23ចំពោះឪពុករបស់គាត់វិញ គាត់ផ្ញើរបស់ទាំងនេះ៖ គឺលាឈ្មោលដប់ ផ្ទុករបស់ល្អៗពីអេស៊ីប និងលាញីដប់ផ្ទុកស្រូវ នំប៉័ង
និងស្បៀងអាហារសម្រាប់ឪពុករបស់គាត់ធ្វើដំណើរ។
24ដូច្នេះ គាត់បានចាត់បងៗរបស់គាត់ឲ្យទៅ ហើយពួកគេក៏ចេញទៅ។ គាត់ប្រាប់ពួកគេថា៖ «បងៗ សូមកុំឈ្លោះគ្នានៅតាមផ្លូវឲ្យសោះ»។25ពួកគេបានចេញពីអេស៊ីប
ហើយត្រឡប់ទៅទឹកដីកាណាន ទៅរកលោកយ៉ាកុប ជាឪពុករបស់ពួកគេវិញ។26ពួកគេប្រាប់គាត់វិញ ថា៖ «យ៉ូសែបនៅរស់ទេ
ហើយគាត់ជាអ្នកគ្រប់គ្រងនៅលើទឹកដីអេស៊ីបទាំងមូល»។ គាត់រន្ធត់ចិត្តជាខ្លាំង ព្រោះគាត់មិនជឿអ្វីដែលពួកគេប្រាប់គាត់ទេ។
27ពួកគេប្រាប់គាត់តាមពាក្យរបស់លោកយ៉ូសែបទាំងអស់ដែលលោកយ៉ូសែបបានប្រាប់ដល់ពួកគេ។ នៅពេលលោកយ៉ាកុបឃើញរទេះដែលលោកយ៉ូសែបបានផ្ញើមក
ដើម្បីដឹកគាត់ វិញ្ញាណរបស់លោកយ៉ាកុបឪពុករបស់ពួកគេបានភ្ញាក់ឡើងវិញ។28លោកអ៊ីស្រាអែលប្រាប់ថា៖ «គ្រប់គ្រាន់ហើយ។ យ៉ូសែបកូនប្រុសរបស់ខ្ញុំនៅរស់ទេ។
ឪពុកនឹងទៅ ដើម្បីជួបវាមុនពេលឪពុកស្លាប់។

## ជំពូក ៤៦

1លោកអ៊ីស្រាអែលបានធ្វើដំណើរជាមួយអ្វីៗទាំងអស់ដែលគាត់មាន ហើយទៅឯបៀរសេបា។ នៅទីនោះ គាត់បានថ្វាយយញ្ញបូជាដល់ព្រះជាម្ចាស់
ជាព្រះជាម្ចាស់របស់លោកអ៊ីសាក ឪពុករបស់គាត់។2ព្រះជាម្ចាស់មានបន្ទូលនឹងលោកអ៊ីស្រាអែលនៅក្នុងនិមិត្តនៅពេលយប់ថា៖ «យ៉ាកុប យ៉ាកុប»។ គាត់ទូលតបថា៖
«ទូលបង្គំនៅទីនេះ»។3ព្រះអង្គមានបន្ទូលថា៖ «យើងគឺជាព្រះជាម្ចាស់ ជាព្រះជាម្ចាស់របស់ឪពុករបស់អ្នក។ កុំភ័យខ្លាច នឹងចុះទៅក្នុងទឹកដីអេស៊ីបឡើយ ដ្បិត
យើងនឹងធ្វើឲ្យអ្នកក្លាយជាប្រជាជាតិដ៏ធំនៅទីនោះ។4យើងនឹងចុះទៅអេស៊ីបជាមួយអ្នក ហើយយើងនឹងនាំអ្នកត្រឡប់មកវិញ
ហើយលោកយ៉ូសែបនឹងបានបិទភ្នែករបស់អ្នកនៅដៃរបស់គាត់ផ្ទាល់»។
5លោកយ៉ាកុបក៏ក្រោកឡើងចេញពីបៀរសេបា។ កូនប្រុសៗរបស់អ៊ីស្រាអែលបានដឹកជញ្ជូនលោកយ៉ាកុប ឪពុករបស់ពួកគេ កូនចៅរបស់ពួកគេ
ព្រមទាំងភរិយារបស់ពួកគេ នៅក្នុងរទេះដែលស្ដេចផារោនបានផ្ញើមកឲ្យដឹកគាត់។6ពួកគេបានយកហ្វូងសត្វ និងទ្រព្យសម្បត្តិរបស់ពួកគេ
ដែលពួកគេបានរកបាននៅក្នុងទឹកដីកាណាន។ ពួកគេបានចូលទៅដល់អេស៊ីប លោកយ៉ាកុប និងកូនចៅទាំងអស់របស់គាត់ទៅជាមួយគាត់ដែរ។
7គាត់បាននាំកូនៗរបស់គាត់ និងចៅៗរបស់គាត់ កូនស្រីៗ និងចៅស្រីៗ ព្រមទាំងពូជពង្សទាំងអស់របស់គាត់ទៅអេស៊ីបជាមួយគាត់។
8អ្នកទាំងនេះ គឺជាឈ្មោះកូនចៅរបស់លោកអ៊ីស្រាអែល ដែលចុះមកអេស៊ីប លោកយ៉ាកុប និងកូនប្រុសៗរបស់គាត់៖ លោករូបេនលោកយ៉ាកុប ជាកូនច្បងរបស់លោក
យ៉ាកុប។9កូនប្រុសៗរបស់លោករូបេនមាន ហេណុក ប៉ាលូវ ហេស្រុន និងកើមី។10កូនប្រុសៗរបស់លោកស៊ីម្មានមាន យេមូអែល យ៉ាមីន អូហាត់ យ៉ាគីន សូហារ និងសូល
ជាកូនរបស់ស្ត្រីជនជាតិកាណាន។11កូនប្រុសៗរបស់លោកលេវីមាន គើរសុន កេហាត់ និងម្រ៉ារី។
12កូនប្រុសៗរបស់លោកយូដាមាន អ៊ើរ អូណាន់ សេឡា ពេរេស និងសេរ៉ាស (ប៉ុន្តែ អ៊ើរ និងអូណាន់ បានស្លាប់នៅទឹកដីកាណាន)។ កូនប្រុសៗរបស់ពេរេសមាន ហេស្រុន
និងហាមុល។13កូនប្រុសៗរបស់លោកអ៊ីសាខារមាន ថូឡា ពូវ៉ា យ៉ូប និងស៊ីមរ៉ូន។14កូនប្រុសៗរបស់លោកសាប់យូឡូនមាន សេរែក អេឡូន និងយ៉ាលាល។15អ្នកទាំងនោះ
ជាកូនប្រុសៗ ដែលនាងលេអាបានបង្កើតឲ្យលោកយ៉ាកុប នៅទឹកដីប៉ាដាន់ អើរ៉ាម។ រួមជាមួយកូនស្រីរបស់គាត់គឺនាងឌីណា។ កូនប្រុសៗរបស់គាត់ និងកូនៗស្រីរបស់
នាងលេអាមានទាំងអស់សាមសិបបីនាក់។
16កូនប្រុសៗរបស់លោកកាដមាន សេផុន ហាក់គី ស៊ូនី អេសបូន អេរី អើរ៉ូត និងអើរេលី។17កូនប្រុសៗរបស់លោកអេស៊ើរមាន យីមណា យីសវ៉ា យីសវី និងបេរា
ហើយនាងសេរ៉ាគឺជាប្អូនស្រីរបស់ពួកគេ។ កូនប្រុសៗរបស់បេរាមាន ហេប៊ើរ និងម៉ាលគាល។18អ្នកទាំងនេះគឺជាកូនប្រុសៗរបស់នាងស៊ីលផា ដែលលោកឡាបាន់បានឲ្យ
នាងលេអា កូនស្រីរបស់គាត់។ កូនប្រុសៗទាំងនេះ នាងបានបង្កើតជូនលោកយ៉ាកុប មានចំនួនទាំងអស់ដប់ប្រាំមួយនាក់។
19កូនប្រុសៗរបស់នាងរ៉ាជែល ជាភរិយាលោកយ៉ាកុប មានយ៉ូសែប និងបេនយ៉ាមីន។20នៅទឹកដីអេស៊ីប លោកយ៉ូសែបមានកូនប្រុសពីរនាក់ គឺ ម៉ាណាសេ និងអេប្រាអ៊ីម
ជាកូនដែលនាងអាសណាត់ កូនស្រីលោកប៉ូទីផេរ៉ា បូជាចារ្យនៅក្រុងអូន បានបង្កើតជូនគាត់។21កូនប្រុសៗរបស់លោកបេនយ៉ាមីនមាន បេឡា បេគើរ អ័សបេល គេរ៉ា


generated on Wed Mar 12 15:32:40 2025

ណាម៉ាន អេហ៊ី រ៉ូស មូភីម ហ៊ូភីម និងអើឌ។ លោកទាំងនោះជាកូនដែលនាងរ៉ាជែលបានបង្កើតជូនលោកយ៉ាកុប។
22អ្នកទាំងនេះគឺជាកូនប្រុសៗដែលនាងរ៉ាជែលបានបង្កើតជូនលោកយ៉ាកុប មានចំនួនទាំងអស់ដប់បួននាក់។
23កូនប្រុសៗរបស់លោកដាន់មាន ហ៊ូស៊ីម។24កូនប្រុសៗរបស់លោកណែបថាលីមាន យ៉ាស៊ាល គូនី យេស៊ើរ និងស៊ីលិម។25អ្នកទាំងនេះជាកូន
ដែលបានបង្កើតជូនលោកយ៉ាកុបតាមរយៈនាងប៊ីលហា ដែលលោកឡាបាន់បានឲ្យនាងរ៉ាជែល កូនស្រីរបស់គាត់ មានចំនួនទាំងអស់ប្រាំពីរនាក់។
26អស់អ្នកដែលបានចុះទៅអេស៊ីបជាមួយលោកយ៉ាកុប ដែលជាពូជពង្សរបស់គាត់ មានគ្នាទាំងអស់ហុកសិបប្រាំមួយនាក់ មិនបានរាប់បញ្ចូលកូនប្រសាស្រី
ៗរបស់លោកយ៉ាកុបទេ។27រួមជាមួយកូនទាំងពីររបស់លោកយ៉ូសែប ដែលកើតឲ្យគាត់នៅស្រុកអេស៊ីបផង ចំនួននៃក្រុមគ្រួសាររបស់គាត់ ដែលមករស់នៅក្នុងទឹកដីអេស៊ីប
មានទាំងអស់ចិតសិបនាក់។
28លោកយ៉ាកុបបានចាត់លោកយូដា ឲ្យទៅជួបលោកយ៉ូសែបមុនគាត់ នៅតំបន់កូសែន ហើយ ពួកគេបានមកដល់តំបន់កូសែន។29លោកយ៉ូសែបបានរៀបចំរទេះរបស់គាត់
ហើយបានឡើងទៅជួបលោកអ៊ីស្រាអែលជាឪពុកនៅក្នុងតំបន់កូសែន។ គាត់បានឃើញឪពុក គាត់ឱបកឪពុករបស់គាត់ ហើយយំយ៉ាងយូរ។30លោកអ៊ីស្រាអែលមាន
ប្រសាសន៍ទៅកាន់លោកយ៉ូសែបថា៖ «ឥឡូវនេះ សូមឲ្យឪពុកស្លាប់ចុះ ព្រោះឪពុកបានឃើញមុខកូន ហើយដឹងថាកូននៅមានជីវិតនៅឡើយ»។
31លោកយ៉ូសែបបាននិយាយទៅបងៗ និងក្រុមគ្រួសារឪពុករបស់គាត់ថា៖ «ខ្ញុំនឹងឡើងទៅ ហើយទូលស្តេចផារ៉ោនថា៖ «បងៗ និងក្រុមគ្រួសាររបស់ឪពុកទូលបង្គំ នៅ
ស្រុកកាណានបានមកជួបជុំនឹងទូលបង្គំហើយ។32ពួកគេទាំងអស់គ្នាសុទ្ធតែជាអ្នកគង្វាលចៀម ដ្បិត ពួកគេគឺជាអ្នកចិញ្ចឹមសត្វ។ ពួកគេបាននាំហ្វូងចៀម ហ្វូងគោ និងអ្វីៗ
ទាំងអស់ដែលគេមានមកជាមួយដែរ»។
33នៅពេលព្រះបាទផារ៉ោនកោះហៅបងៗទៅសួរថា៖ «តើអ្នករាល់គ្នាមានមុខរបរអ្វី»34នោះបងៗត្រូវទូលស្តេចថា៖ «យើងខ្ញុំជាអ្នកបម្រើស្តេច ជាអ្នកចិញ្ចឹមសត្វ តាំងពីក្មេង
រហូតមកទល់សព្វថ្ងៃនេះ ចាប់តាំងពីដូនតារបស់យើងខ្ញុំ រហូតមកដល់យើងខ្ញុំដែរ»។ បើទូលដូច្នេះ បងៗនឹងអាចរស់នៅក្នុងតំបន់កូសែន ដ្បិត ជនជាតិអេស៊ីបស្អប់ខ្ពើម
ពួកគង្វាលណាស់»។

## ជំពូក ៤៧

1បន្ទាប់មក លោកយ៉ូសែបបានចូលទៅក្នុងគាល់ស្តេចផារោនថា៖ «ឪពុក និងបងប្អូនរបស់ទូលបង្គំ ហ្វូងចៀម និងហ្វូងសត្វរបស់ពួកគេ ព្រមទាំងអ្វីៗដែលជារបស់ពួកគេ
ដែលមកពីទឹកដីកាណានបានមកដល់ហើយ។2មើល៍ ពួកគេនៅក្នុងទឹកដីកូសែន»។ គាត់បានយកបងប្រុសៗប្រាំនាក់ ហើយបានណែនាំពួកគេដល់ស្តេចផារោន។
3ស្តេចផារោនមានរាជឱង្ការទៅបងៗរបស់គាត់ថា៖ «តើអ្នករាល់គ្នាមានមុខរបរអ្វី»។ ពួកគេទូលឆ្លើយថា៖ «យើងខ្ញុំគឺជាអ្នកគង្វាលចៀម ដូចដូនតាយើងខ្ញុំដែរ»។
4បន្ទាប់មក ពួកគេទូលទៅស្តេចផារោនថា៖ «យើងខ្ញុំមកទឹកដីនេះ ជ្រកកោនបណ្ដោះអាសន្នទេ។ គ្មានវាលស្មៅសម្រាប់ហ្វូងសត្វយើងខ្ញុំ ដោយសារគ្រោះទុរ្ភិក្ស
ខ្លាំងពេកនៅក្នុងទឹកដីកាណាន។ ដូច្នេះហើយ សូមព្រះអង្គមេត្តាឲ្យយើងខ្ញុំរស់នៅក្នុងទឹកដីកូសែននេះផង»។
5បន្ទាប់មក ស្តេចផារោនមានរាជឱង្ការទៅកាន់លោកយ៉ូសែបថា៖ «ឪពុក និងបងប្អូនរបស់អ្នកបានមករកអ្នកហើយ។6ទឹកដីអេស៊ីបនៅចំពោះអ្នកស្រាប់។
ចូរតាំងទីលំនៅឲ្យឪពុក និងបងប្អូនរបស់អ្នកនៅក្នុងតំបន់ដ៏ល្អបំផុត នៅក្នុងទឹកដីកូសែនចុះ។ ប្រសិនបើ អ្នកណាក្នុងចំណោមពួកគេមានសមត្ថភាព
ដាក់ឲ្យពួកគេមើលថែហ្វូងសត្វរបស់យើងចុះ»។
7បន្ទាប់មក លោកយ៉ូសែបបាននាំលោកយា៉កុប ឪពុករបស់គាត់ ហើយនាំគាត់ចូលគាល់ស្តេចផារោន។ លោកយ៉ាកុបឲ្យពរដល់ស្តេចផារោន។
8ស្តេចផារោនមានរាជឱង្ការទៅលោកយ៉ាកុបថា៖ «តើលោកមានអាយុប៉ុន្មានឆ្នាំហើយ?»9លោកយ៉ាកុបទូលទៅស្តេចផារោនថា៖
«ទូលបង្គំមានអាយុមួយរយសាមសិបឆ្នាំហើយ។ ទូលបង្គំមានអាយុតិចណាស់ ហើយជីវិតរបស់ទូលបង្គំមានទុកលំបាកជាច្រើន។
អាយុរបស់ទូលបង្គំមិនបានវែងដូចជាដូនតារបស់ទូលបង្គំទេ»។10បន្ទាប់មក លោកយ៉ាកុបឲ្យពរដល់ស្តេចផារោនម្តងទៀត ហើយចាកចេញពីស្តេចទៅ។
11បន្ទាប់មក លោកយ៉ូសែបបានប្រគល់ដីដែលល្អជាងគេបំផុតនៅក្នុងទឹកដីអេស៊ីប ដល់ឪពុក និងបងប្អូនរបស់គាត់តាំងទីលំនៅគឺនៅក្នុងតំបន់រ៉ាមសេស
ដូចដែលស្តេចផារោនបានបង្គាប់។12លោកយ៉ូសែបបានផ្តល់ស្បៀងដល់ឪពុក និងបងប្អូនរបស់គាត់ ព្រមទាំងក្រុមគ្រួសារទាំងអស់របស់គាត់
ទៅតាមចំនួននៃកូនចៅនៅក្នុងបន្ទុករបស់ពួកគេ។
13ឥឡូវនេះ ដល់ពេលដែលលែងមានស្បៀងនៅសល់ក្នុងទឹកដីអេស៊ីបទៀតហើយ ដ្បិតគ្រោះទុរ្ភិក្សខ្លាំងពេក។ ទឹកដីអេស៊ីប និងទឹកដីកាណានត្រូវហិនហោចទាំងអស់
ដោយសារគ្រោះទុរ្ភិក្ស។14លោកយ៉ូសែបបានប្រមូលប្រាក់ដែលមាននៅក្នុងទឹកដីអេស៊ីប និងទឹកដីកាណាន ដោយការលក់ស្រូវឲ្យប្រជាជន។ បន្ទាប់មក
លោកយ៉ូសែបបានយកប្រាក់នោះទៅដាក់នៅក្នុងរាំងរបស់ស្តេចផារ៉ោន។
15ពេលទឹកដីអេស៊ីប និងទឹកដីកាណានលែងមានប្រាក់ទៀត ជនជាតិអេស៊ីបទាំងអស់បានចូលមកឯលោកយ៉ូសែប ពោលថា៖ «សូមឲ្យស្បៀងយើងផង!
ហេតុអ្វីបានជាយើងត្រូវស្លាប់ចំពោះមុខលោក ដោយព្រោះលែងមានប្រាក់ដូច្នេះ?»16លោកយ៉ូសែបឆ្លើយថា៖ «ប្រសិនបើ អ្នករាល់គ្នាលែងមានប្រាក់ទៀត
ចូរយកហ្វូងសត្វរបស់អ្នករាល់គ្នាមកឲ្យខ្ញុំ ហើយខ្ញុំនឹងប្តូរជាស្បៀងឲ្យអ្នករាល់គ្នាវិញជាមួយនឹងហ្វូងសត្វនោះ»។17ដូច្នេះ
ពួកគេក៏នាំយកហ្វូងសត្វរបស់ពួកគេមកជូនលោកយ៉ូសែប។ លោកយ៉ូសែបក៏ប្តូរស្បៀងជាមួយនឹងសត្វសេះ ហ្វូងគោ ហ្វូងចៀម និងលាផង។
លោកបានចម្អែតពួកគេជាមួយនឹងនំប៉័ង ដូចជាហ្វូងសត្វរបស់ពួកគេនៅក្នុងឆ្នាំនោះ។
18នៅពេលផុតឆ្នាំនោះ ពួកគេបានមករកលោកនូវឆ្នាំបន្ទាប់ទៀត ហើយនិយាយលោកថា៖ «យើងមិនលាក់បាំងអ្វីជាមួយនឹងលោកម្ចាស់ទេ ប្រាក់របស់យើងអស់មែន
ហើយហ្វូងសត្វទាំងអស់ជារបស់លោកម្ចាស់ហើយ។ គ្មានសល់អ្វីនៅចំពោះមុខលោកម្ចាស់ទេ លើកលែងតែខ្លួនប្រាណ និងដីរបស់យើងខ្ញុំទេ។
19ហេតុអ្វីបានជាលោកម្ចាស់ទុកឲ្យយើងខ្ញុំស្លាប់ ទាំងខ្លួនប្រាណ និងដីរបស់យើងខ្ញុំនៅចំពោះមុខលោកម្ចាស់ឬ? សូមទិញដីរបស់យើងខ្ញុំ ប្តូរជាមួយស្បៀង ហើយយើងខ្ញុំ
និងដីរបស់យើងខ្ញុំ នឹងក្លាយជាអ្នកបម្រើរបស់ស្តេចផារ៉ោន។ ចូរផ្តល់គ្រាប់ពូជ ដើម្បីឲ្យយើងខ្ញុំអាចរស់ កុំឲ្យស្លាប់ និងដើម្បីកុំឲ្យដីរបស់យើងខ្ញុំត្រូវបោះបង់ចោលឡើយ»។
20ដូច្នេះ លោកយ៉ូសែបបានទិញដីទាំងអស់នៅក្នុងទឹកដីអេស៊ីបថ្វាយស្តេចផារ៉ោន។ ជនជាតិអេស៊ីបទាំងអស់លក់ដីរបស់ពួកគេ ដោយសារកើតគ្រោះទុរ្ភិក្សយ៉ាងខ្លាំង។
ដូច្នេះ ទឹកដីទាំងអស់បានក្លាយជារបស់ស្តេចផារ៉ោន។21ចំណែកប្រជាជន គាត់បានធ្វើឲ្យពួកគេទៅជាបាវបម្រើ តាំងពីចុងម្ខាង ទៅចុងម្ខាងរបស់អេស៊ីប។
22មានតែដីពួកបូជាចារ្យទេ ដែលលោកយ៉ូសែបមិនបានទិញ ដោយសារពួកបូជាចារ្យបានដីនោះជាអំណោយមកពីស្តេចផារ៉ោន។
ពួកគេបានទទួលចំណែកដែលអំណោយមកពីស្តេចផារ៉ោនប្រគល់ដល់ពួកគេ។ ដូច្នេះហើយ បានជាមិនលក់ដីនោះ។
23បន្ទាប់មក លោកយ៉ូសែបមានប្រសាសន៍ទៅប្រជាជនថា៖ «មើល៍ យើងបានទិញអ្នករាល់គ្នា និងដីរបស់អ្នករាល់គ្នាថ្វាយស្តេចផារ៉ោន។
នេះគឺជាគ្រាប់ពូជសម្រាប់អ្នករាល់គ្នា ហើយអ្នករាល់គ្នានឹងដាំនៅក្នុងដីបាន។24នៅរដូវចម្រូត អ្នករាល់គ្នាត្រូវយកមួយក្នុងប្រាំថ្វាយស្តេចផារ៉ោន
ហើយបួនចំណែកទៀតជារបស់អ្នករាល់គ្នា ដើម្បីគ្រាប់ពូជនៅក្នុងស្រែ និងបានជាស្បៀងសម្រាប់គ្រួសារ និងកូនចៅរបស់អ្នករាល់គ្នា»។
25ពួកគេនិយាយថា៖ លោកបានសង្គ្រោះជីវិតយើងខ្ញុំ។ យើងខ្ញុំបានទទួលមេត្តាពីលោកម្ចាស់។ យើងខ្ញុំព្រមធ្វើជាបាវបម្រើរបស់ស្តេចផារ៉ោន»។26ដូច្នេះ
លោកយ៉ូសែបបានចេញរាជ្យក្រឹត្យមួយដល់ទឹកដីអេស៊ីបទាំងមូល ថា មួយភាគប្រាំត្រូវថ្វាយដល់ស្តេចផារ៉ោន។ មានតែដីរបស់ពួកបូជាចារ្យទេ
ដែលមិនបានក្លាយជារបស់ស្តេចផារ៉ោន។
27ដូច្នេះ លោកអ៊ីស្រាអែលបានរស់នៅក្នុងទឹកដីអេស៊ីប នៅក្នុងតំបន់កូសែន។ កូនចៅរបស់គាត់មានកេរអាករនៅទីនោះ។28ពួកគេមានគ្នាកាន់តែច្រើន
ហើយចម្រើនយ៉ាងខ្លាំង។ លោកយ៉ាកុបរស់នៅក្នុងទឹកដីអេស៊ីបដប់ប្រាំពីរឆ្នាំ ដូច្នេះ លោកយ៉ាកុបរស់បានមួយរយសែសិបប្រាំពីរឆ្នាំ។

 generated on Wed Mar 12 15:32:40 2025

29ដល់ពេលដែលលោកអ៊ីស្រាអែលស្លាប់ហើយ គាត់បានហៅលោកយ៉ូសែប កូនប្រុសរបស់គាត់ ហើយប្រាប់គាត់ថា៖ «ប្រសិនបើ កូនអាណិតឪពុក
ចូរដាក់ដៃកូននៅលើភ្លៅរបស់ឪពុក ហើយសម្ដែងចិត្តសប្បុរស និងភាពស្មោះត្រង់ដល់ឪពុកផង។30សូមកុំបញ្ចុះឪពុកនៅក្នុងទឹកដីអេស៊ីបឡើយ។
នៅពេលឪពុកសម្រាកជាមួយជីតារបស់ឯង កូនត្រូវនាំឪពុកចេញពីអេស៊ីបនេះ ហើយបញ្ចុះសពឪពុកនៅកន្លែងដូនតារបស់ឪពុកណា»។ លោកយ៉ូសែបបានឆ្លើយថា៖
«កូននឹងធ្វើ ដូចលោកឪពុកបានប្រាប់»។31លោកអ៊ីស្រាអែលប្រាប់ថា៖ «ចូរស្បថនឹងឪពុកចុះ» ហើយលោកយ៉ូសែបក៏ស្បថជាមួយនឹងគាត់។ បន្ទាប់មក
លោកអ៊ីស្រាអែលលុតជង្គង់ចុះ នៅក្បាលគ្រែរបស់គាត់។

ជំពូក ៤៨

1បន្ទាប់ពីហេតុការណ៍ទាំងនេះហើយ មានគេប្រាប់លោកយ៉ូសែបថា៖ «មើល៍ ឪពុករបស់លោកឈឺហើយ»។ ដូច្នេះ គាត់បានយកកូនប្រុសពីរនាក់ទៅជាមួយគាត់
គឺម៉ាណាសេ និងអេប្រាអ៊ីម ។2ពេលគេប្រាប់លោកយ៉ាកុបថា៖ «មើល៍ លោកយ៉ូសែបកូនប្រុសរបស់លោកបានមកដល់ហើយដើម្បីមើលលោក»។
លោកអ៊ីស្រាអែលខំប្រឹងក្រោកអង្គុយលើគ្រែនោះ។
3លោកយ៉ាកុបប្រាប់លោកយ៉ូសែបថា៖ «ព្រះជាម្ចាស់ដ៏មានគ្រប់ទាំងព្រះចេស្ដាបានយាងមកជួបឪពុកនៅលូស ក្នុងទឹកដីកាណាន។
ព្រះអង្គបានប្រទានពរដល់ឪពុក4ហើយមានបន្ទូលមកឪពុកថា៖ «មើល៍ យើងនឹងធ្វើឲ្យអ្នកបង្កើតផលផ្លែជាច្រើន ហើយនិងចម្រើនឡើង។
យើងនឹងធ្វើឲ្យអ្នកក្លាយជាប្រជាជាតិមួយដ៏ធំ។ យើងនឹងឲ្យទឹកដីនេះដល់ពូជពង្សរបស់អ្នក ទុកជាកេរអាករដ៏នូវអស់កល្បជានិច្ច»។
5ឥឡូវនេះ កូនប្រុសទាំងពីររបស់ឯង ដែលបានកើតនៅទឹកដីអេស៊ីបដល់ឯង មុនពេលដែលឪពុកមករកឯងនៅអេស៊ីប ពួកគេជារបស់ឪពុក។ គឺអេប្រាអ៊ីម និង
ម៉ាណាសេនឹងត្រូវជារបស់ឪពុក ដូចជារូបេន និងស៊ីម្មានក៏ជារបស់ឪពុកដែរ។6កូនៗដែលកើតមកតាមក្រោយពួកគេជារបស់ឯង
ពួកគេត្រូវចុះទៅក្នុងបញ្ជីឈ្មោះរបស់បងប្អូនពួកគេនឹងទទួលកេរមត៌ករបស់ពួកគេ។7ប៉ុន្តែ ចំណែកឪពុកវិញ ពេលឪពុកទៅប៉ាដាន់វិញ
ដើម្បីកាន់ទុក្ខឲ្យនាងរ៉ាជែលដែលស្លាប់នៅតាមផ្លូវទៅក្នុងទឹកដីកាណាន ដែលនៅជិតភូមិអេប្រាតា។ ឪពុកបានបញ្ចុះសពនាងនៅទីនោះ តាមផ្លូវទៅអេប្រាតា» (គឺភូមិ
បេថ្លេហិម)។
8នៅពេលលោកអ៊ីស្រាអែលឃើញកូនប្រុសៗរបស់លោកយ៉ូសែប គាត់សួរថា៖ «ពួកគេជានរណា?»9លោកយ៉ូសែបឆ្លើយទៅឪពុកថា៖ «ពួកគេជាកូនរបស់ខ្ញុំ
ដែលព្រះជាម្ចាស់បានប្រទានមកខ្ញុំនៅទីនេះ»។ លោកអ៊ីស្រាអែលប្រាប់ថា៖ «ចូរនាំពួកគេមកឯឪពុកមក៍ ដើម្បីឪពុកឲ្យពរដល់ពួកគេ»។10ពេលនោះ
ភ្នែករបស់លោកអ៊ីស្រាអែលមើលលែងឃើញហើយ ដោយសារអាយុរបស់គាត់ ដូច្នេះហើយបានជាគាត់មើលលែងឃើញ។ ដូច្នេះ លោកយ៉ូសែបបាននាំពួកគេទៅជិតគាត់
ហើយគាត់បានឱបហើយថើបពួកគេ។
11លោកអ៊ីស្រាអែលប្រាប់ទៅលោកយ៉ូសែបថា៖ «ឪពុកមិនសង្ឃឹមថាបានឃើញមុខកូនម្ដងទៀតទេ ប៉ុន្តែ
ព្រះជាម្ចាស់បានអនុញ្ញាតឲ្យឪពុកបានឃើញរហូតដល់ចៅទៀត»។12លោកយ៉ូសែបបាននាំពួកគេចេញពីភ្លៅរបស់លោកអ៊ីស្រាអែល ហើយបន្ទាប់មក
គាត់បានលុតជង្គង់ចុះ ហើយឱនមុខរបស់គាត់ដល់ដី។13លោកយ៉ូសែបបានយកពួកគេទាំងពីរ គឺអេប្រាអ៊ីមនៅដៃស្ដាំរបស់គាត់ គឺនៅខាងឆ្វេងដៃរបស់លោកអ៊ីស្រាអែល
ហើយម៉ាណាសេនៅដៃឆ្វេងរបស់គាត់ គឺនៅខាងស្ដាំដៃលោកអ៊ីស្រាអែល ហើយនាំពួកគេចូលទៅជិតគាត់។
14លោកអ៊ីស្រាអែលបានលូកដៃស្ដាំរបស់គាត់ ហើយដាក់នៅលើក្បាលរបស់អេប្រាអ៊ីម ដែលត្រូវជាប្អូន ហើយដៃឆ្វេងរបស់គាត់នៅលើក្បាលរបស់ម៉ាណាសេ។
គាត់បានខ្វែងដៃរបស់គាត់ ដើម្បីម៉ាណាសេគឺជាកូនច្បង។15លោកអ៊ីស្រាអែលបានឲ្យពរដល់លោកយ៉ូសែបដោយពោលថា៖ «ព្រះជាម្ចាស់ដែលលោកអប្រាហាំ
និងលោកអ៊ីសាក ជាឪពុករបស់ទូលបង្គំបានដើរតាម ព្រះជាម្ចាស់ដែលថែរក្សាទូលបង្គំរហូតមកដល់ពេលនេះ16ទេវតាដែលការពារទូលបង្គំពីគ្រោះថ្នាក់គ្រប់យ៉ាង
សូមព្រះអង្គប្រទានពរក្មេងប្រុសទាំងពីរនាក់នេះ។ សូមឲ្យឈ្មោះរបស់ទូលបង្គំ ឈ្មោះរបស់លោកអប្រាហាំ និងលោកអ៊ីសាកបាននៅក្នុងពួកគេ។ សូមឲ្យពួកគេបានចម្រើន
ឡើងនៅលើផែនដី»។
17នៅពេលលោកយ៉ូសែបឃើញឪពុករបស់គាត់ដាក់ដៃស្ដាំនៅលើក្បាលរបស់អេប្រាអ៊ីម គាត់មិនពេញចិត្តទេ។ គាត់បានយកដៃរបស់ឪពុកគាត់ពីក្បាលរបស់អេប្រាអ៊ីម
ទៅដាក់នៅលើក្បាលរបស់ម៉ាណាសេវិញ។18លោកយ៉ូសែបប្រាប់ឪពុកគាត់ថា៖ «លោកឪពុកមិនមែនបែបហ្នឹងទេ នេះគឺជាកូនច្បង។
សូមដាក់ដៃរបស់លោកឪពុកនៅលើក្បាលវាចុះ»។
19ឪពុករបស់គាត់បានបដិសេធ ហើយប្រាប់ថា៖ «ពុកដឹងហើយកូន ពុកដឹង។ អេប្រាអ៊ីមនឹងក្លាយជាជាជនជាតិមួយ ហើយគាត់នឹងក្លាយជាប្រជាជាតិមួយដ៏ធំ។
លើសជាងនេះទៅទៀតប្អូនប្រុសពៅរបស់វានឹងមានអំណាចធំជាងវាទៀត ហើយពូជពង្សរបស់វានឹងក្លាយជាប្រជាជាតិដ៏ធំមួយ»។
20លោកអ៊ីស្រាអែលឲ្យពរដល់ពួកគេនៅថ្ងៃនោះ ជាមួយនឹងពាក្យទាំងនេះថា៖ «ប្រជាជនអ៊ីស្រាអែលនឹងប្រកាសព្រះពរដោយនូវឈ្មោះរបស់ឯង ដោយពោលថា៖
«សូមព្រះជាម្ចាស់ធ្វើឲ្យអ្នកបានដូចជាអេប្រាអ៊ីម និងដូចជាម៉ាណាសេ»។ លោកអ៊ីស្រាអែលបានធ្វើបែបនេះ នៅចំពោះមុខម៉ាណាសេ។
21លោកអ៊ីស្រាអែលប្រាប់លោកយ៉ូសែបថា៖ «មើល៍ ឪពុកជិតស្លាប់ហើយ ប៉ុន្តែ ព្រះជាម្ចាស់នឹងគង់នៅជាមួយកូន
ហើយនឹងនាំកូនត្រឡប់ទៅទឹកដីរបស់ឪពុករបស់កូនវិញ។22ចំណែក កូនវិញ កូនធំជាងបងប្អូនរបស់កូន ឪពុកនឹងប្រគល់ជ្រលងភ្នំ ដែលពុកយកពីជនជាតិអាំម៉ូន
ដោយដាវ និងធ្នូរបស់ឪពុកដល់កូន»។

ជំពូក ៤៩

1បន្ទាប់មក លោកយ៉ាកុបបានហៅកូនប្រុសៗរបស់គាត់ ហើយប្រាប់ថា៖ «ចូរមកជួបជុំគ្នា ដើម្បីឲ្យពុកអាចប្រាប់នូវអ្វីដែលនឹងកើតឡើងជាមួយកូនៗនាពេលអនាគត។
2ចូរជួបជុំគ្នា ហើយស្ដាប់កូនប្រុសៗរបស់យ៉ាកុបអើយ។ ចូរស្ដាប់លោកអ៊ីស្រាអែល ជាឪពុករបស់អ្នករាល់គ្នា។
3រូបេន កូនគឺជាកូនច្បងរបស់ឪពុក ជាឫទ្ធិ និងជាផលដំបូងនៃកម្លាំងរបស់ឪពុក កូនមានកិត្តិយស និងអំណាចខ្លាំងជាងគេ។
4កូនប្រៀបដូចជាទឹកហូរដែលមិនអាចឃាត់បាន តែកូនមិនអាចធ្វើមេបានទេ ដោយសារកូនបានឡើងទៅលើគ្រែរបស់ឪពុក។ បន្ទាប់មក
កូនបានបង្ខូចកិត្តិយសរបស់ឪពុក ដោយកូនឡើងទៅដេកជាមួយភរិយារបស់ឪពុក។
5ស៊ីម្មាន និងលេវី ជាបងប្អូនគ្នា។ ដាវរបស់ពួកគេបានប្រព្រឹត្តអំពើឃោរឃៅ។6ឱព្រលឹងខ្ញុំអើយ សូមកុំឲ្យខ្ញុំចូលរួមទៅក្នុងគំនិតរបស់ពួកគេ
ហើយកុំចូលរួមជាមួយការជួបជុំរបស់គេឡើយ ដ្បិត ដួងចិត្តរបស់ខ្ញុំខឹងចំពោះអំពើឃោរឃៅនោះ។ ដ្បិត នៅក្នុងកំហឹងរបស់ពួកគេ ពួកគេបានសម្លាប់មនុស្ស។
ហើយពេលគេសប្បាយ ពួកគេកាត់ជើងគោ។
7សូមឲ្យបណ្ដាសាធ្លាក់លើកំហឹងរបស់ពួកគេ ដ្បិត ជាកំហឹងដ៏ខ្លាំង ហើយកំហឹងដ៏ខ្លាំងនេះ អាក្រក់ណាស់។ ឪពុកនឹងញែកពួកគេចេញពីយ៉ាកុប
ហើយបំបែកពួកគេចេញពីលោកអ៊ីស្រាអែល។
8យូដា បងប្អូនរបស់កូននឹងសរសើរដល់កូន។ ដៃរបស់កូននឹងច្របាច់កខ្មាំងសត្រូវរបស់កូន។ បងប្អូនរបស់កូននឹងលុតជង្គង់នៅចំពោះកូន។
9យូដាគឺជាតោស្ទាវ។ កូនអើយ កូនបានឡើងមកពីស៊ីរំពា។ វាបានក្រាបដេកចុះ វាបានដេក ដូចជាតោះឈ្មោល ដូចជាតោញី តើនរណាហ៊ានដាស់វា?

10ដំបងរាជ្យនឹងមិនចេញឆ្ងាយពីយូដាឡើយ ហើយដំបងគ្រប់គ្រងក៏មិនឃ្លាតឆ្ងាយចេញពីជើងរបស់គាត់ដែរ រហូតតែស៊ីឡូមកដល់។
ប្រជាជាតិទាំងឡាយនឹងស្តាប់បង្គាប់គាត់។
11លោកនឹងចងលារបស់លោកនឹងដើមទំពាំងបាយជូរ លោកបោកអាវរបស់លោកនៅក្នុងស្រាទំពាំងបាយជូរ ហើយបោកអាវវែងរបស់លោកនៅក្នុងទឹកទំពាំងបាយជូរដែរ។
12ភ្នែករបស់លោកខ្មៅដូចជាស្រាទំពាំងបាយជូរ ហើយធ្មេញរបស់លោកសដូចជាទឹកដោះគោ។
13សាប់យូឡូននឹងរស់នៅតាមមាត់សមុទ្រ។ គាត់នឹងក្លាយជាកំពង់សម្រាប់នាវា ហើយព្រំប្រទល់របស់គាត់នឹងលាតសន្ធឹងទៅដល់ក្រុងស៊ីដូន។
14អ៊ីសាខារគឺជាសត្វលាដ៏រឹងមាំ ដេកនៅក្នុងចន្លោះរោងចៀម។15គាត់បានឃើញកន្លែងសម្រាកដ៏ល្អ ហើយទឹកដីក៏ស្រួលរស់នៅផង។ គាត់ក៏ឱនខ្នងឲ្យគេដាក់កែបផ្ទុករបស់
របរពីលើ និងឲ្យគេប្រើដូចទាសករផង។
16ដាន់នឹងគ្រប់គ្រងលើជនជាតិរបស់ខ្លួន ក្នុងចំណោមកុលសម្ព័ន្ធមួយនៃកុលសម្ព័ន្ធអ៊ីស្រាអែល។17ដាន់នឹងក្លាយជាពស់ដែលលូននៅតាមផ្លូវ ដូចពស់វែកនៅតាមផ្លូវលំ
ដែលចចឹកកែងជើងសេះបណ្តាលឲ្យអ្នកជិះដាច់ផ្ងារធ្លាក់ចុះមកក្រោម។18ឱព្រះអម្ចាស់អើយ ទូលបង្គំរង់ចាំសេចក្តីសង្គ្រោះរបស់ព្រះអង្គ។
19កាដត្រូវកងទ័ពមួយមកវាយប្រហារលើកូន តែកូននឹងវាយកងទ័ពនោះពីក្រោយខ្នងរបស់ពួកគេវិញ។20អេស៊ើបចេះធ្វើម្ហូបអាហារយ៉ាងឆ្ងាញ់ កូននឹងធ្វើព្រះស្ងោយថ្វាយ
មហាក្សត្រ។21ណែបថាលីគឺជាសត្វក្តាន់ញីដែលរត់ដោយសេរី កូននឹងបង្កើតកូនយ៉ាងស្អាតៗ។
22យ៉ូសែបគឺជាមែកដែលផ្លែ ដុះនៅជិតប្រភពទឹក មានមែកដុះព័ទ្ធឡើងនៅលើជញ្ជាំង។23ខ្មាំងសត្រូវនឹងវាយប្រហារកូន ហើយគេនឹងបាញ់លើកូន
ហើយវាយប្រហារកូនថែមទៀតផង។
24ប៉ុន្តែ ធ្នូរបស់កូននឹងនៅតែរឹងមាំ ហើយដៃរបស់កូនមានភាពស្ទាត់ជំនាញ ដោយសារព្រះហស្តរបស់ព្រះដ៏ខ្លាំងពូកែរបស់លោកយ៉ាកុប
ដោយព្រោះនាមព្រះអង្គជាអ្នកគង្វាល និងជាថ្មដានៃអ៊ីស្រាអែល។
25ព្រះជាម្ចាស់ឪពុករបស់កូននឹងជួយកូន ហើយព្រះជាម្ចាស់ដ៏មានគ្រប់ទាំងព្រះចេស្តានឹងប្រទានពរដល់កូនជាមួយនឹងព្រះពរដែលមកពីលើមេឃ
ព្រះពរចេញពីទីជម្រៅដែលនៅខាងក្រោម និងព្រះពរពីទឹកដោះ និងពីផ្ទៃផង។
26ពរឪពុករបស់កូនធំជាងពរដែលចេញពីភ្នំបុរាណ ឬអ្វីៗដែលគួរឲ្យចង់បានពីភ្នំបុរាណ។ សូមឲ្យពរនេះបានហូរមកលើក្បាលរបស់យ៉ូសែប
ថែមទាំងមកលើមកុដនៅលើក្បាលរបស់មេនៃបងប្អូនរបស់កូន។
27បេនយ៉ាមីនគឺជាឆ្កែចចកដែលស្រេកឃ្លាន។ នៅពេលព្រឹកវាខាំស៊ីរំពា ហើយដល់ពេលល្ងាចវាចែកគ្នាស៊ី»។
28អ្នកទាំងនេះគឺជាកុលសម្ព័ន្ធទាំងដប់ពីររបស់អ៊ីស្រាអែល។ នេះគឺជាអ្វីដែលឪពុករបស់ពួកគេបាននិយាយទៅកាន់ពួកគេ នៅពេលគាត់ឲ្យពរដល់ពួកគេ។
គាត់បានឲ្យពរដល់ម្នាក់ តាមពរដែលគេស័ក្តិសមនឹងទទួលរៀងៗខ្លួន។29បន្ទាប់មក គាត់បានបង្គាប់ដល់ពួកគេហើយនិយាយទៅកាន់ពួកគេថា៖
«ឪពុកជិតត្រឡប់ទៅរកដូនតារបស់ឪពុកវិញហើយ។ ចូរបញ្ចុះសពឪពុកជាមួយបុព្វបុរសរបស់ឪពុកនៅក្នុងល្អាងដែលនៅចម្ការរបស់លោកអេហ្រូន ជនជាតិ
ហេត30គឺនៅក្នុងល្អាងដែលនៅចម្ការរបស់លោកម៉ាកពេឡា ដែលនៅក្បែរម៉ាមរេ ក្នុងទឹកដីកាណាន ជាចម្ការដែលលោកអប្រាហាំ
បានទិញសម្រាប់ជាកន្លែងបញ្ចុះសពពីលោកអេហ្រូន ជនជាតិហេត។
31ពួកគេបានបញ្ចុះសពរបស់លោកអប្រាហាំ និងនាងសារ៉ា ភរិយារបស់គាត់នៅទីនោះ ហើយក៏បញ្ចុះសពរបស់លោកអ៊ីសាក និងនាងរេបេកា ភរិយារបស់គាត់
និងនាងលេអានៅទីនោះដែរ។32ចម្ការ និងល្អាងដែលបានទិញពីជនជាតិហេត»។33ពេលលោកយ៉ាកុបបានបង្គាប់ដល់កូនៗរបស់គាត់ចប់សព្វគ្រប់ហើយ
គាត់បានលើកជើងដាក់លើគ្រែវិញ ហើយបានដកដង្ហើមចុងក្រោយរបស់គាត់ ហើយបានត្រឡប់ទៅបុព្វបុរសរបស់គាត់វិញទៅ។

## ជំពូក ៥០

1បន្ទាប់មក លោកយ៉ូសែបកើតទុក្ខជាខ្លាំង គាត់បានក្រាបមុខលើឪពុករបស់គាត់ ហើយយំឱប ថើបគាត់។
2លោកយ៉ូសែបបានបង្គាប់ដល់អ្នកបម្រើរបស់គាត់ដែលជាគ្រូពេទ្យអប់ឪពុករបស់គាត់។ ដូច្នេះ គ្រូពេទ្យបានអប់លោកអ៊ីស្រាអែល។
3ពួកគេបានចំណាយពេលសែសិបថ្ងៃពេញ សម្រាប់ធ្វើពិធីអប់។ ជនជាតិអេស៊ីបកាន់ទុក្ខគាត់អស់រយៈពេលចិតសិបថ្ងៃ។
4ពេលថ្ងៃកាន់ទុក្ខបានបញ្ចប់ លោកយ៉ូសែបបាននិយាយទៅកាន់ពួកគេដែលនៅក្នុងដំណាក់របស់ស្តេចផារ៉ោនថា៖ «ឥឡូវនេះ ប្រសិនបើ
ខ្ញុំបានប្រកបដោយព្រះគុណនៅចំពោះអស់លោកមែន សូមទូលទៅព្រះបាទផារ៉ោន ដោយពោលថា៖5«ឪពុករបស់ខ្ញុំបានឲ្យខ្ញុំស្បថ ដោយប្រាប់ថា៖ «មើល៍
ឪពុកជិតស្លាប់ហើយ។ ចូរបញ្ចុះឪពុកនៅក្នុងផ្នូររបស់ឪពុកដែលឪពុកបានជីកសម្រាប់ឪពុកខ្លួនឯងនៅក្នុងទឹកដីកាណាន។ ចូរបញ្ចុះឪពុកនៅទីនោះចុះ»។
6ព្រះបាទផារ៉ោនឆ្លើយថា៖ «ទៅ ហើយបញ្ចុះសពឪពុករបស់លោក តាមដែលគាត់ឲ្យលោកស្បថចុះ»។
7លោកយ៉ូសែបបានឡើងទៅ ដើម្បីបញ្ចុះសពឪពុករបស់គាត់។ មន្ត្រីរបស់ស្តេចផារ៉ោនទាំងអស់បានទៅជាមួយគាត់ អស់អ្នកដែលនៅដំណាក់របស់ស្តេចផង
រួមទាំងមន្ត្រីធំៗទាំងអស់នៅក្នុងទឹកដីអេស៊ីប8និងគ្រួសាររបស់លោកយ៉ូសែបទាំងអស់ ព្រមទាំងបងប្អូនរបស់គាត់ និងអស់អ្នកដែលនៅក្នុងគ្រួសាររបស់គាត់។ ប៉ុន្តែ ក្មេងៗ
ហ្វូងចៀម និងហ្វូងគោរបស់ពួកគេទុកនៅក្នុងទឹកដីកូសែនដដែល។9មានរទេះ មានពួកជិះសេះក៏បានចូលរួមដង្ហែទៅជាមួយលោកដែរ។ មានហ្វូងមនុស្សយ៉ាងច្រើនកុះករ។
10ពេលពួកគេមកដល់លានស្រូវរបស់លោកអ័ថាត់ ដែលនៅខាងនាយទន្លេយ័រដាន់ ពួកគេយំសោកជាខ្លាំងនៅទីនោះ។ នៅទីនោះ លោកយ៉ូសែបកាន់ទុក្ខឪពុកអស់រយៈ
ពេលប្រាំពីរថ្ងៃ។11ពេលប្រជាជនដែលរស់នៅទឹកដីនោះ គឺទឹកដីកាណាន បានឃើញការកាន់ទុក្ខនៅលានស្រូវរបស់លោកអ័ថាត់ ពួកគេនិយាយថា៖
«នេះគឺជាការកាន់ទុក្ខយ៉ាងខ្លាំងសម្រាប់ជនជាតិអេស៊ីប»។ ហេតុនេះហើយបានជាគេហៅកន្លែងនោះថា៖ «អេបិល មីសរ៉ែម ដែលនៅខាងនាយទន្លេយ័រដាន់។
12ដូច្នេះ កូនប្រុសៗរបស់លោកយ៉ាកុបបានធ្វើសម្រាប់គាត់ ដូចដែលគាត់បានបង្គាប់ដល់ពួកគេ។13កូនប្រុសៗរបស់គាត់បានដឹកសពរបស់គាត់ទៅកាន់ទឹកដីកាណាន
ហើយបញ្ចុះសពរបស់គាត់នៅក្នុងល្អាងនៅក្នុងចម្ការរបស់លោកម៉ាកពេឡា នៅក្បែរម៉ាមរេ
ដែលលោកអប្រាហាំបានទិញល្អាងជាមួយនឹងចម្ការសម្រាប់ជាកន្លែងបញ្ចុះសព។ គាត់បានទិញពីលោកអេហ្រូន ជនជាតិហេត។
14បន្ទាប់ពីគាត់បានបញ្ចុះសពឪពុករបស់គាត់ហើយ លោកយ៉ូសែបបានត្រឡប់ទៅកាន់ទឹកដីអេស៊ីបវិញ គាត់បានទៅជាមួយបងប្អូនរបស់គាត់
ហើយនិងអស់អ្នកដែលរួមដំណើរដើម្បីបញ្ចុះសពឪពុករបស់គាត់ជាមួយគាត់។
15ពេលបងៗរបស់លោកយ៉ូសែបឃើញថា ឪពុករបស់ពួកគេបានស្លាប់ហើយ ពួកគេនិយាយគ្នាថា៖ «តើមានរឿងអ្វីកើតឡើង ប្រសិនបើ យ៉ូសែបចងគំនុំជាមួយពួកយើង
ហើយចង់សងសឹកនឹងយើង ដោយព្រោះការអាក្រក់ទាំងអស់របស់យើងដែលយើងបានធ្វើជាមួយនឹងវា?»16ដូច្នេះ ពួកគេបានបង្គាប់ម្នាក់ឲ្យទៅជួបលោកយ៉ូសែប
ប្រាប់ថា៖ «លោកឪពុកបានបង្គាប់មុនពេលគាត់លាចាកលោកនេះថា៖17«ចូរប្រាប់យ៉ូសែបដូច្នេះ «សូមអត់ទោសដល់កំហុសបងៗរបស់កូន
និងបាបនៅពេលដែលពួកគេធ្វើអាក្រក់នឹងកូន»។ ឥឡូវនេះ សូមអត់ទោសដល់ពួកគេ ដែលជាអ្នកបម្រើព្រះជាម្ចាស់ឪពុករបស់កូន»។
18បងៗរបស់គាត់ក៏បានទៅលុតជង្គង់នៅចំពោះគាត់។ ពួកគេនិយាយថា៖ «មើល៍ ពួកយើងជាអ្នកបម្រើរបស់ប្អូន»?19ប៉ុន្តែ លោកយ៉ូសែបបានប្រាប់ពួកគេថា៖
«កុំភ័យខ្លាចអី។ តើខ្ញុំជាព្រះជាម្ចាស់ឬ?20បងៗមានបំណងធ្វើបាបខ្ញុំ ប៉ុន្តែ ព្រះជាម្ចាស់ធ្វើឲ្យវាទៅជាល្អវិញ គឺដើម្បីការពារជីវិតរបស់មនុស្សជាច្រើន
ដូចដែលបងៗបានឃើញសព្វថ្ងៃនេះ។21ដូច្នេះ សូមកុំភ័យខ្លាចធ្វើអ្វី។ ខ្ញុំនឹងផ្គត់ផ្គង់បងៗ និងកូនចៅរបស់បងៗដែរ»។ គាត់បានកម្សាន្តចិត្តដល់ពួកគេបែបនេះឯង
ហើយបាននិយាយដោយស្រទន់ទៅកាន់ដួងចិត្តរបស់ពួកគេ។

[22]លោកយ៉ូសែបរស់នៅក្នុងអេស៊ីប ជាមួយនឹងក្រុមគ្រួសារឪពុករបស់គាត់។ គាត់រស់នៅបានមួយរយដប់ឆ្នាំ។
[23]លោកយ៉ូសែបបានឃើញកូនចៅរបស់លោកអេប្រាអ៊ីមរហូតដល់បីជំនាន់។ គាត់ក៏បានឃើញកូនរបស់លោកម៉ាគៀរ ជាកូនរបស់លោកម៉ាណាសេ
ជាអ្នកដែលបានដាក់លើភ្លៅរបស់លោកយ៉ូសែប។
[24]លោកយ៉ូសែបប្រាប់ទៅបងៗរបស់គាត់ថា៖ «ខ្ញុំជិតស្លាប់ហើយ ប៉ុន្តែ ព្រះជាម្ចាស់ប្រាកដជាមកជួបបងៗ ហើយនាំបងៗចេញពីទឹកដីនេះ
ទៅកាន់ទឹកដីដែលព្រះអង្គបានស្បថថានឹងប្រទានដល់លោកអប្រាហាំ ដល់លោកអ៊ីសាក និងដល់លោកយ៉ាកុប»។[25]បន្ទាប់មក
លោកយ៉ូសែបបានឲ្យជនជាតិអ៊ីស្រាអែលស្បថសម្បថ។ គាត់ប្រាប់ថា៖ «ព្រះជាម្ចាស់ប្រាកដជាមកជួបអ្នករាល់គ្នា។ នៅពេលនោះ
អ្នករាល់គ្នាត្រូវដឹកយកឆ្អឹងរបស់ខ្ញុំចេញពីទីនេះ»។[26]ដូច្នេះ លោកយ៉ូសែបបានស្លាប់ ក្នុងអាយុ ១១០ឆ្នាំ។ ពួកគេបានអប់សពគាត់ ហើយគេបានដាក់លោកនៅក្នុងមឈូស
នៅក្នុងអេស៊ីប។